# ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១

## ក្រសួងការងារ លើកហេតុផលនិងដំណោះស្រាយសុវត្ថិភាព ៤ចំណុច ពន្យល់ដល់ពលករខ្មែរដែលកំពុងធ្វើការនៅថៃ

http://freshnewsasia.com/ 2021-07-30 12:11pm

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងអំពីហេតុផល និងដំណោះស្រាយសុវត្ថិភាព ៤ ចំណុច ប្រាប់ដល់ពលករខ្មែរដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ ដើម្បីពន្យល់ឱ្យពួកគាត់រក្សាភាពស្ងៀមស្ងាត់នៅនឹងកន្លែងដដែល ពោលគឺកុំចល័តចេញពីកន្លែងស្នាក់នៅ ឆ្ពោះមកព្រំដែនកម្ពុជា-ថៃឱ្យសោះ ពីព្រោះការធ្វើដំណើរទាំងប្រថុយប្រថាននេះ ពិតជាអាចប្រឈមមហានិភ័យខ្ពស់ក្នុងការឆ្លង និងការចម្លងជំងឺកូវីដ-១៩ ពិសេសគឺប្រភេទបំប្លែងថ្មី Delta។ ហេតុផលនិងដំណោះស្រាយសុវត្ថិភាពទាំង ៤ ចំណុចនេះ គឺមានបញ្ជាក់ក្នុងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ ស្តីពីការសហការផ្អាកការធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅរបស់ពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃឆ្ពោះមកព្រំដែនកម្ពុជា-ថៃ រយៈពេល ១៤ ថ្ងៃ ដែលបានចេញផ្សាយជាផ្លូវការនាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១។

ការចេញសេចក្តីជូនដំណឹងនេះ ធ្វើឡើងដោយយោងតាមវិធានការបិទខ្ទប់ភូមិសាស្ត្របណ្តាខេត្តមួយចំនួនជាពិសេសខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងការរឹតបន្តឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីនៅកម្ពុជា ក៏ដូចជាយោងលើវិធានការបិទខ្ទប់ការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ដែលកំពុងស្ថិតនៅជាធរមាននៅក្នុងប្រទេសថៃ។ **យោងតាមវិធានការទាំងនេះហើយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជូនដំណឹងដល់ពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នូវហេតុផល និងដំណោះស្រាយ ៤ ចំណុច៖**

**១៖** កុំចល័តចេញពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួនឆ្ពោះមកព្រំដែនកម្ពុជា-ថៃ រយៈពេល ១៤ ថ្ងៃ ចាប់ពីថ្ងៃទី៣០ ខែកក្កដា រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។ ប្រសិនបើមានធុរៈចាំបាច់ ឬចប់ការងារត្រូវវិលត្រឡប់មកប្រទេសកម្ពុជាវិញ សូមពលករមេត្តារង់ចាំរហូតដល់ក្រោយថ្ងៃទី១២ ខែសីហា។

**២៖** ប្រសិនជាពលករធ្វើដំណើរមកព្រំដែនកម្ពុជា-ថៃ តាមមធ្យោបាយណាមួយក៏ដោយ គឺនឹងត្រូវគេតម្រូវឱ្យធ្វើដំណើរវិលត្រឡប់ទៅកន្លែងដើមវិញ។ ម្ចាស់រថយន្ត ឬមេខ្យល់ដែលបំផុស ឬដឹកជញ្ជូនពលករ គឺល្មើសនឹងបម្រាមរបស់អាជ្ញាធរថៃ ហើយត្រូវប្រឈមនឹងការចាត់វិធានការតាមច្បាប់ផងដែរ។

**៣៖** ក្នុងរយៈពេលស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ប្រសិនជាពលករមានបញ្ហានៅកន្លែងធ្វើការ ឬមានបញ្ហាជីវភាពលំបាកខ្លាំង គឺអាចទំនាក់ទំនងទៅស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ នៅរៀងរាល់ម៉ោងធ្វើការ (តាមរយៈទូរស័ព្ទលេខ 092 8050 561 ឬ 094 0925 905 ឬ 062 1413 009 ឬ 086 7999 957) ឬពលករអាចទំនាក់ទំនងទៅក្រុមការងារស្ម័គ្រចិត្តនៃក្រុមការងារទឹកចិត្តពលករនៅថៃ តាមរយៈក្រុមតេឡេក្រាមឈ្មោះ «ជំនួយកូវីដ-១៩ នៅថៃ» ដែលមានលីងតំណភ្ជាប់ https://t.me/helpkhmerinthailand) ដើម្បីស្ថានទូត ក៏ដូចជាក្រុមការងារស្ម័គ្រចិត្តពិនិត្យ និងខិតខំស្វែងរកដំណោះស្រាយជូនពលករ។ ពលករគួរខិតខំព្យាយាមទំនាក់ទំនងទៅលេខទូរស័ព្ទរបស់អាជ្ញាធរពាក់ព័ន្ធនៃប្រទេសថៃ ដូចមានក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីជូនដំណឹងនេះផងដែរ។

៤៖ ចំពោះពលករដែលសង្ស័យថាខ្លួនមានវិជ្ជមានកូវីដ-១៩ ឬមានវិជ្ជមានកូវីដ-១៩ កម្រិតស្រាល ហើយមិនទាន់ដឹងថាត្រូវទំនាក់ទំនងទៅផ្នែកណា គឺពលករអាចទទួលការពិគ្រោះយោបល់អំពីការព្យាបាលជំងឺកូវីដ-១៩ តាមរយៈក្រុមតេឡេក្រាមឈ្មោះ «ពិគ្រោះកូវីដ-១៩ នៅថៃ» ដែលមានលីងតំណភ្ជាប់ https://t.me/consultcovidinthailand ដែលមានក្រុមគ្រូពេទ្យសម្រាប់ផ្តល់ប្រឹក្សាយោបល់បឋម និងមានក្រុមស្ម័គ្រចិត្ត ដើម្បីផ្តល់កញ្ចប់ថ្នាំព្យាបាលជំងឺកូវីដ-១៩ កម្រិតស្រាលជូនពលករក្នុងករណីចាំបាច់។ ពលករគួរខិតខំព្យាយាមទំនាក់ទំនងទៅលេខទូរស័ព្ទរបស់មន្ទីរពេទ្យ ឬអាជ្ញាធរថៃ ដែលមានសមត្ថកិច្ចក្នុងការយកសំណាក និងព្យាបាលជំងឺកូវីដ-១៩ ដូចមាននៅក្នុងឧបសម្ព័ន្ធ២ នៃសេចក្តីជូនដំណឹងនេះ។

## ឃាត់ខ្លួនជនជាតិថៃប្រុសស្រី៧នាក់ លួចឆ្លងដែនចូលកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៣០ កក្កដា ២០២១ដោយ Sorn Phanith

លោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ៥១៤ ដឹកនាំកម្លាំង សហការជាមួយកម្លាំងចម្រុះ បានឃាត់ខ្លួនជនជាតិថៃប្រុសស្រី ឆ្លងដែនពីប្រទេសថៃចូលមកប្រទេសកម្ពុជា ចំនួន០៧នាក់ ក្នុងនោះប្រុស០១នាក់ នៅចំណុច ផ្លូវឧកញ៉ា សំ ផាន់ណារិទ្ធិ ស្ថិតក្នុងភូមិ/ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីទៀបភ្លឺឈានថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១។ លោកវរសេនីយ៍ទោ ប៉ែន សុគន្ធ បានបញ្ជាក់ថា ខណៈដែលកម្លាំងដើរល្បាតតាមបន្ទាត់ព្រំដែនក៏បានជួបជនជាតិថៃ បម្រុងលួចឆ្លងដែនចូលប្រទេសកម្ពុជា ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបានតែម្តង។ ក្នុងនាមលោកជាមេបញ្ជាការប្រចាំទិសតែងតែបញ្ជាកម្លាំងគ្រប់គោលដៅល្បាត២៤ម៉ោងលើ២៤ម៉ោង ឲ្យខានតែបានមិនធ្វេសប្រហែសឡើយព្រោះ ខណៈពេលប្រទេសថៃនៅតែបន្តរកឃើញអ្នកឆ្លងកូវីដ-១៩ ជាបន្តបន្ទាប់។ ក្រោយការឃាត់ជនជាតិថៃប្រុសស្រី ទាំង០៧នាក់ ត្រូវបានកម្លាំងសមត្ថកិច្ចប្រគល់ឲ្យនគរបាល អន្តោប្រវេសន៍ ដើម្បីចាត់ការបន្តតាមនីតិវិធីតាមច្បាប់។ មានការឆ្ងល់និងលើកឡើងថា ហេតុអ្វីបានជាជនជាតិថៃចេះតែលួចឆ្លងកម្ពុជាសំដៅចូលទៅតំបន់ប៉ោយប៉ែត ខណៈដែលកាស៊ីណូក៏បានបិទហើយព្រំដែនក៏បានបិទនិងរឹតបន្តឹង៕ អត្ថបទ៖ អពៅ

## អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា ៖ ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅថៃ យកចិត្តទុកដាក់ ដល់ពលករដែលឆ្លងជម្ងឺកូវីដ

https://cen-news.com/ Posted ByPen Srey NeatJuly 31, 2021

ភ្នំពេញ ៖ លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានបញ្ជាក់ប្រាប់ CEN នៅព្រឹកថ្ងៃទី៣១ ខែកក្កដានេះថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅប្រទេសថៃ បានខិតខំសហការជាមួយអាជ្ញាធរពាក់ព័ន្ធថៃ ឲ្យជួយមើលថែទាំដោយយកចិត្តទុកដាក់ ពលករណាដែលឆ្លងជម្ងឺកូវីដ និងបានទាក់ទងជាប្រចាំពេងចក្រ សហគ្រាស ក្រុមហ៊ុន ឲ្យផ្គត់ផ្គង់អាហារគ្រប់គ្រាន់ ដល់ពលករដែលស្ថិតក្នុងតំបន់បិទខ្ទប់ ហើយស្ថានទូតតែងយកគ្រឿងឧបភោគបរិភោគមួយចំនួន ចែកជូនពលករដែលជួបការលំបាកខ្លាំង។ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានបញ្ជាក់ទៀតថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅប្រទេសថៃ បានខិតខំប្រឹងប្រែងតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ ពលករខ្មែរយើងនៅប្រទេសថៃ មានចំនួនជាងមួយលាននាក់។

ចំណែកស្ថានទូតកម្ពុជាប្រចាំនៅថៃ ក៏បានជូនដំណឹងស្តីពីការសហការផ្អាកការធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅ របស់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឆ្ពោះមកព្រំដែនកម្ពុជា-ថៃ ចំនួន ១៤ថ្ងៃ។ ប្រសិនជាបងប្អូនពលករមានបញ្ហា នៅកន្លែងធ្វើការ ឬមានបញ្ហាជីវភាពលំបាកខ្លាំង គឺអាចទំនាក់

ទំនងទៅស្ថានឯកអគ្គរាជទូត ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ តាមរយៈលេខទូរស័ព្ទ៖ 092 8050 561 094 0925 905 062 1413 009 086 7999 957 ឬ តាមរយៈតេឡេក្រាម «ជំនួយកូវីដ-១៩ នៅថៃ» តំណរភ្ជាប់៖ https://t.me/helpkhmerinthailand ស្ថានទូតបន្តថា ចំពោះបងប្អូនពលករដែលសង្ស័យថាខ្លួនមានវិជ្ជមានកូវីដ-១៩ ឬមានវិជ្ជមានកូវីដ-១៩ កម្រិតស្រាល ហើយមិនទាន់ដឹងថាត្រូវទំនាក់ទំនង ទៅផ្នែកណា អាចពិគ្រោះយោបល់តាមរយៈតេឡេក្រាម « ពិគ្រោះកូវីដ-១៩ នៅថៃ» តំណរភ្ជាប់៖ https://t.me/consultcovidinthailand ជាមួយគ្នានេះ ស្ថានទូតសូមបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ជ្រាបជាព័ត៌មាន និងសូមកុំធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួនឱ្យសោះ ដើម្បីចៀសវាងប្រឈមនឹងវិធានការច្បាប់នានា និងចៀសវាងការចម្លងជំងឺកូវីដ-១៩ ដល់មិត្តភក្តិ និងក្រុមគ្រួសារ៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## ឧត្តមសេនីយ៍ទោ សេង ធារិន អំពាវនាវដល់ពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ សូមកុំឆ្លងដែន មកប្រទេសកម្ពុជា ក្នុងដំណាក់កាលនេះ

https://cen-news.com/ Posted ByPen Srey NeatJuly 31, 2021

ខេត្តបន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរងនាយសេនាធិការយោធភូមិភាគទី៥ នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ បានអញ្ជើញចុះត្រួតពិនិត្យ រឹតបន្តឹងនូវវិធានការ បិទខ្ទប់តាមបណ្តាច្រកព្រំដែនកម្ពុជា-ថៃ ទិសទី១ ខេត្តបន្ទាយមានជ័យ។ អញ្ជើញចូលរួមមាន លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការទិសទី១ បន្ទាយមានជ័យ លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ។ ក្នុងដំណើរចុះត្រួតពិនិត្យនាឱកាសនេះ គឺអនុវត្តទៅតាមបទបញ្ជា របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការបិទខ្ទប់តាមបណ្តាច្រកព្រំដែនកម្ពុជា-ថៃ សំដៅទប់ស្កាត់ការឆ្លងរីករាលដាលនូវជំងឺកូវីដ-១៩ ប្រភេទដែលតា។

លោកឧត្តមសេនីយ៍ទោ សេង ធារិន សូមអំពាវនាវ ដល់បងប្អូនដែលជាពលករខ្មែរ ធ្វើការនៅប្រទេសថៃ សូមមេត្តាកុំធ្វើដំណើរឆ្លងដែន មកប្រទេសកម្ពុជា ក្នុងដំណាក់កាលនេះ ព្រោះវាអាចបង្កឱ្យមានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ប្រភេទដែលតាចូលខ្លួនយើង និងក្រុមគ្រួសារយើង ហើយពេលនេះប្រទេសកម្ពុជា កំពុងអនុវត្តនូវវិធានការ របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការបិទច្រកព្រំដែនកម្ពុជា-ថៃ មិនឱ្យមានការឆ្លងកាត់ក្នុងរយៈពេលខ្លី ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចូលកម្ពុជាយើង ដូច្នេះសូមបងប្អូនទ្រាំលំបាកមួយរយៈពេលខ្លី ដើម្បីខ្លួនយើង ដើម្បីក្រុមគ្រួសារយើង និងដើម្បីកម្ពុជាយើង ឆ្លងផុតពីការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងដំណាក់កាលនេះ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ទោះបីរដ្ឋបិទខ្ទប់ ក៏នៅតែមានពលរដ្ឋខ្មែរឆ្លងដែនពីថៃមកស្រុកខ្មែរវិញ

https://khmeread.com/ July 31, 2021 01:44PM

បាត់ដំបង ៖ ទោះបីរាជរដ្ឋាភិបាលបានសម្រេចបិទខ្ទប់ខេត្តចំនួន៨ជាប់ព្រំដែនភាគខាងលិចដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលមេរោគកូវីដ-១៩បំប្លែងថ្មី យ៉ាងណាក្តី រហូតមកដល់ថ្ងៃសុក្រទី៣០ ខែកក្កដា ឆ្នាំ២០២១ នៅតែមានពលករខ្មែរមកពីថៃ ឆ្លងចូលមកស្រុកវិញ ហើយសមត្ថកិច្ចខ្មែរបានទៅទទួល រួចបញ្ជូនទៅធ្វើចត្តាឡីស័ក។ សមត្ថកិច្ចនិយាយថា លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូល

មកប្រទេសកម្ពុជាវិញ។ សមត្ថកិច្ចបន្តថា សមត្ថកិច្ចចម្រុះបានទៅទទួលពលរដ្ឋខ្មែរ៤នាក់ (ស្រី២នាក់) ត្រង់ចំណុច និងភូមិសាស្ត្រ ភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃសុក្រទី៣០ ខែកក្កដា ឆ្នាំ២០២១។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងសមត្ថកិច្ចបានប្រគល់បងប្អូនឱ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ រួចរាល់ហើយ៕

## បញ្ជាការកងកម្លាំងតាមបន្ទាត់ព្រំដែនយកចិត្តទុកដាក់ខ្ពស់បិទខ្ទប់ពលករមកពីប្រទេសថៃដើម្បីប្រយុទ្ធនឹងវីរុសដែលតា

https://www.rasmeinews.com/ 31 July, 2021

ដោយ:ភ្នំស្វាយ / បន្ទាយមានជ័យ: មេបញ្ជាការបានដាក់បញ្ជាថ្មីបន្ថែមដល់កងកម្លាំងទាំងឡាយដែលឈរជើងទទួលខុសត្រូវតាមខ្សែបន្ទាត់ព្រំដែនគោកក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងបណ្តាខេត្តនៃយោធភូមិភាគទី៥ ឱ្យយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការបិទខ្ទប់ការលួចឆ្លងដែនរបស់ពលករមកពីប្រទេសថៃមកកម្ពុជាដែលគ្មានការត្រួតពិនិតកយ។

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យបានរួមដំណើរជាមួយលោកឧត្តមសេនីយ៍ទោ សេង ផារិន មេបញ្ជាការរង នាយសេនាធិការយោធភូមិភាគទី៥ និងជាប្រធានគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់គោលដៅចត្តាឡីស័កប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ យោធភូមិភាគទី៥ និងលោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការរងយោធភូមិភាគទី៥ មេបញ្ជាការទិសទី១ បន្ទាយមានជ័យ និងនាយទាហានជាច្រើនរូបទៀត អញ្ជើញចុះត្រួតពិនិត្យ និងពង្រឹងដល់កងកម្លាំងកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។

ការចុះត្រួតពិនិត្យនាថ្ងៃនេះ ក្នុងគោលបំណង ដាក់វិធានការដល់កងកម្លាំងទាំងអស់តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ឱ្យយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការបិទខ្ទប់ការលួចឆ្លងដែនរបស់ពលករខ្មែរ និងពលរដ្ឋថៃឬជនបរទេសទាំងឡាយ ដែលលួចឆ្លងដែនតាមច្រករបៀងខុសច្បាប់មកពីប្រទេសថៃមកប្រទេសកម្ពុជាដែលគ្មានការត្រួតពិនិត្យសុខភាពនិងសុវត្ថិភាពពីជំងឺកូវីថ១៩ ៕

## ស្ថានទូតកម្ពុជានៅថៃ អំពាវនាវឲ្យពលករខ្មែរផ្អាកការចល័តចេញពីកន្លែងស្នាក់នៅ ជាបណ្តោះអាសន្ន បើមានបញ្ហាសូមទាក់ទង

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៣១ កក្កដា ២០២១ដោយ Kang Tola

ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជូនដំណឹងឲ្យពលករខ្មែរ ជាពិសេសប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកំពុងមានវត្តមាននៅប្រទេសថៃ ផ្អាកការធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅ ឬឆ្ពោះមកព្រំដែនកម្ពុជា-ថៃ ចំនួន១៤ថ្ងៃ ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩។ បើតាមស្ថានទូត ប្រសិនជាបងប្អូនពលករខ្មែរ មានបញ្ហានៅកន្លែងធ្វើការ ឬមានបញ្ហាជីវភាពលំបាកខ្លាំង គឺអាចទំនាក់ទំនងទៅស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ តាមរយៈលេខទូរស័ព្ទ៖ 092 8050 561, 094 0925 905, 062 1413 009, 086 7999 957 ឬតាមរយៈតេឡេក្រាម "ជំនួយកូវីដ-១៩ នៅថៃ" តំណរភ្ជាប់៖ https://t.me/helpkhmerinthailand។ ចំពោះបងប្អូនពលករដែលសង្ស័យថា ខ្លួនមានវិជ្ជមានកូវីដ-១៩ ឬមានវិជ្ជមានកូវីដ-១៩ កម្រិតស្រាលហើយមិនទាន់ដឹងថា ត្រូវទំនាក់ទំនងទៅផ្នែកណា អាចពិគ្រោះយោបល់តាមរយៈតេឡេក្រាម "ពិគ្រោះកូវីដ-១៩ នៅថៃ" តំណរភ្ជាប់៖ https://t.me/consultcovidinthailand។ ជាមួយគ្នានោះ ស្ថានទូតបានបងប្អូនពលករ ដែល

កំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ជ្រាបជាព័ត៌មាន និងកុំធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួនឱ្យសោះ ដើម្បីចៀសវាងប្រឈមនឹងវិធានការច្បាប់នានា និងចៀសវាងការចម្លងជំងឺកូវីដ-១៩ ដល់មិត្តភក្តិ និងក្រុមគ្រួសារ។

សូមបញ្ជាក់ថា កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ក្រសួងការងារបានជូនដំណឹងឲ្យបងប្អូនពលករខ្មែរទាំងអស់ ដែលកំពុងស្នាក់នៅធ្វើការនៅប្រទេសថៃ ផ្អាកការធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅ ឬឆ្លោះមកព្រំដែនកម្ពុជា-ថៃចំនួន១៤ថ្ងៃ ពីព្រោះរាជរដ្ឋាភិបាលបានសម្រេចបិទខ្ទប់បណ្ដាខេត្តមួយចំនួនជាប់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ ជាពិសេសប្រភេទ Delta ៕ *ដោយ ៖ កោះកែវ*

## តម្រួតថៃឃាត់ខ្លួនពលករខ្មែរ១៤នាក់ បម្រុងឆ្លងដែនមកកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៣០ កក្កដា ២០២១ដោយ deth leng

ពលករខ្មែរចំនួន១៤នាក់ ត្រូវបានកម្លាំងតម្រួតការពារព្រំដែនថៃលេខ៣ និងលេខ១២ ធ្វើការឃាត់ខ្លួនលើពីរគោលដៅ ស្របពេលដែលប្រទេសថៃកំពុងឆ្លងរាលដាលខ្លាំងនូវជំងឺកូវីដ-១៩ និងមេរោគបំប្លែងខ្លួន ធ្វើឱ្យពួកគេគេចខ្លួនត្រឡប់ចូលមកកម្ពុជាវិញ។ ការឃាត់ខ្លួននេះគឺបានធ្វើឡើងជាបន្តបន្ទាប់ នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ នៅក្នុងស្រុកតាប្រាក់យ៉ា និងក្នុងស្រុកអារញ្ញប្រាថេតតាមចំការដំឡូងមី ត្រង់ចំណុចដុងង្គ ក្នុងឃុំប៉ារ៉ៃ ដោយក្នុងស្រុកតាប្រាក់យ៉ាឃាត់បានចំនួន ៦ នាក់ និងក្នុងស្រុកអារញ្ញប្រាថេតចំនួន ៨ នាក់។

ក្រោយពីត្រួតពិនិត្យកម្តៅ ដើម្បីទប់ស្កាត់នូវជំងឺកូវីដ-១៩ រួចមក ពួកគេបានសារភាពថា ដោយសារតែការភ័យខ្លាចនូវជំងឺប្រភេទថ្មីផងទើបពួកគេសម្រេចវិលត្រឡប់មកកម្ពុជាវិញ ដោយចំណាយថវិកាក្នុងម្នាក់ៗទៅលើអ្នកបង្ហាញផ្លូវអស់ចំនួន ៤ ពាន់បាត៕ ដោយ: សោ និយមរ័ត្ន

# ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១

## កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញ-ចូល

http://cambodiapolice.com/policekh/ 7:57 pm 1 សីហា 2021

ខេត្តបាត់ដំបង ៖ កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០គោលដៅ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញ_ចូល។

ការដាក់កម្លាំងពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០គោលដៅនេះ បានធ្វើឡើង នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងការណែនាំរបស់លោកវរសេនីយ៍ ឯក ពៅ ថារុង ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ៕

# ដាក់វិធានការទប់ស្កាត់ពលករខ្មែរត្រឡប់ពីថៃខណៈរាប់រយនាក់កំពុងស្នះនៅព្រំដែនដីថៃ

https://kohsantepheapdaily.com.kh/ Banteay Meanchey០២ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១០:២៨

ខេត្តបន្ទាយមានជ័យ ៖ មេបញ្ជាការរងយោធភូមិភាគទី៥ បានដាក់វិធានការដល់កងកម្លាំងដែលឈរតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់អោយបានលើពលករត្រឡប់ពីប្រទេសថៃ ក្នុងពេលដែលលោកដឹកនាំកម្លាំងចុះពិនិត្យតាមបន្ទាត់ព្រំដែន កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។ ក្នុងឱកាសដែលចុះពិនិត្យតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ គឺមានការចូលរួមដោយលោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង និងនាយសេនាធិការយោធភូមិភាគទី៥ និងលោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការទឹសទី១បន្ទាយមានជ័យ និងចូលរួមមេបញ្ជាការ និងមេបញ្ជាការរងកងកម្លាំងយោធភូមិភាគទី៥ ។

លោកឧត្តមសេនីយ៍ទោ សេង ធារិន បានអោយដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចការបិទខ្ទប់ភូមិសាស្ត្រ៨ខេត្ត រវាងព្រំប្រទល់ខេត្ត និងខេត្តជាប់ជាយដែនថៃ ក្នុងនោះ មានខេត្តបន្ទាយមានជ័យ ជាបណ្តោះអាសន្នរយៈពេល១៤ថ្ងៃចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ សំដៅទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍ដែលបណ្តាលមកពីមេរោគកូវីដ.១៩ប្រភេទដែលតា ។ លោកបានបញ្ជាក់ថា ក្រោយមានការបិទខ្ទប់រវាងខេត្ត និងខេត្តនៅខេត្តបន្ទាយមានជ័យ ដែលខេត្តជាប់ព្រំប្រទល់និងប្រទេសថៃត្រូវបានបិទព្រំដែនមិនអោយប្រជាពលរដ្ឋឆ្លងកាត់សំដៅទប់ស្កាត់ពលករមិនអោយត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា ដើម្បីការពារទប់ស្កាត់ការរីករាលដាលដោយជំងឺកូវីដ.១៩ប្រភេទដែលតា ការពារមិនអោយរីករាលដាលក្នុងសហគមន៍ ។ លោកឧត្តមសេនីយ៍ទោ សេង ធារិន បានដាក់វិធានការកងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវតែបង្កើនការយកចិត្តទុកដាក់ការពារទប់ស្កាត់អោយចំពោះពលករដែលត្រឡប់ពីប្រទេសថៃ ដើម្បីការពារទប់ស្កាត់កូវីដ.១០ប្រភេទដែលតា តាមការណែនាំពីប្រមុខរាជរដ្ឋាភិបាលកម្ពុជានិងក្រសួងសុខាភិបាល ។ នៅពេលដែលប្រតិយោធភូមិភាគទី៥ ចុះពិនិត្យព្រំដែនពង្រឹងការទប់ស្កាត់ពលករដែលត្រឡប់ពីប្រទេសថៃ ឃើញកងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែនបានឃាត់ពលករខ្មែរជាង១០នាក់ ដែលលួចចូលពីប្រទេសថៃតាមច្រករបៀង ហើយក៏ទទួលព័ត៌មានបានដឹងថា មានពលករខ្មែរជាច្រើនរយនាក់ដែលកំពុងដេកនៅតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ក្រោយមានការបិទខ្ទប់ចេញមិនរួច។

គួរបញ្ជាក់ថា មុនថ្ងៃបិទខ្ទប់ព្រំប្រទល់ពីខេត្តមួយទៅខេត្តមួយ និងទប់ស្កាត់តាមបន្ទាត់ព្រំដែននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ឃើញមានពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ តាមច្រកអូរបីជាន់ស្រុកអូរជ្រៅ មានចំនួន២៩៨នាក់ (ស្រី១២៧) នាក់ រកឃើញអ្នកវិជ្ជមានកូវីដ.១៩មានចំនួន៧០នាក់ (ស្រី២៨នាក់) ។

## អំឡុងពេលបិទព្រំដែនកម្ពុជា-
## ថៃ ពុំមានសកម្មភាពលួចឆ្លងដែន តាមច្រកជាប់ខេត្តបាត់ដំបង

https://news.btv.com.kh/ 08/02/2021 11:08 AM

បាត់ដំបង ៖ ចាប់តាំងពីរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសបិទខ្ទប់ខេត្តចំនួន៨ និងបិទព្រំដែនមិនឲ្យ មានការឆ្លងដែនជាមួយថៃ ជាបណ្តោះអាសន្នលើកលែងការដឹកទំនិញ អាជ្ញាធរខេត្តបាត់ដំបង បានឲ្យដឹងថា រហូតមកដល់ពេលនេះ ពុំមានសកម្មភាពលួចឆ្លងដែនខុសច្បាប់ តាមច្រកនានាជាប់ខេត្តបាត់ដំបងឡើយ ខណៈអាជ្ញាធរ និងកងកម្លាំងជំនាញ កំពុងបន្តធ្វើការរឹតបន្តឹងតាមបន្ទាប់ព្រំដែន ។

លោក សុខ គឹមខុន អភិបាលស្រុកកំរៀង នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២១នេះ បានថ្លែងថា ក្នុងដំណើរការបិទព្រំដែននេះ ភាគីកម្ពុជាបានសហការយ៉ាងល្អជាមួយខាងភាគីថៃ ហើយរហូតមកដល់ពេលនេះ ខាងភាគីថៃពុំ

មានបញ្ជូនពលករខ្មែរ មកតាមច្រកព្រំដែនឡើយ ដោយខាងថៃបានរៀបចំឲ្យពលករខ្មែរធ្វើចត្តាឡីស័ក នៅក្នុងទឹកដីថៃ តែប្រសិនបើក្នុងករណីមានពលករខ្មែរលួចឆ្លងដែនទៅប្រទេសថៃ ត្រូវសមត្ថកិច្ចថៃចាប់បាន នឹងបញ្ជូនមកឲ្យភាគីកម្ពុជាវិញ ។ លោក បញ្ជាក់ថា ដោយសារតែភាគីកម្ពុជាបានឯកភាព និងស្រុះស្រួលគ្នាជាមួយខាងភាគីថៃរួចហើយ ទើបរហូតមកដល់ពេលនេះ ពុំមានករណីពលករលួចឆ្លងដែនខុសច្បាប់ ហើយកាលពីមុនពេលបិទព្រំដែននេះ ដោយមានការព្រមព្រៀងគ្នា គឺភាគីថៃបានបញ្ជូនពលករមានបំណងមកស្រុកកំណើតវិញ តាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងស្រុកកំរៀងនេះ ។ ចំពោះស្ថានភាពតាមបន្ទាត់ព្រំដែនវិញ លោកអភិបាលស្រុក បានអះអាងថា អាជ្ញាធរ និងកងកម្លាំង បានសហការគ្នាពង្រឹងយន្តការគ្រប់គ្រងព្រំដែនតាមអង្គភាពនីមួយៗ បានយ៉ាងល្អ និងតឹងរ៉ឹងបំផុត ពិសេសការទទួលខុសត្រូវរបស់មន្ត្រីតាមបន្ទាត់ព្រំដែន គឺមានកម្រិតខ្ពស់ពុំមានបាតុភាពមិនប្រក្រតីណាមួយកើតឡើងឡើយ ។

យោងតាមរបាយការណ៍រដ្ឋបាលខេត្តបាត់ដំបង កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ បានឲ្យដឹងថា មិនថាតែច្រកព្រំដែនជាប់ស្រុកកំរៀងនោះទេ ដែលគ្មានសកម្មភាពលួចឆ្លងដែន ខណៈស្រុក ៣ទៀត មានស្រុកសំពៅលូន ស្រុកភ្នំព្រឹក និងស្រុកសំឡូត ក៏គ្មានសកម្មភាពនេះដែរ និងបច្ចុប្បន្ននៅក្នុងខេត្តបាត់ដំបង មានអ្នកកំពុងធ្វើចត្តាឡីស័ក តាមមណ្ឌលនានាមាន ចំនួន២៥៣០នាក់ ។

ចាប់ពីមានការផ្ទុះឆ្លងជំងឺកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា សម្រាប់ខេត្តបាត់ដំបង មានអ្នកវិជ្ជមានជំងឺនេះចំនួន៣ ៤៨៧នាក់ បានព្យាបាលជាសះស្បើយចំនួន ២ ០៨៦នាក់ ករណីស្លាប់ ចំនួន ៤៣នាក់ និងកំពុងសំរាកព្យាបាល ១ ៣៥៨នាក់ ៕ អត្ថបទ បាន សុខវិទ្ធ

## អាជ្ញាធរខេត្តបន្ទាយមានជ័យ បន្តរកឃើញពលករខ្មែរ មកពីប្រទេសថៃ ចំនួន១២១នាក់ វិជ្ជមានកូវីដ១៩

https://cen-news.com/ Posted ByPen Srey Neat August 2, 2021

បន្ទាយមានជ័យ ៖ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ បានបន្តរកឃើញអ្នកវិជ្ជមានកូវីដ១៩ ចំនួន២០២នាក់ និងមានអ្នកជាសះស្បើយ ១០៩នាក់ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ ដោយក្នុងនោះ ពលករមកពីប្រទេសថៃ១២១នាក់ទៀត វិជ្ជមានកូវីដ១៩ ក្នុងចំណោមអ្នកឆ្លង២០២នាក់។

រដ្ឋបាលខេត្តបន្ទាយមានជ័យ សូមជម្រាបជូនដំណឹង ដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណៈជនឲ្យបានជ្រាបថា នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ មានករណីជាសះស្បើយអ្នកជំងឺកូវីដ-១៩ ចំនួន១០៩នាក់ និងយោងតាមលទ្ធផល តេស្តរហ័ស (Rapid Test)+ មន្ទីរពិសោធន៍ជាតិភ្នំពេញ(NIPH) នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ បានរកឃើញវិជ្ជមានជំងឺកូវីដ-១៩ថ្មី ដែលជាករណីឆ្លងនៅក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ និងពលករ វិលត្រឡប់ពីប្រទេសថៃ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខេត្ត លើបុរស ស្ត្រីជនជាតិខ្មែរ ចំនួន២០២នាក់ នៅក្នុងខេត្តបន្ទាយមានជ័យ ។ រដ្ឋបាលខេត្ត សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋ និងសាធារណៈជន ដែលបានប៉ះពាល់ដោយផ្ទាល់ សូមប្រញាប់មកជួបក្រុមគ្រូពេទ្យ និងធ្វើចត្តាឡីស័ក ដើម្បីយកសំណាកទៅពិនិត្យ និងអ្នកប៉ះពាល់ ដោយប្រយោលជាមួយ អ្នកវិជ្ជមានជំងឺកូវីដ-១៩ ទាំង២០២នាក់ខាងលើ សូមប្រញាប់ធ្វើចត្តាឡីស័ក តាមផ្ទះក្នុងក្រុមគ្រួសាររៀងៗខ្លួន ដោយមិនត្រូវពាក់ព័ន្ធ និងប៉ះពាល់ជាមួយអ្នកដទៃជាដាច់ខាត។

ក្នុងករណីមានការប្រែប្រួលសុខភាពខុសប្រក្រតី ដូចជា ឡើងកម្តៅលើសពី៣៧អង្សាស ក្អក កណ្តាស់ ហៀរ សំបោរ ឈឺបំពង់ក មានកំហាក ថប់ដង្ហើម...។ល។ ត្រូវប្រញាប់ទំនាក់ទំនងទៅក្រុមឆ្លើយតបបន្ទាន់នៃមន្ទីរសុខា ភិបាលនៃរដ្ឋបាលខេត្ត ឬមន្ទីរពេទ្យខេត្ត ក្រុង ស្រុក ឬមណ្ឌលសុខភាពឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋាន តាមរ

យៈ ទូរស័ព្ទលេខ០១២ ៧២៤០៤២ / ០១២ ៩៤៨៧៧៩។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ និងសាធារណៈជន មេត្តាជ្រាបជាព័ត៌មាន និង បន្តចូលរួមអនុវត្តតាមវិធានការ "៣ការពារ ៣កុំ" ជាដាច់ខាត៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ទប់ស្កាត់កូវីដបំប្លែងថ្មី Delta៖
## ជំនួយរបស់រដ្ឋាភិបាលពិតជាចាំបាច់ ដើម្បីទប់ស្កាត់ការចល័តរបស់ពលករ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 02/08/2021 - 08:43

*សម្រាប់អ្នកក្រីក្រ ឬអ្នកទីទាល់ក្រ និងមិនមានចំណេះវិជ្ជាផងនោះ បានចាត់ទុកថាប្រទេសថៃគឺជាឋានសួគ៌នៃការងារ ដោយសារតែទីនោះពលករចំណាកស្រុកខ្មែរ ទទួលបានការងារទាំងស្របច្បាប់ និងមិនស្របច្បាប់ ដោយមិនចាំបាច់មានសញ្ញាបត្រអ្វីឡើយ។ ក៏ប៉ុន្តែអំឡុងពេលកូវីដនេះ ជាពិសេសពេលកំពុងមានការរាតត្បាតយ៉ាងលឿននៃមេរោគកូវីដបំប្លែងថ្មីប្រភេទដែលតា(Delta) ទីផ្សារការងារជាច្រើននៅក្នុងប្រទេស ថៃត្រូវបានបិទ ហើយពលករចំណាកស្រុកខ្មែរជាច្រើនកំពុងស្ថិតនៅក្នុងស្ថានភាព«ចុះទឹកក្រពើ ឡើងលើខ្លា»។*

ប្រទេសកម្ពុជាកាលពីថ្ងៃពុធកន្លងទៅ បានប្រកាសដាក់វិធានការបិទខ្ទប់ខេត្តជាប់ព្រំដែនថៃចំនួន៨ និងដាក់បំរាមគោចរទូទាំងប្រទេសពីម៉ោង៩យប់ ដល់ម៉ោង៣ទៀបភ្លឺ រយៈពេល១៤ថ្ងៃ ដោយសារតែរកឃើញពលករខ្មែរ ដែលត្រលប់មកពីប្រទេសថៃមានវិជ្ជមានកូវីដ-១៩ កាន់តែច្រើន ជាពិសេសប្រភេទបំប្លែងថ្មីដែលតា(Delta) ដែលបានឆ្លងចូលសហគមន៍។ ជំណាលគ្នានេះ ពលករខ្មែរដែលកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ បាននិងកំពុងជ្រួលច្របល់ដោយសារពួកគេប្រឈមនឹងបញ្ហាធំៗមួយចំនួន គឺការឆ្លងជំងឺកូវីដ-១៩ ភាពអត់ការងារធ្វើ និងត្រូវធ្វើដំណើរដោយលួចលាក់ ខណៈដែលព្រំដែនកម្ពុជា-ថៃ ត្រូវបានបិទ និងរឹតបន្តឹងបន្ថែមទៀត។ នៅក្នុងស្ថានភាពបែបនេះ មានការចោទសួរថា តើពលករខ្មែរ នឹងទៅជាយ៉ាងណា ដោយសារតែពេលនេះ ថៃ ដែលជាទីផ្សារការងារដ៏ធំរបស់ពលករទេសន្តប្រវេសន៍ខ្មែរ កំពុងរងការឆ្លងរាលដាលជំងឺកូវីដ-១៩ បំប្លែងថ្មីដែលតា?

ជាការកត់សម្គាល់ ប៉ុន្មានថ្ងៃ មុនការប្រកាសបិទខ្ទប់ខេត្តចំនួន៨ រួមទាំងព្រំដែនជាមួយថៃយ៉ាងតឹងរឹងនោះ អង្គការសង្គមស៊ីវិល ដែលធ្វើការងារទាក់ទងទៅនឹងបញ្ហាពលករទេសន្តប្រវេសន៍ បានរាយការណ៍ថា ពលករខ្មែរបានត្រលប់មកប្រទេសរបស់ខ្លួនវិញក្នុងរង្វង់ពី ៤០០ ទៅ៥០០នាក់ ក្នុងមួយថ្ងៃៗ។ ពួកគេគឺជាក្រុមមនុស្សដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ជាច្រើនជំពូក និងកំពុងត្រូវការជំនួយសង្គ្រោះជាចាំបាច់។ ជាមួយគ្នានេះ ក្រសួងការងារកម្ពុជាក៏បានចេញសេចក្តីជូនដំណឹងទៅពលករដែរ កាលពីថ្ងៃសុក្រមុន ដោយស្នើឲ្យពលករកុំចល័តពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន ឆ្ពោះមកព្រំដែនកម្ពុជា-ថៃ ចំនួន១៤ថ្ងៃ រហូតដល់ថ្ងៃទី១២ ខែសីហា បើទោះណាជាមានធុរៈចាំបាច់ក៏ដោយ។ ពលករ នឹងត្រូវតម្រូវឲ្យវិលទៅកន្លែងដើមវិញប្រសិនបើនៅតែធ្វើដំណើរមកព្រំដែនកម្ពុជា-ថៃ។ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ក៏បាន និងកំពុងមានដំណោះស្រាយដែរ ដោយប្រាប់ឲ្យពលករខ្មែរ ដែលជួបប្រទះនឹងបញ្ហានៅកន្លែងធ្វើការ និងបញ្ហាជីវភាពទាក់ទងទៅស្ថានទូតរាល់ម៉ោងធ្វើការ។

នៅក្នុងដំណាក់កាលនេះ ពលករចំណាកស្រុកខ្មែរ គួរតែមានភាពអត់ធ្មត់កំរិតខ្ពស់ ដោយហេតុថា ការចល័ត ប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ នៃការឆ្លងកូវីដ-១៩ ជាពិសេសប្រភេទដែលតា។ ក៏ប៉ុន្តែភាពអត់ការងារធ្វើ កង្វះដីកសិកម្ម នៅក្នុងប្រទេសកំណើត និងកំរៃពលកម្មខ្ពស់នៅប្រទេសថៃ គឺជាចលករជម្រុញឲ្យពលករខ្មែរ ត្រូវតែប្រថុយឆ្លងកាត់ឧបសគ្គធំៗជាច្រើន ចូលទៅក្នុងប្រទេសថៃ ដើម្បីរកការងារធ្វើ។ ដូច្នេះអាជ្ញាធរ និងតំណាងកម្ពុជាគួរតែមានការយកចិត្តទុកដាក់លើពលករខ្មែរ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសថៃ ក្នុងតំណាក់កាលដ៏លំបាកនេះ ជាពិសេសផ្តល់ស្បៀងអាហារ និងផ្តល់សេវាសុខភាពដ៏ជាក់លាក់ បើពុំដូច្នោះទេ ការប្រថុយរបស់ពល

ករ ប្រកបដោយការប្រឈមនៅតែមាន ហើយការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ច្បាស់ណាស់ថានឹងមានការលំបាក។

សូមបញ្ជាក់ថា បច្ចុប្បន្នពលករខ្មែរ ដែលធ្វើការស្របច្បាប់ និងមិនស្របច្បាប់ នៅក្នុងប្រទេសថៃមានចំនួនជិត ២លាននាក់។ កាលពីពេលថ្មីៗនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០ ៨៨៥នាក់ ដែលក្នុងនោះមានស្ត្រី ៥៤ ៥៥៦នាក់ និង អនីតិជន៥៦៤នាក់ ផងដែរ៕

## ស្ថានទូតកម្ពុជានៅថៃរៀបចំ kits ចំនួន ៥ ពាន់កញ្ចប់ បន្តចែកជូនដល់បងប្អូនពលករខ្មែរ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២ សីហា ២០២១ដោយ deth leng

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឱ្យដឹងនៅព្រឹកថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១នេះថា ក្រុមការងារស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ បាននិងកំពុងបន្តសហការជាមួយក្រុមការងារទឹកចិត្តពលករនៅថៃ រៀបចំ kits ចំនួន៥០០០ កញ្ចប់ ដែលមានអង្ករ មី ត្រីខកំប៉ុង ថ្នាំពេទ្យ ដើម្បីបន្តចុះចែកជូនដល់បងប្អូនពលករខ្មែរ ដែលជួបការលំបាកខ្លាំងនៅតាមបណ្តាខេត្តនានា នៅក្នុងប្រទេសថៃ ខណៈដែលប្រទេសនេះ កំពុងជួបវិបត្តិធ្ងន់ធ្ងរ ដោយសារការរីករាល នៃជំងឺកូវីដ១៩។

កាលពីថ្មីៗនេះ ស្ថានទូតក៏បាននាំយកអំណោយ ដែលមានគ្រឿងឧបភោគបរិភោគចុះចែកជូនដល់បងប្អូនពលករខ្មែរចំនួន១៣០គ្រួសារ នៅទីតាំងចំនួន២ផងដែរដែលរួមមាន ការដ្ឋានសំណង់ ស្ថិតនៅសង្កាត់ចមកុនខណ្ឌចតុចក្រ ក្រុងបាងកក ទីនោះមានពលករខ្មែរ ៩០គ្រួសារ និង ទី១-ការដ្ឋានសំណង់ ស្ថិតនៅសង្កាត់ចមកុនខណ្ឌចតុចក្រ ក្រុងបាងកក ដែលនៅទីនោះ មានបងប្អូនពលករខ្មែរចំនួន ៩០គ្រួសារ និងទី២- ការដ្ឋានសំណង់ ស្ថិតនៅឃុំបាងភ្លីយ៉ៃ ស្រុកបាងភ្លី ខេត្តសមុទ្រប្រាកាន មានពលករខ្មែរចំនួន៤០គ្រួសារ។ ការចុះចែកអំណោយដល់បងប្អូនពលករខ្មែរនេះ គឺតែងទទួលបានការចូលរួមសហការ និងជួយសម្រួលពីអាជ្ញាធរពាក់ព័ន្ធរបស់ថៃ រួមមានតំណាងខាងសុខាភិបាលថៃ និងក្រសួងការងារថៃ ដោយអនុវត្តតាមវិធានការរបស់សុខាភិបាល ក្នុងការការពារ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ យ៉ាងខ្ជាប់ខ្ជួន៕ ដោយ: កោះកែវ

## សមត្ថកិច្ចថៃឃាត់ខ្លួនជនជាតិថៃប្រុស ស្រី៨នាក់បម្រុងឆ្លងដែនចូលកម្ពុជា

http://nokorwatnews.com/ 02/08/2021

ក្រុងប៉ោយប៉ែត៖ សមត្ថកិច្ចកងកម្លាំងការពារព្រំដែនខេត្តស្រះកែវរបស់ថៃ សហការជាមួយអង្គភាពពាក់ពន្ធ័កាលពីវេលាម៉ោង៥និង២៤នាទីថ្ងៃទី០១សីហា ២០២១នេះ បានឃុំខ្លួនជនជាតិថៃចំនួន៨ ខណៈកំពង់លួចឆ្លងដែនដោយខុសច្បាប់ ចូលមកក្រុងប៉ោយប៉ែតប្រទេសកម្ពុជា នៅបរិវេណភូមិ ណង យ៉ាកែវ ឃុំ/ស្រុក គោកឃ្សូង ខេត្តស្រះកែវ។នៅពេលសមត្ថកិច្ចសួរនាំ ពួកគេទាំង៨នាក់ បានសារភាពថា ត្រូវការឆ្លងចូលទៅធ្វើការកាស៊ីណូអនឡាញ នៅក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា ដោយក្នុងនោះ៤នាក់ការចំណាយទាំងថ្លៃរថយន្ត នឹងថ្លៃអោយមេខ្យល់នាំដើរឆ្លងកាត់តាមច្រករបៀង ត្រូវបានខាងថៅកែក្រុមហ៊ុនអនឡាញនៅប៉ោយប៉ែតជាអ្នកចំណាយ ដោយឡែកជនជាតិថៃ៤នាក់ទៀត ត្រូវចំណាយលុយថ្លៃឡានដឹកពីអារញ្ញមកព្រំដែនកម្ពុ-ថៃ ក្នុងម្នាក់៣០០បាត នឹងត្រូវចំណាឲ្យមេខ្យល់ជនជាតិខ្មែរ ដែលរង់ចាំនាំដើរឆ្លងកាត់តាមច្រករបៀងចូលមកកម្ពុជា ក្នុងម្នាក់ចំនួន១០.០០០បាតទៀត សរុបក្នុងម្នាក់១៣.០០០បាត៕

# ឃាត់ខ្លួនជនជាតិថៃ៧នាក់ បម្រុងឆ្លងដែនមកធ្វើការនៅក្នុងទឹកដីកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២ សីហា ២០២១ដោយ Sokhom Khon

ជនជាតិថៃចំនួន៧នាក់ ដែលក្នុងនោះមានមេខ្យល់ចំនួន២នាក់ផងនោះ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១១២ ធ្វើការឃាត់ខ្លួននៅក្បែរបន្ទាត់ព្រំដែន ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ។

ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង១រំលងអាធ្រាត្រ ឈានចូលថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុចភូមិណងយ៉ាកែវ ឃុំគោកខ្សូង ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបំប្លែងខ្លួន ដែលតា ។ ជនជាតិថៃទាំង៧នាក់ គឺមានប្រុស៤នាក់ និងស្រី៣នាក់ ដោយពួកគេមកពីខេត្តស្រះកែវ៣នាក់ ខេត្តណងខាយ១នាក់ និងទីក្រុងបាងកក១នាក់ ដោយឡែកប្រុស២ ២នាក់ទៀតគឺជាមេខ្យល់នាំផ្លូវ ដោយគេបានសារភាពថា ដោយគ្រាន់តែនាំឆ្លងកាត់ចំណុចណងសាមិត ចេញតាមច្រករបៀង ចូលទៅកាន់ទឹកដីខ្មែរគឺគេទទួលបាន ៧០០បាតក្នុងម្នាក់។

ដោយឡែកជនជាតិថៃទាំង៥នាក់ បានអះអាងថា ការលបឆ្លងដែននេះ គឺអាចធ្វើអោយពួកគេសល់កម្រៃច្រើន ដោយចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត បើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ៕ អត្ថបទ ៖ សោ និយមរ័ត្ន

## ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

## សម្តេចក្រឡាហោម ស ខេង ៖ កម្ពុជា-វៀតណាម សហការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ បទល្មើសគ្រឿងញៀន អំពើជួញដូរ និងរត់ពន្ធមនុស្សឆ្លងដែន

https://cen-news.com/ Posted ByPen Srey NeatAugust 4, 2021

រាជធានីភ្នំពេញ ៖ នៅព្រឹកថ្ងៃអង្គារ ទី៣ ខែសីហា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាសហប្រធានដឹកនាំកិច្ចប្រជុំពិនិត្យវាយតម្លៃលទ្ធផលកិច្ចសហប្រតិបត្តិការ និងចុះហត្ថលេខាលើអត្ថបទបំពេញបន្ថែមទៅលើផែនការសហប្រតិបត្តិការឆ្នាំ២០២០ ជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក តូ ឡឹម សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមប្រព័ន្ធវីដេអូ។

ស្របតាមស្មារតីនៃទំនាក់ទំនងដ៏ល្អ និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ រវាងថ្នាក់ដឹកនាំគ្រប់កម្រិត នៃប្រទេសទាំងពីរ កម្ពុជា-វៀតណាម សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម ឧត្តមសេនីយ៍ឯក តូ ឡឹម រដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយលទ្ធផលជាផ្លែផ្កា ក្នុងការងារថែរក្សាបានយ៉ាងរឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ និងសុវត្ថិភាពសង្គម ទោះបីស្ថិតក្នុងស្ថានភាពប្រឈមនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយជំងឺកូវីដ-១៩។ ភាគីទាំងពីរក៏បានកត់សម្គាល់នូវលទ្ធផល និងសមិទ្ធផលសំខាន់ៗ នៃកិច្ចសហប្រតិបត្តិការ ក្នុងរយៈពេលជាង១ឆ្នាំកន្លងទៅនេះ ក្នុងនោះរួមមាន៖ ការជួយគាំទ្រគ្នាទៅវិញមក ក្នុងការប្រយុទ្ធប្រឆាំងការរាតត្បាតនៃជំងឺកូវីដ-១៩ ការជួយឧបត្ថម្ភគាំទ្រផ្នែកសម្ភារបច្ចេកទេស ការងារកសាងសមត្ថភាពកងកម្លាំង ការផ្លាស់ប្តូរទស្សនកិច្ចប្រតិភូជំនាញ និងកិច្ចសហការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសបទល្មើសគ្រឿងញៀន អំពើជួញដូរ និងរត់ពន្ធមនុស្សឆ្លងដែន។

ទន្ទឹមនេះ សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ឧត្តមសេនីយ៍ឯក តូ ឡឹម ក៏បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការជិតស្និទ្ធរវាងអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនៃបណ្តាខេត្តជាប់

ព្រំដែន ដែលតែងជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ក្នុងការប្រយុទ្ធប្រឆាំងការរីករាលដាល នៃជំងឺកូវីដ-១៩ និងការថែរក្សាបរិយាកាសសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនបានល្អប្រសើរ ដែលរួមចំណែកបង្កលក្ខខណ្ឌសមស្របដល់ការប្រកបជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាបម្រើដល់ការអភិវឌ្ឍសង្គមជាតិ និងផលប្រយោជន៍ទៅវិញទៅមក របស់ប្រជាជននៃប្រទេសទាំងពីរ។ ដើម្បីបន្តអនុវត្តនូវយន្តការសហប្រតិបត្តិការប្រចាំឆ្នាំទ្វេភាគីរវាងក្រសួងទាំងពីរ ដែលបានអាក់ខាន អស់រយៈពេលជាង១ឆ្នាំកន្លងមកនេះ ដោយសារស្ថានភាពប្រឈមដ៏ស្មុគស្មាញបង្កឡើងដោយជំងឺកូវីដ-១៩ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា និងឯកឧត្តមឧត្តមសេនីយ៍ឯក តូ ឡឹម សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម បានចុះហត្ថលេខាលើអត្ថបទបំពេញបន្ថែមទៅលើខ្លឹមសារនៃផែនការសហប្រតិបត្តិការឆ្នាំ២០២០ សម្រាប់អនុវត្តបន្តជាផែនការសហប្រតិបត្តិការឆ្នាំ២០២១ រវាងក្រសួងទាំងពីរ និងបានឯកភាពយកចិត្តទុកដាក់បន្តអនុវត្តកិច្ចការសំខាន់ៗមួយចំនួនបន្ថែមទៀត រួមមាន៖ បង្កើនកិច្ចសហការធានាសន្តិសុខតាមព្រំដែន តាមរយៈការជំរុញវិធានការបង្ការ និងទប់ស្កាត់ការចេញ-ចូលឆ្លងដែនខុសច្បាប់ ព្រមទាំងបន្តកិច្ចសហការរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពតំបន់ព្រំដែន ដើម្បីកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព មិត្តភាព និងការអភិវឌ្ឍ, បង្កើនកិច្ចសហការបង្ការ និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ប្រព្រឹត្តដោយបុគ្គល ឬបទល្មើសមានអង្គការចាត់តាំង ជាពិសេសបទល្មើសគ្រឿងញៀន និងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ដោយអនុលោមតាមច្បាប់នៃប្រទេសនីមួយៗ និងការបន្តកិច្ចសហការជិតស្និទ្ធ ក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងការជួយគាំទ្រគ្នាទៅវិញទៅមក លើការងារថែរក្សាសន្តិសុខ សុវត្ថិភាព បម្រើឲ្យការប្រារព្ធនូវព្រឹត្តការណ៍ជាតិ និងអន្តរជាតិសំខាន់ៗ ដែលប្រទេសទាំងពីរត្រូវរៀបចំ ឬធ្វើជាម្ចាស់ផ្ទះ។

សូមជម្រាបជូនថា ឆ្នាំ២០២១នេះ ក្រសួងមហាផ្ទៃកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះប្តូរវេន រៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ២០២១ ដើម្បីពិនិត្យវាយតម្លៃលទ្ធផលកិច្ចសហប្រតិបត្តិការឆ្នាំ២០២០ រវាងក្រសួងមហាផ្ទៃ កម្ពុជា និងក្រសួងនគរបាលវៀតណាម។ ក៏ប៉ុន្តែដោយសារស្ថានភាពប្រឈមនៃជំងឺកូវីដ-១៩ កិច្ចប្រជុំប្រចាំឆ្នាំ២០២១នេះត្រូវបានលើកមកប្រារព្ធធ្វើតាមប្រព័ន្ធវីដេអូវិញ ៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ផ្តែផ្តាំដល់បងប្អូនពលករ ដែលចង់ត្រលប់មកស្រុកកំណើត សូមកុំធ្វើបែបនេះ អាចគ្រោះថ្នាក់ណាស់

https://cambonews-plus.online/ by MMO 1 03/08/2021

បន្ទាយមានជ័យ៖ រដ្ឋាភិបាលមានការព្រួយបារម្ភដល់សុវត្ថិភាពបងប្អូនប្រជាពលរដ្ឋទាំងក្នុងស្រុក និងចំណាកស្រុកជាខ្លាំង បន្ទាប់ពីពលករខ្មែរចំណាកស្រុកដែលត្រឡប់មកស្រុកកំណើតវិញដោយធ្វើសកម្មភាពល្មើសនឹងវិធានការរបស់ក្រសួនសុខាភិបាល។ កាលពីថ្ងៃទី០២ សីហា ម្សិលមិញនេះ ខាងកម្លាំងមន្ត្រីសមត្ថកិច្ច បានសហការគ្នាចុះស្វែងរកតាមភូមិសាស្ត្រតូចៗ និងចាប់បានបងប្អូនពលករខ្មែរ មួយចំនួនដែលបានរត់គេចតាមព្រៃឆ្លងអូ ដើម្បីគេចពីការធ្វើតាមវិធានការអនុវត្ត ចត្តាឡីស័ក្ក១៤ថ្ងៃរបស់ក្រសួងសុខាភិបាល។ កាន់តែព្រួយបារម្ភនោះគឺ បងប្អូនពលករខ្មែរទាំងនេះ បានលួចឆ្លងអូរត់កាត់ព្រៃ លួនតាមប្រកតូចៗ ដែលជាតំបន់មានគ្រាប់មីនមិនទាន់ផ្ទុះលើសពីនោះវាអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតជាជាងការធ្វើចត្តាឡីស័ក្កទៅទៀត។ យោងតាមហេតុការណ៍នេះ សូមផ្តែផ្តាំដល់បងប្អូនពលករដែលវិលត្រឡប់មកស្រុកកំណើតវិញសូមរក្សាភាពអត់ធ្មត់និងធ្វើការវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីការពារសុវត្ថិភាពពីការចម្លង ជម្ងឺកូវីដ១៩ ដល់អ្នកដ៏ទៃ។ ជាពិសេសសូមបងប្អូន

កេកន្លែងសុវត្ថិភាព រួចរាយការណ៍ចូលស្ថានទូតឬក្រុមការងារតាមព្រំដែនក៏ដូចជាក្រុមការងារដែលចុះទៅជួយបងប្អូននៅដីថៃ៕ប្រភព៖ Banteay Meanchey News Youths

## ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បន្តចុះសួរសុខទុក្ខកម្លាំងតាមព្រំដែនកម្ពុជា-ថៃនិងកម្លាំងកំពុងឈរជើងបិទខ្ទប់ព្រំប្រទល់ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

http://cambodiapolice.com/policekh/ 4:39 pm 3 សីហា 2021

បន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមាមជ័យ អមដំណើរដោយលោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការរង ទទួលផែនការងារសេនាធិការ, លោកវរសេនីយ៍ឯក វ៉ាត ចន្ថា នាយការិយាល័យគណនេយ្យ នៃស្នងការដ្ឋាននគរបាលខេត្ត បានបន្តចុះសំណេះសំណាលសួរសុខទុក្ខ និងត្រួតពិនិត្យការរៀបចំសណ្តាប់ធ្នាប់ កងកម្លាំងកំពុងឈរជើងបិទខ្ទប់នៅតាមព្រំប្រទល់ ក្នុងភូមិសាស្រ្តខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ កម្លាំងវរៈនគរបាលការពារព្រំដែនគោកលេខ៨០៧ កម្លាំងអធិការដ្ឋាននគរបាលស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

នៅក្នុងពិធីពិធីសំណេះសំណាលនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១នេះ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បាននាំយកអំណោយរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ មានទឹកបរិសុទ្ធវីតាល់ចំនួន១០០កេស, ម៉ាស់ចំនួន២.៥០០ម៉ាស់ និងរបាំងពាក់មុខចំនួន៨០ ប្រគល់ជូនដល់កម្លាំងវរៈនគរបាលការពារព្រំដែនគោកលេខ៨០៧ កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលថ្មពួក សហការជាមួយកម្លាំងយោធា កងរាជអាវុធហត្ថ និងអាជ្ញាធរមូលដ្ឋាន ក្នុងយុទ្ធនាបិទខ្ទប់ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ប្រភេទថ្មីដែលតា ដូចជាតាមគោលដៅនៃព្រំប្រទល់ខេត្តឧត្តរមានជ័យ ស្រុកបន្ទាយអំពិល និងភូមិសាស្រ្តខេត្តបន្ទាយមានជ័យ ស្រុកថ្មពួក និងគោលដៅផ្សេងៗទៀត ដូចជាគោលដៅអក្សរ (T) ស្ថិតក្នុងភូមិថ្មរមៀលលើផ្លូវជាតិលេខ៥៩, គោលដៅគោងាប់ជាប់ព្រំដែនកម្ពុជា-ថៃស្ថិតក្នុងភូមិតាម៉ុាំង,គោលដៅច្រកតំបនបឹងត្រកួនជាប់ព្រំដែនកម្ពុជា-ថៃស្ថិតភូមិបន្ទាយមានឫទ្ធិ ឃុំគោករមៀត ។

ទន្ទឹមនោះដែរ លោកឧត្តមសេនីយ៍ស្នងការបានជំរុញដល់កងកម្លាំងគ្រប់គោលដៅទាំងអស់ ត្រូវតែបង្កើនការយកចិត្តទុកដាក់ត្រួតពិនិត្យឲ្យបានហ្មត់ចត់ នូវវិធានការបិទខ្ទប់ការឆ្លងកាត់ព្រំប្រទល់ពីខេត្តមួយទៅខេត្តមួយ ក៏ដូចជាការបិទខ្ទប់តាមបន្ទាត់ព្រំដែន មិនត្រូវឲ្យមានប្រជាពលរដ្ឋឆ្លងដែនមកពីប្រទេសថៃ បើសិនជាមានហាមដាច់ខាតមិនឲ្យឆ្លងចូលមក ត្រូវឲ្យពួកគាត់សម្រាកដោយមានសុវត្ថិភាពនៅនឹងព្រំដែននោះមួយរយៈសិន រហូតមានបទបញ្ជាពីថ្នាក់លើ ។ ក្នុងនោះក៏ត្រូវប្រគល់តង់ជូនគាត់ធ្វើជាជម្រកនិងផ្តល់ស្បៀងអាហារ ទឹក ជូនពួកគាត់ហូបចុកប្រចាំថ្ងៃ ។ ជាមួយគ្នានេះដែរ លោកឧត្តមសេនីយ៍ទោស្នងការ ក៏បានក្រើនរំលឹកដល់កងកម្លាំងដែលកំពុងឈរជើងតាមគោលដៅទាំងអស់មិនត្រូវធ្វែសប្រហែសនោះឡើយ គឺត្រូវថែរក្សាសុខភាពឲ្យបានល្អ យើងអាចភ្លេចកូវីដ-១៩ តែកូវីដ-១៩វាមិនភ្លេចយើងនោះទេ គឺត្រូវមានអមយ័ជានិច្ច និងអនុវត្តតាមគោលការណ៍របស់ក្រសួងសុខាភិបាល និងវិធានការ «៣ការពារ និង៣កុំ» របស់រាជរដ្ឋាភិបាលជាប់ជាប្រចាំ ៕

## ចាញ់បោកមេខ្យល់យកមកប្លុងចោលនៅចម្ការមីន ម្ដាយខំរត់គេចទាំងរបួសជើង

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៣ សីហា ២០២១ដោយ Dy Bunnara

ខេត្តបន្ទាយមានជ័យ៖ អាជីវករលក់ដូរនៅផ្សាររុងគ្លឿពីរនាក់ម្ដាយកូន ចាញ់បោកមេខ្យល់យកមកប្លុងចោលក្នុងចំការមីននៅចំណុចប៉ុស្តិ៍ប្រាសាទតែ្បង រត់ធ្លាក់ប្រឡាយបាក់ជើងត្រូវសមត្ថកិច្ចចម្រុះសង្គ្រោះទាន់។ ហេតុការណ៍កើតឡើងនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ នៅចំណុចក្នុងចំការមីនក្បែរប៉ុស្តិ៍ប្រាសាទតែ្បង ស្ថិតក្នុងភូមិប្រាសាទតែ្បង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

សមត្ថកិច្ចចម្រុះបានបញ្ជាក់ឲ្យដឹងថា ពេលកំពុងដើរល្បាតនៅតាមបន្ទាត់ព្រំដែន ស្រាប់តែឃើញស្ត្រី២នាក់ម្ដាយនិងកូន រត់ចេញពីចំការមីនធ្លាក់ប្រឡាយ បណ្ដាលឲ្យបាក់កជើងខាងស្ដាំសមត្ថកិច្ចចម្រុះបានធ្វើការឃាត់យកមកសួនាំ។ បើតាមស្ត្រីរូបនោះបាននិយាយថា ខ្លួនជាអាជីវករលក់ដូរក្នុងផ្សាររុងគ្លឿប្រទេសថៃ។ ថ្ងៃកើតហេតុខ្លួននិងកូនបានឲ្យមេខ្យល់ជូនចេញពីផ្សាររុងគ្លឿស៊ីសងតាមតម្លៃជូន ពេលនិយាយត្រូវគ្នាហើយ មេខ្យល់បានជូនយកមកប្លុងចោលក្នុងចំការមីន ដោយដឹងថា ត្រង់ចំណុចនេះជាចំការមីនក៏នាំកូនរត់ធ្លាក់ប្រឡាយ បណ្ដាលឲ្យបាក់ជើងតែម្ដង ហើយសំណាងណាស់បានសមត្ថកិច្ចល្បាតនៅទីនោះជួយទាន់។ ស្ត្រីម្ដាយនិងកូន ក្រោយពីក្រុមគ្រូពេទ្យយកសំណាកធ្វើតេស្តហើយម្ដាយវិជ្ជមានកូវីដ១៩។ ឥឡូវត្រូវបានខាងក្រុមសុខាភិបាលស្រុកថ្មពួក ដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យហើយ៕ អត្ថបទ៖ វ៉ាន់ ណាង

## ពលករ ខ្មែរ,មីយ៉ាន់ម៉ា,ឡាវ ត្រូវថៃបោះបង់ចោល ខណៈពេលកូវីដកំពុងផ្ទុះខ្លាំង

https://www.facebook.com/CHNChannelNews/ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ម៉ោង ១៨:១៧:០០

ថៃ៖ ពលករចំណាកស្រុកមកពី មីយ៉ាន់ម៉ា កម្ពុជា និង ឡាវ ត្រូវបានប្រទេសថៃបោះបង់ចោល ខណៈអាជ្ញាធរថៃ បានចាត់វិធានការ ដើម្បីទប់ស្កាត់ការរីករាលដាលនៃកូវីដ ១៩ នៅទីក្រុងបាងកក ដោយបិទកន្លែងការដ្ឋានកម្មករចំនួន ៥៧៥ កន្លែងនៅក្នុងទីក្រុង។

ពលករចំណាកស្រុកទាំង៣ប្រទេសនេះ ត្រូវប៉ូលីសថៃកេណ្ឌប្រមូលផ្ដុំគ្នាបិទការដ្ឋានសំណង់ ក្នុងគោលបំណងកុំមានការរាតត្បាតក្នុងប្រទេស។ ការផ្លាស់ប្ដូរនេះបានធ្វើឱ្យកម្មករសំណង់ជាង៨ម៉ឺននាក់ ដែលកំពុងរស់នៅក្នុងការដ្ឋានសំណង់ទាំងនោះ ធ្វើឲ្យពួកគេគ្មានប្រាក់ចំនូលដើម្បីទិញម្ហូបអាហារ និងរបស់របរចាំបាច់ផ្សេងៗទៀត។ ពលករចំណាកស្រុកមីយ៉ាន់ម៉ា បាននិយាយថា គេមិនបានញ៉ាំបាយអស់រយៈពេលពីរថ្ងៃមកហើយ គាត់រស់នៅជាមួយជនចំណាកស្រុកជាង ៤០ នាក់ផ្សេងទៀត មកពីមីយ៉ាន់ម៉ា និងកម្ពុជា នៅកន្លែងសំណង់បិទខ្ទប់នៅចំកណ្ដាលទីក្រុងបាងកក។ មុនពេលមានជំងឺរាតត្បាតពួកគេបានរស់នៅញ៉ាំ និងគេងនៅក្នុងអគារដែលមិនទាន់សាងសង់ហើយ បានផ្ញើប្រាក់សន្សំភាគច្រើនទៅផ្ទះ ដើម្បីផ្គត់ផ្គង់គ្រួសារ។ ពលករចំណាកស្រុកមីយ៉ាន់ម៉ា និយាយទៀតថា "យើងកំពុងរងទុក្ខខ្លាំង យើងគ្មានលុយទេ យើងមិនអាចផ្ញើប្រាក់ទៅផ្ទះទៅគ្រួសាររបស់យើងដែលកំពុងរងទុក្ខបានទេ។ យើងចង់ទៅផ្ទះវិញ ទោះបីយើងគ្មានអ្វីក៏ដោយ យ៉ាងហោចណាស់យើងអាចនៅជាមួយគ្រួសារបាន។

ពលករចំណាកស្រុកប្រមាណពី ៤ ទៅ ៥ លាននាក់នៅប្រទេសថៃ ដែលភាគច្រើនមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ កំពុងរស់នៅដោយសេចក្ដីមេត្តា ករុណាពី និយោជករបស់ពួកគេ។ ដោយសាររោងចក្រត្រូវបានបិទ និងការដ្ឋានសាងសង់ត្រូវបានបិទ ជនចំណាកស្រុករាប់សែននាក់ដែលកំពុងរស់នៅក្រោមលក្ខខណ្ឌ ជំងឺរាតត្បាត និងត្រូវបានកាត់ផ្ដាច់ពីជំនួយ។

លោក ឡេង សុផុន មន្ត្រីគម្រោងនៃអង្គការសិទ្ធិការងារកម្ពុជា បាននិយាយថា ជីវិតរបស់ជនចំណាកស្រុកកម្ពុជា គឺដូចជាការរត់គេចពីសត្វខ្លា ប៉ុន្តែធ្លាក់ចូលក្នុងមាត់ក្រពើ។ ការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែនឥឡូវនេះ

ពោរពេញទៅដោយហានិភ័យ។ សម្រាប់អ្នកដែលមានលទ្ធភាពវិលត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ ពួកគេមានឱកាសការងារតិចតួចប៉ុណ្ណោះ។

លោក ឌួង ជាពលករចំណាកស្រុកកម្ពុជា បាននិយាយថា "ខ្ញុំដឹងថាគ្មានការងារធ្វើនៅទីនេះទេ។ ខ្ញុំគ្មានដីសំរាប់ធ្វើស្រែចំការ ដូច្នេះអ្វីដែលខ្ញុំអាចធ្វើបានគឺនៅផ្ទះតែ ដោយសារគ្មានការងារធ្វើនៅប្រទេសថៃអស់រយៈពេលជាងមួយខែមកហើយ។"

គួរបញ្ជាក់ថា ប្រទេសថៃជាទិសដៅការងារយូរយារណាស់មកហើយ សម្រាប់ប្រជាជនកម្ពុជា ដែលកំពុងស្វែងរកការងារធ្វើ។ យោងតាមក្រសួងការងាររបស់ប្រទេសកម្ពុជា មានពលករចំណាកស្រុកខ្មែរចំនួន ១.០២០.០០០ នាក់ប៉ុន្តែចំនួនពិតប្រាកដគឺជិត ២ លាននាក់៕

## ពលករខ្មែរមួយចំនួននាំគ្នាដេកហាលភ្លៀងយ៉ាងលំបាកនៅព្រំដែនថៃ ដោយសារអាជ្ញាធរចូលប្រទេស

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន2021-08-02

ពលករខ្មែរមួយចំនួននាំគ្នាដេកហាលភ្លៀងយ៉ាងលំបាកអស់ជាច្រើនថ្ងៃ នៅព្រំដែនប្រទេសថៃ ក្រោយពេលអាជ្ញាធរបិទខ្ទប់ព្រំដែនមិនឱ្យពួកគេចូលកម្ពុជា។ ពលករទាំងនោះធ្វើដំណើរមកពីតំបន់ទីក្រុងបាងកក ដើម្បីគេចចេញពីការឆ្លងជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា ពលករទាំងនោះប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតប្រសិនបើអាជ្ញាធរខ្មែរមិនឆាប់ជួយដល់ពួកគាត់។ ពលករខ្មែរជាច្រើននាក់ដែលកំពុងជាប់គាំងនៅតំបន់ព្រំដែនថៃនោះ ថ្លែងថា ពួកគេព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន។ ពួកគេអំពាវនាវដល់អាជ្ញាធរខ្មែរឱ្យជួយសង្គ្រោះអាយុជីវិតរបស់ពួកគេជាបន្ទាន់។

ពលករមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យលោកស្រី ប៉ុង ស៊ីម ប្រាប់វិទ្យុអាស៊ីសេរីនៅព្រឹកថ្ងៃទី២ ខែសីហាថា លោកស្រីបានជាប់គាំងនៅតំបន់ព្រំដែនថៃជាប់ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យតាំងពីថ្ងៃទី៣០ ខែកក្កដា រហូតមកដល់ពេលនេះមិនទាន់ចូលទៅដល់កម្ពុជានៅឡើយទេ។ បច្ចុប្បន្នលោកស្រីបានបោះតង់ស្នាក់នៅក្នុងកំប៉ុតព្រៃនៅតំបន់ព្រំដែនថៃយ៉ាងលំបាក ដោយគ្មានថ្នាំព្យាបាលជំងឺនោះឡើយ។ ពលករដែលធ្លាប់ធ្វើការក្នុងហាងលក់បាយនៅខេត្តជាប់ទីក្រុងបាងកករូបនេះបញ្ជាក់ទៀតថា មូលហេតុដែលលោកស្រីត្រឡប់ទៅកម្ពុជាអំឡុងពេលនេះ ដោយសារមិនអាចទ្រាំរស់នៅប្រទេសថៃបន្តទៅទៀតបាន ព្រោះគ្មានប្រាក់ចាយវាយនិងខ្លាចឆ្លងជំងឺកូវីត១៩៖ « ពេលភ្លៀងមកពួកខ្ញុំនាំគ្នាងើបអង្គុយហើយ វាសាចសើមទាំងអស់បង្គន់ក៏អត់មានដែរ នាំគ្នារត់ទៅព្រៃហើយងូតទឹកអូរ។ ប្រុសៗអត់បានដេកទេ អង្គុយចាំ ទល់ភ្លឺលំបាកណាស់។ខ្ញុំអំពាវនាវឱ្យរដ្ឋាភិបាលនាំពួកខ្ញុំទៅខាងខ្មែរ ធ្វើតេស្តរកមេរោគកូវីដ១៩ហើយ បើអ្នកណាកើតក៏ឱ្យទៅព្យាបាល អ្នកណាអត់កើត ក៏ឃុំខ្លួននៅសាលារៀនទៅខ្ញុំចង់បានតែប៉ុណ្ណឹងឯង»។

ដូចគ្នានេះដែរ ពលករធ្វើការនៅហាងលក់បាយនៅខេត្តប្រាក់ថុមថានី (Prathumthany) ម្នាក់ទៀតលោក សេង សុគន្ធ ថ្លែងថា លោកគ្មានលទ្ធភាពរស់នៅប្រទេសថៃនោះទេ ទើបសម្រេចចិត្តប្រថុយជីវិតធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ។ ពលករវ័យ ២៧ ឆ្នាំរូបនេះសោកស្តាយយ៉ាងខ្លាំងដែលអាជ្ញាធរខ្មែរមិនឱ្យលោកចូលទៅកម្ពុជានៅក្នុងគ្រាអាសន្ននេះ។ ពលកររូបនេះបញ្ជាក់ថា អំឡុងពេលស្នាក់នៅព្រំដែននោះលោកដេកហាលភ្លៀងជារៀងរាល់យប់ ដូច្នេះលោកព្រួយបារម្ភខ្លាចជួបគ្រោះធំនៅពេលខាងមុខ ពីព្រោះលោកហូបចុកក្រៀមក្រោះអស់ជាច្រើនថ្ងៃមកហើយ៖ «ឱ្យតែមេឃភ្លៀង គឺអត់បានសម្រាន្តទេ ហើយក្មេងៗយំពេញហ្នឹងឯង មើលទៅគួរឱ្យអាណោចអាធម្មណា

ស់។ អាណោចអាធម្មត្រង់ថា លំបាកខោទឹកនោមក៏អត់មាន ហើយណាមួយកូនតូចទៀត ត្រូវទឹកភ្លៀងរងាហើយមួសខាំ និយាយរួមវេទនាហ្មង ម៉ែឪវាក៏មិនបានដេកដៃរអង្គុយបក់មូសមួយយប់ទល់ភ្លឺ។

ពលករខ្មែរមួយក្រុមនេះមានគ្នា ២៨ នាក់ក្នុងនោះមានទារកអាយុ ៧ ខែម្នាក់ផង បានធ្វើដំណើរមកពីខេត្តជាប់ទីក្រុងបាងកកកាលពីថ្ងៃទី៣០ ខែកក្កដា ដើម្បីត្រឡប់ទៅកម្ពុជារកកន្លែងមានសុវត្ថិភាព។ ក្រុមពលករអះអាងថា បច្ចុប្បន្នមានពលករខ្លះបានឆ្លងជំងឺកូវីដ១៩ ហើយគ្មានគ្រូពេទ្យព្យាបាលពួកគាត់នៅឡើយទេ។ ក្រុមពលករបន្តថា អាជ្ញាធរបានឧបត្ថម្ភស្បៀងបន្តិចបន្តួចដល់ពួកគាត់ដែរ ក៏ប៉ុន្តែមិនបានបញ្ជូនគ្រូពេទ្យមកពិនិត្យជំងឺកូវីដ១៩ នោះទេ។

ទាក់ទងនឹងបញ្ហានេះស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីថា លោកមិនទាន់ទទួលដំណឹងអំពីពលករខ្មែរ ដែលកំពុងជាប់គាំងនៅប្រទេសថៃ ទាំងនោះទេ។ លោកថា អំឡុងពេលនេះអាជ្ញាធរនៅតែអនុញ្ញាតឱ្យពលករចូលមកកម្ពុជាបានដដែល ប៉ុន្តែត្រូវមានការត្រួតពិនិត្យតឹងតែងជាងមុខទ្វេដង។ លោកបញ្ជាក់ថា បច្ចុប្បន្នមានពលករ ប្រមាណពី ២០០ ទៅ ៣០០ នាក់ក្នុងមួយថ្ងៃបានឆ្លងដែលចូលមកកម្ពុជា។ លោកបន្តថា ពលករណាដែលកើតជំងឺកូវីដ១៩ អាជ្ញាធរនឹងបញ្ជូនពួកគេទៅព្យាបាលនៅទីរួមខេត្តបន្ទាយមានជ័យ ចំណែកពលករដែលគ្មានជំងឺឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃនៅព្រំដែន៖ «ឱ្យចូលប៉ុន្តែពិនិត្យសិន ខ្លាចមានជំងឺមានអីទៅមានជំងឺកូវីដអីមិនទាន់ហ៊ានឱ្យចូល។ អ្នកណាមានកើតជំងឺកូវីដ-១៩ យើងដឹកទៅមុន អ្នកណាមិនទាន់ឱ្យទុកសិន ទុកពិនិត្យមើលសិន ទុកដីខ្មែរខ្លះនៅដីថៃខ្លះ អ្នកណាមិនទាន់មកដល់នៅដីថៃ អ្នកណាមកដល់ហើយនៅតាមទឹកដីយើង»។

ទោះជាយ៉ាងណា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា បច្ចុប្បន្នមានពលករខ្មែរជាច្រើននាក់បានជាប់គាំងនៅព្រំដែនខាងដីថៃ ហើយពួកគេរស់នៅលំបាកវេទនាដោយគ្មានទីជម្រកស្នាក់អាស្រ័យឡើយ។ លោកយល់ថា ពលករទាំងនោះប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតនៅពេលដ៏ខ្លីខាងមុខ ប្រសិនបើអាជ្ញាធរមិនឆាប់បញ្ជូនគ្រូពេទ្យព្យាបាលជំងឺ និងផ្តល់ស្បៀងអាហារហូបចុកគ្រប់គ្រាន់នោះ៖ «អ្វីដែលសំខាន់ត្រូវតែយកចិត្តទុកដាក់សង្គ្រោះជីវិតដល់ពួកគាត់ បើពួកគាត់ដង្ហោយហៅហើយ ប្រាប់ហើយ យើងបែរធ្វើមិនដឹងមិនឮ យើងគិតថាតួនាទីរបស់រដ្ឋនៅកន្លែងហ្នឹងខ្វះចន្លោះហើយ។ អីចឹងត្រូវតែបំពេញធ្វើយ៉ាងម៉េចដើម្បីជួយដល់ប្រជាពលរដ្ឋយើង។ សូម្បីពួកគាត់ជាកម្មករថៃក្រីក្រពួកគាត់ស៊ីឈ្នួលគេប៉ុណ្ណាក៏ដោយ ប៉ុន្តែពួកគាត់ជាមនុស្សដែរ ជាប្រជាពលរដ្ឋកម្ពុជាដែរ»។

អាជ្ញាធរកម្ពុជាបានបិទខ្ទប់ខេត្តចំនួន ៨ នៅជាប់ព្រំដែនថៃ ចាប់តាំងពីថ្ងៃទី២៩ ខែកក្កដា ដល់ថ្ងៃទី១២ ខែសីហា ដើម្បីទប់ស្កាត់មេរោគកូវីដ-១៩ បំប្លែងថ្មីឈ្មោះដែលតា (Delta)។ អំឡុងពេលបិទខ្ទប់នេះមានពលករខ្មែរជាច្រើននាក់បានវិលត្រឡប់ទៅកម្ពុជាវិញដោយសារពួកគេមិនអាចទ្រាំនៅប្រទេសថៃបន្តទៅទៀតបាន បណ្ដាលមកពីផ្ទុះការរាតត្បាតជំងឺកូវីដ-១៩ ខ្លាំងនៅក្នុងប្រទេសនេះ។

របាយការណ៍អង្គការសង់ត្រាល់ (Central) ឱ្យដឹងថា មានពលករខ្មែរធ្វើការស្របច្បាប់និងមិនស្របច្បាប់ជិត២លាននាក់ធ្វើការនៅប្រទេសថៃ៕

# ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១

## ពលករខ្មែរ លួចឆ្លងដែនចេញពីប្រទេសថៃ តែត្រូវសមត្ថកិច្ចឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃពុធ ៤ សីហា ២០២១ដោយ Sorn Phanith

ពលករខ្មែរចំនួន១០នាក់ ដែលក្នុងនោះមានក្មេងតូចៗផងនោះ ត្រូវបានកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ឃាត់ដើម្បីបញ្ជូនទៅឲ្យភាគីថៃវិញ ខណៈដែលពួកគេបានលបឆ្លងដែនចេញពីទឹកដីថៃ ស្របពេលថៃកំពុងផ្ទុះកូវីដបម្លែងខ្លួនកំពុងវាយលុកខ្លាំង។

កាលពីល្ងាចថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជាថៃ ច្រកទ្វារអន្តរជាតិភ្នំដីគីឡូ១៣ ដឹកនាំដោយ លោក វរសេនីយ៍ត្រី ប៊ុន វឌ្ឍនៈ បានដឹកនាំកម្លាំងចំនួន៥ នាក់ និងបានសហការណ៍ជាមួយវរសេនាតូច៥៣៣ ប៉ូលីសរ:៨១៧ កម្លាំងអធិការស្រុកសំពៅលូន បានចុះអន្តរាគមន៍ ពលករលួចឆ្លងដែនចូលមកកម្ពុជាត្រូវកម្លាំងឈរជើង ចំណុចជំនោជាយដែន ព័ទ្ធចាប់បាននៅចំណុចបូរីជាយដែន ពេលនេះកំពុងស្ថិតក្នុងការគ្រប់គ្រងរបស់កងកម្លាំង ពលករទាំង៧នាក់មានទីលំនៅ ភូមិគីឡូ១៣ ដោយបានទាក់ទងទៅ លោក វរសេនីយ៍ត្រី សូ រ៉ាត់ មេបញ្ជាការកងរយ១៣០៥ ឲ្យមកទទួលពលករខ្មែរទៅទឹកដីថៃវិញ ពលករចំនួន ៧នាក់ ប្រុស ៥នាក់-ស្រី ២នាក់

១.ឈ្មោះ ព្រឹម សូ ភេទប្រុស អាយុ២៦ឆ្នាំ
២,.ឈ្មោះ ឈួន ចាន់ ភេទប្រុស អាយុ ៣០ឆ្នាំ
៣.ឈ្មោះ ផន បុល ភេទប្រុស អាយុ១៥ឆ្នាំ
៤.ឈ្មោះ វ៉ាន់ សូរីយា ភេទប្រុស អាយុ ១៧ឆ្នាំ
៥.ឈ្មោះ វ៉ាន់ ឡេង ភេទស្រី អាយុ៣៤ឆ្នាំ
៦.ឈ្មោះ វ៉ាន់ លីន ភេទស្រី អាយុ៣១ឆ្នាំ
៧.ឈ្មោះ ឈុំ ចាន់ថន ភេទប្រុស អាយុ ៥ឆ្នាំ ។

ដោយឡែកនៅចំណុចភូមិសាស្ត្រ គីឡូ៩ កាលពីវេលាម៉ោង ០៤និង៣០ នាទីល្ងាច ក៏មានពលករបម្រុងលួចឆ្លងដែនមកកម្ពុជា ត្រូវបានកងកម្លាំង ឈរជើង កងវរសេនាតូចលេខ១ ប៉ូលិសវរ ៨១៧ កម្លាំងសឹករងស្រុកសំពៅលូន ហាមឃាត់មិនឲ្យចូលមកកម្ពុជា និងបានទាក់ទងទៅ លោក វរសេនីយ៍ត្រី សូ រ៉ាត់ មេបញ្ជាការកងរយ១៣០៥ ឲ្យមកទទួលពលករខ្មែរទៅទឹកដីថៃវិញដែរ ដោយពលករទាំងនោះមានចំនួន៣ នាក់៖

១. ឈ្មោះ បេន បុល អាយុ២៧ ភេទប្រុស នៅភូមិអូ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង
២. ឈ្មោះ ចាន់ សំអាន់ អាយុ៤០ ភេទប្រុស នៅភូមិចេក ឃុំពង្រលើ ស្រុកជីក្រែង ខេត្តសៀមរាប
៣. ហ៊ិន សុនិន ភេទស្រី អាយុ៣១ នៅភូមិអូ ឃុំសន្តិភាព ស្រុក សំពៅលូន ខេត្តបាត់ដំបង៕

**អត្ថបទ៖ សោ និយមវត្ថ**

## ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ជំរុញដល់កម្លាំងតាមព្រំដែនជួរមុខ ត្រូវយកចិត្តទុកដាក់បង្ក្រាបរាល់បទល្មើស ឆ្លងដែនខុសច្បាប់ ខណៈជម្ងឺកូវីដDeltaរាតត្បាតខ្លាំង

https://cen-news.com/ Posted ByPen Srey NeatAugust 4, 2021

បន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ អមដំណើរដោយលោកឧត្តមសេនីយ៍ត្រី រ៉ែម វីរៈ ស្នងការរង ទទួលផែនការងារសេនាធិការ លោកវរសេនីយ៍ឯក វ៉ាត ចន្ថា នាយការិយាល័យ គណនេយ្យ នៃស្នងការដ្ឋាននគរបាលខេត្ត រួមសហការី បានបន្តចុះសួសុខទុក្ខ និងត្រួតពិនិត្យ

ការរៀបចំសណ្ដាប់ធ្នាប់ កងកម្លាំងការពារព្រំដែនជួរមុខ មានវរៈនគរបាលការពារព្រំដែនគោក លេខ៨០៧ កម្លាំងអធិការដ្ឋាននគរបាលស្រុកថ្មពួក និងកម្លាំងដែលឈរជើង បិទខ្ទប់ក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ព្រំប្រទល់ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១នេះ។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បានថ្លែងជំរុញដល់កងកម្លាំងនគរបាលការពារព្រំដែនជួរមុខ ត្រូវយកចិត្តទុកដាក់ ក្នុងការបង្ក្រាបរាល់បទល្មើស ពិសេសបទល្មើសឆ្លងដែនខុសច្បាប់ ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដDelta។ ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ក៏បានផ្ដាំផ្ញើដល់កងកម្លាំងទាំងអស់ ត្រូវយកចិត្តទុកដាក់ ចំពោះសុខភាពរបស់ខ្លួន ឲ្យបានខ្ពស់ និងអនុវត្តឱ្យបាននូវវិធានការសុខាភិបាល គឺកុំភ្លេច ៣កុំ ៣ការពារ៕ រក្សាសិទ្ធិដោយៈ បញ្ញាស័ក្តិ

## ពលករខ្មែរ ២១៦នាក់ កំពុងជាប់នៅតាមព្រំដែនថៃ ខណៈខេត្តជាប់ព្រំដែនកំពុងបិទខ្ទប់

https://www.kampucheathmey.com/ ថ្ងៃពុធ ៤ សីហា ២០២១ដោយ Sorn Phanith

ពលករខ្មែរសរុបចំនួន២១៦នាក់ ដែលមានបំណងវិលត្រឡប់មកមាតុភូមិវិញ កំពុងជាប់នៅលើតំបន់សដែលភាគីទាំងពីរ (កម្ពុជា-ថៃ) បានសម្រេចឲ្យចូលទៅស្នាក់ជាបណ្ដោះអាសន្ន នៅត្រង់ចំណុច បរិវេណថាប់សន ឬ បរិវេណព្ធៃខ្សែន ដែលស្ថិតនៅក្នុងទឹកដីស្រុកតាប្រាយ៉ា ខេត្តស្រះកែវ។

ទីតាំងដែលថៃសម្រេចឲ្យពលករខ្មែរស្នាក់នៅ គឺស្ថិតនៅប៉ែកខាងកើតនៃច្រកបឹងត្រកួនប្រមាណ ៣៦០ ម៉ែត្រ តែប៉ុណ្ណោះ ប៉ុន្តែដោយសារតែបច្ចុប្បន្នខេត្តមួយចំនួនដែលមានព្រំប្រទល់ជាប់នឹងខ្សែបន្ទាត់ព្រំដែនថៃ ត្រូវបានប្រកាសបិទខ្ទប់។ បច្ចុប្បន្ននៅទីនោះ ភាគីថៃគ្រាន់តែជួយមើលការពារតែប៉ុណ្ណោះចំណែកភាគីកម្ពុជា ជាអ្នកផ្គត់ផ្គង់ចំណីអាហារ សម្ភារៈប្រើប្រាស់ និងដាក់ក្រុមគ្រូពេទ្យឲ្យចុះតាមដាមសុខភាពថែមទៀតរហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ទើបអនុញ្ញាតឲ្យពលករទាំង២១៦នាក់ នេះ ធ្វើដំណើរចូលមកកម្ពុជាវិញបាន៕

## ឃាត់ខ្លួនជនជាតិថៃ ម៉ាឡេស៊ី និងចិន ២២នាក់ ប៉ុនប៉ងឆ្លងដែនចូលកម្ពុជា មកកាស៊ីណូនៅប៉ោយប៉ែត

https://www.kampucheathmey.com/ ថ្ងៃពុធ ៤ សីហា ២០២១ដោយ Sorn Phanith

យ៉ាងហោចណាស់មានជនជាតិថៃ ជនជាតិម៉ាឡេស៊ី ជនជាតិចិន ចំនួន២២នាក់ ត្រូវបានសមត្ថកិច្ចថៃ ធ្វើការឃាត់ខ្លួន ខណៈព្យាយាមលួចឆ្លងដែនខុសច្បាប់ ពីប្រទេសថៃមកកម្ពុជា ។ ការឃាត់ខ្លួននេះ ធ្វើឡើងកាលពីទៀបភ្លឺថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅចំណុចភូមិណងយ៉ាកែវ ឃុំណងសាមិត្ត ស្រុកគោកធ្យូង ខេត្តស្រះកែវ ប្រទេសថៃ ឈមនឹងកម្ពុជា ចំណុចភូមិចក់ពួក ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

យោងតាមប្រភពព័ត៌មានការឃាត់ខ្លួននេះ ធ្វើឡើងក្រោមការដឹកនាំដោយលោកវរសេនីយ៍ទោ ជីណាវ៉ាត់ ឡាំងសាត មេបញ្ជាការកងរយ១២៦ បានដឹកនាំកម្លាំង ៧ន សហការជាមួយកម្លាំងអធិការស្រុកគោកធ្យូង ខណៈចុះល្បាតតាមបន្ទាត់ព្រំដែន បានប្រទះឃើញ និងឃាត់ខ្លួនជនជាតិថៃ ជនជាតិម៉ាឡេស៊ី និងជនជាតិចិន សរុបចំនួន២២នាក់ ក្នុងនោះជនជាតិថៃ ចំនួន១៨នាក់ (មានម្នាក់មេខ្យល់), ជនជាតិម៉ាឡេស៊ី ២នាក់ និងជនជាតិចិន ១នាក់។ ចំពោះមុខសមត្ថកិច្ច អ្នកទាំង២២នាក់ ដែលត្រូវបានឃាត់ខ្លួនខាងលើ បានសារភាពថា ពួកគេលួចឆ្លងដែនមកកម្ពុជានេះ គឺ ដើម្បីទៅធ្វើការនៅកាស៊ីណូអនឡាញ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ក្រោយ

ឃាត់ខ្លួន និងសាកសួរ ជនជាតិថៃ ជនជាតិម៉ាឡេស៊ី ជនជាតិចិន ទាំង២២នាក់ខាងលើ ត្រូវបានសមត្ថកិច្ចថៃ ឃុំខ្លួន ដើម្បីធ្វើការផ្តន្ទាទោសតាមផ្លូវច្បាប់ និងបន្តអនុវត្តតាមវិធានការត្រួតពិនិត្យជំងឺកូវីដ-១៩៕ **អត្ថបទ៖ អពៅ**

## ស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ ចុះជួបសួរសុខទុក្ខពលករខ្មែរ ចំនួន៤៨នាក់ ដែលបានធ្វើដំណើរពីខេត្ត ផ្សេងៗ ក្នុងប្រទេសថៃ និងចង់វិលទៅកម្ពុជាវិញ

https://cen-news.com/ Posted ByPen Srey NeatAugust 4, 2021

ព្រំដែនថៃ-កម្ពុជា ៖ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ ដែលក្រុមការងារស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ នៃព្រះរាជាណាចក្រថៃ បានចុះជួបសួរសុខទុក្ខ បងប្អូនពលករខ្មែរចំនួន៤៨នាក់ ដែលបានធ្វើដំណើរពីខេត្តផ្សេងៗ ក្នុងប្រទេសថៃ និងចង់វិលទៅកម្ពុជាវិញ។

ពួកគាត់ខាងលើបច្ចុប្បន្នកំពុង ជាប់នៅតាមព្រំដែនថៃ-កម្ពុជា ស្ថិតនៅ ស្រុកតាប្រាយ៉ា ខេតសាកែវ ទល់នឹងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តែដោយសារខេត្តបន្ទាយមានជ័យ កំពុងស្ថិតក្រោមការបិទខ្ទប់ ដើម្បីទប់ស្កាត់ការរីករាល ដាលជម្ងឺកូវីដ-១៩។ ក្រុមការងារបាន សហការជាមួយជាអាជ្ញាធរពាក់ព័ន្ធ ទាំងកម្ពុជា-ថៃ នៃស្រុក-ខេត្តខាងលើ ដើម្បីដឹកជញ្ជូន និងរៀបចំកន្លែង ស្នាក់នៅដែលមានសុវត្ថិភាពជូនពួកគាត់ នៅខាងទឹកដីថៃ ចំណុចច្រកព្រំដែនតាប្រាយ៉ា-បឹងត្រកួន។

ក្នុងការចុះសួសុខទុក្ខនេះ មន្ត្រីនៃស្ថានអគ្គកុងស៊ុល ក៏បាននាំយកនូវ ស្បៀងអាហារមួយចំនួន និងមួយចំនួនទៀត ជារបស់សប្បុរសជនខ្មែរ និងថៃ ជូនពួកគាត់មានដូចជា អង្ករ ទឹកត្រី ទឹកស៊ីអីវ ត្រីខកំប៉ុង មីកញ្ចប់ ទឹកសុទ្ធ ទឹកដោះគោ សម្រាប់ទទួលទាន និងរួមជាមួយសំលៀកបំពាក់ ថ្នាំដុសធ្មេញ ច្រាស់ដុសធ្មេញ សម្រាប់ប្រើប្រាស់ និង ម៉ាស់ ទឹកអាកុលលាងដៃ សម្រាប់បង្ការ ការឆ្លងមេរោគកូវីដ-១៩ ព្រមទាំងតង់សម្រាប់ធ្វើជម្រក៕ រក្សាសិទ្ធិដោយ៖ ចេស្តារ

## សមត្ថកិច្ចខេត្តកោះកុង ឃាត់ខ្លួនជនជាតិថៃម្នាក់ លួចចូលមកប្រទេសកម្ពុជា ដោយខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៥ សីហា ២០២១ដោយ sopheak khoun

(កោះកុង)៖ កម្លាំងអធិការដ្ឋាន នគរបាលស្រុកកោះកុង កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១កន្លងទៅនេះ បានឃាត់ខ្លួនជនបរទេស ជាជនជាតិថៃម្នាក់ មានឈ្មោះ កិត្ត ង៉ាមខាំ ភេទប្រុស អាយុ៣០ឆ្នាំ (ជាជនមានសតិមិនប្រក្រតី) មានទីលំនៅខេត្តនខនស្រីធម្មរ៉ាធ ប្រទេសថៃ ដែលបានលួចចូល មកប្រទេសកម្ពុជាដោយខុសច្បាប់។ ក្រោយសាកសួររួច កម្លាំងជំនាញ បានឲ្យដឹងថា ជនសង្ស័យរូបនេះ បានធ្វើដំណើរដោយថ្មើរជើង តាមឆ្នេរសមុទ្រខាងក្រោយប៉ុស្តិ៍ ច្រកទ្វាអន្តរជាតិចាំយាម ពេលយប់នៅពេលទឹកនាច ក្នុងគោលបំណង មករកការងារធ្វើ។ លុះចូលមកដល់ទឹកដីកម្ពុជា បានប្រទះឃើញម៉ូតូ១គ្រឿង របស់ប្រជាពលរដ្ឋ ចតចោលនៅចញ្ចើមផ្លូវ ក៏បានយកកូនសោរក្នុងកាបូបស្ពាយ មកចាក់រហូតម៉ូតូអាចបើកសោរបាន រួចជនសង្ស័យរូបនេះ ក៏បានជិះចេញមក ដោយគ្មានគោលដៅច្បាស់លាស់ រហូតមកដល់ភូមិសាស្ត្រ ស្រុកកោះកុង។

កម្លាំងជំនាញ បានសហការជាមួយគ្រូពេទ្យ ធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ ជាលទ្ធផល(អវិជ្ជមាន)និងធ្វើតេស្តទឹកនោមរកសាជាតុញៀន (អវិជ្ជមាន)។ ទោះជាយ៉ាងណា កម្លាំងជំនាញ នៅតែបារម្ភអំពីមេរោគបម្លែងថ្មី (Delta)។ បច្ចុប្បន្ន កម្លាំងសមត្ថកិច្ច កំពុងរៀបចំសុំណុំរឿង ដើម្បីចាត់វិធានការ លើជនសង្ស័យរូបនេះ តាមនីតិវិធីច្បាប់៕

# អាជ្ញាធរខេត្តជាប់ព្រំដែនថៃ ទប់ស្កាត់មិនឱ្យពលករខ្មែរនៅប្រទេសថៃវិលចូលភូមិស្រុកវិញ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2021-08-04

អាជ្ញាធរព្រំដែនខេត្តបន្ទាយមានជ័យជាប់ព្រំដែនថៃ ទប់ស្កាត់ពលករចំណាកស្រុកខ្មែរ ដែលនៅធ្វើការនៅក្នុងប្រទេសថៃ មិនឲ្យវិលចូលភូមិស្រុករបស់ពួកគេវិញឡើយ។

មន្ត្រីសម្របសម្រួល នៃសមាគមសិទ្ធិមនុស្សអាដហុក ខេត្តបន្ទាយមានជ័យលោក ស៊ុម ចន្ទគា ឲ្យវិទ្យុអាស៊ីសេរីដឹងនៅយប់ថ្ងៃពុធ ទី៤ ខែសីហា ម្សិលមិញថា ពលករទាំងអស់មានគ្នាប្រមាណ ២០០នាក់ បានស្នាក់នៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ដោយខ្លះនៅក្នុងទឹកដីថៃនៅឡើយ ហើយខ្លះទៀត បានជ្រៀតចូលមកខាងទឹកខ្មែរជាប់ព្រំដែន ប៉ុន្តែមិនអាចបន្តដំណើរមកផ្ទះបានឡើយដោយសារអាជ្ញាធរដាក់កម្លាំងរាំងពួកគេ។ លោកបន្តថា ការរាំងនោះ ដោយសារតែអាជ្ញាធរអះអាងថា ពលករភាគច្រើនមានជំងឺកូវីដ១៩ ហើយខេត្តបន្ទាយមានជ័យ និងខេត្តជាប់ព្រំដែនដទៃទៀត កំពុងបិទខ្ទប់មិនឲ្យមានការចេញចូលឡើយ ដើម្បីការពារការរីករាលដាលនៃជំងឺកូវីដ១៩ ក្នុងសហគមន៍។ មន្ត្រីសម្របសម្រួលនៃសមាគមសិទ្ធិមនុស្សអាដហុករូបនេះ ឲ្យដឹងទៀតថា ទោះបីយ៉ាងណា ក្រុមសមត្ថកិច្ចការពារព្រំដែន និងអាជ្ញាធរខេត្តកំពុងមមាញឹក ដឹកស្បៀងអាហារខ្លះៗជូនពលករដែលកំពុងជាប់គាំងនៅតាមព្រំដែននោះ និងនាំគ្នាកាប់កូនឈើ ទៅសង់ជាជម្រកឲ្យពលករស្នាក់នៅបណ្ដោះអាសន្ន៖ «បាទ ឃើញមានបោះតង់ក្បែរព្រំដែន ហើយឃើញមានជួយចំណីអាហារ មានមី អង្ក ត្រីខ អីហ្នឹង ហើយឃើញមានកាត់ស្បូវ កាត់ស្មៅ ដើម អាកាស្យាមកធ្វើជាតង់ហាក់ដូចជាជុំរុំជនភៀសខ្លួនតាមព្រំដែន មានន័យថា លើកទឹកចិត្តពួកគាត់កុំទាន់វិលចូលភូមិស្រុកវិញដោយរង់ចាំមួយរយៈពេលទៀតបន្តិចទៀតសិន»។ លោកបន្តថា ការជួយនេះមិនទាន់ដឹងថា បានគ្រប់គ្រាន់ ឬក៏យ៉ាងណានៅឡើយទេ ដោយអង្គការលោកកំពុងតាមដានលើរឿងនេះ។ ពលករទាំងនោះ ដាច់ចិត្តវិលមកស្រុកវិញ ដោយសារពួកគាត់ឆ្លងជំងឺកូវីដ-១៩ ហើយកន្លែងពួកគេធ្វើការងារនោះ គ្មានកន្លែងស្នាក់នៅ ពុំមានថ្នាំព្យាបាល និងគ្មានអាហារហូបចុកឡើយ ខណៈប្រទេសថៃកំពុងឆ្លងជំងឺកូវីដ-១៩ខ្លាំង។

កាលពីទៀបភ្លឺ ថ្ងៃទី២៩ ខែកក្កដា កម្លាំងនគរបាលការពារព្រំដែន ខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនពលរដ្ឋចំនួន៦នាក់ ដែលបាន ហែលទឹកអូរ ឆ្លងដែន ពីប្រទេសថៃ ចូលមកកម្ពុជា។ អាជ្ញាធរបានបញ្ជូនពលរដ្ឋទាំង៦នាក់នោះ ទៅធ្វើតេស្តរកមេរោគកូវីដ១៩ នៅចំណុចសំចត ក្នុងភូមិនិមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

រដ្ឋាភិបាលបានសម្រេចបិទព្រំដែនកម្ពុជា-ថៃ បណ្ដោះអាសន្ន និងហាមឃាត់អ្នកធ្វើដំណើរចេញ-ចូល រយៈពេល១៤ថ្ងៃ គិតចាប់ពីថ្ងៃទី២៩ ខែកក្កដា រហូតដល់ថ្ងៃទី១២ ខែសីហា ខាងមុខ ប៉ុន្តែបម្រាមនេះលើកលែងការដឹកជញ្ជូនទំនិញ និងករណីពិសេសដែលមានការអនុញ្ញាតពីអាជ្ញាធរ ដូចជាករណីជំងឺសង្គ្រោះបន្ទាន់។ បន្ថែមពីនេះ អាជ្ញាធរកម្ពុជានឹងសម្រួលជាមួយអាជ្ញាធរថៃ ដើម្បីផ្ដល់ការគាំពារដល់ពលករខ្មែរ នៅប្រទេសថៃ ប៉ុន្តែ ពន្យារពេលពលរដ្ឋខ្មែរ ដែលគ្រោងវិលមកកម្ពុជាវិញ រហូតដល់ការបិទខ្ទប់នេះបញ្ចប់៕

# ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១

## អ្នកវិជ្ជមានកូវីដប្រភេទដែលតា(DELTA)ចំនួន២៤នាក់សុទ្ធតែជាពលករមកពីថៃ

https://kohsantepheapdaily.com.kh/ Banteay Meanchey ០៥ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១៤:៤១

ខេត្តបន្ទាយមានជ័យ ៖ អ្នកវិជ្ជមានកូវីដ.១៩ប្រភេទដែលតា(DELTA)មានចំនួន២៤នាក់ ជាពលករត្រឡប់ពីថៃក្នុងចំណោម៤.៣២០នាក់កំពុងសម្រាកព្យាបាលក្នុងខេត្តបន្ទាយមានជ័យ ។

យោងតាមមន្ត្រីសុខាភិបាលខេត្តបន្ទាយមានជ័យបានឱ្យដឹងនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ថា ខេត្តបន្ទាយមានជ័យបានរកឃើញអ្នកវិជ្ជមានកូវីដ.១៩ប្រភេទដែលតា(DELTA)មានចំនួន២៤នាក់ និង៣នាក់ជាកូនពលករត្រឡប់ពីប្រទេសថៃក្នុងចំណោមអ្នកវិជ្ជមានកូវីដ.១៩ដែលកំពុងសម្រាកព្យាបាល៤.៣២០នាក់។ យោងសេចក្តីប្រកាសព័ត៌មានរដ្ឋបាលខេត្តបន្ទាយមានជ័យ បានរកឃើញអ្នកវិជ្ជមានកូវីដ.១៩ចំនួន១៩០នាក់ ហើយមានអ្នកជាសះស្បើយចំនួន២០៨នាក់ ក្នុងនោះពលករដែលត្រឡប់ពីប្រទេសថៃ នៅមណ្ឌលចត្តាឡីស័កនិងយកពីតាមបន្ទាត់ព្រំដែនមានចំនួន៦០នាក់និងឆ្លងក្នុងសហគមន៍មានចំនួន១៤៨នាក់។ ព្រឹត្តិការណ៍២០ កុម្ភៈ ២០២១មានអ្នកឆ្លងកូវីដ.១៩មានចំនួន១២.៤០៩នាក់ ជាសះស្បើយដោយដោយវិជ្ជមានកូវីដ.១៩មានចំនួន៧.៧៧៦នាក់ និងកំពុងសម្រាកព្យាបាលវិជ្ជមានកូវីដ.១៩មានចំនួន៤.៣២០នាក់ ស្លា.ប់ដោយវិជ្ជមានកូវីដ.១៩កើនឡើងមានចំនួន៩៧នាក់៕

## ពលករខ្មែរដែលជាប់នៅដីថៃតាមព្រំដែនចំនួន ៥៤ នាក់ ត្រូវបានបញ្ជូនទៅព្យាបាល បន្ទាប់ពីរកឃើញឆ្លងកូវីដ

https://www.postkhmer.com/ យុត សុភចរិយា | Publication date 05 August 2021 | 17:18 ICT

**បន្ទាយមានជ័យៈ** ហូតមកទល់ពេលនេះមានពលករខ្មែរចំនួន ៥៤ នាក់ ក្នុងចំណោម ២៤៥ នាក់ ដែលបានវិលត្រឡប់ពីថៃមកកម្ពុជាវិញ ហើយជាប់គាំងនៅតាមព្រំដែន ដោយសារបម្រាមបិទខ្ទប់ព្រំដែន ត្រូវបានសមត្ថកិច្ចកម្ពុជាបញ្ជូនទៅមណ្ឌលព្យាបាលជំងឺកូវីដ ក្នុងវិទ្យាល័យសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ បន្ទាប់ពីរកឃើញមានវិជ្ជមានជំងឺកូវីដ ១៩ ក្នុងនោះមានប្រភេទបំប្លែងថ្មី Delta ផង។ នេះបើតាមមន្ត្រីនគរបាលការពារព្រំដែនប្រចាំតំបន់ច្រកបឹងត្រកួន។

លោក វ៉ាន់ ដារ៉ាន់ ប្រធានប៉ុស្តិ៍នគរបាលការពារព្រំដែនច្រកបឹងត្រកួន បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី៥ សីហាថា នៅតាមច្រកព្រំដែនកម្ពុជា-ថៃទាំងអស់ ត្រូវបានបិទខ្ទប់មិនឱ្យឆ្លងកាត់ចាប់តាំងពីយប់ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២១ មក។ ក្នុងរយៈពេលជិត ១ សប្តាហ៍ [២៩ កក្កដា-៤ សីហា ២០២១] នៃការបិទខ្ទប់ព្រំដែន ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ ១៩ នេះ គឺមានពលករខ្មែរចំនួន ២៤៥ នាក់ បាននាំគ្នាវិលត្រឡប់ចូលកម្ពុជាវិញ តាមច្រករបៀងតូចៗជិតច្រកតំបន់បឹងត្រកួន ប៉ុន្តែត្រូវបានជាប់គាំងនៅតាមព្រំដែនក្នុងទឹកដីថៃដោយសារការបិទព្រំដែនកំពុងបន្ត។ លោក ដារ៉ាន់ បានបញ្ជាក់ថា៖«ដោយមានកិច្ចអន្តរាគមន៍ពីអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវនិងពីអាជ្ញាធរខេត្តជាប់ព្រំដែននៃប្រទេសទាំង២ ពួកគេចំនួន ៥៤ នាក់ក្នុងចំណោម ២៤៥ នាក់ ត្រូវបានអនុញ្ញាតឲ្យបញ្ជូនទៅកាន់មណ្ឌលព្យាបាលជំងឺកូវីដ ១៩ ដែលមានទីតាំងក្នុងវិទ្យាល័យសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យបន្ទាប់ពីរកឃើញមានវិជ្ជមានជំងឺកូវីដ ១៩ដោយមានទាំងប្រភេទបំប្លែងថ្មី Delta ផង»។

បើតាមលោក ដារ៉ាន់ ពលករខ្មែរដែលបាត់បង់ការងារនៅប្រទេសថៃដោយសារវិបត្តិជំងឺកូវីដ ១៩ នៅតែបន្តសម្រុកវិលត្រឡប់មកកម្ពុជាតាមច្ររបៀងជិតច្រកព្រំដែនតំបន់បឹងត្រកួនជារៀងរាល់ថ្ងៃ។ អ្នកខ្លះត្រូវបានគេដឹកមកទម្លាក់ក្នុងតំបន់ព្រៃចម្ការមីនជាប់ព្រំដែនក៏មាន។ យ៉ាងណាក្តីពួកគេត្រូវបានអាជ្ញាធរខេត្តសាកែវប្រទេសថៃជួយនាំយកទៅទីតាំងប្រមូលផ្តុំ១កន្លែងក្នុងទឹកដីថៃទល់មុខច្រកតំបន់បឹងត្រកួនរបស់កម្ពុជា ប៉ុន្តែការផ្គត់ផ្គង់ស្បៀងអាហារនិងសម្ភារប្រើប្រាស់ដូចជា ជំបូលតង់ កន្ទេលភួយមុង រួមទាំងថ្នាំព្យាបាលជំងឺទូទៅនិងសាប៊ូនិងអាល់កុលសម្រាប់លាងដៃជើងដើម្បីបង្ការការឆ្លងជំងឺកូវីដ ១៩ គឺជាបន្ទុករបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ។ លោកបានបន្ថែមថា៖ «រដ្ឋបាលខេត្តបន្ទាយមានជ័យ តាមរយៈគណៈកម្មការបង្ការទប់ស្កាត់ជំងឺកូវីដ ១៩ ស្រុកថ្មពួក បានផ្តល់អាហារ៣ពេល ក្នុង ១ ថ្ងៃ ដល់ពលករខ្មែរដែលកំពុងជាប់គាំងក្នុងទឹកដីថៃមុខច្រកតំបន់បឹងត្រកួនព្រមទាំងបានសហការជាមួយភាគីថៃចុះត្រួតពិនិត្យសុខភាពរបស់ពួកគេជារៀងរាល់ថ្ងៃផងដែរ។ ក្នុងស្ថានភាពសង្ស័យមានការ

ឆ្លងជំងឺកូវីដ ១៩ យើងប្រមូលសំណាកធ្វើតេស្តរកជំងឺកូវីដ ១៩ ភ្លាមៗ ហើយបញ្ជូនមកព្យាបាលនៅមណ្ឌលបាលជំងឺកូវីដ ក្នុងខេត្តបន្ទាយមានជ័យរបស់យើងភ្លាមផងដែរ ក្នុងករណីរកឃើញមានអ្នកវិជ្ជមាន»។ លោកជាវ៉ាន់ បានប្រាប់ឲ្យដឹងទៀតថា ពលករខ្មែរដែលកំពុងជាប់គាំងក្នុងទឹកដៃថៃទាំងនោះ នឹងត្រូវបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កទាំងអស់ ក្រោយឱសានវាទនៃការបិទខ្ទប់ព្រំដែនកម្ពុជា-ថៃ ត្រូវបានបញ្ចប់ ។

កាលពីថ្ងៃទី ៣ ខែសីហា ក្រុមការងារស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវរបស់ថៃ បានចុះសួរសុខទុក្ខ និងផ្តល់អំណោយដល់បងប្អូនពលករខ្មែរដែលកំពុងជាប់គាំងនៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តស្រុកតាប្រយ៉ា ខេត្តសាកែវ ឈមនឹងស្រុកថ្មពួកខេត្តបន្ទាយមានជ័យ។រីឯនៅថ្ងៃទី ៥ សីហា ក្រុមការងារដដែលនេះក៏បាននាំស្បៀងអាហារចែកជូនបន្ថែមផងដែរ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ប្រាប់អ្នកសារព័ត៌មានតាម Telegram កាលពីថ្ងៃទី ៤ ខែសីហា ថា៖«ក្រៅពីផ្តល់ជំនួយសង្គ្រោះបឋម...ក្រុមការងារក៏បានសហការជាមួយជាអាជ្ញាធរពាក់ព័ន្ធទាំងកម្ពុជា-ថៃ នៃស្រុក-ខេត្តខាងលើ ដើម្បីដឹកជញ្ជូន និងរៀបចំកន្លែងស្នាក់នៅដែលមានសុវត្ថិភាពជូនពួកគាត់នៅខាងទឹកដីថៃ នៅចំណុចច្រកព្រំដែនតាប្រាយ៉ា-បឹងត្រកួន ផងដែរ»៕

## អាជ្ញាធរឃាត់ទុកពលករខ្មែរជាច្រើននាក់តាមព្រំដែនថៃជាបណ្តោះអាសន្ន មិនទាន់ឱ្យចូលមកកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៥ សីហា ២០២១ដោយ deth leng

ពលករខ្មែរជាច្រើនដែលចង់វិលត្រឡប់មកកម្ពុជាត្រូវបានអាជ្ញាធរនៅតាមខ្សែបន្ទាត់ព្រំដែនខេត្តបន្ទាយមានជ័យធ្វើការឃាត់ទុកជាបណ្តោះអាសន្ននៅទឹកដីថៃ ដោយមិនទាន់អនុញ្ញាតឱ្យចូលមកកម្ពុជាវិញនោះទេ។ ចំណែកអាជ្ញាធរខេត្តបន្ទាយមានជ័យ ក៏បានធ្វើសេចក្តីជូនដំណឹងទៅភាគីថៃឱ្យជួយសម្របសម្រួលបងប្អូនពលករខ្មែរដែលមានបំណងចង់វិលចូលប្រទេសកម្ពុជា ត្រូវផ្អាកចូលមកកម្ពុជារយៈពេល២សប្តាហ៍សិន ដែលជាវិធានការណ៍ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ បំប្លែងថ្មី Delta ចូលក្នុងសហគមន៍។

តាមរយៈផេកហ្វេប៊ុករបស់អគ្គស្នងការនគរបាលជាតិបង្ហោះនៅថ្ងៃទី០៥ សីហានេះ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានធ្វើការអំពាវនាវយ៉ាងទទូចដល់បងប្អូនពលករនៅប្រទេសថៃ ដែលមានបំណងចង់វិលត្រលប់មកកម្ពុជា សូមផ្អាកមួយរយៈសិន ដើម្បីជាការចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលកូវីដ-១៩ បម្លែងថ្មី Delta ដែលកំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងនោះខេត្តបន្ទាយមានជ័យ ក៏មានករណីរកឃើញវីរុសបម្លែងថ្មីប្រភេទ Delta នេះផងដែរ។

លោក ស្វាយ ជា អភិបាលស្តីទីស្រុកម៉ាឡៃ បានបញ្ជាក់ឱ្យដឹងដែរថា សម្រាប់នៅក្នុងស្រុកមានគោល៨កន្លែងដែលកងកម្លាំងឈរជើងយាមកាមតាមបន្ទាត់ព្រំដែន២៤ម៉ោង លើ ២៤ម៉ោង និងមានការចុះល្បាតតាមគោលដៅសំខាន់ៗជាប់ជាប្រចាំ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនចូលមកកម្ពុជាក្នុងដំណាកាល នៃការបិទខ្ទប់ខេត្តជាប់ព្រំដែន ពិសេសស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដែលមានព្រំទល់ជាប់នឹងប្រទេសថៃ។ លោកអភិបាលស្រុកស្តីទី បានឲ្យទៀតថាជាក់ស្តែងនៅថ្ងៃទី៤ ខែសីហា នេះមានបងប្អូនពលករចូលដល់ព្រំដែនប្រមាណ៨០នាក់ តែអាជ្ញាធរមិនទាន់ អនុញ្ញាតឱ្យចូលមកកម្ពុជាយើងឡើយ។ លោកបានបន្តថា«ក្រុមការងារចំរុះដែលប្រចាំការនៅទីនោះ បានផ្តល់ជា តង់ដេក អង្ករ រួមនឹងគ្រឿងឧបភោគបរិភោគ ជូនដល់ពួកគាត់សម្រាប់ដោះស្រាយមួយរយៈទម្រាំយើងទទួលបានបទបញ្ជារឲ្យបើកព្រំដែនវិញ»។

ប្រមុខរាជរដ្ឋាភិបាល បានសម្រេចដាក់ចេញវិធានការបិទខ្ទប់បណ្ដារខេត្តជាប់ព្រំដែន ពិសេសព្រំដែននៃព្រះរាជាណាចក្រថៃឡូងដ៍រយៈពេល១៤ថ្ងៃចាប់ពីថ្ងៃទី៣០ ខែកក្កដារហូតដល់ថ្ងៃទី១២ខែសីហាឆ្នាំ២០២១ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ បម្លែងខ្លួនថ្មីDelta ដែលកំពុងមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដែលភាគច្រើនឆ្លងទៅលើបងប្អូនពលករដែលធ្វើដំណើរមកពីប្រទេសថៃ។ គិតដល់ថ្ងៃទី៣ ខែសីហា កម្ពុជាបានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩បំប្លែងថ្មីដែលតា ចំនួន២៦០នាក់ ស្រី១២៥នាក់ ដែលជាពលករមកពីប្រទេសថៃ បុគ្គលិកសុខាភិបាល អ្នកធ្វើដំណើរតាមយន្តហោះនិងប្រជាពលរដ្ឋក្នុងសហគមន៍៕ ដោយៈ សំអឿន

## មន្រ្តីទូតខ្មែរ ចែកអំណោយដល់ពលករ ២៤៥នាក់នៅប្រទេសថៃ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានអគ្គកុងស៊ុលកម្ពុជានៅថៃ ចែកអំណោយដល់ពលករខ្មែរ ២៤៥នាក់ កំពុងរស់នៅតាមបណ្តាលខេត្ត និង ទីក្រុងបាងកក។ នៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃបានចុះសួរសុខទុក្ខ និងនាំ យកនូវស្បៀងអាហារមួយចំនួន មានដូចជា មីកញ្ចប់ ពងមាន់ ទឹកដោះគោ សាប៊ូបោកខោអាវ សំលៀកបំពាក់ និងប៉ាតង់ និងបាយចំនួន២៥០ប្រអប់ ផ្តល់ជូនដល់បងប្អូនពលករខ្មែរចំនួន២៤៥នាក់ដែលធ្វើដំណើរមកពីបណ្តាលខេត្តនិងទីក្រុងបាងកក ប្រទេសថៃ មានបំណងវិលត្រឡប់ទៅកម្ពុជាវិញ៕

## ពលករខ្មែរ៧នាក់បានព្យាយាមឆ្លងដែនពីថៃចូលមកក្នុងទឹកដីខ្មែរវិញ ត្រូវបានសមត្ថកិច្ចចម្រុះកម្ពុជាទប់ស្កាត់

https://khmeread.com/ August 04, 2021 12:32PM

បាត់ដំបង ៖ ពលករជនជាតិខ្មែរ៧នាក់បានព្យាយាមឆ្លងដែនពីថៃចូលមកក្នុងទឹកដីខ្មែរវិញ ត្រូវបានសមត្ថកិច្ចចម្រុះកម្ពុជាទប់ស្កាត់ ហើយប្រាប់ពួកគាត់ឱ្យវិលត្រឡប់ទៅទីតាំងដើមវិញកាលពីថ្ងៃអង្គារទី០៣ ខែសីហា ឆ្នាំ២០២១ នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ក្នុងគោលបំណងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta)។

សមត្ថកិច្ចនិយាយថា លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចប៉ូលិសការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍កូនភ្នំនៅគោលដៅទី៤ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ-ពាត់ ជានាយប៉ុស្តិ៍រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ចំណុះវរសេនាតូចប៉ូលិសការពារព្រំដែនគោកលេខ ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង-រ៉ើន ជានាយផ្នែកសហការជាមួយកម្លាំងយោធាកងអនុសេនាធំគាំទ្រវរៈ៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភួង-វ៉ៃ ជាមេបញ្ជាការរងគ និងកម្លាំងកងយោធាកងអនុសានាធំទី១, វរសេនាតូចលេខ១ ដឹកនាំដោយលោក អនុសេនីយ៍ត្រី ឡៃ-លឿន ជាមេបញ្ជាការខ បានទប់ស្កាត់ប្រជាពលរដ្ឋដែលបម្រុងឆ្លងដែនចូលក្នុងប្រទេសវិញ។ សមត្ថកិច្ចបន្តថា ខណៈកំពុងល្បាតក៏ជួបពលរដ្ឋខ្មែរ៧នាក់ (ស្រី២នាក់ និងក្មេងប្រុសម្នាក់) ត្រង់ចំណុចនិយាមការ TV0214269-1486218 ក្នុងភូមិសាស្រ្ត ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ សមត្ថកិច្ចបន្តទៀតថា ពេលនោះកម្លាំងសមត្ថកិច្ចបានអនុវត្តតាមវិធានការបិទខ្ទប់របស់រាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) ហើយប្រាប់ពួកគាត់វិលត្រឡប់ទៅកន្លែងដើមរបស់ពួកគាត់ក្នុងទឹកដីថៃវិញ៕

## អាជ្ញាធរខេត្តច័ន្ទបុរី ត្រៀមទីតាំង៣កន្លែងសម្រាប់ពលករខ្មែរស្នាក់នៅ ខណៈព្រំដែនកម្ពុជាត្រូវបានបិទខ្ទប់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៦ សីហា ២០២១ដោយ Sokhom Khon

លោក សុធី ថងយ៉ែម អភិបាលខេត្តច័ន្ទបុរី បានអញ្ជើញចុះពិនិត្យផ្ទាល់ កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ ទៅលើទីតាំងក្បែរខ្សែបន្ទាត់ព្រំដែនថៃ-កម្ពុជា ដើម្បីរកកន្លែងសម្រាប់ឲ្យពលករខ្មែរដែលបម្រុងឆ្លងដែនចូលមកកម្ពុជាស្នាក់នៅជាបណ្ដោះអាសន្ន។ បច្ចុប្បន្នគឺមានទីតាំង២កន្លែងហើយដែលបាននឹងកំពុងដាក់ឲ្យពលករខ្មែរស្នាក់នៅជាង១០០នាក់ ដោយទីតាំងទី១ ក្បែរកងរយលេខ១១៤ ក្នុងភូមិបានតារឿង ឃុំប៉ាដុង ស្រុកសយដាវ និងទីតាំងទី២គឺ ក្បែរកងរយលេខ១១៥ ក្នុងភូមិបានពោងកៅ ឃុំពោងណាំរ៉ន ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី ។ ថ្មីៗនេះអាជ្ញាធរខេត្តច័ន្ទបុរី បានកំណត់យកទីតាំង១កន្លែងទៀត ដែលជាទីតាំងទី៣ សម្រាប់ដាក់ពលករបន្ថែមក្នុងខេត្តច័ន្ទបុរី គឺទីលានចំណតរថយន្តរបស់ក្រុមហ៊ុន ផៃរិនគ្រុប ដែលស្ថិតនៅក្បែរច្រកអន្តរជាតិបានផាកាត ព្រោះទីនោះអាចដាក់គ្រែបានប្រមាណជាង៥០គ្រែ។

នៅក្នុងដំណាក់កាលនៃការបិទខ្ទប់ព្រំដែននៃខេត្តដែលជាប់នឹងប្រទេសថៃ ចាប់ពីយប់ថ្ងៃទី២៩ ដល់ថ្ងៃទី១២ ខែសីហានេះ អាជ្ញាធរខេត្តច័ន្ទបុរី បានចាត់អោយមានអាហារ៣ពេល និងមានក្រុមគ្រូពេទ្យនៅពិនិត្យ តាមដានសុខភាពរបស់ពលករខ្មែរទាំងអស់នោះផង រហូតដល់ថ្ងៃដែលអាចវិលចូលទៅកាន់មាតុភូមិរបស់ខ្លួនវិញបាន៕ អត្ថបទ ៖ សោ និយមរ័ត្ន

## អាជ្ញាធរខេត្តបន្ទាយមានជ័យ រឹតបន្តឹងតាមបន្ទាត់ព្រំដែនខណៈ ពលករខ្មែរចង់វិលត្រលប់មកកម្ពុជា ត្រូវបានអាជ្ញាធរតាមបន្ទាត់ព្រំដែន ឃាត់ទុកបណ្ដោះអាសន្នមិនទាន់ឲ្យវិលចូលកម្ពុជា

http://cambodiapolice.com/policekh/ 11:06 am 5 សីហា 2021

ខេត្តបន្ទាយមានជ័យ ៖ ក្រោយពីប្រមុខរាជរដ្ឋាភិបាល បានសម្រេចដាក់ចេញវិធានការបិទខ្ទប់បណ្ដារខេត្តជាប់ព្រំដែន ពិសេសព្រំដែននៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីជាវិធានការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ បម្លែងខ្លួនថ្មីDelta ដែលកំពុងមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជា ជាមួយការបិទខ្ទប់តាមបន្ទាត់ព្រំដែនរយៈពេល២សប្ដាហ៍ ពិសេសបងប្អូនពលករដែលធ្វើការនៅប្រទេសថៃ ។ អាជ្ញាធរខេត្តបន្ទាយមានជ័យ ក៏បានធ្វើសេចក្ដីជូនដំណឹងមួយជូនទៅភាគីថៃ ក្នុងការជួយសម្របសម្រួលបងប្អូនពលករកម្ពុជាដែលមានបំណងចង់វិលចូលប្រទេសកម្ពុជា ត្រូវផ្អាកចូលមកកម្ពុជារយៈពេល២សប្ដាហ៍សិន ដែលជាវិធានការណ៍ទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ បម្លែងថ្មី Delta ចូលក្នុងសហគមន៍ ។

ដោយឡែកចំពោះសភាពការណ៍នៅតាមព្រំដែនឯណោះវិញ តាមការបញ្ជាក់ពីលោក អែម សុខា អភិបាលស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បានប្រាប់នៅព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២១ម្សិលមិញនេះថា៖ បងប្អូនពលករនៅតែបន្តចូលមកកម្ពុជា ក្នុងដំណាក់កាលនៃការបិទខ្ទប់ ក្នុងនោះអាជ្ញាធរក៏បានធ្វើការសម្របសម្រួលឲ្យពួកគាត់សម្រាកនៅព្រំដែនដែលក្រុមការងារចំរុះបានរៀបចំកន្លែងស្នាក់នៅក្នុងតំបន់"ស"ខាងកម្ពុជាជាបណ្ដោះអាសន្នសិន ។ លោក អភិបាលស្រុក ក៏បានបញ្ជាក់បន្ថែមថា ៖ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១កន្លងទៅ អគ្គកុងស៊ុល បានចាត់លោក ណុប រដ្ឋា ជាកុងស៊ុល និងជាតំណាងលោកអគ្គកុងស៊ុល ដឹកនាំមន្ត្រីនៃស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ ចុះជួបសួរសុខទុក្ខបងប្អូនពលករខ្មែរ ចំនួន២១៦ នាក់ ដែលបានធ្វើដំណើរពីខេត្តផ្សេងៗ ក្នុងប្រទេសថៃ មានបំណងចង់វិលត្រឡប់ទៅកម្ពុជាវិញ។ បច្ចុប្បន្នពួកគាត់កំពុងជាប់នៅតាមព្រំដែនកម្ពុជា-ថៃ ស្ថិតនៅស្រុកតាប្រាយ៉ា ខេត្តសាកែវ ទល់នឹងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ តែ

ដោយសារខេត្តបន្ទាយមានជ័យ កំពុងស្ថិតក្រោមការបិទខ្ទប់ ដើម្បីទប់ស្កាត់ការរីករាលដាលជម្ងឺកូវីត-១៩ ស្ថានអគ្គកុងស៊ុលបាន សហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងកម្ពុជា-ថៃ ដើម្បីដឹកពួកគាត់ទៅកន្លែងដែលមានសុវត្ថិភាពនិងជួយរៀបចំកន្លែងស្នាក់នៅបណ្តោះអាសន្ន ។

មួយវិញទៀត បើតាមការបញ្ជាក់ឲ្យដឹងពីលោក ស្វាយ ជា អភិបាល ស្តីទីស្រុកម៉ាឡៃ បានបញ្ជាក់ឲ្យដឹងដែរថា ៖ សម្រាប់នៅក្នុងស្រុកមានគោល៨កន្លែងដែលកងកម្លាំងឈរជើងយាមកាមតាមបន្ទាត់ព្រំដែន២៤ម៉ោងលើ២៤ម៉ោង និងមានការចុះល្បាតតាមគោលដៅសំខាន់ៗជាប់ជាប្រចាំ ទប់ស្កាត់ការលួចឆ្លងដែនចូលមកកម្ពុជាក្នុងដំណាកាលនៃការបិទខ្ទប់ខេត្តជាប់ព្រំដែន ពិសេសស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដែលមានព្រំទល់ជាប់នឹងប្រទេសថៃ។ លោកអភិបាលស្រុក ស្តីទី ក៏មានឲ្យដឹងដែរថា ៖នៅថ្ងៃទី៤ ខែសីហា នេះមានបងប្អូនពលករចូលដល់ព្រំដែនប្រមាណ៨០នាក់ តែអាជ្ញាធរមិនទាន់ អនុញ្ញាតិឲ្យចូលមកកម្ពុជាយើងឡើយ។ ក្នុងនោះក្រុមការងារចំរុះដែលប្រចាំការនៅទីនោះ បានផ្តល់ជា តង់ដេក អង្ករ រួមនឹងគ្រឿងឧបភោគបរិភោគ ជូនដល់ពួកគាត់សម្រាប់ដោះស្រាយមួយរយៈ ទម្រាំយើងទទួលបានបទបញ្ជារឲ្យបើកព្រំដែនវិញ។ លោក ស្វាយ ជា ក៏បានបន្ថែមទៀតថា ៖ ក្នុងដំណាក់នៃការបិទខ្ទប់នេះដែរ ក៏មានការចូលរួមយ៉ាងផុសផុលពីសប្បុរសជនក្នុងការចូលរួមឧបត្ថម្ភជាសម្ភារៈ និងគ្រឿងឧបភោគបរិភោគ សម្រាប់ចែកជូនបងប្អូនពលករ ហើយខាងភាគីថៃក៏មានកិច្ចសហការយ៉ាងល្អជាមួយភាគីកម្ពុជាយើងផងដែរ។

ទន្ទឹមនោះឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្ត បន្ទាយមានជ័យ ក៏បានធ្វើការអំពាវនាវយ៉ាងទទូចដល់បងប្អូនពលករ នៅប្រទេសថៃ ដែលមានបំណងចង់វិលត្រលប់មកកម្ពុជា សូមផ្អាកមួយរយៈសិន ដើម្បីជាការចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលកូវីដ-១៩ បម្លែងថ្មី Delta ដែលកំពុងមានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងនោះខេត្តបន្ទាយមានជ័យ ក៏មានករណីរកឃើញវីរុសបម្លែងថ្មីប្រភេទ Delta នេះផងដែរ។ឯកឧត្តម អភិបាលខេត្ត ក៏បានអំពាវនាវបន្ថែមដល់ពលរដ្ឋត្រូវបន្តអនុវិធានការណ៍របស់សុខាភិបាលឲ្យបានល្អ ពិសេសបន្តអនុវត្តវិធានការ "៣ការពារ ៣កុំ " ឲ្យបានខ្ជាប់ខ្ជួន ទាំងអស់គ្នា ៕

## ពលករខ្មែរកំពុងស្នាក់នៅក្បែរបន្ទាត់ព្រំដែនអូរស្មាច់រង់ចាំថ្ងៃចូលស្រុកកំណើតវិញ

https://kohsantepheapdaily.com.kh/ Oddar Meanchey 06 ខែ សីហា ឆ្នាំ ២០២១ ម៉ោង 0៩:៤១

ខេត្តឧត្តរមានជ័យ ៖ ក្រោយពីរាជរដ្ឋាភិបាលបិទខ្ទប់តាមបណ្តាច្រកទ្វារអន្តរជាតិនិងច្រកតំបន់នានា ដែលមានរយៈពេល១៤ថ្ងៃជាបណ្តោះអាសន្ន ក៏មានពលករប្រុស-ស្រីប្រមាណ៣០នាក់បានមកដល់ព្រំដែនច្រកទ្វារអន្តរជាតិអូរស្មាច់ កាលពីរសៀលថ្ងៃទី៥ សីហា នេះ ត្រង់ចំណុចភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

លោក សមុទ្រ សុខនី គ្រូពេទ្យចត្តាឡីស័កប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់បានឱ្យដឹងថា ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ គឺមានចំនួន៣០នាក់ មកដល់ព្រំដែន។ ហើយបច្ចុប្បន្ន បានឱ្យពួកគេស្នាក់នៅនិងព្រំដែនដោយមានការរៀបចំពីក្រុមអាជ្ញាធរថៃ ដែលជាកន្លែងស្នាក់នៅនិងទទួលនូវគ្រឿងឧបភោគបរិភោគផងដែរ។ ហើយបើពួកគេត្រូវរង់ចាំ បើអាជ្ញាធរយើងបើកពេលណានោះនឹងឱ្យពួកគាត់ចូលមកស្រុកកំណើតវិញហើយ ។ សូមបញ្ជាក់ថា ក្រុមអាជ្ញាធរថៃបានទទួលនូវទីតាំងកងទ័ពផ្ទះមានចំនួន៣ ទៅ៤ផ្ទះ ដោយយកបន្លាលួស និងស្បែពណ៌ខៀវហ៊ុមព័ទ្ធជុំវិញនិង ការពារមិនឱ្យដើរហើរផ្តេសផ្តាសនោះទេ ។

# ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១
## សម្តេចតេជោ ហ៊ុន សែន ឲ្យបន្ថែមរថយន្តប្រមាណជា២០០គ្រឿង ដើម្បីដឹកពលករខ្មែរមកពីថៃ

https://cen-news.com/ Posted ByPen Srey NeatAugust 6, 2021

ភ្នំពេញ ៖ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ ពាក់ព័ន្ធការធ្វើចត្តាឡីស័ក របស់បងប្អូនពលករខ្មែរ ត្រឡប់មកពីប្រទេសថៃ នៅរសៀលថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ នេះ។ តាមសារពិសេសរបស់សម្តេចតេជោ ហ៊ុន សែន បានឲ្យដឹងថា កន្លងទៅនេះយើងបានធ្វើការបិទខ្ទប់បណ្តាខេត្តនៅតាមព្រំដែន កម្ពុជា ថៃ ក្នុងគោលបំណង ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃកូវីដ១៩ ប្រភេទដែលតា បូកបន្ថែមទៅ ដោយការជន់ជោរទៅដោយអ្នកធ្វើចត្តាឡីស័កនៅតាមព្រំដែនកម្ពុជា ថៃ ។ ឥឡូវបានសង្កេតឃើញអំពីវត្តមាននៃបងប្អូន ជនរួមជាតិរបស់យើងដែល វិលត្រឡប់មកពីប្រទេថៃ ដើម្បីស្វែងរកការព្យាបាលនៅក្នុងប្រទេសរបស់ខ្លួនវិញ យើងក៏បានខិតខំសម្រួលឲ្យបងប្អូនដែលមានជំងឺបានឆ្លងកាត់ព្រំដែន មកទទួលសេវាព្យាបាលនៅខាងទឹកដីកម្ពុជា បូកបន្ថែមទៅដោយការបញ្ជូន ស្មៀងទៅកាន់ទឹកដីថៃ ដើម្បីជួយផ្គត់ផ្គង់បងប្អូននៅទីនោះ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "យើងមិនបានបំណងអូសបន្លាយពេល ដើម្បីពន្យារនូវការបិទខ្ទប់នោះទេ ហើយថែមលើសពីនោះទៅទៀត យើងមានបំណងបើកទល់ដែនឡើងវិញឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ដើម្បីបម្រើឲ្យកិច្ចការងារនេះ មានកិច្ចការងារមួយចំនួនដែលចាំបាច់អភិបាលរាជធានី ខេត្ត នៅខាងក្នុងត្រូវធ្វើ៖

ទី១.អភិបាលរាជធានី ខេត្ត ដែលនៅខាងក្នុងដែលមានពលករត្រឡប់មកវិញ ត្រូវតែរៀបចំឲ្យបានច្បាស់លាស់ដោយខិតខំបញ្ជូន អ្នកដែលកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលដែលបានរៀបចំ ហើយដែលមានស្ថានភាពធូរស្រាល ឲ្យទៅធ្វើចត្តាឡីស័កនៅតាមផ្ទះរបស់ខ្លួនវិញ។ ការធ្វើនេះ គឺក្នុងគោល ដៅដើម្បីត្រៀមរៀបចំនូវទីកន្លែងសម្រាប់បងប្អូនដែលវិលត្រឡប់មកពីប្រទេសថៃ ឬមណ្ឌលចត្តាឡីស័កនៅតាមព្រំដែនកម្ពុជា ថៃ ដើម្បីធ្វើចត្តាឡីស័កជំនួស។ ដូច្នេះសូមឯកឧត្តម លោកជំទាវ អភិបាលខេត្ត រាជធានី សូមរៀបចំបន្ថែមនៅទីកន្លែងដែលត្រូវធ្វើចត្តាឡីស័កសម្រាប់ទទួលបងប្អូនដែលវិលត្រឡប់មកពីព្រំដែនកម្ពុជា ថៃ នឹងក៏ដូចជាដើម្បីទទួលយកបងប្អូនដែលវិលត្រឡប់មកពីព្រំដែនកម្ពុជា ថៃ ចូលទៅក្នុងមណ្ឌលចត្តាឡីស័ក នៅតាមទៅកន្លែងដែលបានរៀបចំ អីចឹងម្ខាងត្រូវរៀបចំទីកន្លែងថ្មី និងម្ខាងទៀតគឺត្រូវរៀបចំផ្ទេរអ្នក ដែលកំពុងធ្វើចត្តាឡីស័កទៅធ្វើចត្តាឡីស័កនៅតាមផ្ទះរបស់ខ្លួនវិញ ដើម្បីត្រៀមបម្រុងទុកទីកន្លែងនេះសម្រាប់ទទួលបងប្អូនមកពីប្រទេសថៃ។

ទី២.គឺសូមឲ្យអង្គភាពដឹកជញ្ជូន របស់កងយោធពលខេមរភូមិន្ទ ហើយត្រូវបញ្ជូនរថយន្តបន្ថែមទៅពីខាងក្រោយ ដែលបានត្រៀមរៀបចំប្រមាណជា ២០០គ្រឿង បងប្អូនដែលបានធ្វើចត្តាឡីស័ក នៅតាមមណ្ឌលតាមព្រំដែនកម្ពុជា ថៃ ចំនួន៧ថ្ងៃរួចមកហើយនោះ ត្រូវដឹកជញ្ជូនបងប្អូនទាំងនេះ ចូលមកកាន់ខេត្តខាងក្រោយ ប្រគល់ឲ្យខេត្ត និងរាជធានីនៅខាងក្រោយ ដើម្បីបន្តធ្វើចត្តាឡីស័កនៅខាងក្នុង។ ធ្វើបែបនេះ ដើម្បីឲ្យបងប្អូនដែលមានមណ្ឌលចត្តាឡីស័កនៅតាមព្រំដែនកម្ពុជា ថៃ មានទីកន្លែងសម្រាប់ឲ្យបងប្អូនដែលវិលមក កំពុងស្នាក់នៅត្រើយម្ខាងព្រំដែន ចូលមកធ្វើចត្តាឡីស័កជំនួសកន្លែងនោះ។ ក្រៅពីការរៀបចំបែបនេះ វិធីនេះគឺជាវិធីដែលត្រូវតែឲ្យកងកំម្លាំង ពិសេសផ្នែកកងទ័ពដែលទទួលបន្ទុកដឹកជញ្ជូន បង្កើនរថយន្តហើយរៀបចំការដឹកជញ្ជូនបងប្អូន ដែលធ្វើចត្តាឡីស័កបាន៧ថ្ងៃរួចមកហើយ ត្រូវបញ្ជូនរថយន្តដឹកបងប្អូនទាំងនេះមកកាន់ខេត្ត រាជធានី នៅខាងក្រោយ"៕ រក្សាសិទ្ធិដោយ៖ ចេស្តារ

# ការរកឃើញ ក្នុងចំនួនកាន់តែច្រើនឡើង នៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ប្រភេទដែលតា លើពលករខ្មែរដែល វិលត្រឡប់មកពី ប្រទេសថៃ តាមព្រំដែនគោក ព្រមទាំងការឆ្លាយចូលក្នុងសហគមន៍

https://cen-news.com/ Posted ByPen Srey NeatAugust 6, 2021

ភ្នំពេញ ៖ រាជរដ្ឋាភិបាល នៅល្ងាចថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១នេះ បានចេញសារាចរ ស្តីពីការរៀបចំមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅតាមបណ្តារាជធានី-ខេត្ត ដើម្បីទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃតាមព្រំដែនគោក។ បើតាមសារាចរមានខ្លឹមសារថា កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លង រាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន។ បន្ថែមលើវិធានការបង្ការ, ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះ និងជាខ្សែក្រវាត់ការពារ សំខាន់ជាងគេ ដើម្បីបង្កើតឱ្យមានភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះ តាមគន្លងប្រក្រតីភាពថ្មី។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បាន និងកំពុងយកចិត្ត ទុកដាក់ខ្ពស់ក្នុងការផ្តល់ការថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ ទាំងអស់ដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ និងមណ្ឌលព្យាបាលរបស់រដ្ឋទាំងអស់។

ផ្អែកតាមស្ថានភាពវិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងរយៈពេលចុងក្រោយនេះ, ការរកឃើញ ក្នុងចំនួនកាន់តែច្រើនឡើង នៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) លើពលករខ្មែរដែល វិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក ព្រមទាំងការឆ្លាយចូលក្នុងសហគមន៍ក្នុងពេលថ្មីៗនេះនូវមេរោគ ប្រភេទថ្មីនេះនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ ព្រមទាំងខេត្តសៀមរាប, ខេត្តកំពង់ធំ និងរាជធានីភ្នំពេញ គឺ ជាកង្វល់ដ៏ធំ និងជាការគំរាមកំហែងជាប់ជាប្រចាំ ដល់ព្រះរាជាណាចក្រកម្ពុជា ដោយសារមេរោគប្រភេទថ្មីនេះ មានកម្រិតនៃការឆ្លងរាលដាលលឿន និងកម្រិតគ្រោះថ្នាក់ធ្ងន់ធ្ងរជាងមុន។ ចំពោះមុខស្ថានភាពដែលកំពុងវិវត្តយ៉ាងលឿនគួរឱ្យបារម្ភនេះ និងក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ពុំទាន់សម្រេចបានដោយជោគជ័យ ក្នុងការបង្កើតឱ្យមានពេញលេញនូវ "ភាពស៊ាំក្នុងសហគមន៍ សម្រាប់ ប្រជាជនកម្ពុជានៅទូទាំងប្រទេស ដោយសារយុទ្ធនាការជាតិចាក់វ៉ាក់សាំងពុំទាន់ត្រូវបានបញ្ចប់នៅឡើយ, រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដាក់ចេញនូវ "យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" នៅទូទាំងប្រទេស និង វិធានការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងខេត្ត សៀមរាប សម្រាប់រយៈពេល ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីវេលាម៉ោង ២៣និង៥៩ នាទី (ម្ភៃបីនិងហាសិបប្រាំបួន នាទី) នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។ វិធានការទាំងនេះ ត្រូវបាន រំពឹងថានឹងជួយដល់ការគ្រប់គ្រង និងការពន្យាពេលបានមួយកម្រិត នូវការឆ្លងរាលដាលទ្រង់ទ្រាយធំក្នុង សហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទ Delta។

តាមការរំពឹងទុក បន្ទាប់ពីការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវបានបញ្ចប់, ពលករខ្មែរ ដែលនឹងវិលត្រឡប់មកពីប្រទេសថៃវិញ នឹងអាចមានការកើនឡើង ក្នុងចំនួនដ៏ច្រើន ដែលអាចហួសពីសមត្ថភាព ទទួលយករបស់មណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងបណ្តា ខេត្តជាប់នឹងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ខណៈដែលមេរោគប្រភេទ Delta ក៏ត្រូវបានបន្តរកឃើញជាបន្តបន្ទាប់ នៅក្នុងចំនួនកាន់តែច្រើនឡើងនៅក្នុងសហគមន៍ ហើយមេរោគនេះ កំពុងតែពង្រីកខ្លួនយ៉ាងលឿនទៅកាន់ តំបន់ផ្សេងទៀតដែលរហូតមកដល់បច្ចុប្បន្ននេះ មានរាជធានី-ខេត្តចំនួន១៧ ដែលមានវត្តមានមេរោគប្រភេទDeltaក្នុងសហគមន៍។

ផ្អែកតាមការវិវត្តថ្មីនៃសភាពការណ៍នេះ និងដើម្បីត្រៀមលក្ខណៈទុកជាមុនក្នុងគ្រប់គ្រងមេរោគ ប្រភេទ Delta ពិសេស ករណីនាំចូលពីប្រទេសជិតខាងជាប់ព្រំដែនកម្ពុជា ព្រមទាំងដើម្បីម្ចាស់ការដោះស្រាយ បញ្ហាប្រឈមនានា នៅតាមមូលដ្ឋានរាជធានី-ខេត្តនាពេលខាងមុខនេះ ដែលបណ្តាលមកពីការឆ្លងរាលដាល ក្នុងសហគមន៍នៃមេរោគ ប្រភេទ Delta, រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់បណ្តារាជធានី-ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី-ខេត្ត ដូចខាងក្រោម៖

១.អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល ត្រូវសហការគ្នាជាមួយបណ្តារាជធានី-ខេត្ត ដើម្បីធានាដល់ការគ្រប់គ្រងការធ្វើ ចត្តាឡីស័ក និងការព្យាបាលជំងឺកូវីដ-១៩ ចំពោះប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសជិតខាងជាប់ ព្រំដែនកម្ពុជា ដោយផ្អែកលើអភិក្រមបត់បែន ទៅតាមសភាពការណ៍ជាក់ស្តែង នៃចំនួនប្រជាពលរដ្ឋដែល វិលត្រឡប់ចូលមកកម្ពុជាវិញ និងសមត្ថភាពឆ្លើយតបជាក់ស្តែង នៃមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាល នៅតាមបណ្តាខេត្តពាក់ព័ន្ធ ពិសេសបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។ ទន្ទឹមនេះ អនុគណៈកម្មការគ្រប់គ្រង ច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ត្រូវដឹកនាំសម្របសម្រួល ជាមួយបណ្តារាជធានី-ខេត្តនៅ ផ្ទៃក្នុងប្រទេស និងសហការជាមួយយន្តការដែលមានការពាក់ព័ន្ធ ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរដែល វិលត្រឡប់មកពីប្រទេសជិតខាងវិញ ពិសេស មកពីប្រទេសថៃទៅតាមរាជធានី-ខេត្ត ដែលជាមូលដ្ឋានរស់នៅ របស់ប្រជាពលរដ្ឋទាំងនោះ ដើម្បីធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក និងធ្វើការព្យាបាលចំពោះអ្នកដែល ត្រូវបានរកឃើញថាមានវិជ្ជមានកូវីដ-១៩ ដោយត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ អំពីការគ្រប់គ្រងហានិភ័យ ឱ្យនៅកម្រិតអប្បបរមាពាក់ព័ន្ធនឹងការឆ្លាយមេរោគប្រភេទ Delta ចូលក្នុងសហគមន៍។

២-បណ្តារាជធានី-ខេត្តនៅផ្ទៃក្នុងប្រទេស ជាពិសេសខេត្តដែលមានពលករចំណាកស្រុកទៅ ប្រទេសថៃច្រើន ត្រូវរៀបចំមណ្ឌលចត្តាឡីស័ក នៅតាមភូមិ-ឃុំ និងមណ្ឌលព្យាបាលនៅតាមស្រុក ដែលស្ថិត នៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីត្រៀមលក្ខណៈទទួលយកពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃវិញ។ ជាមួយគ្នានេះ បណ្តារាជធានី-ខេត្តនៅផ្ទៃក្នុងប្រទេស ត្រូវចាប់ផ្តើមផ្អាកការទទួលយកការធ្វើចត្តាឡីស័កនៅ តាមមណ្ឌលចត្តាឡីស័ករបស់ខ្លួនបច្ចុប្បន្ន ចំពោះអ្នកពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩ (មិនមែនប្រភេទ Delta) ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១ ដោយបង្វែរការធ្វើចត្តាឡីស័កនេះ ទៅធ្វើនៅតាមផ្ទះរៀងៗ ខ្លួន សំដៅធានាឱ្យមណ្ឌលចត្តាឡីស័កទាំងនោះ អាចត្រៀមលក្ខណៈក្នុងការទទួលពលករខ្មែរ ដែលវិលត្រឡប់ មកពីប្រទេសថៃវិញ ដែលភាគច្រើនជាករណីពាក់ព័ន្ធនឹងមេរោគកូវីដ-១៩ ប្រភេទ Delta។

៣-ក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានី-ខេត្ត ត្រូវផ្តល់ការគាំទ្រឱ្យបានពេញទំហឹង តាមគ្រប់មធ្យោបាយ ជាពិសេស ផ្នែកសម្ភារៈ និងថវិកា ដើម្បីជួយដល់បណ្តារាជធានី-ខេត្ត ក្នុងការគ្រប់គ្រង និង ទទួលយកពលករខ្មែរដែលវិលត្រឡប់ មកពីប្រទេសថៃវិញ សម្រាប់ការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺ កូវីដ-១៩ ព្រមទាំងយកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋានដែលមានការពាក់ព័ន្ធនឹងជំងឺ កូវីដ-១៩។

ទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានី-ខេត្ត គណៈអភិបាលរាជធានី-ខេត្ត និងគណៈប្រតិបត្តិ នៃគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រមទាំងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយ ស្មារតីទទួលខុសត្រូវខ្ពស់៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៥ សរ

# សារាចរ

## ស្តីពី

## ការរៀបចំមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅតាមបណ្តារាជធានី-ខេត្ត ដើម្បីទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃតាមព្រំដែនគោក

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន។ បន្ថែមលើវិធានការបង្ការ, ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះ និងជាខ្សែក្រវ៉ាត់ការពារសំខាន់ជាងគេ ដើម្បីបង្កើតឱ្យមានភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះតាមគន្លងប្រក្រតីភាពថ្មី។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ការថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ ទាំងអស់ដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ និងមណ្ឌលព្យាបាលរបស់រដ្ឋទាំងអស់។

ផ្អែកតាមស្ថានភាពវិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងរយៈពេលចុងក្រោយនេះ, ការរកឃើញក្នុងចំនួនកាន់តែច្រើនឡើងនៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) លើពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក ព្រមទាំងការឆ្លាយចូលក្នុងសហគមន៍ក្នុងពេលថ្មីៗនេះនូវមេរោគប្រភេទថ្មីនេះ នៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ ព្រមទាំងខេត្តសៀមរាប, ខេត្តកំពង់ធំ និងរាជធានីភ្នំពេញ គឺជាកង្វល់ដ៏ធំ និងជាការគំរាមកំហែងជាប់ជាប្រចាំដល់ព្រះរាជាណាចក្រកម្ពុជា ដោយសារមេរោគប្រភេទថ្មីនេះមានកម្រិតនៃការឆ្លងរាលដាលលឿន និងកម្រិតគ្រោះថ្នាក់ធ្ងន់ធ្ងរជាងមុន។

ចំពោះមុខស្ថានភាពដែលកំពុងវិវត្តយ៉ាងលឿនគួរឱ្យបារម្ភនេះ និងក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជាពុំទាន់សម្រេចបានដោយជោគជ័យក្នុងការបង្កើតឱ្យមានពេញលេញនូវ "**ភាពស៊ាំក្នុងសហគមន៍**" សម្រាប់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ដោយសារយុទ្ធនាការជាតិចាក់វ៉ាក់សាំងពុំទាន់ត្រូវបានបញ្ចប់នៅឡើយ, រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដាក់ចេញនូវ "**យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លង**

**រាលដាលនៃជំងឺកូវីដ-១៩"** នៅទូទាំងប្រទេស និង **វិធានការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងខេត្តសៀមរាប** សម្រាប់រយៈពេល **១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីវេលាម៉ោង ២៣:៥៩ នាទី (ម្ភៃបីនិងហាសិបប្រាំបួននាទី) នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។** វិធានការទាំងនេះ ត្រូវបានរំពឹងថានឹងជួយដល់ការគ្រប់គ្រង និងការពន្យាពេលបានមួយកម្រិត នូវការឆ្លងរាលដាលទ្រង់ទ្រាយធំក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទ Delta។

តាមការរំពឹងទុក បន្ទាប់ពីការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវបានបញ្ចប់, ពលករខ្មែរដែលនឹងវិលត្រឡប់មកពីប្រទេសថៃវិញ នឹងអាចមានការកើនឡើងក្នុងចំនួនដ៏ច្រើន ដែលអាចហួសពីសមត្ថភាពទទួលយករបស់មណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងបណ្តាខេត្តជាប់នឹងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ខណៈដែលមេរោគប្រភេទ Delta ក៏ត្រូវបានបន្តរកឃើញជាបន្តបន្ទាប់នៅក្នុងចំនួនកាន់តែច្រើនឡើងនៅក្នុងសហគមន៍ ហើយមេរោគនេះ កំពុងតែពង្រីកខ្លួនយ៉ាងលឿនទៅកាន់តំបន់ផ្សេងទៀត ដែលរហូតមកដល់បច្ចុប្បន្ននេះ មានរាជធានី-ខេត្តចំនួន ១៧ ដែលមានវត្តមានមេរោគប្រភេទ Delta ក្នុងសហគមន៍។

ផ្អែកតាមការវិវត្តថ្មីនៃសភាពការណ៍នេះ និងដើម្បីត្រៀមលក្ខណៈទុកជាមុនក្នុងគ្រប់គ្រងមេរោគប្រភេទ Delta ពិសេស ករណីនាំចូលពីប្រទេសជិតខាងជាប់ព្រំដែនកម្ពុជា ព្រមទាំងដើម្បីម្ចាស់ការដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានរាជធានី-ខេត្តនាពេលខាងមុខនេះ ដែលបណ្តាលមកពីការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគប្រភេទ Delta, **រាជរដ្ឋាភិបាល** សូមធ្វើការណែនាំដល់បណ្តារាជធានី-ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី-ខេត្ត ដូចខាងក្រោម៖

១- អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក អនុគណៈកម្មការបច្ចេកទេសនិងព្យាបាល ត្រូវសហការគ្នាជាមួយបណ្តារាជធានី-ខេត្ត ដើម្បីធានាដល់ការគ្រប់គ្រងការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺកូវីដ-១៩ ចំពោះប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសជិតខាងជាប់ព្រំដែនកម្ពុជា ដោយផ្អែកលើអភិក្រមបត់បែនទៅតាមសភាពការណ៍ជាក់ស្តែងនៃចំនួនប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកកម្ពុជាវិញ និងសមត្ថភាពឆ្លើយតបជាក់ស្តែងនៃមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅតាមបណ្តាខេត្តពាក់ព័ន្ធ ពិសេសបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។ ទន្ទឹមនេះ អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ត្រូវដឹកនាំសម្របសម្រួលជាមួយបណ្តារាជធានី-ខេត្តនៅផ្ទៃក្នុងប្រទេស និងសហការជាមួយយន្តការដែលមានការពាក់ព័ន្ធ ដើម្បីដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសជិតខាងវិញ ពិសេស មកពីប្រទេសថៃ ទៅតាមរាជធានី-ខេត្តដែលជាមូលដ្ឋានរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ ដើម្បីធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក និងធ្វើការព្យាបាលចំពោះអ្នកដែលត្រូវបានរកឃើញថាមានវិជ្ជមានកូវីដ-១៩ ដោយត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយអំពីការគ្រប់គ្រងហានិភ័យឱ្យនៅកម្រិតអប្បបរមាពាក់ព័ន្ធនឹងការជ្លាយមេរោគប្រភេទ Delta ចូលក្នុងសហគមន៍។

២-បណ្តារាជធានី-ខេត្តនៅផ្ទៃក្នុងប្រទេស ជាពិសេស ខេត្តដែលមានពលករចំណាកស្រុកទៅប្រទេសថៃច្រើន ត្រូវរៀបចំមណ្ឌលចត្តាឡីស័កនៅតាមភូមិ-ឃុំ និងមណ្ឌលព្យាបាលនៅតាមស្រុក ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីត្រៀមលក្ខណៈទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ។ ជាមួយគ្នានេះ បណ្តារាជធានី-ខេត្តនៅផ្ទៃក្នុងប្រទេស ត្រូវចាប់ផ្តើមផ្អាកការទទួលយកការធ្វើចត្តាឡីស័កនៅ

តាមមណ្ឌលចត្តាឡីស័ករបស់ខ្លួនបច្ចុប្បន្ន ចំពោះអ្នកពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩ (មិនមែនប្រភេទ Delta) ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១ ដោយបង្វែរការធ្វើចត្តាឡីស័កនេះទៅធ្វើនៅតាមផ្ទះរៀងៗខ្លួន សំដៅធានាឱ្យមណ្ឌលចត្តាឡីស័កទាំងនោះ អាចត្រៀមលក្ខណៈក្នុងការទទួលពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ ដែលភាគច្រើនជាករណីពាក់ព័ន្ធនឹងមេរោគកូវីដ-១៩ ប្រភេទ Delta។

៣-ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី-ខេត្ត ត្រូវផ្តល់ការគាំទ្រឱ្យបានពេញទំហឹង តាមគ្រប់មធ្យោបាយ ជាពិសេស ផ្នែកសម្ភារ និងថវិកា ដើម្បីជួយដល់បណ្តារាជធានី-ខេត្ត ក្នុងការគ្រប់គ្រង និងទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ សម្រាប់ការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺកូវីដ-១៩ ព្រមទាំងយកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលមានការពាក់ព័ន្ធនឹងជំងឺកូវីដ-១៩។

ទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័ន ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី-ខេត្ត គណៈអភិបាលរាជធានី-ខេត្ត និងគណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រមទាំងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ពលករខ្មែររាប់ម៉ឺននាក់កកកុញតាមព្រំដែនថៃ ត្រៀមដឹកបញ្ជូនមកមណ្ឌលចត្តាឡីស័កតាមខេត្តក្រុងខាងក្នុងវិញ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៦ សីហា ២០២១ដោយ Dy Bunnara

ប្រមុខរដ្ឋាភិបាលសម្តេចតេជោ ហ៊ុន សែន តាមសារសំឡេងបានដាក់វិធានការជាបន្ទាន់ដល់អាជ្ញាធរខេត្តក្រុង ត្រូវរៀបចំមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលដើម្បីទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ។ ប្រមុខរដ្ឋាភិបាលក៏បានបញ្ជាដល់កងដឹកជញ្ជូនកងទ័ព ត្រៀមរថយន្តដឹកជញ្ជូនពលករដែលកំពុងកកកុញក្នុងទឹកដីថៃជាងមួយម៉ឺននាក់ ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័កតាមខេត្តក្រុងដែលបានរៀបចំ។ សម្តេចបានបញ្ជាក់យ៉ាងដូច្នេះថា៖ "ត្រូវរៀបចំអ្នកជំងឺដែលមានកម្រិតស្រាលតាមមណ្ឌលនានា បញ្ជូនទៅចត្តាឡីស័ក ព្យាបាលតាមផ្ទះ និងទុកទីតាំងសម្រាប់ពលករមកពីតាមព្រំដែន និងមកពីថៃ"។

តាមការរំពឹងទុក បន្ទាប់ពីការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជាថៃ ត្រូវបានបញ្ចប់ ពលករខ្មែរដែលនឹងវិលត្រឡប់មកពីប្រទេសថៃវិញ នឹងអាចមានការកើនឡើងក្នុងចំនួនដ៏ច្រើន ដែលអាចហួសពីសមត្ថភាព ទទួលយករបស់មណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅបណ្តាខេត្តជាប់ព្រំដែនកម្ពុជាថៃ និងបណ្តាខេត្តជាប់នឹងខេត្តជាប់ព្រំដែនកម្ពុជាថៃ ខណៈដែលមេរោគប្រភេទ Delta ក៏ត្រូវបានបន្តរកឃើញជាបន្តបន្ទាប់ នៅក្នុងចំនួនកាន់តែច្រើនឡើងនៅក្នុងសហគមន៍ ហើយមេរោគនេះកំពុងតែពង្រីកខ្លួនយ៉ាងលឿនទៅកាន់ តំបន់ផ្សេងទៀត ដែលរហូតមកដល់បច្ចុប្បន្ននេះ មានរាជធានីខេត្តចំនួន ១៧ ដែលមានវត្តមានមេរោគប្រភេទ Delta ក្នុងសហគមន៍។

សម្តេចតេជោបានបញ្ជាក់ថា ចំពោះអ្នកពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩ កម្រិតស្រាល ត្រូវបង្វែរការធ្វើចត្តាឡីស័កទៅធ្វើនៅតាមផ្ទះរៀងៗខ្លួនវិញ ដើម្បីទុកមណ្ឌលចត្តាឡីស័កទាំងនោះ អាចត្រៀមលក្ខណៈក្នុងការទទួលពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ ដែលភាគច្រើនជាករណីពាក់ព័ន្ធនឹងមេរោគកូវីដ-១៩ ប្រភេទ Delta។ ប្រមុខរដ្ឋាភិបាល ក៏ណែនាំឲ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីខេត្ត ត្រូវផ្តល់ការគាំទ្រឱ្យបានពេញទំហឹង តាមគ្រប់មធ្យោបាយ ជាពិសេសផ្នែកសម្ភារនិងថវិកា ដើម្បីជួយដល់បណ្តារាជធានីខេត្ត ក្នុងការគ្រប់គ្រង និង ទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ សម្រាប់ការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺ កូវីដ-១៩ ព្រមទាំងយកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលមានការពាក់ព័ន្ធនឹងជំងឺ កូវីដ-១៩៕

## ឯកឧត្តម ងួន រតនៈ នាំយកស្បៀងនិងឱសថៈមួយចំនួន របស់សម្តេចក្រឡាហោម ផ្តល់ជូនពលករខ្មែរ១១នាក់

https://www.facebook.com/cphnnews/ 6សីហា 2021 ម៉ោង 9:51 PM ·

បាត់ដំបង: នៅព្រឹកថ្ងៃសុក្រ ១៣រោច ខែទុតិយសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១នេះ ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និង ឯកឧត្តម សុខ គង់ សមាជិកក្រុមប្រឹក្សាខេត្ត ព្រមទាំងថ្នាក់នាំសំខាន់ៗ និងស្ថាប័នមន្ទីរអង្គភាពមួយចំនួនក្នុងខេត្ត បានអញ្ជើញចុះសាកសួរសុខទុក្ខដល់ពលករខ្មែរចំនួន១១នាក់ ដែលវិលត្រឡប់ពីប្រទេសថៃ ក្នុងគោលបំណងដើម្បីឆ្លងព្រំដែនចូលមកកាន់ស្រុកកំណើតខ្លួនវិញ ហើយត្រូវបានកម្លាំងសមត្ថកិច្ចព្រំដែនថៃធ្វើការចាប់ឃាត់ខ្លួនក្នុងភូមិសាស្រ្ត ស្រុកខ្លងហាត ខេត្តស្រះកែវ មុនឆ្លងកាត់ព្រំដែនវិលត្រឡប់ចូលមកស្រុកខ្មែរ កាលពីថ្ងៃទី៤ខែសីហាកន្លងទៅនេះ ត្រូវបានឯកឧត្តមអភិបាលខេត្តបាត់ដំបង ដឹកនាំប្រតិភូមួយក្រុមចុះពិនិត្យមើលពីស្ថានភាពរស់នៅក្នុងទឹកដីថៃ ដែលត្រូវបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច នៅតាមបន្ទាត់ព្រំដែនរបស់ថៃក្នុងភូមិសាស្រ្តស្រុកខ្លងហាត ខេត្តស្រះកែវ ដែលជាប់ និងស្រុកសំពៅលូន ខេត្តបាត់ដំបង និងបានពាំនាំគ្រឿងឧបភោគ-បរិភោគអង្ករ២០០គក្រ មី ត្រីខ និង

គេសជ្ជៈមួយចំនួន ជាអំណោយសម្តេចក្រឡាហោម ស ខេង និងលោកជំទាវ ទៅប្រគលជូនដល់បងប្អូនពលករទាំងនោះដល់ទីតាំងកំពុងបោះតង់ស្នាក់នៅ ដែលរៀបចំដោយអាជ្ញាធរថៃ នៅទីនោះ។

ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តក៏បានថ្លែងអំណរគុណដល់ភាគីថៃដែលបានយកចិត្តទុកដាក់ក្នុងការសម្របសម្រួលធ្វើការឃាត់ទុក និងផ្តល់នូវទីតាំងឲ្យស្នាក់នៅជាបណ្តោះអាសន្នចំពោះពលករខ្មែរ។ដោយក្នុងនោះដែរឯកឧត្តមអភិបាលខេត្តនិងរ៉ាប់រងក្នុងការដោះស្រាយស្បៀងជូនបងប្អូនពលករទាំងនោះជាមួយគ្នានេះ ឯកឧត្តមអភិបាលខេត្ត ក៏បានសំណូមពរដល់ភាគីថៃ សូមជួយផ្តល់នូវកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀត ដើម្បីជួយទប់ស្កាត់នូវការឆ្លងដែនរបស់ពលករខ្មែរ សូមឲ្យបន្តជួយឃាតទុកនិងនាំមកកាន់ទីនេះឲ្យស្នាក់នៅជាបណ្តោះអាសន្នមួយរយៈសិន ក្នុងគ្រាដែលរាជរដ្ឋាភិបាលកម្ពុជា បានធ្វើការបិទខ្ទប់ព្រំដែនមិនឲ្យឆ្លងកាត់ ចេញចូល ដើម្បីការពារនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-19 បំប្លែងថ្មី ប្រភេទDelta។ ដោយ: ម៉ាលីស

## រដ្ឋមន្ត្រីកសិកម្ម ស្នើក្រុមហ៊ុននាំពលករកម្ពុជាទៅបម្រើការងារលើផ្នែកកសិកម្ម នៅអូស្ត្រាលី ស្របច្បាប់

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៧ សីហា ២០២១ដោយ Inn Pisey

លោក វេង សាខុន ស្នើក្រុមហ៊ុន Lexmin Pty Ltd Cambodia ខិតខំឲ្យអស់ពីលទ្ធភាពក្នុងការនាំយកពលករកម្ពុជាទៅបម្រើការក្នុងវិស័យកសិកម្ម ក្នុងប្រទេសអូស្ត្រាលី ត្រឹមត្រូវ ស្របច្បាប់ ដើម្បីទទួលបានមេរៀនបទពិសោធន៍ល្អៗ យកមកអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនថែមទៀត។

ការស្នើសុំនេះបានធ្វើឡើង កាលពីរសៀលថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២១ ក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង លោក Robert K.Chelliah នាយកក្រុមហ៊ុន Lexmin Pty Ltd Cambodia ជាមួយអគ្គនាយកដ្ឋានកសិកម្ម ស្តីពី "ការជំរុញផលិតកម្មដំណាំស្តង់ដារសរីរាង្គ និងការពង្រឹងសមត្ថភាពកសិករ ដើម្បីទទួលបានឱកាសការងារនៅតាមបណ្តាកសិដ្ឋាននានាក្នុងប្រទេសអូស្ត្រាលី "។

លោករដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់ទុកអនុស្សរណៈនេះ នឹងជួយបំពេញនូវអត្ថប្រយោជន៍ឲ្យគ្នាទៅវិញទៅមកក្នុងការកសាងភាពជាដៃគូអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃផលិតកម្មដំណាំ ការកែច្នៃប្រកបដោយចីរភាព និរន្តរភាព បរិយាប័ន្ន ការប្រកួតប្រជែង ការប្រែប្រួលអាកាសធាតុ និង នវានុវត្តន៍។ ជាពិសេសនឹងចូលរួមចំណែកអនុវត្តផែនការយុទ្ធសាស្រ្តរបស់ក្រសួងក្នុងការជំរុញផលិតភាព និង ពិពិធកម្មដំណាំសរីរាង្គឲ្យកាន់តែល្អប្រសើរឡើង។ លោករដ្ឋមន្ត្រី បានបន្តទៀតថា ក្រៅពីនេះ MOU នេះ ពិតជាចូលរួមលើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្ម ការកែច្នៃ តម្លៃបន្ថែម ទីផ្សារក្នុង និង ក្រៅប្រទេស បង្កើតឱកាសការងារ បង្កើនសមត្ថភាពបច្ចេកទេសដល់កសិករ បង្កើនប្រាក់ចំណូល ស្របតាមអភិក្រម "រដ្ឋ -ឯកជន-ដៃគូអភិវឌ្ឍន៍-សហគមន៍កសិកម្ម"។ ដើម្បីទទួលបានជោគជ័យដូចការរំពឹងទុក លោករដ្ឋមន្ត្រី បានឲ្យដឹងថា ក្រុមហ៊ុនគួរស្វែងរកដៃគូដែលមានសក្តានុពលផលិតដំណាំបន្ថែមទៀតក្រៅពីម្រុំ ស្លឹកគ្រៃ និង ខ្ញីខ្មៅ ដែលក្រុមហ៊ុនកំពុងផលិត និង ពង្រីកផលិតកម្មកែច្នៃជាអាហារបន្ថែមសម្រាប់សុខភាពផងដែរ។ មិនតែប៉ុណ្ណោះក្រុមហ៊ុន គួរតែស្វែងរកជំនួយហិរញ្ញវត្ថុបន្ថែមពីរដ្ឋាភិបាលអូស្ត្រាលី ដើម្បីពង្រីកវិសាលភាព នៃផលិតកម្មរបស់ខ្លួនឲ្យអស់លទ្ធភាព ប្រយោជន៍ដើម្បីជួយជំរុញ និង លើកកម្ពស់ផលិតកម្មដំណាំសរីរាង្គក្នុងស្រុក និង ធ្វើការនាំចេញ។

ដោយឡែក ចំពោះជំហានទី០២ នៃគម្រោងផ្តល់ឱកាសការងារជូនកសិករទៅបម្រើការតាមបណ្តាកសិដ្ឋាននានាក្នុងប្រទេសអូស្ត្រាលី នាពេលអនាគត លោករដ្ឋមន្ត្រី បានបញ្ជាក់ថា « ខ្ញុំសូមធ្វើក្តីសង្ឃឹមយ៉ាងមុតមាំឲ្យក្រុមហ៊ុនខិតខំឲ្យអស់ពីលទ្ធភាពក្នុងការពុះពារនាំយកពលករកម្ពុជាទៅបម្រើការក្នុងវិស័យកសិកម្ម ក្នុងប្រទេសអូស្ត្រាលីត្រឹមត្រូវ ស្របច្បាប់ ដើម្បីទទួលបានមេរៀន និងបទពិសោធន៍ល្អយកមកអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើន។ ករណីនេះ ក្រសួង នឹងរង់ចាំផ្តល់កិច្ចសហការគ្រប់បែបយ៉ាងតាមការចាំបាច់»៕ អត្ថបទ ៖ សំអឿន

## អភិបាលខេត្តបាត់ដំបង ស្នើភាគីថៃផ្តល់កិច្ចសហការល្អបន្ថែមទៀត ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ បង្ការការរីករាលដាលជំងឺកូវីដ១៩ ជាពិសេសមេរោគបំប្លែងថ្មី

http://freshnewsasia.com/ 2021-08-07 01:07pm

**(បាត់ដំបង)៖** លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានសំណូមពរដល់ភាគីថៃ សូមផ្តល់នូវកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀត ដើម្បីជួយទប់ស្កាត់នូវការលួចឆ្លងដែនរបស់ពលករខ្មែរ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ជាពិសេសមេរោគកូវីដ១៩ បំប្លែងថ្មី។

ការសំណូមពរបែបនេះ របស់លោក ងួន រតនៈ បានធ្វើឡើងនាថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ នៅក្នុងឱកាសដែលលោកបានដឹកនាំក្រុមការងារ នាំយកអំណោយរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រគល់ផ្តល់ជូនពលករខ្មែរ១១នាក់ ដែលសមត្ថកិច្ចព្រំដែនថៃ ឃាត់ខ្លួនក្នុងភូមិសាស្រ្ត ស្រុកខ្លងហាត ខេត្តស្រះកែវ មុនឆ្លងកាត់ព្រំដែនវិលត្រឡប់ចូលមកកម្ពុជា កាលពីថ្ងៃទី៤ ខែសីហា កន្លងទៅនេះ។ លោកអភិបាលខេត្តបានស្នើសុំយ៉ាងដូច្នេះថា «**សំណូមពរដល់ភាគីថៃ សូមជួយផ្តល់នូវកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀត ដើម្បីជួយទប់ស្កាត់នូវការឆ្លងដែន របស់ពលករខ្មែរ សូមឱ្យបន្តជួយឃាត់ទុក និងនាំមកកាន់ទីនេះ ឱ្យស្នាក់នៅជាបណ្តោះអាសន្នមួយរយៈសិន ក្នុងគ្រាដែលរាជរដ្ឋាភិបាលកម្ពុជា បានធ្វើការបិទខ្ទប់ព្រំដែនមិនឱ្យឆ្លងកាត់ចេញ-ចូល ដើម្បីការពារ និងទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ បំប្លែងថ្មី ប្រភេទ Delta មួយរយៈផងដែរ**»។

នាឱកាសនោះដែរ លោក ងួន រតនៈ ក៏បានថ្លែងអំណរគុណដល់ភាគីថៃ ដែលបានយកចិត្តទុកដាក់ក្នុងការសម្របសម្រួលធ្វើការឃាត់ទុក និងផ្តល់នូវទីតាំងឱ្យស្នាក់នៅជាបណ្តោះអាសន្ន ចំពោះពលករខ្មែរ។ ដោយក្នុងនោះដែរ អភិបាលខេត្តនឹងរ៉ាប់រងក្នុងការដោះស្រាយស្បៀង ជូនបងប្អូនពលករជាដើម។ លោកបានដឹកនាំប្រតិភូមួយក្រុម ចុះពិនិត្យមើលពីស្ថានភាពរស់នៅក្នុងទឹកដីថៃ ដែលត្រូវបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច នៅតាមបន្ទាត់ព្រំដែនរបស់ថៃ ក្នុងភូមិសាស្រ្តស្រុកខ្លងហាត ខេត្តស្រះកែវ ដែលជាប់នឹងស្រុកសំពៅលូន ខេត្តបាត់ដំបង និងបានពាំនាំគ្រឿងឧបភោគបរិភោគ អង្ករ២០០គីឡូក្រាម មី ត្រីខ និងភេសជ្ជៈមួយចំនួន ជាអំណោយសម្តេចក្រឡាហោម ស ខេង និងលោកស្រី ទៅប្រគល់ជូនដល់បងប្អូនពលករទាំងនោះ ដល់ទីតាំងកំពុងបោះតង់ស្នាក់នៅ ដែលរៀបចំដោយអាជ្ញាធរថៃ នៅទីនោះផងដែរ៕

## អាជ្ញាធរខេត្តតាកែវ ត្រៀមមណ្ឌលចត្តាឡីស័ក សម្រាប់ទទួលពលករមកពីថៃបន្ថែមទៀត

https://cen-news.com/ Posted ByPen Srey NeatAugust 7, 2021

តាកែវ ៖ អភិបាលខេត្តតាកែវ ឯកឧត្តម អ៊ូច ភា បានធ្វើការណែនាំ ទៅដល់លោក កង អាណាន់ អភិបាលក្រុង ក៏ដូចជាមន្រ្តីជំនាញពាក់ព័ន្ធ ត្រូវបន្តត្រៀម និងរៀបចំសម្អាតឡើងវិញ នូវមណ្ឌលចត្តាឡីស័ក នៅសាលាគរុកោសល្យ និងភូមិភាគតាកែវ ពិសេសក៏ត្រូវសម្អាតផងដែរ នូវអាគារផ្សេងទៀតនៅក្បែរគ្នា សម្រាប់ពលករមកពីប្រទេសថៃ និងក្រុមគ្រូពេទ្យ កម្លាំងសមត្ថកិច្ច សម្រាក និងយាមប្រចាំការនៅទីនេះ ។ ថ្លែងនៅក្នុងឱកាស ចុះត្រួតពិនិត្យទីតាំងមណ្ឌលចត្តាឡីស័ក នៅសាលាគរុកោ សល្យ និងភូមិភាគតាកែវ ដើម្បីធ្វើការរៀបចំ និងសម្អាតឡើងវិញ នូវអាគារទាំងនេះសម្រាប់បងប្អូនប្រជាពលករ មកពីប្រទេសថៃ និងក្រុមគ្រូពេទ្យស្នាក់នៅ និងធ្វើចត្តាឡីស័ក នៅព្រឹកថ្ងៃសៅរ៍ ទី ០៧ ខែសីហា ឆ្នាំ២០២១នេះ ឯកឧត្តម អ៊ូច ភា អភិបាលខេត្ត បានមានប្រសាសន៍បន្តថា ដោយស្ថានភាពជំងឺកូវីដ១៩ បំលែងថ្មីប្រភេទដែលតា បាននិងកំពុងតែ ឆ្លងរីករាលដាលយ៉ាងខ្លាំងនៅក្នុងប្រទេសថៃ ដោយធ្វើឱ្យបងប្អូនខ្មែរយើង ដែលធ្វើការនៅទីនោះ នាំគ្នាសម្រុកចេញពីប្រទេសថៃ មកស្រុកកំណើតខ្លួនវិញ ហើយភាគច្រើន គឺរកឃើញមានមេរោគបំប្លែងខ្លួនថ្មីដែលតា ដែលបញ្ហានេះតម្រូវឱ្យយើងទាំងអស់គ្នា ត្រូវត្រៀមលក្ខណៈទុកមុនសម្រាប់យកពួកគាត់ មកធ្វើចត្តាឡីស័ក ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ។

ឯកឧត្តមអភិបាលខេត្ត បន្ថែមទៀតថា កាលពីម្សិលមិញ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា តាមរយៈសារជាសំឡេង បានណែនាំដល់អភិបាលខេត្តជាប់ព្រំដែនថៃទាំងអស់ ឱ្យផ្ទេរពលករខ្មែរ ដែលកំពុងធ្វើចត្តាឡីស័ក នៅតាមព្រំដែន ចូលមកបន្តធ្វើចត្តាឡីស័ក នៅតាមបណ្តារាជធានី-ខេត្ត ដែលជាមូលដ្ឋានរបស់ពួកគេ ដើម្បីទុកទីតាំងចត្តាឡីស័កនៅព្រំដែន សម្រាប់ទទួលពលករថ្មីទៀត ដោយឡែកសម្រាប់អ្នកធ្វើចត្តាឡីស័ក នៅតាមមណ្ឌលមូលដ្ឋានរាជធានី-ខេត្ត ដែលមិនពាក់ព័ន្ធ Delta នឹងអនុញ្ញាតឲ្យទៅធ្វើនៅតាមផ្ទះវិញ។ ឯកឧត្តម អ៊ុច ភា ក៏បានធ្វើការណែនាំបន្ថែមទៀតផងដែរ ទៅដល់អាជ្ញាធរក្រុង ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវតែសហការគ្នាក្នុងការត្រៀមរៀបចំកន្លែង សម្រាប់ទទួលបងប្អូនប្រជាពលករ ដែលមកពីប្រទេសថៃ ឱ្យពួកគាត់ធ្វើចត្តាឡីស័ក និងសម្រាកនៅទីតាំងដែលយើង បានត្រៀមរៀបចំជាមុននេះ ពិសេសគឺពន្លឿនការសម្អាតទីតាំងទាំងនោះ ដោយរៀបចំប្រព័ន្ធទឹក ភ្លើង បន្ទប់ទឹក ដើម្បីឱ្យពលករមកពីថៃ បានធ្វើចត្តាឡីស័កដាច់ដោយឡែកពីគ្នា និងជានាបាននូវការមិនបន្តឆ្លងរាលដាល ក្នុងសហគមន៍របស់យើង ចំពោះមេរោគប្រភេទដែលតានេះ ៕ រក្សាសិទ្ធិដោយៈតាកែវ

## ពលករមកពីថៃ មកស្រុកកំណើត ចម្លងកូវីដបំប្លែងខ្លួនមកម្តាយ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៦ សីហា ២០២១ដោយ Dy Bunnara

អាជ្ញាធរសុខាភិបាលបានបញ្ជាក់ពីករណីពលករខ្មែរម្នាក់មកពីថៃ បានចម្លងកូវីដបំប្លែងខ្លួនមកម្តាយនៅឯស្រុកកំណើត។ នេះបើតាមសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ក្រោយរាយការណ៍ករណីរកឃើញវីរុសបំប្លែងខ្លួនថ្មី Delta ចំនួន ៦៧ ករណីបន្ថែមទៀតក្នុងរយៈពេលពីរថ្ងៃពីថ្ងៃ ៤ ដល់ ៥ សីហាឆ្នាំ២០២១។ ជនរងគ្រោះជាម្តាយដែលឆ្លងកូវីដបំប្លែងខ្លួនពីកូនជាពលករមកពីថៃ មានស្រុកកំណើតនៅខេត្តស្វាយរៀង។

គួរបញ្ជាក់ថា ពីថ្ងៃ ៤ ដល់ ៥ សីហាឆ្នាំ២០២១ កម្ពុជាបន្តរកឃើញវីរុសបំប្លែងខ្លួនថ្មី Delta ចំនួន ៦៧ ករណីបន្ថែមទៀត មានពាក់ព័ន្ធពលករ អាជីវករ អ្នកដំណើរតាមផ្លូវអាកាសពីក្រៅប្រទេស និងការឆ្លងរាលដាលក្នុងសហគមន៍។ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបិទខ្ទប់ខេត្តជាប់ព្រំដែនថៃ ដែលរួមមានខេត្តកោះកុង ពោធិសាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហាររួមទាំងខេត្តសៀមរាប រយៈពេល១៤ថ្ងៃចាប់ពីថ្ងៃទី២៩កក្កដារហូតដល់ថ្ងៃទី១២ សីហា។ ការសម្រេចបិទខ្ទប់ជាបន្ទាន់នេះ គឺដើម្បីទប់ស្កាត់ការនាំចូលមេរោគកូវីដ១៩បំប្លែងថ្មីដែលតាចូលទៅក្នុងសហគមន៍ បន្ទាប់ពីមានការកើនឡើងចំនួនអ្នកឆ្លងមេរោគកូវីដ១៩បំប្លែងថ្មីដែលតាជាបន្តបន្ទាប់។

មកដល់ពេលនេះ កម្ពុជាមានអ្នកឆ្លងកូវីដបំប្លែងខ្លួនថ្មី ដែលតា ឡើងដល់ចំនួន **៣២៧នាក់** ក្នុងនោះរកឃើញក្នុងអំឡុងខែមេសា១នាក់ ថ្ងៃ០៤មិថុនា៤នាក់ ថ្ងៃ១៨មិថុនា៧នាក់ ថ្ងៃទី២៥មិថុនា២៥នាក់ ថ្ងៃទី១៦កក្កដា៣៧នាក់ ថ្ងៃទី២២កក្កដា និងថ្ងៃទី២៥កក្កដាមានចំនួន៣៩នាក់ ថ្ងៃទី៣១កក្កដា៤៣នាក់ ថ្ងៃទី០១សីហា៦៧នាក់ ថ្ងៃទី៣សីហា ៣៦នាក់ ថ្ងៃទី៤សីហា៣២នាក់ និងថ្ងៃទី៥សីហាចំនួន៣៥នាក់។ វីរុសបំប្លែងខ្លួនដែលតាដែលមានប្រភពមកពីប្រទេសឥណ្ឌានេះ បានកំពុងបន្តវាយលុកចូលក្នុងសហគមន៍ជាពិសេសនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ព្រះវិហារ កំពង់ចាម និងកំពង់ធំ និងបណ្តាខេត្តជាប់ព្រំដែនថៃ៕ អត្ថបទ៖ ប៊ុណ្ណារ៉ា

## ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

## សម្តេច ស ខេង បញ្ជាឲ្យខិតខំដោះស្រាយ បញ្ហាពលករខ្មែរ ត្រឡប់មកពីថៃ ព្រោះថៃ កំពុង ឆ្លងកូវីដ-១៩ បំប្លែងថ្មីខ្លាំង

https://dap-news.com/national/ ByPH104Posted on August 9, 2021

**ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបា លចុះជួយមូលដ្ឋានខេត្តបាត់ដំបង បានឲ្យដឹងថា ខេត្តបាត់ដំបង ជាខេត្តជាប់ព្រំដែន ជាមួយថៃ ហើយថៃកំពុង ស្ថិតក្នុងអត្រាឆ្លងខ្ពស់ នៃមេរោគកូវីដ-១៩ បំប្លែងថ្មី Delta ធ្វើឲ្យពលករខ្មែរ ត្រឡប់មកកម្ពុជា វិញជាបន្តបន្ទាប់។** ករណីនេះ បានក្លាយជាបញ្ហា ប្រឈមថ្មីមួយទាមទារ ឲ្យមានការខិតខំដោះស្រាយ។

ក្នុងកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅខេត្តបាត់ដំបង និងបញ្ហាប្រឈម នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ សម្តេច ស ខេង បានថ្លែងថា ការដោះស្រាយបញ្ហាប្រឈមនានា បង្កឡើងដោយការរីករាលដាល មេរោគបំប្លែងថ្មី ដែលខេត្តបាត់ដំបង ក៏ស្ថិតក្នុងតំបន់ងាយឆ្លងជំងឺនេះដែរ។ សម្តេច មានប្រសាសន៍ថា «**ខេត្តបាត់ដំបង គឺជាខេត្តមួយជាប់ព្រំដែន ជាមួយប្រទេសថៃ ហើយប្រទេសថៃកំពុងស្ថិត ក្នុងអត្រាឆ្លងខ្ពស់នៃមេរោគកូវីដ-១៩ ពិសេសមេរោគបំប្លែងថ្មី ដែលធ្វើឲ្យ ប្រជាពលរដ្ឋខ្មែរ ពិសេសក្រុម ប្រជាពលរដ្ឋ ជាក្រុមពលករនាំគ្នាធ្វើ ដំណើរត្រឡប់មកវិញជាបន្តបន្ទាប់ និងបានក្លាយជា បញ្ហាប្រឈមថ្មីមួយ ដែលទាមទារឱ្យមានការខិតខំដោះស្រាយ**»។ សម្តេចបញ្ជាក់ថា បញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា និយាយជារួម និងរដ្ឋបាលខេត្តបាត់ដំបង និយាយដោយឡែក ក៏បានខិតខំប្រឹងប្រែង អនុវត្តតាមគោលការណ៍នានា ប្រកបដោយការទទួលខុសត្រូវ ខ្ពស់រួចមកហើយដែរ ។ សម្តេច ក៏បានកោតសរសើរចំពោះក្រុមការងារថ្នាក់ជាតិ ទាំងអស់ដែលបានជួយជ្រោមជ្រែង ដល់រដ្ឋបាលខេត្តបាត់ដំបង ទាំងជំនួយសម្ភារៈ និងស្មារតី៕

## សម្តេចក្រឡាហោម ៖ ក្រុមពលករ នាំគ្នាធ្វើដំណើរត្រឡប់មកវិញ ជាបន្តបន្ទាប់ និងបានក្លាយជាបញ្ហាប្រឈមថ្មីមួយ ដែលទាមទារ ឱ្យមានការខិតខំដោះស្រាយ

https://cen.com.kh/ Posted ByPen Srey NeatAugust 9, 2021

ភ្នំពេញ ៖ នៅព្រឹកថ្ងៃចន្ទ ទី៩ ខែសីហា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តបាត់ដំបង បានអញ្ជើញដឹកនាំកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅក្នុងខេត្តបាត់ដំបង និងបញ្ហាប្រឈម។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញដឹកនាំកិច្ចប្រជុំនេះ ពីទីស្តីការក្រសួងមហាផ្ទៃ ដោយមានការញ្ជើញចូលរួមផ្ទាល់ ពីឯកឧត្តមរដ្ឋលេខាធិការប្រចាំការ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃមួយចំនួនទៀត ចំណែកអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសមាជិកអង្គប្រជុំមួយចំនួនទៀតបានចូលរួមតាមវីដេអូសន្និសីទZoom ។

អញ្ជើញថ្លែងបើកកិច្ចប្រជុំនាឱកាសនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះជួយមូលដ្ឋានខេត្តបាត់ដំបង បានមានប្រសាសន៍ថា កិច្ចប្រជុំនៅថ្ងៃនេះ គឺទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ពិសេសការដោះស្រាយបញ្ហាប្រឈមនានាបង្កឡើងដោយការរីករាលដាលមេរោគបំប្លែងថ្មី ដែលខេត្តបាត់ដំបងក៏ស្ថិតក្នុងតំបន់ងាយឆ្លងជំងឺនេះ។ សម្តេចបានគូសបញ្ជាក់ថា ខេត្តបាត់ដំបង គឺជាខេត្តមួយជាប់ព្រំដែនជាមួយប្រទេសថៃ ហើយប្រទេសថៃកំពុងស្ថិតក្នុងអត្រាឆ្លងខ្ពស់នៃមេរោគកូវីដ-១៩ ពិសេសមេរោគបំប្លែងថ្មី ដែលធ្វើឱ្យប្រជាពលរដ្ឋខ្មែរ ពិសេសប្រជាពលរដ្ឋក្រុមប្រជាពលជាក្រុមពលករនាំគ្នាធ្វើដំណើរត្រឡប់មកវិញជាបន្តបន្ទាប់ និងបានក្លាយជាបញ្ហាប្រឈមថ្មីមួយ ដែលទាមទារឱ្យមានការខិតខំដោះស្រាយ។ សម្តេច

ក្រឡាហោមបានបន្ថែមថាប្រឈមនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជានិយាយជារួម និងរដ្ឋបាលខេត្តបាត់ដំបង និយាយដោយឡែក ក៏បានខិតខំប្រឹងប្រែងអនុវត្តតាមគោលការណ៍នានា ប្រកបដោយការទទួលខុសត្រូវខ្ពស់រួចមកហើយដែរ ។ សម្តេចបានថ្លែងកោតសរសើរចំពោះក្រុមការងារថ្នាក់ជាតិទាំងអស់ ដែលបានជួយជ្រោមជ្រែងដល់រដ្ឋបាលខេត្តបាត់ដំបង ទាំងជំនួយសម្ភារៈ និងស្មារតី។

បន្ទាប់មក ឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ក៏បានអញ្ជើញធ្វើរបាយការណ៍ជូនសម្តេចក្រឡាហោម ព្រមទាំងអង្គប្រជុំ អំពីសភាពការណ៍ទូទៅ នៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ក្នុងខេត្តបាត់ដំបង ដែលរួមមានទាំងវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ដែលខេត្តកំពុងជួបប្រទះនារយៈពេលចុងក្រោយនេះ។ ក្នុងនាមរដ្ឋបាលខេត្ត ឯកឧត្តម ងួន រតនៈ ក៏បានលើកសំណូមពរជូនឯកឧត្តម លោកជំទាវ ប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះជួយមូលដ្ឋានក្រុង ស្រុក ទាំងអស់ក្នុងខេត្តបាត់ដំបង បន្តជួយគាំទ្រដល់រដ្ឋបាលក្រុងស្រុក ឱ្យមានលទ្ធភាពកាន់តែច្រើន ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ជាពិសេសនៅក្នុងអំឡុងពេលនៃការធ្វើយុទ្ធនាការចាក់វ៉ាក់សាំង ជូនដល់ប្រជាពលរដ្ឋក្នុងខេត្តបាត់ដំបង ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## កំពង់ធំ! ពលករមកពីថៃ គ្មានរោគសញ្ញា នៅធ្វើចត្តាឡីស័កតាមផ្ទះ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២១

(កំពង់ធំ)៖ ក្រោយទទួលអនុសាសន៍ ពីសម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជានារសៀលថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២១នេះ ឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ បានបើកកិច្ចប្រជុំបន្ទាន់តាមរយៈប្រព័ន្ធវីដេអូ Zoom ជាមួយរដ្ឋបាលក្រុងស្រុក និងមន្ទីរអង្គភាពជុំវិញខេត្ត ដើម្បីត្រៀមលក្ខណៈទុកជាមុនសំរាប់ទទួលពលករវិលត្រឡប់មកពីប្រទេសថៃ ដោយ ឯកឧត្តម សុខ លូ បញ្ជាក់ថា ករណីគ្មានរោគសញ្ញាអ្វីទេ គឺសូមស្នើសុំពិនិត្យលទ្ធភាព ដើម្បីបញ្ចេញពួកគាត់ទៅធ្វើចត្តាឡីស័កបញ្ចប់នៅតាមផ្ទះបន្តទៀត។ ជាមួយគ្នានោះដែរ ឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ មានប្រសាសន៍លើកឡើងថា នៅថ្ងៃខាងមុខនេះ ប្រមុខរាជរដ្ឋាភិបាលនឹងបើកច្រកព្រំដែន ដែលតម្រូវឱ្យតាមបណ្តាខេត្តនីមួយៗ ត្រូវត្រួតពិនិត្យមើលត្រៀមរៀបចំមណ្ឌលចត្តាឡីស័ក សម្រាប់ទទួលពលករដែលវិលត្រឡប់មកពីប្រទេសថៃ រហូតដល់កម្រិតថ្នាក់ ឃុំ សង្កាត់ ក្រុង ស្រុក និងខេត្ត ប៉ុន្តែមណ្ឌលសម្រាប់ព្យាបាលកម្រិតស្រាលអ្នកជំងឺកូវីដ ១៩ ត្រឹមកម្រិតថ្នាក់ ក្រុង ស្រុក និងថ្នាក់ខេត្ត ។

ឯកឧត្តមបន្តថា ចំពោះអ្នកដែលពាក់ព័ន្ធទៅនឹងប្រភេទវីរុសបំលែងថ្មី (Delta) ត្រូវដាក់ពួកគាត់នៅដាច់ដោយឡែកពីគេ និងចូលរួមអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ការពារ ៣កុំ របស់រាជរដ្ឋាភិបាលកម្ពុជា និងគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ឯកឧត្តមបន្ថែមទៀតថា ចំពោះបងប្អូនដែលពាក់ព័ន្ធផ្ទាល់ និងប្រយោលក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ សូមពិនិត្យមើលឱ្យបានច្បាស់លាស់ បើគ្មានរោគសញ្ញាអ្វីទេ គឺសូមស្នើសុំពិនិត្យលទ្ធភាព ដើម្បីបញ្ចេញពួកគាត់ទៅធ្វើចត្តាឡីស័កបញ្ចប់នៅតាមផ្ទះបន្តទៀត ដោយមានការតាមដាន ឃ្លាំមើល និងត្រួតពិនិត្យពីអាជ្ញាធរមូលដ្ឋានឲ្យបានហ្មត់ចត់ និងមានការចងខ្សែហ៊ុមព័ទ្ធផ្ទះរបស់ពួកគាត់ផងដែរ៕

## អាជ្ញាធរខេត្តកណ្តាល ត្រៀមយកវិទ្យាល័យចំនួន ២ ធ្វើជាមណ្ឌលចត្តាឡីស័ក

## សម្រាប់ពលករមកពី ថៃ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៨ សីហា ២០២១ដោយ Blue Sky

អាជ្ញាធរខេត្តកណ្ដាល ត្រៀមយកវិទ្យាល័យសិរីមង្គល និងវិទ្យាល័យ ជាស៊ីម សាមគ្គី ស្ថិតក្នុងស្រុកពញាឮ ខេត្តកណ្ដាល សម្រាប់ទទួលពលករ ដែលវិលត្រលប់មកពីប្រទេសថៃវិញ។ ការត្រៀមមណ្ឌលចត្តាឡីស័កនេះបាន ធ្វើឡើងអនុវត្តនូវសារាចរណែនាំលេខ០៥ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ក៏ដូចជា ប្រសាសន៍ណែនាំរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់រាជធានី ខេត្តទាំងអស់ ក្នុងការត្រៀមលក្ខណៈរៀបចំមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅតាម រាជ ធានី ខេត្ត ដើម្បីទទួលយកពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃវិញ។

ថ្លែងនៅក្នុងឱកាសចុះពិនិត្យមណ្ឌលចត្តាឡីស័ក ទាំងពីរកន្លែងនេះកាលពីរសៀលថ្ងៃទី ៧ សីហា លោក តាំង ម៉េងលាន អភិបាលរងខេត្តកណ្ដាល បាន ណែនាំដល់អាជ្ញាធរស្រុកពញាឮ ត្រូវរៀបចំមណ្ឌលចត្តាឡីស័ក ទាំងពីរឲ្យបានស្អាត ដោយធានាបាននូវផាសុខភាព និងសុវត្ថិភាព ក្នុងពេលកំពុងធ្វើចត្តាឡីស័ករបស់បងប្អូនពល ករ ដែលបានវិលត្រឡប់មកពីប្រទេសថៃ។ ជាងនេះទៅទៀតអាជ្ញាធរស្រុក ត្រូវរៀបចំគ្រែឲ្យបានគ្រប់គ្រាន់ ត្រូវមាន កន្លែងសម្រាប់លាងដៃ បន្ទប់ទឹកត្រូវឲ្យបានស្អាត ព្រមទាំងរៀបចំទីធ្លាឲ្យបានធំទូលាយ ដើម្បីឲ្យបងប្អូនពលករទាំង អស់ ធ្វើលំហាត់ប្រាណ។ លើសពីនេះទៀតអាជ្ញាធរស្រុក ត្រូវរៀបចំនូវអាហារឲ្យបានសមរម្យចំនួនបីពេលក្នុងមួយ ថ្ងៃ ជូនដល់បងប្អូនពលករដែលកំពុងធ្វើចតាឡីស័កផងដែរ។

លោក យី យ៉េន អភិបាលស្រុកពញាឮ បានឲ្យដឹងថា មណ្ឌលចត្តាឡីស័កចំនួន២កន្លែងដើម្បីត្រៀម សម្រាប់ទទួលបងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃនេះ ក្នុងនោះរួមមានមណ្ឌលចត្តាឡីស័ក វិទ្យាល័យ សិរីមង្គល និងវិទ្យាល័យ ជា ស៊ីម សាមគ្គី ដែលអាចដាក់អ្នកចត្តាឡីស័កបានជិត ១ពាន់នាក់។ លោកបន្ថែមថា នៅ ទូទាំងស្រុកពញាឮ មានប្រជាពលរដ្ឋដែលកំពុងធ្វើពលករនៅប្រទេសថៃ ប្រមាណជាង៣០០នាក់៕ **សំអឿន**

## កងទ័ពកំពុងសម្រុកដឹកជញ្ជូនពលករ ដែលត្រឡប់ពីថៃ ដើម្បីឱ្យបន្តធ្វើចត្តាឡីស័កនៅស្រុកកំណើត

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 08 August 2021 | 20:09 ICT

**ភ្នំពេញៈ** កងយោធពលខេមរភូមិន្ទ និងរថយន្តជាច្រើនគ្រឿងកំពុងចេញប្រតិបត្តិការដឹកជញ្ជូនពលករខ្មែរ ជាង១ម៉ឺននាក់ ដែលបានវិលត្រឡប់មកពីថៃវិញ ហើយកំពុងធ្វើចត្តាឡីស័កនៅក្នុងខេត្តកម្ពុជាជាប់ព្រំដែនថៃដោយ បញ្ជូនពួកគាត់ឱ្យទៅបន្តធ្វើចត្តាឡីស័កនៅស្រុកកំណើត ដើម្បីទុកកន្លែងធ្វើចត្តាឡីស័កនៅខេត្តជិតព្រំដែន សម្រាប់ ពលករដែលជាប់ក្នុងទឹកដីថៃនៅពេលពួកគេមកដល់កម្ពុជា។

លោកឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិបានប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី៨សីហាថា ការដឹកជញ្ជូនពលករ ពីតាមព្រំដែននាពេលកន្លងមកគឺ បានធ្វើជាបន្តបន្ទាប់រួចមកហើយ។ ប៉ុន្តែពេលនេះគឺ រដ្ឋាភិ បាលបានដាក់ចេញវិធានការក្នុងទ្រង់ទ្រាយធំដើម្បីនាំយកពលករទាំងអស់ដែលកំពុងធ្វើចត្តាឡីស័កនៅតាមព្រំដែន បញ្ជូនទៅបន្តធ្វើចត្តាឡីស័កនៅស្រុកកំណើតបន្តទៀត បើទោះជាពួកគេ មិនទាន់ធ្វើចត្តាឡីស័កគ្រប់ចំនួនហើយក៏ ដោយ ។ លោកបញ្ជាក់ថា ការធ្វើយ៉ាងដូច្នេះ គឺដើម្បីរក្សាកន្លែងធ្វើចត្តាឡីស័កនៅតាមព្រំដែនទាំងនេះសម្រាប់ដាក់ ពលករដែលកំពុងជាប់គាំងនៅលើទឹកដីថៃ ដែលគ្រោងនឹងអនុញ្ញាតឲ្យចូលកម្ពុជាវិញ។ លោកបានរៀបរាប់ថាៈ« ចំពោះដំណាក់ការចុងក្រោយនេះគឺយើងធ្វើការងារនេះមានលក្ខណពិសេសជាងមុនៗទៀត មានន័យថា អ្នកដែល ចូលមកមុននេះយើងឲ្យដាក់នៅកន្លែងចត្តាឡីស័កនៅតាមខេត្តជាប់ព្រំដែនទាំងអស់។ ឥឡូវនេះ អ្នកចត្តាឡីស័ក

ហ្នឹង បើធ្វើចត្តាឡីស័កបានតែ១អាទិត្យហើយគឺយើងរំដោះចេញពីកន្លែងចត្តាឡីស័កនៅតាមបណ្តាខេត្តជាប់ព្រំដែន បញ្ជូនទៅតាមខេត្តផ្សេងៗ »។

បើតាមលោក ទៀ បាញ់ ចំនួនពលករកំពុងធ្វើចត្តាឡីស័កដែលត្រូវបញ្ជូនចេញពីបណ្តាខេត្តជាប់ព្រំដែនកម្ពុជា ថៃ គឺមានជាង១ម៉ឺននាក់ដោយក្នុងនោះត្រូវប្រើប្រាស់រថយន្តចំនួន២០០គ្រឿងនិងកម្លាំងទ័ពប្រចាំការទូទាំងប្រទេសដើម្បីចូលរួមអនុវត្តវិធានការនេះ។ លោកបានបន្ថែមទៀតថា៖«យើងបានរៀបចំជាហូរហែមកហើយនូវរថយន្តមានជាង ២០០គ្រឿង និងអ្នកនៅប្រចាំការតាមបណ្តាទិសជាង ២០០នាក់។ ក៏ប៉ុន្តែយើងនឹងមានគម្រោងបន្ថែមទៀត ប្រសិនបើមានសំណើពីបណ្តាខេត្តជាប់ព្រំដែនច្រើន គឺយើងត្រូវបន្ថែម។ គ្រាន់ពេលនេះ រថយន្តជាង ២០០គ្រឿង កំពុងចូលគោលដៅ»។

កាលពីល្ងាចថ្ងៃទី៦ ខែសីហា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបទបញ្ជាឲ្យកងទ័ព ចេញឡានទៅដឹកជញ្ជូនពលករដែលកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័កនៅតាមខេត្តជាប់ព្រំដែនថៃ ដើម្បីត្រៀមកន្លែងទាំងនោះទុកទទួលពលករខ្មែរថ្មី ដែលកំពុងវិលត្រឡប់មកពីប្រទេសថៃ។ ការសម្រុកវិលត្រឡប់មកកម្ពុជាវិញរបស់ពលករខ្មែរនាពេលនេះ ក៏ព្រោះតែប្រទេសថៃកំពុងផ្ទុះនូវការរីករាលជំងឺកូវីដ១៩ ជាពិសេសវីរុសបំប្លែងថ្មីប្រភេទដែលតា ដែលធ្វើឱ្យរដ្ឋាភិបាលនៃប្រទេសទាំង២សម្រេចបិទខេត្តជាច្រើននិងផ្អាកសកម្មភាពការងារជាច្រើនផងដែរ។

លោក ហ៊ុល សំអុន មេបញ្ជាការកងពលតូចដឹកជញ្ជូនលេខ ៩៩ ដែលបានដឹកនាំកម្លាំងនិងរថយន្តជាច្រើនគ្រឿងឆ្ពោះទៅកាន់ព្រំដែនកម្ពុជា-ថៃ បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី៨ សីហាថា កម្លាំងបានដឹកពលករជាច្រើនពាន់យកទៅដាក់បន្តនៅមណ្ឌលចត្តាឡីស័កនៃខេត្តដែលជាស្រុកកំណើតរបស់ពលករ។ លោកថា ក្នុងពេលនេះ កម្លាំងទ័ព ក៏បន្តប្រតិបត្តិការនេះ យ៉ាងមមាញឹក ហើយចំនួនពលករដែលត្រូវបញ្ជូន ក៏នៅតែមានចំនួនច្រើនផងដែរ។ លោកបានបញ្ជាក់ថា៖ «យើងមិនទាន់បូកសរុបចំនួនមនុស្សនោះទេ។ គ្រាន់តែដឹងថា ចំនួនមនុស្សដែលយើងបានដឹកចេញពីព្រំដែន គឺច្រើនណាស់។ ខ្ញុំនឹងបញ្ជូនរបាយការណ៍ឲ្យនៅពេលក្រោយ»។

លោក សុខ លូ អភិបាលខេត្តកំពង់ធំបានលើកឡើងថា រដ្ឋបាលខេត្តកំពង់ធំបានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលពលករវិលត្រឡប់មកពីប្រទេសថៃតាមរយៈយន្តការថ្មីរបស់រដ្ឋាភិបាល ក្នុងការបើកព្រំដែនទទួលយកពលករខ្មែរចំណូលថ្មី។ លោកបានបញ្ជាក់ថា៖«ប្រមុខរាជរដ្ឋាភិបាលនឹងបើកច្រកព្រំដែនដែលតម្រូវឲ្យតាមបណ្តាខេត្តនីមួយៗ ត្រូវត្រួតពិនិត្យមើលត្រៀមរៀបចំមណ្ឌលចត្តាឡីស័កសម្រាប់ទទួលពលករ ដែលវិលត្រឡប់មកពីប្រទេសថៃ រហូតដល់កម្រិតថ្នាក់ ឃុំ សង្កាត់ ក្រុង ស្រុក និងខេត្ត។ ចំពោះអ្នកដែលពាក់ព័ន្ធទៅនឹងប្រភេទវីរុសបំប្លែងថ្មី(Delta) ត្រូវដាក់ពួកគាត់នៅដាច់ដោយឡែកពីគេ និងចូលរួមអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ៣ការពារ ៣កុំរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល»។ ក្នុងនោះលោកអះអាងថា សម្រាប់អ្នកដែលពាក់ព័ន្ធផ្ទាល់និងប្រយោលក្នុងព្រឹត្តិការណ៍២០កុម្ភៈ សូមពិនិត្យមើលឱ្យបានច្បាស់លាស់ បើគ្មានរោគសញ្ញាអ្វីទេ គឺសូមស្នើសុំពិនិត្យលទ្ធភាព ដើម្បីបញ្ចេញពួកគាត់ទៅធ្វើចត្តាឡីស័កបញ្ចប់នៅតាមផ្ទះបន្តទៀត ដោយមានការតាមដាន ឃ្លាំមើល និងត្រួតពិនិត្យពីអាជ្ញាធរមូលដ្ឋានឲ្យបានហ្មត់ចត់ និងមានការចងខ្សែហ៊ុមព័ទ្ធផ្ទះរបស់ពួកគាត់ផងដែរ៕

## ត្រៀមគ្រែប្រមាណជិតបួនពាន់សម្រាប់ទទួលព្យាបាលពលករមកពីប្រទេសថៃ

https://www.rasmeinews.com/ 8 August, 2021

**ដោយៈបូកគោ/កំពត:** អនុវត្តតាមប្រសាសន៍ណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាពលករវិលត្រឡប់មកពីប្រទេសថៃ កាលពីរសៀលថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ អភិបាលខេត្តកំពត បានតម្រូវដល់អាជ្ញាធរក្រុងស្រុកត្រៀមកន្លែងសម្រាប់ធ្វើចត្តាឡីស័ក និងមណ្ឌលព្យាបាលជំងឺកូវីដ១៩ ឱ្យបានត្រឹមត្រូវ។ ក្នុងនោះ គ្រែសម្រាប់សម្រាកព្យាបាលជិត៤.០០០គ្រែ ត្រូវបានរៀបចំរួចរាល់។

លោក ជាវ តាយ អភិបាលខេត្តកំពត បានមានប្រសាសន៍ថា តាមការបញ្ជាក់ឱ្យដឹងរបស់សម្តេចតេជោ គឺពលករប្រមាណជាង១ម៉ឺននាក់ ដែលកំពុងធ្វើចត្តាឡីស័កនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃនឹងត្រូវបញ្ជូនបន្តមកកាន់ខេត្តរៀងៗខ្លួន ដើម្បីទុកកន្លែងសម្រាប់អ្នកមកក្រោយបន្ទាប់ទៀត។ ម្ល៉ោះហើយ រដ្ឋបាលក្រុងស្រុកត្រូវចាប់ផ្តើមអនុវត្តនូវវិធានការបីចំណុចជាសំខាន់។ ក្នុងនោះ រួមមាន៖ ១. បញ្ជូនអ្នកធ្វើចត្តាឡីស័កនៅតាមបណ្តាក្រុងស្រុកឱ្យទៅធ្វើចត្តាឡីស័កបន្តនៅតាមផ្ទះរៀងៗខ្លួន។ ២. ទៅទទួលពលករដែលកំពុងធ្វើចត្តាឡីស័កនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជាថៃមកកាន់ខេត្តកំពត។ ៣.រៀបចំមណ្ឌលសម្រាកព្យាបាល និងចត្តាឡីស័កបន្ទាន់សម្រាប់ទទួលពលករមកពីបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃជាបន្តបន្ទាប់ទៀត ។

លោកអភិបាលខេត្តបានបញ្ជាក់ថា នាដំណាក់កាលចុងក្រោយនេះ លទ្ធផលនៃការធ្វើតេស្តលើពលករត្រឡប់មកពីប្រទេសថៃ គឺអ្នកផ្ទុកជំងឺកូវីដ១៩ភាគច្រើនជាប្រភេទវីរុសដែលតា។ ដូច្នេះ ដើម្បីទប់ស្កាត់បាននូវការឆ្លងរីករាលដាលនូវជំងឺកូវីដប្រភេទបំប្លែងថ្មី អាជ្ញាធរត្រូវអនុវត្តតាមសារាចរណែនាំឱ្យបានម៉ឺងម៉ាត់ និងច្បាស់លាស់បំផុត។ និយាយរួម ពេលបញ្ជូនពលករមកដល់គឺអ្នករស់នៅក្រុងស្រុកណា រដ្ឋបាលក្រុងស្រុកនោះជាអ្នកទទួលខុសត្រូវ ទាំងមណ្ឌលព្យាបាល និងកន្លែងធ្វើចត្តាឡីស័ក។ ជាជំហានបឋម រដ្ឋបាលខេត្តបានត្រៀមមណ្ឌលព្យាបាលដែលមានគ្រែប្រមាណជិតបួនពាន់៕

## អាជ្ញាធរខេត្តបាត់ដំបង ត្រៀមទីតាំងជាង៤០កន្លែង សម្រាប់ទទួលពលករខ្មែរមកពីថៃ

https://cen.com.kh/ Posted ByPen Srey NeatAugust 9, 2021

បាត់ដំបង ៖ អាជ្ញាធរខេត្តបាត់ ដំបងបានត្រៀមទីតាំងជាង ៤០កន្លែង សម្រាប់ធ្វើជាមណ្ឌលចត្តាឡីស័កទទួលពលករខ្មែរមកពីថៃ ក្រោយពីរាជរដ្ឋាភិបាល បានប្រកាសបើកច្រកព្រំដែនជាមួយភាគីថៃឡើងវិញ ក្នុងពេលឆាប់ៗខាងមុខនេះ ។

ក្នុងកិច្ចប្រជុំស្តីពី ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩ ក្នុងខេត្តបាត់ដំបង និងបញ្ហាប្រឈម តាមរយៈប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី៩ ខែ សីហា ឆ្នាំ ២០២១ ឯកឧត្តម ងួន រតនៈ អភិបាល ខេត្តបាត់ដំបងបានថ្លែងថា រដ្ឋបាលខេត្តបានរៀបចំផែនការត្រៀមទីតាំងចំនួន ៤១ កន្លែង ដើម្បីធ្វើជាមណ្ឌលចត្តាឡីស័កទទួលពលករមកពីប្រទេសថៃ ព្រមទាំងត្រៀមនូវក្រុមគ្រូពេទ្យសម្រាប់ការធ្វើតេស្តរហ័ស និងកងកម្លាំងប្រចាំការការពារទីតាំងមណ្ឌល ដោយសារតែពលករដែលនឹងចូលមក គឺត្រូវបានចាត់ទុកថាជាអ្នកដែលនឹងផ្ទុកនូវវីរុសកូវីដប្រភេទ Delta» ។

ឯកឧត្តមអភិបាលខេត្ត ក៏បានបញ្ជាក់អំពីការពង្រឹងកងកម្លាំងមានសមត្ថកិច្ចឈរ ជើងតាមខ្សែបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រខេត្តមិនឱ្យពលករ ឬប្រជាជនលួចចេញចូលបាន ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ ឯកឧត្តម ងួន រតនៈបានឱ្យដឹងទៀតថា ក្នុងអំឡុងពេលដែលខេត្តបាត់ដំបង បិទខ្ទប់រយៈពេល១៤ថ្ងៃនេះ មានបងប្អូនពលករខ្មែរ ដែលជាប់គាំងនៅទល់ដែនសរុប ២៤៥ នាក់ (ក្នុងនោះខេត្តច័ន្ទបូរី ២៣៤នាក់ និង

ខេត្តស្រះកែវ ១១នាក់)។ បច្ចុប្បន្ននេះ ខេត្តបាត់ដំបង មានមណ្ឌលចត្តាឡីស័កសរុបចំនួន ២០មណ្ឌល នៅតាមបណ្តាក្រុងស្រុកទាំង១៤ និងមានអ្នកចូលធ្វើចត្តាឡីស័កសរុបចំនួន ៣៧ ៦៥០នាក់ បញ្ចប់ចំនួន ៣៥ ៧៤៥នាក់ និងសល់កំពុងធ្វើចត្តាឡីស័កសរុប ១ ៩០៥នាក់៕ រក្សាសិទ្ធិដោយៈCEN

## ពលករខ្មែរ៤២នាក់ មានទាំងកូនក្មេងផង ដែលកំពុងជាប់នៅព្រំដែនកម្ពុជា-ថៃ ទទួលស្បៀងអាហារ និងសម្ភារៈ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៩ សីហា ២០២១ដោយ Kang Tola

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានឲ្យដឹងនៅរសៀលថ្ងៃទី០៩ ខែសីហា នេះថា ថ្ងៃនេះក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តសាកែវ នៃព្រះរាជាណាចក្រថៃ បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធថៃ ខេត្តសុរិន្ទ ចុះជួបសួរសុខទុក្ខ និងនាំយកអំណោយមួយចំនួនចែកជូនពលករខ្មែរ ដែលកំពុងជាប់នៅស្រុកកាបធឹង ខេត្តសុរិន្ទ ព្រំដែនកម្ពុជា-ថៃ សំរាប់ប្រើប្រាស់ និងទទួលទានជាបណ្តោះអាសន្ន ក្នុងរយៈពេលរង់ចាំវិលត្រឡប់មកកម្ពុជាវិញ។ បើតាមលោក កុយ គួង ស្បៀងអាហារ និងសម្ភារៈប្រើប្រាស់ទាំងនោះ មានដូចជា អង្ករ មីកញ្ចប់ ត្រីខកំប៉ុង ពងមាន់ ទឹកដោះគោ ទឹកសុទ្ធ នំកញ្ចប់ ផ្លែឈើ ម៉ាស់ ដែល អាកុល សាប៊ូបោកខោអាវ ថ្នាំពេទ្យ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត។

សូមបញ្ជាក់ថា បងប្អូនពលករខ្មែរទាំងនោះមានចំនួន៤២នាក់ (ស្រី១៩នាក់) និងកូនក្មេង០៣នាក់ ធ្វើដំណើរមកពីតាមបណ្តាខេត្ត-ក្រុងផ្សេងៗ នៃប្រទេសថៃ ដើម្បីវិលត្រឡប់ទៅកម្ពុជាវិញ ហើយបច្ចុប្បន្នពួកគាត់កំពុងជាប់ និងស្នាក់នៅក្បែរព្រំដែនថៃ-កម្ពុជា ស្ថិតក្នុងស្រុកកាបធឹង ខេត្តសុរិន្ទ ទល់មុខនឹងក្រុងសំរោង ខេត្តឧត្តរមានជ័យ៕ *ដោយ ៖ កោះកែវ*

## អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ នាំស្បៀងអាហារចែកជូនពលករខ្មែរជាប់តាមព្រំដែន

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៨ សីហា ២០២១ដោយ Dy Bunnara

កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ ម្សិលមិញ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ បានសហការជាមួយមូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ (Labour Rights Promotion Network Foundation-LPN) និងអាជ្ញាធរពាក់ព័ន្ធថៃ-កម្ពុជា ចុះជួបសួរសុខទុក្ខ និងនាំយកនូវស្បៀងអាហារចែកជូនពលករខ្មែរចំនួន២៤៧នាក់ និងក្មេង២២នាក់ ដែលកំពុងស្នាក់នៅច្រក ព្រំដែនស្រុកតាប្រាយ៉ា ខេត្តសាកែវ។

បើតាមលោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ស្បៀងអាហារទាំងនោះរួមមាន មីកញ្ចប់ ត្រីខកំប៉ុង ទឹកដោះគោសំរាប់កូនក្មេង មើមឆៃថាវ ខ្ទឹមក្រហម ថ្នាំមូស ម៉ាស់ ទឹកអាកុលលាងដៃ ថ្នាំពេទ្យ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត ព្រមទាំងបាយចំនួន២៥០ ប្រអប់ សំរាប់ប្រើប្រាស់ និងទទួលទានជាបណ្តោះអាសន្ន ក្នុងរយៈពេលរង់ចាំវិលត្រឡប់ទៅកម្ពុជាវិញ។

លោកបញ្ជាក់ថា ពេលនេះ ពួកគេកំពុងស្នាក់នៅច្រកព្រំដែនស្រុកតាប្រាយ៉ា ខេត្តសាកែវ ទល់មុខនឹងច្រកតំបន់បឹងត្រកួន ខេត្តបន្ទាយមានជ័យ រង់ចាំវិលត្រឡប់មកប្រទេសកម្ពុជាវិញ៕ អត្ថបទ៖ កោះកែវ

## អគ្គកុងស៊ុលកម្ពុជា នាំយកស្បៀងអាហារចែកជូនពលករខ្មែរ១៨៥នាក់ ដែលកំពុងជាប់ នៅខេត្តចាន់ថាបុរី

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៧ សីហា ២០២១ដោយ Sorn Phanith

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងនៅថ្ងៃទី០៧ ខែសីហានេះថា កាលពីនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០២១ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ សហការជាមួយមូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករ (Labour Rights Promotion Network Foundation-LPN) និងអាជ្ញាធរពាក់ព័ន្ធខេត្តចាន់ថាក់បុរី បានចុះជួបសួរសុខទុក្ខ និងនាំយកនូវស្បៀងអាហារមួយចំនួន ទៅចែកជូនពលករខ្មែរ ចំនួន១៨៥នាក់ និងកូនក្មេង០៧នាក់ ដែលធ្វើដំណើរមកពីបណ្តាលខេត្តផ្សេងៗ និងទីក្រុងបាងកក មានបំណងវិលត្រឡប់ទៅកម្ពុជាវិញ ហើយ បច្ចុប្បន្នពួកគាត់កំពុងជាប់ និងស្នាក់នៅក្នុងខេត្តចាន់ថាបុរី។ បើតាមលោក កុយ គួង ស្បៀងអាហារទាំងនោះ មានដូចជា អង្ករ មីកញ្ចប់ ទឹកត្រី ទឹកស៊ីអីវ ត្រីខកំប៉ុង មើមឆៃថាវ ប៉េងបោះ ខ្ទឹមបារាំង ពងមាន់ ទឹកដោះគោ ទឹកសុទ្ធ ម៉ាស់ ដែល ទឹកអាកុលលាងដៃ និងសម្ភារៈប្រើ ប្រាស់មួយចំនួនទៀត។ លោកបញ្ជាក់ថា ពលករខ្មែរទាំងអស់ខាងលើ ត្រូវបានអាជ្ញាធរថៃ ផ្តល់កន្លែងអោយស្នាក់នៅសមរម្យ និងអាហារបីពេល ក្នុងមួយថ្ងៃ និងមានសុខភាពល្អជាធម្មតា។

សូមបញ្ជាក់ថា កាលពីនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃ ក៏បានចុះសួរសុខទុក្ខ និងនាំយកនូវស្បៀងអាហារមួយចំនួន មានដូចជា មីកញ្ចប់ ពងមាន់ ទឹកដោះគោ សាប៊ូបោកខោអាវ សំលៀកបំពាក់ និងប៉ាតង់ និងបាយចំនួន២៥០ ប្រអប់ ផ្តល់ជូនដល់បងប្អូនពលករខ្មែរចំនួន ២៤៥នាក់ ដែលធ្វើដំណើរមកពីបណ្តាខេត្ត នានា និងទីក្រុងបាងកក ប្រទេសថៃ មានបំណងវិលត្រឡប់ទៅកម្ពុជាវិញផងដែរ៕

# ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១

## អំឡុងពេលបិទខ្ទប់១៤ថ្ងៃ ខេត្តបាត់ដំបងមានពលករខ្មែរជាប់គាំងនៅទល់ដែនជិត២៥០នាក់

https://kohsantepheapdaily.com.kh/ ០៩ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ២០:០០

ខេត្តបាត់ដំបង ៖ អាជ្ញាធរខេត្តបាត់ដំបង បានត្រៀមទីតាំងជាង ៤០កន្លែង សម្រាប់ធ្វើជាមណ្ឌលចត្តាឡីស័ក ទទួលពលករខ្មែរមកពីថៃ ក្រោយពីរាជរដ្ឋាភិបាលបានប្រកាសបើកច្រកព្រំដែនជាមួយភាគីថៃឡើងវិញ ក្នុងពេលឆាប់ៗខាងមុខនេះ ។

ព្រឹកថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ លោក អ៊ុយ រី ប្រធានក្រុមប្រឹក្សាខេត្ត លោក ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង បានអញ្ជើញចូលរួម ក្នុងកិច្ចប្រជុំ បច្ចុប្បន្នភាព ស្ថានភាពជំងឺកូវីដ-១៩ ជាពិសេស វីរុសបំលែងថ្មី Delta នៅខេត្តបាត់ដំបង ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះជួយមូលដ្ឋានខេត្តបាត់ដំបង តាមរយៈប្រព័ន្ធបញ្ជូនសម្លេង និងរូបភាព (Zoom) ។ កិច្ចប្រជុំនេះ លោក ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង បានថ្លែងថា រដ្ឋបាលខេត្ត បានរៀបចំផែន ការត្រៀមទីតាំងចំនួន ៤១កន្លែង ដើម្បីធ្វើជាមណ្ឌលចត្តាឡីស័កសម្រាប់ទទួលពលករមកពីប្រទេសថៃ ព្រមទាំងត្រៀមនូវ ក្រុមគ្រូពេទ្យសម្រាប់ការធ្វើតេស្តរហ័ស និងកងកម្លាំងប្រចាំការការពារទីតាំងមណ្ឌល ដោយសារតែពលករដែលនឹងចូលមក គឺត្រូវបានចាត់ទុកថា ជាអ្នកដែលនឹងផ្ទុកនូវវីរុសកូវីដប្រភេទ Delta ។ លោកអភិបាលខេត្ត ក៏បានបញ្ជាក់ថា ក្នុងអំឡុងពេលដែលខេត្តបាត់ដំបងបិទខ្ទប់រយៈពេល១៤ថ្ងៃនេះ មានបងប្អូនពលករខ្មែរ ដែលជាប់គាំងនៅទល់ដែនសរុប ២៤៥នាក់ (ក្នុងនោះខេត្តច័ន្ទបូរី ២៣៤នាក់ និងខេត្តស្រះកែវ ១១នាក់) ៕

## ពលករខ្មែរ លបឆ្លងដែនខុសច្បាប់១០នាក់ ត្រូវស្ទាក់ចាប់បាន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១០ សីហា ២០២១ដោយ Sorn Phanith

ពលករខ្មែរចំនួន៥នាក់ ត្រូវបានក្រុមទាហានថៃចាប់ខ្លួន និង ៥ នាក់ទៀត ដែលប្រឹងរត់ឆ្លងអូរព្រំដែនចូលមកកម្ពុជាវិញ ក៏ត្រូវបាននគរបាលវរៈព្រំដែនកម្ពុជាឃាត់ខ្លួនបានដែរ ខណៈដែលពួកគេលបឆ្លងដែនចូលទឹកដីដើម្បីរកការងារធ្វើដោយខុសច្បាប់។ ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ៥ ឃុំណងតាខុង ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី ប្រទេសថៃ។ នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន១០នាក់ បានលបឆ្លងអូរព្រំដែនចូលទៅក្នុងទឹកដីថៃ ស្របពេលដែលកម្លាំងទាហានថៃកំពុងល្បាត ក៏បានស្ទាក់ចាប់បាន៥នាក់ (ប្រុស១ ស្រី៤) ដោយឡែកពលករ៥នាក់ទៀត បានរត់ឆ្លងដែនត្រឡប់ចូលមកកម្ពុជាវិញហើយក៏ត្រូវកម្លាំងវរៈការពារព្រំដែនកម្ពុជាឃាត់ខ្លួនបាននៅវេលាម៉ោង១១ ថ្ងៃត្រង់ នាថ្ងៃដដែលផងដែរដោយសារតែបច្ចុប្បន្នខេត្តជាប់ព្រំដែនថៃទាំងអស់កំពុងត្រូវបានបិទខ្ទប់នៅឡើយ៕

## ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ជួបពលករខ្មែរ មុនធ្វើដំណើរមកកម្ពុជាវិញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានជួបសួរសុខទុក្ខ និង នាំយកអំណោយមួយចំនួន ជូនដល់ពលករខ្មែរ៤២នាក់ និងកូនក្មេង០៣នាក់ ដែលធ្វើដំណើរមកពីតាមបណ្តាខេត្ត-ក្រុងផ្សេងៗ នៃប្រទេសថៃ ដើម្បីវិលត្រឡប់ទៅកម្ពុជាវិញ។ បច្ចុប្បន្នពួកគាត់កំពុងជាប់ និង ស្នាក់នៅក្បែរព្រំដែនថៃកម្ពុជា ស្ថិតក្នុងស្រុកកាបធឹង ខេត្តសុរិន្ទ ទល់មុខនឹងក្រុងសំរោង ខេត្តឧត្តរមានជ័យ។

យោងតាមក្រសួងការបរទេសកម្ពុជា«នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២១ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ នៃព្រះរាជាណាចក្រថៃ បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធថៃ ខេត្តសុរិន្ទ ចុះជួបសួរសុខទុក្ខនិងនាំយកអំណោយមួយចំនួន មានដូចជា អង្ករ មីកញ្ចប់ ត្រីខកំប៉ុង ពងមាន់ ទឹកដោះគោ ទឹកសុទ្ធ នំកញ្ចប់ ផ្លែឈើ ម៉ាស់ ដែល អាកុល សាប៊ូបោកខោអាវ ថ្នាំពេទ្យ និងសម្ភារ:ប្រើប្រាស់ផ្សេងៗទៀត ទៅផ្តល់ជូនដល់បងប្អូនពលករខ្មែរចំនួន៤២នាក់ (ស្រី១៩នាក់) និងកូនក្មេង០៣នាក់ ដែលធ្វើដំណើរមកពីតាមបណ្តាខេត្ត-ក្រុងផ្សេងៗនៃ ប្រទេសថៃ ដើម្បីវិលត្រឡប់ទៅកម្ពុជាវិញ ហើយបច្ចុប្បន្នពួកគាត់កំពុងជាប់និងស្នាក់នៅក្បែរព្រំដែនថៃ-កម្ពុជា ស្ថិតក្នុងស្រុកកាបធឹង ខេត្តសុរិន្ទ ទល់មុខនឹងក្រុងសំរោង ខេត្តឧត្តរមានជ័យ សំរាប់ប្រើប្រាស់និងទទួលទានជាបណ្តោះអាសន្ន ក្នុងរយ:ពេលរង់ចាំវិលត្រឡប់មកកម្ពុជាវិញ»។

បន្ទាប់ពីបិទព្រំដែនជាប់ជាមួយប្រទេសថៃ ដើម្បីទប់ស្កាត់ការចម្លងដែលតា កាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០២១នេះ សម្តេចតេជោ ហ៊ុន សែន បានណែនាំដល់អភិបាលខេត្តជាប់ព្រំដែនថៃទាំងអស់ ឱ្យផ្ទេរពលករខ្មែរដែលកំពុងធ្វើចត្តាឡីស័ក នៅតាមព្រំដែន ចូលមកបន្តធ្វើចត្តាឡីស័ក នៅតាមបណ្តារាជធានី-ខេត្ត ដែលជាមូលដ្ឋានរបស់ពួកគេ ដើម្បីទុកទីតាំងចត្តាឡីស័កនៅព្រំដែន សម្រាប់ទទួលពលករថ្មីទៀត៕

## ពលករជាសះស្បើយពីជំងឺកូវីដ ជាង១០០នាក់ នៅស្រុកអន្លង់វែង ត្រូវគ្រូពេទ្យឲ្យត្រឡប់ទៅស្រុកកំណើតវិញ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១០ សីហា ២០២១ដោយ Sorn Phanith

ពលករឆ្លងដែនមកពីប្រទេសថៃ ដែលឆ្លងកូវីដ១៩ ជាង១០០នាក់ នៅស្រុកអន្លង់វែង ត្រូវបានឲ្យត្រឡប់ទៅលំនៅឋានវិញ កាលពីម្សិលមិញនេះ ក្រោយពីជាសះស្បើយ។ នៅវេលាម៉ោង ២០និង០០នាទី ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ នៅមណ្ឌលព្យាបាលជំងឺកូវីដ១៩ នៅសាលាវិទ្យាល័យអន្លង់វែង ពលករបានជាសះស្បើយពីជំងឺកូវីដ១៩ ចេញទៅតាមបណ្តាខេត្ត ចំនួន ១០២ នាក់ ស្រី ៤៤ នាក់មានដូចជា៖

១. ឧត្តរមានជ័យ ចំនួន ១៣ នាក់ ស្រី ០៤ នាក់។
២. សៀមរាប ចំនួន ១៧ នាក់ ស្រី ០៧ នាក់។
៣. បន្ទាយមានជ័យ ចំនួន ២២ នាក់ ស្រី ០៨ នាក់ ។
៤. បាត់ដំបង ចំនួន ១៧ នាក់ ស្រី ០៦ នាក់ ។
៥. ពោធិ៍សាត់ ចំនួន ០១នាក់ប្រុស។
៦. កំពង់ឆ្នាំង ចំនួន ០១ នាក់ប្រុស ។
៧. កណ្ដាល ចំនួន ០១នាក់ ប្រុស ។
៨. តាកែវ ចំនួន ០៤នាក់ស្រី ០១នាក
៩. កំពត ចំនួន ០៤ នាក់ ស្រី ០២ នាក់ ។
១០. ក្រចេះ ចំនួន ០១ នាក់ស្រី ។
១១. ព្រៃវែង ចំនួន ០៩ នាក់ ស្រី ០៦ នាក់ ។
១២. កំពង់ធំ ចំនួន ០៦ នាក់ ស្រី ០៣ នាក់ ។
១៣. ស្វាយរៀង ចំនួន ០២ នាក់ស្រី។
១៤. ត្បូងឃ្មុំ ចំនួន ០៤ នាក់ស្រី ។

បច្ចុប្បន្ន អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមណ្ឌលព្យាបាលស្រុកអន្លង់វែង ចំនួនបីកន្លែងសរុបចំនួន ៤៥២នាក់ ស្រីចំនួន ២១៦នាក់៕

## ពលករខ្មែរជាង២០នាក់ ចាញ់បោកមេខ្យល់ ដឹកមកទម្លាក់ចោលនៅព្រំដែន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១០ សីហា ២០២១ដោយ Sorn Phanith

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឲ្យដឹងនៅព្រឹកថ្ងៃទី១០ ខែសីហា មុននេះបន្តិចថា កាលពីវេលាម៉ោងប្រមាណ៨ និង៣០ នាទីយប់ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ បានទទួលព័ត៌មានពីអាជ្ញាធរថៃ នៅស្រុកតាប្រាយ៉ា ខេត្តសាកែវថា មានពលករខ្មែរប្រមាណ២០នាក់ត្រូវបានចាញ់បោកមេខ្យល់ ដឹកមកទម្លាក់ចោលនៅពីរកន្លែងផ្សេងគ្នា។ បើតាមលោក កុយ គួង ក្រោយពីទទួលបានព័ត៌មាននេះ ក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលបានចុះទៅសហការជាមួយអាជ្ញាធរពាក់ព័ន្ធថៃ និងកម្ពុជា ដើម្បីសម្របសម្រួល និងបញ្ជូនពលករខ្មែរទាំង២០នាក់ (ប្រុស០៧នាក់-ស្រី១៣នាក់ និងកូនក្មេង០៣នាក់) យកទៅដាក់នៅទីតាំងមាត់ច្រកព្រំដែនស្រុកតាប្រាយ៉ា (ខេត្តសាកែវ) បឹងត្រកួន (ខេត្តបន្ទាយមានជ័យ) ដើម្បីងាយស្រួលដល់អាជ្ញាធរថៃ-កម្ពុជា ក្នុងការគ្រប់គ្រង និងផ្តល់ទីជម្រកសុវត្ថិភាពជូនពួកគាត់។ ជាមួយគ្នានេះ ក្រុមការងារបានយកស្បៀងអាហារ មានដូចជា មីកញ្ចប់ ទឹកសុទ្ធ និងម៉ាស ផ្តល់ជូនពួកគាត់ទាំងអស់ខាងលើសំរាប់ប្រើប្រាស់ និងទទួលទាន និងស្នាក់នៅបណ្តោះអាសន្នរង់ចាំវិលត្រឡប់ទៅកម្ពុជាវិញ៕ **កោះកែវ**

## ពលករមួយចំនួនជាប់តាមព្រំដែន ក្រោយរាជរដ្ឋាភិបាលបិទព្រំដែន, ឧត្តមសេនីយ៍ទោ សេខ ធារិន សុំការយោគយល់ពីប្រជាពលរដ្ឋចំពោះការលំបាកនេះ

http://freshnewsasia.com/ 2021-08-10 05:26pm

**(បន្ទាយមានជ័យ)៖** បើទោះបីរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិទព្រំដែនរវាងកម្ពុជា ជាមួយថៃយ៉ាងណាក្តី តែប្រជាពលករខ្មែរមួយចំនួននៅតែបន្តចាកចេញកន្លែងរស់នៅក្នុងប្រទេសថៃ ដើម្បីចូលមកក្នុងប្រទេសកម្ពុ

ជាវិញ។ ការបង្វិចិត្តចាកចេញពីប្រទេសថៃមកកាន់កម្ពុជាវិញនេះ បានធ្វើឱ្យពលករមួយចំនួនជាប់នៅតាមព្រំដែន មិនអាចចូលមកក្នុងប្រទេសកម្ពុជាបាននោះឡើយ។ រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២៨ ខែកក្កដា កន្លងទៅនេះ បានសម្រេចបិទច្រកព្រំដែនរវាងកម្ពុជា និងប្រទេសថៃ រយៈពេលពីរសប្តាហ៍ ដោយមិនអនុញ្ញាតឱ្យធ្វើដំណើរឆ្លង កាត់នោះឡើយ លើកលែងតែការដឹកជញ្ជូនទំនិញ និងករណីពិសេសប៉ុណ្ណោះ។ ការសម្រេចបែបនេះ ដើម្បីទប់ស្កាត់ការរីករាលដំងឺកូវីដ១៩ ជាពិសេសមេរោគបំប្លែងថ្មី «ដែលតា-Delta» ដែលឆ្លងតាមរយៈពលករត្រឡប់មកពីប្រទេសថៃនោះ។ បើទោះបីមានការសម្រេចបែបនេះយ៉ាងណាក្តី ក៏នៅតែមានពលករមួយចំនួនធ្វើដំណើរចាកចេញពីកន្លែងស្នាក់នៅក្នុងប្រទេសថៃ ក្នុងបំណងចូលមកប្រទេសកម្ពុជាវិញ។ ដោយសារតែវិធានការបិទច្រកព្រំដែន បានធ្វើឱ្យពលករមួយចំនួនត្រូវជាប់នៅតាមព្រំដែននៅខាងដីថៃ។

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១នេះ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ បានចុះសួរសុខទុក្ខពលករខ្មែរ ដែលកំពុងសម្រាកនៅតាមព្រំដែននោះ។ លោកឧត្តមសេនីយ៍ទោ បានការយោគយល់ និងអធ្យាស្រ័យពីសំណាក់ប្រជាពលករខ្មែរ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នជិតបន្ទាត់ព្រំដែននោះ។ លោកបានបញ្ជាក់ថា វិធានការបិទព្រំដែនដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ជាពិសេសមេរោគបំប្លែងថ្មី «ដែលតា» ចូលទៅក្នុងសហគមន៍ ដែលនឹងបង្កមហន្តរាយធ្ងន់ធ្ងរក្នុងសហគមន៍។ លោកឧត្តមសេនីយ៍ទោ បានបញ្ជាក់ដែរថា រាជរដ្ឋាភិបាល ក៏ដូចជាកងកម្លាំង និងអាជ្ញាធរមូលដ្ឋាន បានរួមគ្នាគិតគូរ ហើយមិនទុកឱ្យពលករកំពុងស្នាក់នៅតាមព្រំដែននោះឯកោឡើយ។ លោកឧត្តមសេនីយ៍ទោ សេង ធារិន បានផ្តាំផ្ញើទៅពលករកំពុងជាប់តាមព្រំដែនថា ក្នុងករណីមានបញ្ហាសុខភាព ឬបញ្ហាផ្សេងៗ ត្រូវរាយការណ៍ជូនទៅកងកម្លាំងដែលនៅជិតបំផុត ដើម្បីឱ្យកងកម្លាំងរាយការណ៍ជូនទៅអាជ្ញាធរជួយដោះស្រាយ៕

## អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់-CENTRAL) សហការជាមួយអាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ 10/08/2021

ខេត្តកំពង់ធំ៖ កាលថ្ងៃច័ន្ទទី០៩ និងថ្ងៃអង្គារ៍ ទី១០ ខែសីហា ឆ្នាំ២០២១នេះអង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់-CENTRAL)សហការជាមួយអាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅតាមសាលាឃុំចំនួន៥ ដែលស្ថិតនៅក្នុងឃុំសាគ្រាម ឃុំក្រយា ឃុំផាន់ញើម ឃុំដូង ឃុំសាមគ្គី នៃស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។ ដោយស្ថានភាពកូវីដ-១៩បានកំពុងរីករាលដាលទូទាំងពិភពលោករួមទាំងប្រទេសកម្ពុជាផងដែរ ដែលជាហេតុធ្វើអោយប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជាប្រឈមនឹងបញ្ហាផ្សេងៗ រួមមានការចាញ់បោកខ្យល់ ការឆ្លងដែនដោយប្រថុយប្រថាននឹងគ្រោះថ្នាក់ និងប្រឈមពីការចាប់ខ្លួនពីសំណាក់អាជ្ញាធរថៃ។ ទើបអង្គការសង់ត្រាល់ចូលរួមផ្សព្វផ្សាយលើកបដា ក្នុងគោលបំណងខាងក្រោម៖

១.លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធិការងារគ្រប់រូបភាព។

២.កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈមគ្រោះថ្នាក់ នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗ។

៣.លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

អង្គការសង់ត្រាល់នឹងបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានតាមបណ្តាឃុំស្រុកខេត្តដទៃទៀត ដើម្បីផ្សព្វផ្សាយអប់រំពីសិទ្ធិការងារ ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិផ្សេងៗដែលពលរដ្ឋកម្ពុជាគួរយល់ដឹង។

## ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

### កំពង់ឆ្នាំងត្រៀមមណ្ឌលចត្តាឡីស័កចំនួន១១កន្លែង សម្រាប់ពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១០ សីហា ២០២១ដោយ Kang Tola

កំពង់ឆ្នាំង ៖ ខេត្តកំពង់ឆ្នាំង បានត្រៀមទីតាំងចំនួន១១កន្លែង នៅក្នុងក្រុងស្រុកទាំង៨ ដើម្បីរៀបចំជាមណ្ឌលចត្តាឡីស័ក សម្រាប់ពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក។ នេះបើតាមការបញ្ជាក់របស់លោក អម សុភា អភិបាលរងខេត្តកំពង់ឆ្នាំង នៅរសៀលថ្ងៃទី១០ ខែសីហា នេះ។

លោក អម សុភា អភិបាលរង បានបញ្ជាក់ទៀតថា ក្រៅពីរៀបចំជាមណ្ឌលចត្តាឡីស័ក នៅទូទាំងខេត្តកំពង់ឆ្នាំង មានក៏រៀបចំមណ្ឌលព្យាបាលចំនួន៦កន្លែងផងដែរ។ ជាមួយគ្នានេះ នៅក្នុងកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំមណ្ឌលចត្តាឡីស័កនិងមណ្ឌលព្យាបាលតាមរាជធានីខេត្ត ដើម្បីទទួលពលករខ្មែរមកពីប្រទេសថៃ ដល់អាជ្ញាធរក្រុងស្រុក ឃុំសង្កាត់ និង មន្ទីរអង្គភាពជុំវិញខេត្ត តាមប្រព័ន្ធវីដេអូ zoom កាលពីព្រឹកថ្ងៃទី១០ ខែសីហានេះ លោក ស៊ុន សុវណ្ណារិទ្ធិ អភិបាលខេត្តកំពង់ឆ្នាំង ក៏ជំរុញដល់អាជ្ញាធរក្រុងស្រុកឃុំសង្កាត់ទាំងអស់ ត្រូវរៀបចំ គ្រែ ប្រព័ន្ធទឹក ប្រព័ន្ធអគ្គិសនី បន្ទប់ទឹកនៅតាមមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាល នីមួយៗ ដើម្បីត្រៀមឲ្យបានរួចជាស្រេច សម្រាប់ពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក ចូលក្នុងមូលដ្ឋានវិល។

គួរបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា កាលពីថ្ងៃទី០៦ ខែសីហា បានសារាចរ ស្តីពីការរៀបចំមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលនៅតាមបណ្តារាជធានី-ខេត្ត ដើម្បីទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក។ ជាមួយគ្នានោះ សម្តេចតេជោ ហ៊ុន សែន ក៏បានណែនាំ ឲ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីខេត្ត ត្រូវផ្តល់ការគាំទ្រឲ្យបានពេញទំហឹង តាមគ្រប់មធ្យោបាយ ជាពិសេសផ្នែកសម្ភារ និងថវិកា ដើម្បីជួយដល់បណ្តារាជធានី ខេត្ត ក្នុងការគ្រប់គ្រង និង ទទួលយកពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃវិញ សម្រាប់ការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺ កូវីដ-១៩ ព្រមទាំងយកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលមានការពាក់ព័ន្ធនឹងជំងឺ កូវីដ-១៩៕ *អត្ថបទ ៖ ពុធិកា*

### លោក ហ៊ុន ម៉ាណែត ចុះពិនិត្យវឌ្ឍនភាពការរៀបចំមណ្ឌលព្យាបាលជំងឺកូវីដ១៩ កម្រិតស្រាល នៅក្រុងសំរោង និងមណ្ឌលធ្វើចត្តាឡីស័ក នៅស្រុកអន្លង់វែង សម្រាប់ទទួលពលករមកពីថៃ

http://freshnewsasia.com/ 2021-08-10 06:38pm

**(ឧត្តរមានជ័យ)៖** លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក និងលោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១នេះ បានដឹកនាំ

ក្រុមការងារចុះពិនិត្យមើលវឌ្ឍនភាព នៃការរៀបចំមណ្ឌលព្យាបាលជំងឺកូវីដ១៩ កម្រិតស្រាលក្នុងក្រុងសំរោង និង បន្តចុះពិនិត្យមើលការរៀបចំមណ្ឌលធ្វើចត្តាឡីស័ក នៅស្រុកអន្លង់វែង សម្រាប់ទទួលពលករមកពីប្រទេសថៃ។

សូមបញ្ជាក់ថា ការចុះពិនិត្យមើលវឌ្ឍនភាពការរៀបចំមណ្ឌលព្យាបាលជំងឺកូវីដ១៩ កម្រិតស្រាលនៅក្រុងសំរោង និងមណ្ឌលធ្វើចត្តាឡីស័ក នៅស្រុកអន្លង់វែង គឺសម្រាប់ទទួលពលករ ដែលវិលត្រឡប់មកពីប្រទេសថៃ ម្យ៉ាងទៀតមួយរយៈកន្លងមកនេះ អាជ្ញាធរខេត្តឧត្តរមានជ័យ បានរកឃើញពលករដែលមកពីប្រទេសថៃ មានផ្ទុកជំងឺកូវីដ១៩ គួរឱ្យព្រួយបារម្ភ។ ជាមួយគ្នានេះដែរ លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត បានថ្លែងនូវការកោតសរសើរដល់អាជ្ញធរខេត្តឧត្តរមានជ័យ កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ និងមន្ត្រីសុខាភិបាលខេត្ត ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត អនុវត្តន៍បទបញ្ជារបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ បានយ៉ាងល្អប្រសើរ ពិសេសលើការគ្រប់គ្រងមើលថៃ បងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួនជាង៥ពាន់នាក់ ក្នុងនោះករណីនាំចូលពីក្រៅប្រទេសចំនួនជាង ៤ពាន់នាក់ ករណីឆ្លងក្នុងសហគមន៍ចំនួនជិត ១ពាន់នាក់ និងស្លាប់ចំនួន ៩នាក់ផងដែរ៕

## ឧត្តរមានជ័យរាយការណ៍ពីករណីឆ្លងវីរុសបំប្លែងខ្លួនថ្មីសរុបជិត១រយករណី

https://www.khmertimeskh.com/ ខ្មែរថាមស៍ / August 10, 2021

អាជ្ញាធរខេត្តឧត្តរមានជ័យបានរកឃើញករណីឆ្លងវីរុសបំប្លែងខ្លួនថ្មីចំនួន ៩៧ ករណី ពីពលករដែលកំពុងធ្វើចត្តាឡីស័ក មុនពេលបិទព្រំដែន។ អភិបាលខេត្តឧត្តរមានជ័យលោកប៉ែនកុសលបាននិយាយថា នៅពេលពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃវិញ អាជ្ញាធរខេត្តនឹងធ្វើតេស្តរកមេរោគកូវីដ-១៩ និង ដាក់ឲ្យធ្វើចត្តាឡីស័ក។ លោកអភិបាលបានបន្តថា ក្នុងអំឡុងពេលនោះដែរ ការធ្វើតេស្ត ត្រូវបានធ្វើឡើង ២ ទៅ ៣ ដង មុនពេលចេញលទ្ធផល ដូច្នេះក្រុមការងារបានបញ្ជូនសំណាកទៅធ្វើតេស្ត CPR បន្តទៀត។ លទ្ធផលពីការធ្វើតេស្តបន្ថែមនេះបានបង្ហាញថាជនចំណាកស្រុកមួយចំនួនធំបានឆ្លងវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta)ដែលបាននាំឱ្យមានការឆ្លងបន្តទៅមនុស្សផ្សេងទៀតនៅក្នុងមណ្ឌលចត្តាឡីស័ករួមទាំងបុគ្គលិកសុខាភិបាលជួរមុខរហូតដល់ទៅ៩៧ករណី។ ដោយឡែក លោកអភិបាលខេត្តក៏បានជំរុញឱ្យប្រជាពលរដ្ឋក្នុងខេត្តនេះបន្តអនុវត្តតាមវិធានការបង្ការផងដែរ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ឃាត់ខ្លួនពលរដ្ឋ១៧នាក់ បម្រុងឆ្លងដែនចូលកម្ពុជា ប្រគល់ជូនសមត្ថកិច្ចថៃបញ្ជូនទៅជំរកស្នាក់នៅបណ្តោះអាសន្ន

http://cambodiapolice.com/policekh/ 8:05 pm 10 សីហា 2021

ខេត្តបាត់ដំបង៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។

ជាក់ស្តែង នៅយប់ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០២១ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ កម្លាំងប៉ុស្តិ៍ចំការស្រូវគោលដៅទី៣ ចំនួន១១នាក់ ដឹកនាំដោយលោក អនុសេនីយ៍ឯក កៅ បញ្ញា មេបញ្ជាការរង សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី៣ វរសេនាតូចលេខ១ ចំនួន៥នាក់. ដឹកនាំដោយវរ

សេនីយ៍ត្រី អួន សុខឿន មេបញ្ជាការ- គ, កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំបារាំងធ្លាក់ចំនួន៣នាក់ ដឹកដោយលោកអនុសេនីយ៍ឯក ណន ផេង នាយប៉ុស្តិ៍ស្តីទី បានធ្វើចុះប្រតិបត្តិការ ទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនចូលក្នុងប្រទេសកម្ពុជាវិញ ត្រង់ចំណុច ភូមិសាស្ត្រភូមិអូរចោទ ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ចំនួន ១៧ នាក់ (ស្រី៧នាក់, ក្មេង២នាក់)។ បន្ទាប់ពីឃាត់ខ្លួនពួកគាត់ កម្លាំង បានបញ្ជូនបងប្អូន ទាំងអស់ឲ្យកងអនុសេនាធំលេខ ១១១៣ នៃកងវរសេនាធំលេខ១៣ (ភាគីថៃ) ដឹកនាំដោយលោកព្រិន្ទបាលឯក បល្ល័ង ស៊ីវិទ្យ៉ មេបញ្ជាការរងកងអនុសេនាធំលេខ១១១៣ ដើម្បីបញ្ជូនបន្តទៅកាន់ជំរកស្នាក់នៅបណ្ដោះអាសន្ន ក្នុងទឹកដីថៃ ទល់មុខភូមិសាស្ត្រទទួលខុសត្រូវរបស់ប៉ុស្តិ៍ព្រំដែនចក្រី(ភូមិកោះតូច ឃុំអង្គរបាន ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕

## ត្រៀមទីតាំង ១០ កន្លែង សម្រាប់ពលករ មកពីក្រៅប្រទេស និងប្រគល់សាលារៀន ឱ្យសិស្ស

https://www.rasmeinews.com/ 10 August, 2021

**ដោយៈ គង់ហេង / កំពង់ចាមៈ** *រដ្ឋបាលខេត្តកំពង់ចាម បានត្រៀមទីតាំង ចំនួន ១០ កន្លែង សម្រាប់ពលករ ពលការិនី ធ្វើចត្តាឡីស័ក នៅពេលបើកព្រំដែន កម្ពុជា-ថៃ ឡើងវិញ នៅថ្ងៃទី១២ សីហា និងប្រគល់សាលារៀនជូនសិស្សានុសិស្ស ដើម្បីបើកបវេសនកាល នាពេលខាងមុខ។*

នៅក្នុងកិច្ចប្រជុំមួយ នៅព្រឹកថ្ងៃទី១០ សីហា នេះ លោក អ៊ុន ចាន់ដា ជាអភិបាលខេត្តកំពង់ចាម បានមានប្រសាសន៍ នៅក្នុងសាលាខេត្តនេះថាៈ ឥឡូវ យើងបានចាត់វិធានការ ដាក់ឱ្យអ្នកធ្វើចត្តាឡីស័ក ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ សហគមន៍ ២០ កុម្ភៈ ឱ្យធ្វើចត្តាឡីស័ក នៅតាមផ្ទះរៀងៗខ្លួនហើយ គឺដើម្បីជៀសវាង ការរស់នៅសម្រាកព្យាបាល នៅលាយឡំ ជាមួយអ្នកពាក់ព័ន្ធនឹងមេរោគកូវីដ ១៩ បំប្លែងខ្លួនថ្មី «ដែលតា» (DELTA) ។ នេះបើតាមការណែនាំរបស់ក្រសួងសុខាភិបាល ក្រោយពីរកឃើញ អ្នកឆ្លងដែលតា ចំនួន ១២ នាក់ នៅក្នុងខេត្តរបស់យើង។ លោកអភិបាលខេត្តកំពង់ចាម បានថ្លែងថាៈ យើងបានត្រៀមឃ្លាំង របស់មន្ទីរពាណិជ្ជកម្ម ចំនួន បី កន្លែង គឺដើម្បីយកទីនោះជំនួសសាលារៀន ដែលយើងយកធ្វើចត្តាឡីស័ក និងព្យាបាលកម្រិតស្រាលកន្លងមក ហើយប្រគល់សាលារៀនទាំងអស់នោះឱ្យខាងមន្ទីរអប់រំយុវជន និងកីឡា ផ្តល់ឱ្យសិស្សានុសិស្ស បានចូលរៀនឡើងវិញ។

លោកបានបន្តថាៈ ក្នុងនោះ ឃ្លាំងនៅស្រុកកំពង់សៀម សម្រាប់ជំនួសឱ្យ វិទ្យាល័យព្រះសីហនុ គឺផ្ទេរការព្យាបាល ជំងឺកូវីដ ១៩ កម្រិតស្រាល និងអ្នកជំងឺទាំងអស់ ទៅកាន់ទីនោះវិញ ហើយឃ្លាំង នៅក្បែរមន្ទីរពាណិជ្ជកម្មក្នុងក្រុងកំពង់ចាម និងឃ្លាំងមួយទៀត នៅក្បែរសាលាស្រុកកងមាស សម្រាប់ជាកន្លែងពលករ -ពលការិនី ធ្វើចត្តាឡីស័ក។ ដូចនេះ សាលារៀន ចំនួន ១០ កន្លែង កន្លងមក ដែលយកធ្វើការប្រយុទ្ធ ប្រឆាំងជំងឺកូវីដ ១៩ យើងប្រគល់សាលារៀន ឱ្យសិស្សវិញ ដើម្បីត្រៀមលក្ខណៈ បើកសាលារៀនឡើងវិញ ក្នុងឆ្នាំសិក្សាថ្មី ខាងមុខនេះ បន្ទាប់ពីពួកគេ (សិស្ស) ចាក់វ៉ាក់សាំងបង្ការកូវីដ ១៩ រួចរាល់៕/V

## មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ អំពាវនាវ ដល់ពលករខ្មែរដែលកំពុងស្នាក់នៅបណ្ដោះអាសន្នជិតបន្ទាត់ព្រំដែនកម្ពុជា-ថៃ យោគយល់ដល់កងកម្លាំង ដែលកំពុងអនុវត្តវិធានការ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩

http://nokorwatnews.com/ 11/08/2021

ខេត្តបន្ទាយមានជ័យ៖ បើយោងតាមផេកកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ បានបញ្ជាក់ឲ្យដឹងថា, នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ នេះ ឧត្តមសេនីយ៍ទោ សេងជារិន មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ បានអញ្ជើញចុះសួរសុខទុក្ខ ពលករខ្មែរ កំពុងសម្រាកនៅម្ខាងព្រំដែនក្នុងទឹកដីនៃប្រទេសថៃ។

សូមជម្រាប់ជូនថា ក្រោយពីមានបទបញ្ជា បិទខ្ទប់ព្រំដែនកម្ពុជា-ថៃ ពលករខ្មែរដែលបានធ្វើដំណើរ ឆ្លងព្រំដែនត្រូវបានសម្រាកនៅម្ខាងព្រំដែនជាបណ្តោះអាសន្ន ដើម្បីធ្វើចត្តាឡីស័ក នៅក្នុងនោះផងដែរ កងកម្លាំងចម្រុះនៅតាមបន្ទាត់ព្រំដែនបានធ្វើការឃាត់ពលករដែលបានលួចឆ្លងដែនដោយខុសច្បាប់ ឲ្យស្នាក់នៅជាបណ្តោះអាសន្ននៅតាមបន្ទាត់ព្រំដែននៅលើទឹកដីថៃ ដើម្បីការពារការឆ្លងរីករាលដាលជំងឺកូវីដ-១៩ បម្លែងថ្មីដែលតា( Delta ) ចូលក្នុងសហគមន៍ និងក្នុងប្រទេស ដែលជាហានិភ័យសម្រាប់ប្រទេសជាតិទាំងមូល។

ឧត្តមសេនីយ៍ទោ សេង ធារិន បានសុំអង្វរចិត្ត និងការយោគយល់អំពីប្រជាពលករខ្មែរដែលកំពុងស្នាក់នៅបណ្តោះអាសន្នជិតបន្ទាត់ព្រំដែន មេត្តាយោគយល់ កងកម្លាំងទាំងអស់ដែលកំពុងអនុវត្តន៍វិធានការ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺដែរតាចូលក្នុងប្រទេសក៏ដូចជាក្នុងសមាគមន៍ នឹងបានបញ្ជាក់ជូនពួកគាត់ថារាជរដ្ឋាភិបាលក៏ដូចជាកងកម្លាំង និងអាជ្ញាធរមូលដ្ឋានបានរួមគ្នាគិតគូចំពោះសុខទុក្ខបងប្អូន ក្នុងករណីមានបញ្ហាសុខភាព ឬបញ្ហាផ្សេងៗត្រូវរាយការណ៍ជូនទៅកងកម្លាំងដែលនៅជិតបំផុត ដើម្បីឲ្យកងកម្លាំងរាយការណ៍ជូនទៅអាជ្ញាធរមូលដ្ឋាន និងថ្នាក់ដឹកនាំតាមលំដាប់តាមលំដាប់ថ្នាក់៕

## ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ នាំយកគ្រឿងឧបភោគបរិភោគ បន្លែ និងសាច់ ចុះចែកដល់បងប្អូនពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំងដោយសារការរាតត្បាតជំងឺកូវីដ-១៩ នៅក្នុងការដ្ឋានសំណង់ចំនួន ២កន្លែង

http://nokorwatnews.com/ 11/08/2021

**ប្រទេសថៃ** : ស្ថិតនៅក្នុងស្ថានភាពដ៏លំបាក ជាមួយនឹងការឆ្លងរាតត្បាតជំងឺកូវីដ19 នៅប្រទេសថៃ , នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ ដឹកនាំដោយលោក អ៊ុក សោភ័ណ ឯកអគ្គរាជទូត ព្រមទាំងមន្ត្រីការទូត នាំយកគ្រឿងឧបភោគបរិភោគ បន្លែ និងសាច់ ចុះចែកដល់បងប្អូនពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំងដោយសារការរាតត្បាតជំងឺកូវីដ១៩ នៅក្នុងការដ្ឋានសំណង់ចំនួន ២កន្លែង ស្ថិតនៅនៅសយបាងខៈនុន ៦ និងសយបាងខៈនុន ៦/២ ស្រុកបាងក្រួយ ខេត្តនុនថៈបុរី ដោយមានការសហការ និងជួយសម្រួលពីអាជ្ញាធរស្រុក ប៉ូលីស និងអាជ្ញាធរពាក់ព័ន្ធ។

សូមបញ្ជាក់ផងដែរថា, កន្លងមកលោក អ៊ុក សោភ័ណ ឯកអគ្គរាជទូត កម្ពុជាប្រចាំប្រទេសថៃ តែងដឹកនាំក្រុមការងារចុះចែកអំណោយជូនបងប្អូនពលករខ្មែរដែលនៅប្រទេសថៃជាច្រើនកន្លែងផងដែរ។

សូមជម្រាបថា នៅក្នុង សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល នៅថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០២១ រកឃើញ អ្នកឆ្លងថ្មី ៤៩៩នាក់ទៀត ជាសះស្បើយ ៨៨៣នាក់ និងស្លាប់ ១៧នាក់៖

– ករណីឆ្លងសហគមន៍ ៣៧៥នាក់

– អ្នកដំណើរពីបរទេស ១២៥នាក់គិតត្រឹមព្រឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

– អ្នកឆ្លងសរុប= 82,898 នាក់

– អ្នកជាសះស្បើយ= 77,037 នាក់

– អ្នកស្លាប់= 1,602 នាក់ ៕

## មណ្ឌលព្យាបាលកម្រិតស្រាលត្រៀមសម្រាប់បងប្អូនពលករខ្មែរត្រឡប់ពីថៃ

https://kohsantepheapdaily.com.kh/ ១១ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ០៩:២៧

ខេត្តបន្ទាយមានជ័យ ៖ ឯកឧត្តម ហ៊ុន ម៉ាណែត បានអញ្ជើញចុះពិនិត្យមើលមណ្ឌលព្យាបាលកម្រិតស្រាល កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ នៅខេត្តបន្ទាយមានជ័យ ដែលទុកត្រៀមសម្រាប់ទទួលព្យាបាលបងប្អូនជាពលករខ្មែរដែលត្រឡប់ពីថៃ។ ឯកឧត្តមបានបញ្ជាក់ថា នេះជាការខិតខំយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលបញ្ចប់ការបិទខ្ទប់នៅពេលខាងមុខនេះ សម្តេចតេជោ ហ៊ុន សែន បានត្រៀមរថយន្តសម្រាប់ដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋពលករដែលត្រឡប់ពីប្រទេសថៃទៅតាមមណ្ឌលខេត្តស្រុកកំណើតរបស់ខ្លួនដើម្បីធ្វើចត្តាឡីស័ក ហើយខេត្តបន្ទាយមានជ័យបានត្រៀមរួចជាស្រេច ហើយមណ្ឌលព្យាបាលកម្រិតស្រាលចំនួន២មណ្ឌលនៅក្រុងសិរីសោភ័ណ និងស្រុកមង្គលបូរីក្នុង១មណ្ឌលដាក់បានប្រមាណ៣.០០០នាក់ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យបានបញ្ជាក់ថា ខេត្តបន្ទាយមានជ័យមានមណ្ឌលធ្វើចត្តាឡីស័កចំនួន១៩កន្លែង ពេលនេះបង្រួមមកនៅ១៥កន្លែង និងមណ្ឌលព្យាបាលមានចំនួន២០កន្លែង ព្រឹត្តការណ៍២០ កុម្ភៈ ២០២១ កូវីដ.១៩ ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃចូលកម្ពុជាវិញ មានចំនួន៥១.៧១២នាក់ ស្រី ២៣.២១៨នាក់ ដែលត្រូវបានពិនិត្យសុខភាព ដែលត្រូវបានពិនិត្យសុខភាពយកសំណាកធ្វើតេស្ត ៤៧.២២៩នាក់ ស្រី២០.៨៨០នាក់ ហើយត្រូវបានបញ្ជូនចេញ៤៧.៧០០នាក់ ស្រី២១.៤៧៥នាក់ បញ្ចប់ចត្តាឡីស័ករយៈពេល ១៤ថ្ងៃ មានចំនួន៣៥.៣៦៤នាក់ ស្រី១៦.៩៣៣នាក់ និងកំពុងស្នាក់នៅក្នុងមណ្ឌលមានចំនួន៤.០១២នាក់ ស្រី ១.៧៤៣នាក់។

ឯកឧត្តម ហ៊ុន ម៉ាណែត បានបញ្ជាក់ទៀតថា ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រោយពេលសម្រេចការបិទខ្ទប់ភូមិសាស្ត្រ៨ខេត្តជាប់ជាយដែន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃកូវីដ.១៩ប្រភេទដែលតា ត្រូវបានបិទខ្ទប់ជាបណ្តោះអាសន្នសម្រាប់រយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ហើយត្រូវបានបិទព្រំដែនកម្ពុជា.ថៃ ដែលប្រជាពលរដ្ឋខ្មែរជាកម្មករដែលកំពុងជាប់គាំងក្នុងទឹកដីថៃតាមបន្ទាត់ព្រំដែន ។

សូមបញ្ជាក់ថា នៅក្នុងឱកាសដែលចុះពិនិត្យ មានវត្តមានឯកឧត្តម ហ៊ុន ម៉ាណែត អនុប្រធានគណៈប្រតិបត្តិការនៃគណៈកម្មការអន្តរក្រសួងប្រយុទ្ធកូវីដ.១៩ ទទួលបន្ទុកអនុគណៈកម្មការបច្ចេកទេសនិងព្យាបាល ឯកឧត្តម នាយឧត្តមសេនីយ៍ ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិនិងជាប្រធានអនុគណៈកម្មការសាងសង់ បានដឹកនាំប្រតិភូចុះពិនិត្យវឌ្ឍភាពនៃការរៀបចំមណ្ឌលព្យាបាលកម្រិតស្រាល បម្រុងសម្រាប់ព្យាបាលបងប្អូនពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ។

## ពលករចាស់ក្រៅខេត្ត កំពុងស្នាក់នៅព្រំប្រទល់ នៃខេត្តបាត់ដំបង ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅខេត្តសាមី

https://cen.com.kh/ Posted ByPen Srey NeatAugust 11, 2021

បាត់ដំបង ៖ ស្របពេលថ្ងៃត្រូវបើកច្រកទ្វារព្រំដែនឡើងវិញ បន្ទាប់ពីបានធ្វើការបិទខ្ទប់ អស់រយៈពេលជិត ១៤ថ្ងៃកន្លងមក ហើយដើម្បីជួយសម្រួល និងរង់ចាំទទួលពលករថ្មី ដែលត្រូវវិលមកវិញ ក្នុងពេលឆាប់ៗខាងមុខនេះ អាជ្ញាធរខេត្តបាត់ដំបង សហការជាមួយអាជ្ញាធរស្រុកទាំង៣ នៅជាប់ព្រំដែន មានស្រុកកំរៀង ភ្នំព្រឹក និងស្រុកសំពៅលូន រួមនឹងមន្ត្រីសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបង បានធ្វើការពិនិត្យសម្រួលពលករចាស់ ដែល

បានចូលមកធ្វើចត្តាឡីស័ក នៅតាមមណ្ឌលចត្តាឡីស័ក ដើម្បីដឹកជញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័កបន្តនៅខេត្តសាមី ជាបន្តបន្ទាប់ ។

អភិបាលរងខេត្តនិងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង លោក សឿម ប៊ុនរិទ្ធិ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១នេះ បានប្រាប់ឱ្យដឹងថា ពលករចាស់ក្រៅខេត្ត ដែលបាននិងកំពុងស្នាក់នៅធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័ក នៅស្រុកជាប់ព្រំដែនក្នុងភូមិសាស្ត្រនៃខេត្តបាត់ដំបង កំពុងតែដឹកជញ្ជូនបន្តទៅខេត្តសាមីហើយ។ លោកបានបញ្ជាក់ថា ខេត្តបាត់ដំបង បានបញ្ជូនពលករចាស់មានទីលំនៅរស់នៅក្រៅខេត្ត ដែលត្រូវបន្តការធ្វើចត្តាឡីស័ក រយៈពេល៧ថ្ងៃទៀត ក្រោយពីធ្វើចត្តាឡីស័កអស់រយៈពេល១៤ថ្ងៃ ពលករទាំងនោះធ្វើការដឹកជញ្ជូនទៅខេត្តសាមី បានចំនួនសរុប៤៩នាក់ហើយ និងនៅសល់ពលករក្រៅខេត្តកំពុងនៅក្នុងមណ្ឌលមានចំនួន១០៤នាក់ និងពលករ ដែលមានទីលំនៅក្នុងខេត្តបាត់ដំបងផ្ទាល់មានចំនួន៦៣៥នាក់ ។ លោក សឿម ប៊ុនរិទ្ធិ បានបញ្ជាក់ទៀតថា ពលករដែលកំពុងស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័ក គឺជាពលករមិនទាន់គ្រប់រយៈពេលធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃ និងថែមរយៈពេល៧ថ្ងៃទៀត សរុបរយៈពេលនៃការធ្វើចត្តាឡីស័កចំនួន២១ថ្ងៃ លើកលែងតែពលករក្រៅខេត្តពេលគ្រប់រយៈពេល១៤ថ្ងៃ យកសំណាកផ្ញើទៅភ្នំពេញ បើបានលទ្ធផលអវិជ្ជមាន និងធ្វើតេស្តរហ័ស មុនឡើងរថយន្តកងទ័ព លទ្ធផលអវិជ្ជមានទៀតទើបបញ្ជូនទៅកាន់គោលដៅខេត្តសាមី បន្តធ្វើចត្តាឡីស័ក៧ថ្ងៃបន្ថែមទៀតនៅខេត្តសាមីនោះ។

លោក អភិបាលរងខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង បានបង្ហាញឲ្យដឹងទៀតថា ដោយឡែកពលករក្រៅខេត្ត ដែលនៅខេត្តជាប់គ្នានៅតាមព្រំដែន មិនធ្វើការដឹកជញ្ជូនចេញទេ ទុកដល់រយៈពេល២១ថ្ងៃ ហើយអនុវត្តការយកសំណាកទៅភ្នំពេញ រង់ចាំលទ្ធផល និងធ្វើតស្តរហ័សម្តងទៀតមុនចេញដំណើរ ។ តាមរយៈនេះដែរ លោក សឿម ប៊ុនរិទ្ធិ បានធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ សូមបន្តការចូលរួមអនុវត្តវិធានការសុវត្ថិភាព ៣កុំ ៣ការពារ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសុខាភិបាល ដើម្បីបញ្ចប់ព្រឹត្តិការណ៍ សហគមន៍២០កុម្ភៈនាពេលខាងមុខ ដែលប្រទេសកម្ពុជាកំពុងប្រយុទ្ធប្រឆាំងយ៉ាងស្វិតស្វាញនឹងជំងឺកូវីដ១៩ ដោយគ្មានសម្រាកដៃនោះឡើយ ៕ រក្សាសិទ្ធិដោយ៖CEN

## ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

### សម្តេចក្រឡាហោម ស ខេង អញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១នេះ តាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំនាពេលព្រឹកនេះ ក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី នៃក្រសួងពាក់ព័ន្ធ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ដែលជាអនុប្រធានគ.ជ.ប.ជ ក្រុមការងារអន្តរក្រសួង គ.ជ.ប.ជ ព្រមទាំងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកគ.ជ.ប.ជ ជាច្រើនរូបផងដែរ។

ជាកិច្ចចាប់ផ្តើម សម្តេចក្រឡាហោម ស ខេង ប្រធាន គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនីមួយៗ ដែលធ្វើឲ្យលទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០២១ ទទួល

បានលទ្ធផលគួរជាទីមោទនៈ បើទោះបីជាប្រឈមនឹងបញ្ហាជំងឺកូវីដ-១៩ក៏ដោយ ហើយនេះគឺជាការចូលរួមចំណែកប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាប្រទេសជាតិ។

នាឱកាសនោះលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអានរបាយការណ៍សង្ខេបស្តីពីលទ្ធផលឆមាសទី១ របស់គ.ជ.ប.ជ ដោយលើកឡើងថា ប្រជាពលរដ្ឋខ្មែរវិលត្រឡប់ពីក្រៅប្រទេស សរុបប្រមាណ១៥ម៉ឺននាក់ ក្នុងឆមាសទី១ ឆ្នាំ២០២១ និងសរុបប្រមាណជិត៣០ម៉ឺននាក់ បើគិតពីឆ្នាំ២០២០ហើយនៅតែបន្តវិលត្រឡប់មកកម្ពុជាជាបន្តបន្ទាប់ទៀតហើយភាគច្រើនជាអ្នកមានជីវភាពខ្វះខាត។ បន្ថែមពីនេះ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានប្តេជ្ញានិងលើកទិសដៅបន្តនូវឆមាសទី២ ដូចជា ៖ បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោសបទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស, បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស, បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន, ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាដើម។

ក្រោយស្តាប់របាយការណ៍រួច សម្តេចក្រឡាហោម ស ខេង គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានគាំទ្រ និងឯកភាពចំពោះរបាយការណ៍ឆមាសទី១ និងទិសដៅការងារបន្តសម្រាប់ឆមាសទី២ របស់ គ.ជ.ប.ជ ហើយសម្តេចក៏បានណែនាំដល់ក្រុមការងារឲ្យបំពេញការងាររបស់ខ្លួនបន្ថែមទៀត ដើម្បីឲ្យកាន់តែទទួលបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសកម្ពុជា។ សម្តេចក្រឡាហោម បានបញ្ជាក់ថា ក្រុមការងារទាំងអស់ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងជាតិ និងអន្តរជាតិ ដើម្បីចូលរួមក្នុងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។ បន្ថែមពីនេះ សម្តេចក៏បានអំពាវនាវ និងស្វាគមន៍ចំពោះការចូលរួមរបស់ប្រជាពលរដ្ឋទូទៅ តាមរយៈមធ្យោបាយផ្សេងៗ ដូចជា ផ្តល់ព័ត៌មានអំពីបទល្មើសជួញដូរមនុស្ស ជាដើម។ សម្តេចក្រឡាហោម បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រុមការងារ គ.ជ.ប.ជ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់នឹងបន្តខិតខំប្រឹងប្រែងរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាការរួមចំណែកដល់សេចក្តីសុខ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ហើយក៏ជាការលើកមុខមាត់ប្រទេសជាតិផងដែរ៕

## សម្តេចក្រឡាហោម ស ខេង ជំរុញឲ្យកម្លាំងសមត្ថកិច្ចនគរបាលយុត្តិធម៌ បង្ក្រាបករណីជួញដូរមនុស្ស ទោះបីក្នុងវិបត្តិកូវីដ-១៩ ក៏ដោយ

https://cen.com.kh/ Posted ByPen Srey NeatAugust 12, 2021

ភ្នំពេញ ៖ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី១២ ខែសីហា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ឆមាសទី១ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) តាមប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះ មានការចូលរួមពី ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និងឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ជាអនុប្រធាន និងជាប្រធានដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័នទាំង៦ នៃ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង តំណាងក្រសួង ស្ថាប័ន និងអង្គភាពជាសមាជិក មួយចំនួនទៀត។

លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើរបាយការណ៍សង្ខេប ស្តីពីលទ្ធផលការងាររបស់គណៈកម្មាធិការជាតិ ដែលគ្រប់ក្រសួងស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានខិតខំប្រឹងប្រែង

បំពេញភារកិច្ច ឲ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ ក្នុងដំណាក់កាលដ៏លំបាកដែលបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន។ លោកជំទាវរដ្ឋលេខាធិការបានបន្តថា បញ្ហាប្រឈមទាំងនោះ ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅ បណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ និងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី ដែលតា។

ចំណែកឯការងារអនុវត្តច្បាប់ កម្លាំងសមត្ថកិច្ចនគរបាលយុត្តិធម៌ បានបង្ក្រាបករណីជួញដូរមនុស្ស ច្រើនជាងឆ្នាំមុនបើគិតក្នុងរយៈពេលដូចគ្នា គឺ១៩៨ករណី ដែលក្នុងឆមាសទី១ ឆ្នាំ២០២០ បង្ក្រាបបាន ៦៣ករណី គឺកើន១៣៥ករណី ស្មើនឹង ២១៤.២៨% ក្នុងនោះ ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស បង្ក្រាបបាន ១៣៩ករណី កើនឡើង ១២៣ករណី និងបទល្មើសអាជីវកម្មផ្លូវភេទ បង្ក្រាបបាន៥៩ករណីកើន១២ករណី។ ការងារការពារជនរងគ្រោះ លោកជំទាវបានឱ្យដឹងថា ស្ថានទូតកម្ពុជា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសម្របសម្រួលឲ្យពលរដ្ឋខ្មែរ ដែលមានបញ្ហាប្រឈមនៅក្រៅប្រទេស បានវិលត្រឡប់មកកម្ពុជាវិញ សរុបទាំងអស់២.៣១៧នាក់ ស្រី ៩៧២នាក់ ក្នុងនោះ មួយចំនួនតូច សង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានពលករខុសច្បាប់ដែលត្រូវវិលត្រឡប់មកពីប្រទេសថៃមានរហូតដល់ ១.៦០៨នាក់ ស្រី ៤៨០នាក់។

លោកជំទាវបន្ថែមថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលពលរដ្ឋខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍ពីបរទេស និងទទួលពីអាជ្ញាធរប្រទេសនានា សរុបចំនួន ៤០.៨២២នាក់ ស្ត្រី ១៦.១៣៣នាក់ កុមារា ២.៣៩៥នាក់ កុមារី ២.១៧៥នាក់ ដែលក្រោយការសម្ភាសន៍ក្រុមការងារជាក់ការសង្ស័យថាពួកគេរងគ្រោះដោយករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ ជួញដូរកម្លាំងពលកម្ម ១១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈឬបង្ខំ ១៦២នាក់ និងករណីងាយរងគ្រោះ ៣២នាក់ ។ លោកជំទាវក៏បានរាយការណ៍ដែរថា ក្នុងចំណោមពលករដែលត្រូវអាជ្ញាធរប្រទេសថៃបញ្ជូនមក ក្នុងនាមជាជន ត្រូវនិរទេស មានសរុបចំនួន ៤០ ៥៩៨នាក់ ដោយមណ្ឌលសំចតទទួលពលករនៅប៉ោយប៉ែត បានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណ រកឃើញមុខសញ្ញាសង្ស័យថាជាជនរងគ្រោះ ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ និងជាជនងាយរងគ្រោះ ៤៣នាក់ និងបានបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការកៀន អង្គការសាម៉ារីតាន់ភីស និងអង្គការរតនៈអ៊ុនធើណេសិនណល ជាដើម ។

ចំពោះទិសដៅ សម្រាប់ឆមាសទី២ ឆ្នាំ២០២១ លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ថាគណៈកម្មាធិការជាតិកំណត់យក តាមយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងបន្តជំរុញអនុវត្ត គឺ ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ មាន៩ សកម្មភាព, ការងារបង្ការទប់ស្កាត់មាន ១៦សកម្មភាព, ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ មាន ៥សកម្មភាព, ការងារការពារជនជនរងគ្រោះ មាន ១២សកម្មភាព និងបន្ថែម ការងារពង្រឹងសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ មាន ៧សកម្មភាព។

អញ្ជើញមានប្រសាសន៍នាឱកាសនោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានសម្តែងនូវអំណរសាទរ និងការកោតសរសើរ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃគ្រប់ក្រសួងស្ថាប័ន ក្នុងគណៈកម្មាធិការជាតិ គ្រប់ថ្នាក់ រួមទាំងកងកម្លាំងសមត្ថកិច្ចគ្រប់ផ្នែក ស្ថាប័នអយ្យការ ស្ថានបេសកកម្មការទូត នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបាននាំគ្នាជំរុញអនុវត្តសកម្មភាព ទោះបីជាបាន និងកំពុងប្រឈមដោះស្រាយបញ្ហាផ្សេងៗ រួមទាំងវិបត្តិកូវីដ-១៩ ក៏ដោយ និងបើកការពិភាក្សា ផ្តល់យោបល់បន្ថែម លើរបាយការណ៍ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២១។ សម្តេចក្រឡាហោម ក៏បានផ្តាំផ្ញើឲ្យក្រសួងស្ថាប័ន បន្តជំរុញអនុវត្តសកម្មភាពទាំងឡាយ តាមការគ្រោង

ទុក និងត្រូវខិតខំពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថានទូតអាមេរិក និងគ្រប់ស្ថានទូតប្រទេសជាមិត្ត អង្គការជាតិ និងអន្តរជាតិ អង្គការសហប្រជាជាតិ ដែលបាន និងកំពុងរួមគ្នាជួយគាំទ្រ និងសហការរាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បី ធ្វើឲ្យសម្រេចលទ្ធផលតាមការគ្រោងទុក ដោយពុះពារគ្រប់ឧបសគ្គ និងភាពប្រឈមទាំងឡាយ និងរួមគ្នារៀបចំទិន្នន័យ ដើម្បីចងក្រងជាប្រព័ន្ធ ដែលស៊ីសង្វាក់គ្នា សម្រាប់ប្រើប្រាស់ ជារបាយការណ៍ជាតិ និងសម្រាប់ការចែកផ្សាយទូលំទូលាយ៕ រក្សាសិទ្ធដោយៈបញ្ញាស័ក្តិ

## សម្តេច ទៀ បាញ់ បញ្ជាកងទ័ពទាំងអស់ ចូលរួមឱ្យអស់កម្លាំងកាយចិត្ត ក្នុងបេសកកម្មដឹកជញ្ជូន ប្រជាពលរដ្ឋ ទៅកាន់មណ្ឌលចត្តាឡីស័កនានា

https://dap-news.com/national/ ByTR110Posted on August 12, 2021

**ភ្នំពេញ៖ សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានបញ្ជាដល់ កងទ័ពទាំងអស់ ចូលរួមឱ្យអស់កម្លាំងកាយចិត្ត ក្នុងបេសកកម្មដឹកជញ្ជូន ប្រជាពលរដ្ឋរបស់យើង ទៅកាន់មណ្ឌលចត្តាឡីស័កនានា ដែលបានកំណត់។**

នៅលើគេហទំព័រហ្វេសប៊ុក នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១នេះ សម្តេច ទៀ បាញ់ បានលើកឡើងយ៉ាងដូច្នេះថា «សូមបងប្អូនកងទ័ពទាំងអស់ ចូលរួមឱ្យអស់កម្លាំងកាយចិត្ត ក្នុងបេសកកម្មដឹកជញ្ជូន ប្រជាពលរដ្ឋរបស់យើង ទៅកាន់មណ្ឌលចត្តាឡីស័កនានា ដែលបានកំណត់»។

សូមរំលឹកថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានដាក់បទបញ្ជាទៅ កងទ័ព ឱ្យបញ្ចេញរថយន្ត ចំនួន២០០ គ្រឿង សម្រាប់ដឹកជញ្ជូនពលករខ្មែរ ដែលបាន ធ្វើចត្តាឡីស័ក រយៈពេល ១សប្តាហ៍រួចមកហើយ នៅតាមបណ្តាខេត្តជាប់ព្រំដែន ឱ្យមកបន្តធ្វើ ចត្តាឡីស័ក បន្ថែមទៀត នៅតាមបណ្តាខេត្តជា ស្រុកកំណើតរបស់ពួកគេ៕

## ប្រជាពលរដ្ឋខ្មែរចំនួន៣០នាក់ត្រូវគេនាំមកទម្លាក់ចោលនៅក្នុងភូមិសាស្ត្រខេត្តស្រះកែវ ប្រទេសថៃ

http://cambodiapolice.com/policekh/ 4:48 pm 11 សីហា 2021

អាជ្ញាធរស្រុកខ្លងហាត ខេត្តស្រះកែវ សហការជាមួយកម្លាំងទាហានឈុតខ្មៅទី១៣ និងនគរបាលស្រាវជ្រាវខេត្តស្រះកែវ និងអង្គភាពពាក់ព័ន្ធ នៅព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ បានចូលទៅត្រួតពិនិត្យប្រជាពលរដ្ឋខ្មែរ (ប្រុសចំនួន១២នាក់ និងស្រី១៨នាក់) សរុបចំនួន៣០នាក់ ដែលចូលមកប្រទេសថៃមិនបានទទួលការអនុញ្ញាត ត្រូវបានគេនាំមកទម្លាក់នៅលើផ្លូវជាតិ ក្នុងភូមិសាស្ត្រភូមិវ៉ាំងចើក ឃុំត្រៃជៀវ ស្រុកខ្លងហាត ខេត្តស្រះកែវ ចម្ងាយពីព្រំដែនកម្ពុជា-ថៃ ប្រមាណ២០គីឡូម៉ែត្រ ដើម្បីឲ្យធ្វើដំណើរត្រឡប់ទៅប្រទេសកំណើតខ្លួនវិញ ក្នុងអំឡុងស្ថានការណ៍វិបត្តិកូវីដ-១៩ ដែលកន្លែងធ្វើការភាគច្រើនទទួលរងផលប៉ះពាល់ជំងឺនេះមិនមានការងារធ្វើ ។

សមត្ថកិច្ចថៃបញ្ជាក់ថា ក្រោយពីសមត្ថកិច្ចថៃសួរនាំ ពលរដ្ឋខ្មែរទាំងអស់ខាងលើ បានធ្វើដំណើរមកពីខេត្តឈុនបុរី ចំនួន២៥នាក់ ក្រុងបាងកក ចំនួន៣នាក់ និងសមុទ្រប្រាកាន ចំនួន២នាក់ ពួកគាត់ចង់ធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាវិញ តែត្រូវសមត្ថកិច្ចថៃប្រទះឃើញមុន ។ ក្រោយពីសួរនាំរួចសមត្ថកិច្ចថៃ បាននាំពលរដ្ឋខ្មែរទាំងអស់ឡើងជិះរថយន្តយោធា ដឹកទៅឯចំណុចស្នាក់បណ្តោះអាសន្ន នៅបរិវេណបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងអំឡុងដែលប្រទេសកម្ពុជាប្រកាសបិទខ្ទប់ ហាមចេញ-ចូលព្រំដែន ដើម្បីរង់ចាំការអនុញ្ញាតិឲ្យវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ៕

## កម្លាំងនគរបាលកម្ពុជា សហការជាមួយកម្លាំងយោធា បានទទួលប្រជាពលរដ្ឋ ដែលមានបំណងវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ

http://cambodiapolice.com/policekh/ 1:18 pm 11 សីហា 2021

ខេត្តបាត់ដំបង ៖ នៅយប់ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ កម្លាំងប៉ុស្តិ៍ព្រំដែនចក្រី ចំនួន៦នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ សុខ-ផា(នាយរងប៉ុស្តិ៍)សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២, វរសេនាតូចលេខ១ ចំនួន៨នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ណន-វន្នី (មេបញ្ជាការ គ) បានទំនាក់ទំនងនិងសហការជាមួយភាគីយោធាថៃកងអនុសេនាធំលេខ១១១៣នៃវរសេនាធំលេខ១៣ ចំនួន៥នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ប្រាក់រ៉ាត់-ស៊ុទ្ធិប៊ុត (មេបញ្ជាការ) បានធ្វើការប្រគល់-ទទួលប្រជាពលរដ្ឋយើង ចំនួន៣០នាក់,ស្រី ១៨នាក់ ដែលមានបំណងវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដើម្បីទទួលយកបងប្អូនប្រជាពលរដ្ឋយកទៅកាន់ជំរកស្នាក់នៅបណ្តោះអាសន្នក្នុងទឹកដីថៃទល់មុខប៉ុស្តិ៍ព្រំដែនចក្រីគ្រប់គ្រង ក្នុងភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕

## ឆមាសទី១ ពលរដ្ឋខ្មែរ វិលត្រឡប់ពីក្រៅប្រទេសជាង ១៥ម៉ឺននាក់ ភាគច្រើន អ្នកមាន ជីវភាពខ្វះខាត

https://dap-news.com/national/ ByPH104Posted on August 12, 2021

**ភ្នំពេញ ៖ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស (គ.ជ.ប.ជ) បានឲ្យដឹងថា ក្នុងឆមាសទី១ ឆ្នាំ២០២១ មានប្រជាពលរដ្ឋខ្មែរវិលត្រឡប់ពីក្រៅប្រទេស ជាង១៥ម៉ឺននាក់ ហើយបន្តវិលត្រឡប់មកកម្ពុជា ជាបន្តបន្ទាប់ទៀត ក្នុងនោះ ភាគច្រើនជាអ្នកមានជីវភាពខ្វះខាត ។**

ក្នុងកិច្ចប្រជុំក្រុមការងារ ជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូសន្និសីទ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានថ្លែងថា «ប្រជាពលរដ្ឋខ្មែរវិលត្រឡប់ពីក្រៅប្រទេស សរុបប្រមាណ១៥ម៉ឺននាក់ ក្នុងឆមាសទី១ ឆ្នាំ២០២១ និងសរុបប្រមាណជិត៣០ម៉ឺននាក់ បើគិតពីឆ្នាំ២០២០ ហើយនៅតែបន្តវិលត្រឡប់មកកម្ពុជាជាបន្តបន្ទាប់ទៀត ហើយភាគច្រើនជាអ្នកមានជីវភាពខ្វះខាត»។ លោកស្រីរដ្ឋលេខាធិការ ប្តេជ្ញានិងលើកទិសដៅបន្តឆមាសទី២ ដូចជា ៖ បន្តពង្រឹង សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស , បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោសបទល្មើស ពាក់ព័ន្ធអំពើជួញដូរមនុស្ស , បន្តពង្រឹងកិច្ចសហការ រវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការក្នុងការអនុវត្តនីតិវិធី ស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុក ជនល្មើសជួញដូរមនុស្ស , បន្តពង្រឹងកិច្ចសហការជាមួយ សមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន, ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញ ទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ។

សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ក៏បានថ្លែងដែរថា ទោះជាប្រឈមនឹងបញ្ហាជំងឺកូវីដ-១៩ក៏ដោយ ក៏ក្រសួង-ស្ថាប័ន និងអង្គភាពនីមួយៗ បានប្រឹងប្រែងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សដែលធ្វើឲ្យលទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០២១ ទទួលបានលទ្ធផលគួរជាទីមោទនៈ ។ សម្តេច បញ្ជាក់ថា ក្រុមការងារទាំងអស់ត្រូវបន្តកិច្ចសហប្រតិបត្តិការ ជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងជាតិ-អន្តរជាតិ ដើម្បីចូល រួមប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅកម្ពុជា។ សម្តេច បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រុមការងារ គ.ជ.ប.ជ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ នឹងបន្តខិតខំប្រឹង ប្រែងរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ដែលជាការ រួមចំណែក ដល់សេចក្តីសុខ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ហើយក៏ជាការលើកមុខមាត់ ប្រទេសជាតិផងដែរ ៕

## ពលរដ្ឋជាប់តាមព្រំដែនថៃ ត្រូវបានជួយ និងត្រៀមដឹកដាក់តាមខេត្ត

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១២ សីហា ២០២១ដោយ KC Virak

បន្ទាយមានជ័យ៖ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ដឹកនាំមន្ត្រីក្រោមឱវាទចុះធ្វើអន្តរាគមន៍និងធ្វើ ការសម្របសម្រួល និងត្រៀមដឹកពលករខ្មែរដែលកំពុងកកកុញនៅតាមព្រំដែន ដឹកតាមរថយន្តដាក់តាមខេត្ត ចាក់ វ៉ាក់សាំង និងចត្តាឡីស័កផងដែរ។ លោកឧត្តមសេនីយ៍ទោ សេង ធារិន នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១នេះ បានប្រាប់អ្នកយកព័ត៌មានឱ្យដឹងថា ពលករខ្មែរមកពីប្រទេសថៃក្នុងមួយថ្ងៃៗជាច្រើនរយនាក់កំពុងសម្រាកនៅតាម បន្ទាត់ព្រំដែនក្នុងទឹកដីថៃ ក្នុងដំណាក់កាលនៃការបិទខ្ទប់ខេត្តជាប់ព្រំដែន តាមបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងន័យទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ពិសេសវីរុសបំប្លែងថ្មី Delta ដែលកំពុងផ្ទុះខ្លាំងនៅប្រទេសថៃ។ លោកឧត្តមសេនីយ៍ទោ សេង ធារិន បានធ្វើការអំពាវនាវ និងការយោគយល់ពីប្រជាពលរដ្ឋដែលជាពលករខ្មែរកំពុង ស្នាក់នៅបណ្តោះអាសន្នជិតបន្ទាត់ព្រំដែន មេត្តាយោគយល់ដល់ប្រមុខរាជរដ្ឋាភិបាលក៏ដូចជាកងកម្លាំងទាំងអស់ ដែលកំពុងអនុវត្តវិធានការដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺដែរតា Delta ចូលក្នុងប្រទេស ក៏ដូចជាក្នុងសហ គមន៍។

លោកបានបញ្ជាក់ជូនប្រជាពលរដ្ឋថា រាជរដ្ឋាភិបាលក៏ដូចជាកងកម្លាំង និងអាជ្ញាធរមូលដ្ឋាន បានរួមគ្នាមិន ទុកឱ្យពួកគាត់នៅឯកោនោះឡើយ ទន្ទឹមនោះអាជ្ញាធរក៏បានរៀបចំអំណោយជាស្បៀងអាហារ ជម្រក សម្រាប់ឱ្យ បងប្អូនស្នាក់នៅបណ្តោះអាសន្ននៅតាមបណ្តាខេត្តផ្សេងៗផងដែរ។ ក្នុងករណីមានបញ្ហាសុខភាព ឬបញ្ហាផ្សេងៗ លោកបានផ្តាំផ្ញើដល់ពលរដ្ឋទាំងនោះត្រូវរាយការណ៍ជូនទៅកងកម្លាំងដែលនៅជិតបំផុត ឱ្យកងកម្លាំងរាយការណ៍ ជូនទៅអាជ្ញាធរមូលដ្ឋានក្រុមការងារដើម្បីជួយដោះស្រាយបានទាន់ពេលវេលា៕ អត្ថបទ៖ វ៉ាន់ ណាង

## ខេត្តជាប់ព្រំដែនថៃខ្លះត្រៀមទទួលយកពលករ ខណៈព្រំដែនកម្ពុជា-ថៃ នឹងបើកឡើងវិញថ្ងៃស្អែក

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/08/2021 - 09:38

តាមគម្រោងព្រំដែនកម្ពុជា-ថៃ នឹងបើកដំណើរការឡើងវិញ នៅថ្ងៃទី១៣ សីហាស្អែកនេះបន្ទាប់ពីបិទ បណ្តោះអាសន្នរយៈពេល១៤ថ្ងៃ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលកូវីដ១៩ ដែលតាទ្រង់ទ្រាយធំ។ ថ្លែងប្រាប់វិទ្យុ បារាំងអន្តរជាតិនៅថ្ងៃទី១២ សីហានេះ អ្នកនាំពាក្យខេត្តជាប់ព្រំដែនកម្ពុជាថៃមួយចំនួនត្រៀមរួចស្រេចក្នុងការបើក ច្រកព្រំដែនរបស់ខ្លួន នៅកម្រិតសមស្របណាមួយ។ ក្នុងនោះលទ្ធភាពនៃការទទួលយកពលករត្រឡប់មកកម្ពុជាក៏ បានក្លាយជាការត្រៀមខ្លួនសម្រាប់អាជ្ញាធរខេត្តឧត្តរមានជ័យដែរ។

ពីព្រំដែនកម្ពុជា-ថៃ ខេត្តឧត្តរមានជ័យលោក ឌី រ៉ាដូ អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យបានឲ្យដឹងថានៅចំពោះមុខការត្រៀមបើកច្រកព្រំដែននៅថ្ងៃទី១៣ សីហា ការធ្វើចរាចរណ៍ទំនិញអ្នកបើកបររថយន្តដឹកទំនិញត្រូវយកសំណាក ដើម្បីបង្ការកូវីដ១៩ ដែលតាភ្លាមៗនៅនឹងកន្លែង។ ក្រៅពីបង្កើនការប្រុងប្រយ័ត្នលើមុខទំនិញ អាជ្ញាធរខេត្តក៏ត្រៀមទទួលយកពលករខ្មែរ ធ្វើដំណើរមកពីប្រទេសថៃផងដែរជាមួយនឹងការត្រៀមរួចជាស្រេចមណ្ឌលចត្តាឡីស័កពីរកន្លែងបន្ថែមទៀតដែលមណ្ឌលទាំង២ ផ្ទុកពលករបានក្នុងរង្វង់៦ពាន់នាក់ ខណៈមណ្ឌលចត្តាឡីស័កមានស្រាប់មានចំនួន៣០កន្លែងរួចទៅហើយ។ សូមជម្រាបជូនថា សម្រាប់ព្រំដែនកម្ពុជាថៃខេត្តឧត្តរមានជ័យមុនការបិទខ្ទប់១៤ថ្ងៃជាមធ្យមមានពលករប្រមាណជា៥០០នាក់បានសម្រុកមកប្រទេសកម្ពុជាក្នុងមួយថ្ងៃៗ។ រាប់ចាប់តាំងពីការផ្ទុះកូវីដ១៩នៅក្នុងខេត្តសាមុតសាខនរបស់ថៃកាលពីចុងខែ ឆ្នាំ២០២០ ពលករខ្មែរធ្វើដំណើរចូលមកប្រទេសកម្ពុជាតាមច្រកអូរស្មាច់ខេត្តឧត្តរមានជ័យមានចំនួនជាង១០ម៉ឺននាក់ ហើយ១ម៉ឺននាក់ជាពលរដ្ឋរស់នៅក្នុងខេត្តនេះស្រាប់។

លោក ឡឹង សុផុន មន្រ្តីអង្គការសង់ត្រាល់ប្រចាំនៅក្នុងប្រទេសថៃលើកឡើងថា ប្រសិនបើខេត្តជាប់ព្រំដែនកម្ពុជាថៃ បើកច្រកទទួលពលករព្រមគ្នា ពលករនឹងសប្បាយចិត្តឮតពេលនេះពួកគេកំពុងជាប់គាំងនៅព្រំដែនស្រាប់។ បើតាមលោកសុផុនមានពលករខ្មែរមិនក្រោម១ពាន់នាក់ឡើយជាប់នៅព្រំដែនហើយលទ្ធភាពត្រឡប់មកកម្ពុជាវិញជាការទន្ទឹងរងចាំជាប់ជានិច្ចក្នុងចិត្តរបស់ពួកគេទោះជាត្រូវព្យាបាលឬធ្វើចត្តាឡីស័កក៏ដោយ។

បើតាមសេចក្តីណែនាំរបស់របស់រដ្ឋាភិបាលនៅថ្ងៃទី១១ ខែសីហា ការអនុវត្តវិធានការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជាថៃ និងខេត្តសៀមរាបរួមនឹងយុទ្ធនាការថ្នាក់ជាតិរយៈពេល១៤កន្លងមកនេះបានជួយដល់ការគ្រប់គ្រងនិងពន្យាពេលបានមួយកម្រិតនូវការឆ្លងរាលដាលទ្រង់ទ្រាយធំ ក្នុងសហគមន៍នៃមេរោគកូវីដ១៩ប្រភេទដែលតា។ ជាក់ស្តែង អត្រានៃឆ្លងរាលដាលនៃជំងឺកូវីដ១៩ប្រចាំថ្ងៃ មានលក្ខណៈថេរ បើទោះជាមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតាបានធ្លាយចូលក្នុងសហគមន៍និងបានរាលដាលរហូតទៅ១៧រាជធានីខេត្តក៏ដោយ។ដើម្បីបន្តប្រសិទ្ធិភាពក្នុងការគ្រប់គ្រងហានិភ័យនៃការឆ្លងរាលដាលទ្រង់ទ្រាយធំ ក្នុងសហគមន៍នៃមេរោគដែលតាក្រោយវិធានការបិទខ្ទប់បណ្តាខេត្តជាប់ព្រំដែនកម្ពុជាថៃនិងសៀមរាបត្រូវបានបិទបញ្ចប់ នៅយប់ថ្ងៃទី១២សីហា រដ្ឋាភិបាលបានណែនាំទៅអភិបាលរាជធានីខេត្តនៅទូទាំងប្រទេស បន្តអនុវត្តយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដសម្រាប់រយៈពេល៧ថ្ងៃបន្តទៀតរហូតដល់ថ្ងៃទី១៩សីហា។ សូមជម្រាបជូនថា ចាប់ពីថ្ងៃទី៣១មិនាដល់ថ្ងៃទី១០សីហា កម្ពុជារកឃើញវិជ្ជមានវីរុសដែលតាសរុប៤២៩នាក់៕

## អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស សហការជាមួយ អាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ ថ្ងៃព្រហស្បតិ៍ ទី១២ ខែសីហា ឆ្នាំ២០២១

ខេត្តកំពង់ធំ៖ កាលថ្ងៃព្រហស្បតិ៍ ទី១២ ខែសីហា ឆ្នាំ២០២១នេះ អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (សង់ត្រាល់-CENTRAL)សហការជាមួយ មេឃុំ ណុំ សុត និងអាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅតាមសាលាឃុំ ដែលស្ថិតនៅក្នុងឃុំរុងរឿង នៃស្រុកស្ទោង ខេត្តកំពង់ធំ។ ដោយស្ថានភាពកូវីដ-១៩បានកំពុងរីករាលដាលទូទាំងពិភពលោករួមទាំងប្រទេសកម្ពុជាផងដែរ ដែលជាហេតុធ្វើអោយប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជាប្រឈមនឹងបញ្ហាផ្សេងៗ រួមមានការចាញ់បោកខ្យល់ ការឆ្លងដែនដោយប្រថុយប្រថាននឹងគ្រោះថ្នាក់ និងប្រឈមពីការចាប់ខ្លួនពីសំណាក់អាជ្ញាធរថៃ។ អង្គការសង់ត្រាល់ចូលរួមផ្សព្វផ្សាយលើកបដា ក្នុងគោលបំណងខាងក្រោម៖

១.លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធិការងារគ្រប់រូបភាព។

២.កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈមគ្រោះថ្នាក់នៃអំពើជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗ។

៣.លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

អង្គការសង់ត្រាល់នឹងបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋា តាមបណ្តាឃុំស្រុកខេត្តដទៃទៀត ដើម្បីផ្សព្វផ្សាយអប់រំពីសិទ្ធិការងារ ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិផ្សេងៗដែលពលរដ្ឋកម្ពុជាគួរយល់ដឹង។

## ពលករខ្មែរដែលឃាត់ជាប់នៅតាមព្រំដែន ត្រូវបញ្ជូនទៅពិនិត្យសុខភាព ស្អែកនេះ

https://kohsantepheapdaily.com.kh/ ១២ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១៨:០១

ខេត្តបន្ទាយមានជ័យ ៖ បន្ទាប់ពីការអនុវត្តវិធានការបិទខ្ទប់ព្រំដែន តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ១៤ថ្ងៃ សំដៅទប់ស្កាត់ការឆ្លងរីករាលដាលក្នុងសហគមន៍ មេរោគកូវីដ-១៩ បម្លែងថ្មី ប្រភេទដែលតា (Delta) គិតចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២១នេះ កម្លាំងអន្តរាគមន៍ នៃកងពលតូចថ្មើរជើងលេខ៥១ បានឃាត់ពលករ អោយនៅសម្រាកបណ្តោះអាសន្ន នៃម្នាងព្រំដែន ក្នុងទឹកដីថៃ សរុបចំនួន១៤៧នាក់ ។ ពលករទាំងអស់ នឹងបញ្ជូនទៅត្រួតពិនិត្យសុខភាព នៅប្រកអូរបីជាន់ តាមការណែនាំរបស់ក្រសួងសុខាភិបាល បន្ទាប់ពីថ្ងៃបញ្ចប់ នៃការបិទខ្ទប់ព្រំដែន នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ស្អែកនេះ ៕

## លោកជំទាវ ជូ ប៊ុនអេង៖ ការបង្ក្រាបករណីជួញដូរមនុស្ស ច្រើនជាងឆ្នាំមុន

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១នេះ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ឆមាសទី១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើរបាយការណ៍សង្ខេប ស្តីពីលទ្ធផលការងាររបស់គណៈកម្មាធិការជាតិ ដែលគ្រប់ក្រសួងស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានខិតខំប្រឹងប្រែងបំពេញភារកិច្ច ឲ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ ក្នុងដំណាក់កាលដ៏លំបាកដែលបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន។ លោកជំទាវរដ្ឋលេខាធិការបានបន្តថា បញ្ហាប្រឈមទាំងនោះ ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅ បណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ និងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី ដែលតា។

ចំណែកឯការងារអនុវត្តច្បាប់ កម្លាំងសមត្ថកិច្ចនគរបាលយុត្តិធម៌ បានបង្ក្រាបករណីជួញដូរមនុស្ស ច្រើនជាងឆ្នាំមុនបើគិតក្នុងរយៈពេលដូចគ្នា គឺ១៩៨ករណី ដែលក្នុងឆមាសទី១ ឆ្នាំ២០២០ បង្ក្រាបបាន ៦៣ករណី គឺកើន១៣៥ករណី ស្មើនឹង ២១៤.២៨% ក្នុងនោះ ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស បង្ក្រាបបាន ១៣៩ករណី កើនឡើង ១២៣ករណី និងបទល្មើសអាជីវកម្មផ្លូវភេទ បង្ក្រាបបាន៥៩ករណីកើន១២ករណី។ ការងារការពារជនរងគ្រោះ លោកជំទាវបានឱ្យដឹងថា ស្ថានទូតកម្ពុជា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

បានសម្របសម្រួលឲ្យពលរដ្ឋខ្មែរ ដែលមានបញ្ហាប្រឈមនៅក្រៅប្រទេស បានវិលត្រឡប់មកកម្ពុជាវិញ សរុបទាំងអស់២.៣១៧នាក់ ស្រី ៩៧២នាក់ ក្នុងនោះ មួយចំនួនតូច សង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានពលករខុសច្បាប់ដែលត្រូវវិលត្រឡប់មកពីប្រទេសថៃមានរហូតដល់ ១.៦០៨នាក់ ស្រី ៤៨០នាក់។

លោកជំទាវបន្ថែមថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលពលរដ្ឋខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍ពីបរទេស និងទទួលពីអាជ្ញាធរប្រទេសនានា សរុបចំនួន ៤០.៨២២នាក់ ស្រ្តី ១៦.១៣៣នាក់ កុមារា ២.៣៩៥នាក់ កុមារី ២.១៧៥នាក់ ដែលក្រោយការសម្ភាសន៍ក្រុមការងារដាក់ការសង្ស័យថាពួកគេរងគ្រោះដោយករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ ជួញដូរកម្លាំងពលកម្ម ១១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈឬបង្ខំ ១៦២នាក់ និងករណីងាយរងគ្រោះ ៣២នាក់។ លោកជំទាវក៏បានរាយការណ៍ដែរថា ក្នុងចំណោមពលករដែលត្រូវអាជ្ញាធរប្រទេសថៃបញ្ជូនមក ក្នុងនាមជាជនត្រូវនិរទេស មានសរុបចំនួន ៤០ ៥៩៨នាក់ ដោយមណ្ឌលសំចតទទួលពលករនៅប៉ោយប៉ែត បានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណ រកឃើញមុខសញ្ញាសង្ស័យថាជាជនរងគ្រោះ ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ និងជាជនងាយរងគ្រោះ ៤៣នាក់ និងបានបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន អង្គការសាម៉ារីតាន់ភឺស និងអង្គការរតនៈអ៊ិនធើណេសិនណល ជាដើម។

ចំពោះទិសដៅ សម្រាប់ឆមាសទី២ ឆ្នាំ២០២១ លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ថាគណៈកម្មាធិការជាតិកំណត់យក តាមយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងបន្តជំរុញអនុវត្ត គឺ ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ មាន៩ សកម្មភាព, ការងារបង្ការទប់ស្កាត់មាន ១៦សកម្មភាព, ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ មាន ៥សកម្មភាព, ការងារការពារជនជនរងគ្រោះ មាន ១២សកម្មភាព និងបន្ថែម ការងារពង្រឹងសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ មាន ៧សកម្មភាព៕

## ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

### អាជ្ញាធរខេត្តបន្ទាយមានជ័យ ស្នើសុំខេត្តស្រះកែវ សុំកុំឲ្យមានការបញ្ជូនពលករខ្មែរ មកជាគំហុក មានបញ្ហាអ្វីសូមផ្តល់ព័ត៌មានបន្ទាន់

https://cen.com.kh/ Posted ByPen Srey NeatAugust 13, 2021

ខេត្តបន្ទាយមានជ័យ ៖ ជួបពិភាក្សាដើម្បីដោះស្រាយកិច្ចការបន្ទាន់ជាមួយភាគីថៃ នៅព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ ព្រមទាំងថ្នាក់ដឹកនាំ កងកម្លាំងប្រដាប់អាវុធ បានជួបពិភាក្សាកិច្ចការងារមួយចំនួនជាមួយ ឯកឧត្តមអភិបាលខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ លើស្ពានច្រកទ្វារអន្តរជាតិប៉ោយប៉ែត-ក្លងឡឹក។

ក្នុងជំនួបពិភាក្សាជាមួយឯកឧត្តមអភិបាលខេត្តស្រះកែវ ផ្តោតលើចំណុចសំខាន់មួយចំនួន ដូចជា ដោយសារស្ថានភាព នៃការដាលនៃជំងឺកូវីដ១៩ ពិសេសមេរោគបំប្លែងថ្មីDelta និងមានការបិទព្រំដែន មិនឲ្យបងប្អូនចូលមកទឹកដីកម្ពុជា ១៤ថ្ងៃ ដូច្នេះខាងខេត្តបន្ទាយមានជ័យ ស្នើសុំខេត្តស្រះកែវ និងសមត្ថកិច្ចពាក់ព័ន្ធ សូមជួយសម្របសម្រួលដោះស្រាយ បញ្ហាបងប្អូនប្រជាពលរដ្ឋដែលត្រឡប់មកទឹកដីកម្ពុជា ទាំងសុខភាព សុវត្ថិភាពពួកគាត់ ស្នើសុំកុំឲ្យមានការបញ្ជូនបងប្អូនមកជាគំហុក មានបញ្ហាអ្វីសូមផ្តល់ព័ត៌មានបន្ទាន់ មកភាគីកម្ពុជា ដើម្បីត្រៀមលក្ខណៈទទួលបងប្អូន តាមវិធានសុខាភិបាល។ ដោយទទួលបានគោលការណ៍ឯកភាព លើកមុន ពាក់ព័ន្ធការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋក្នុងផ្សាររុងក្លឿ ខេត្តស្រះកែវ ក្នុងជំនួបពិភាក្សាព្រឹកនេះ បានឯកភាពជាថ្មីនឹងអនុញ្ញាតជាគោល

ការណ៍ រៀបចំការចាក់វ៉ាក់សាំង លើស្ពានច្រកទ្វារអន្តរជាតិប៉ោយប៉ែត ជូនអាជីវករលក់ដូរ ក្នុងផ្សាររុងក្លឿប្រមាណ ១០០០០នាក់ ពេលវេលាថ្ងៃណានឹងជូនដំណឹងបន្ថែម ។

ខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ រួមគ្នាបន្តកិច្ចសហប្រតិបត្តិការល្អ ក្នុងការសម្របសម្រួល ដោះស្រាយបញ្ហាផ្សេងៗ តាមបន្ទាត់ព្រំដែននៃប្រទេសទាំង២ ពិសេសការគ្រប់គ្រងបងប្អូនពលករ ទប់ស្កាត់ការរីករាលនៃជំងឺកូវីដ១៩ ពិសេសមេរោគថ្មីDelta៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរជាង៣០០នាក់ ជាប់នៅតាមព្រំដែនថៃ ឈមខេត្តបន្ទាយមានជ័យ ធ្វើសំណាករកឃើញកូវីដ១៩ ចំនួន៣៧នាក់

https://news.btv.com.kh/ 08/13/2021 12:08 PM

បន្ទាយមានជ័យ ៖ ពលករខ្មែរជាង៣០០នាក់ ធ្វើដំណើរមកស្រុកកំណើតវិញ អំឡុងពេលបិទព្រំដែនរវាងកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ហើយបានជាប់គាំងនៅតាមព្រំដែនថៃ ចំណុចច្រកបឹងត្រកួន ខេត្តបន្ទាយមានជ័យ ចំនួន២សប្តាហ៍ បានឆ្លងដែនមកដល់កម្ពុជា ត្រូវបានមន្ត្រីសុខាភិបាលធ្វើសំណាក រកឃើញចំនួន ៣៧នាក់ មានវិជ្ជមានកូវីដ១៩ ។

ក្នុងអំឡុងរង់ចាំទទួលការវិលត្រឡប់របស់ពលករ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ ឯកឧត្តម អ៊ុ រាត្រី មានប្រសាសន៍ថា សម្រាប់ពលករដែលត្រូវអាជ្ញាធរថៃបានបញ្ជូនទាំងអស់នេះ ពេលមកដល់កម្ពុជាភ្លាម ត្រូវបានមន្ត្រីសុខាភិបាលធ្វើសំណាក ដើម្បីរកវីរុសកូវីដ១៩ មុនបញ្ជូនទៅធ្វើចត្តាឡីស័ក ។ ឯកឧត្តមបានបន្តថា សម្រាប់ពលករទាំង៣០០នាក់ ត្រូវបានយកសំណាករួចរាល់ហើយ ជាលទ្ធផល គឺមានពលករចំនួន ៣៧នាក់ វិជ្ជមានកូវីដ១៩ ដោយអាជ្ញាធរកំពុងរៀបចំដឹកជញ្ជូនពួកគេទៅព្យាបាល ខណៈអ្នកអវិជ្ជមាន ដឹកជញ្ជូនទៅធ្វើចត្តាឡីស័កនៅស្រុកស្វាយចេក។ កាលកន្លងទៅថ្មីៗនេះ ឯកឧត្តមអភិបាលខេត្តបញ្ជាក់ថា អាជ្ញាធរខេត្តបន្ទាយមានជ័យបានរៀបចំរួចរាល់ហើយនូវទីតាំងធ្វើចត្តាឡីស័ក និងទីតាំងសម្រាកព្យាបាលរបស់ពលករ ដែលនៅជាប់គាំងតាមព្រំដែន ៕

## ក្នុងចំណោមពលករ១០០នាក់ មកពីប្រទេសថៃ ធ្វើតេស្តរហ័សឃើញវិជ្ជមានកូវីដ ចំនួន១២នាក់ហើយ

https://cen.com.kh/ Posted ByPen Srey NeatAugust 13, 2021

បាត់ដំបង ៖ ពលករខ្មែរប្រមាណជាង៤០០នាក់ ដែលជាប់គាំងនៅក្នុងប្រទេសថៃ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជា មានវិធានការបិទខ្ទប់ខេត្តជាប់ព្រំដែន ជាពិសេសខេត្តបាត់ដំបង រយៈពេល ១៤ ថ្ងៃ ក្នុងន័យដើម្បីធ្វើការប្រយុទ្ធប្រឆាំង នឹងការឆ្លងរាលដាលក្នុងសហគមន៍នៃវីរុសកូវីដ១៩ ប្រភេទដែលតា(Delta) ដែលនឹងត្រូវបានបញ្ចប់នៅម៉ោង ២៣និង៥៩នាទី ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ហើយឈានចូលដល់ព្រឹកថ្ងៃទី១៣ ខែសីហានេះដែរ ពួកគាត់បានសម្រុកចូលមកស្រុកកំណើតវិញ ដោយបានឆ្លងកាត់ច្រកទ្វារតំបន់ព្រំដែនសួនស៊ុ ហៅ អូរអន្លក់ ក្នុងឃុំតាសែន ស្រុកកំរៀង និងមួយផ្នែកទៀតចូលតាមច្រករបៀង ស្ថិតក្នុងភូមិសាស្ត្រស្រុកសំពៅលូន ខេត្តបាត់ដំបង ។

អភិបាលខេត្តបាត់ដំបង ឯកឧត្តម ងួន រតនៈ បានដឹកនាំប្រតិភូខេត្ត មានថ្នាក់ដឹកនាំតាមស្ថាប័នមន្ទីរនានាក្នុងខេត្ត មកទទួលយកពលករខ្មែរទាំងអស់នោះមកវិញ បន្ទាប់ពីបានជាប់គាំងដោយការបិទខ្ទប់ព្រំដែននៃប្រទេសកម្ពុជា ថៃ ដែលភាគីថៃ បានរៀបចំឱ្យមានការស្នាក់នៅជាបណ្តោះអាសន្ន ក្នុងមណ្ឌលចត្តាឡីស័កនៅស្រុកសយដាវ និងស្រុកប៉ុណាំរ៉ង ខេត្តចាន់បូរី ដែលក្នុងនោះខាងភាគីថៃបានពិភាក្សានិងបញ្ជូនពលករទាំងនោះនៅពេលបើក

ព្រំដែនឡើងវិញបន្ទាប់ពីបានបិទខ្ទប់អស់រយៈពេល១៤ថ្ងៃកន្លងមក ។ លោក ងួន រតនៈ បានបញ្ជាក់ថា ពលករដែលមកដល់ច្រកទ្វារព្រំដែនត្រូវបានមន្ត្រីជំនាញ របស់មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបង បានយកសំណាក និងធ្វើតេស្តរហ័ស ដោយបានរកឃើញវិជ្ជមានវីរុសកូវីដ១៩ ទៅលើពួកគេជាបន្តបន្ទាប់ ។ ឯកឧត្តម បានបញ្ជាក់ថា ពលករដែលបានរកឃើញអ្នកវិជ្ជមានកូវីដ១៩ ត្រូវបានបញ្ជូនទៅមណ្ឌលព្យាបាល នៅមណ្ឌលព្យាបាលដោយដាក់ពួកគាត់ នៅដាច់ដោយឡែកពីអ្នកជំងឺចាស់ និងអ្នកអវិជ្ជមានត្រូវបានដឹកជញ្ជូន ទៅកាន់មណ្ឌលចត្តាឡីស័ក នៅតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រនៃខេត្តបាត់ដំបង មុននឹងបញ្ជូនបន្តទៅមណ្ឌលចត្តាឡីស័កនៅខេត្តសាមីរបស់ពួកគាត់ទៀត ។

សូមបញ្ជាក់ថា ពេលពលករចូលមកដល់ច្រកទ្វារព្រំដែន ត្រូវបានយកសំណាកធ្វើតេស្តរហ័ស ដោយបានរកឃើញវិជ្ជមានកូវីដ១៩ ជាលទ្ធផលបឋម ពលករចំនួន១០០នាក់ បានរកឃើញអ្នកវិជ្ជមានចំនួន១២នាក់ ។ នៅក្នុងការបើកឱ្យដំណើរការព្រំដែនឡើងវិញនេះ កងកម្លាំងយោធពលខេមរភូមិន្ទ បានយករថយន្តដែលជាអំណោយរបស់សម្តេចនាយករដ្ឋមន្ត្រី ដឹកពលករដែលកំពុងជាប់គាំងនៅព្រំដែនក្នុងទឹកដីថៃ ប្រមាណ៤០០នាក់ ចូលមកក្នុងប្រទេសកម្ពុជាវិញ ដើម្បីបញ្ជូនពួកគេទៅព្យាបាលជំងឺ និងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័ក តាមខ្សែបន្ទាត់ព្រំដែននៃខេត្តបាត់ដំបងផងដែរ ៕ រក្សាសិទ្ធិដោយ៖CEN

## ពលករជាប់តាមព្រំដែនថៃ ត្រូវបានអនុញ្ញាតឱ្យចូលប្រទេស ក្រោយព្រំដែនបើកឡើងវិញ

http://freshnewsasia.com/ 2021-08-13 12:03pm

**(បន្ទាយមានជ័យ)៖** ពលករខ្មែរប្រមាណ ១៤៧នាក់ មានក្មេងតូចៗផងនោះ ត្រូវបានអនុញ្ញាតឱ្យចូលទឹកដីកម្ពុជាវិញហើយនៅព្រឹកថ្ងៃសុក្រ ទី១៣ ខែសីហា ឆ្នាំ២០២១នេះ បន្ទាប់ពីបានជាប់តាមព្រំដែនលើទឹកដីថៃ ក្នុងកំលុងបិទព្រំដែនពីរសប្តាហ៍កន្លងទៅ។ ក្នុងពេលកម្ពុជាបិទព្រំដែនពីរសប្តាហ៍កន្លងទៅនេះ មានពលករខ្មែរត្រឡប់មកពីប្រទេសថៃជាបន្តបន្ទាប់។ ដោយសារវិធានការបិទព្រំដែន ដូច្នេះពួកគេក៏បានបោះតង់ស្នាក់នៅបណ្តោះអាសន្ននៅតាមបន្ទាត់ព្រំដែនលើទឹកដីថៃ។

ជាមួយការអនុញ្ញាតឱ្យចូលក្នុងប្រទេសវិញនេះ កម្លាំងទ័ពកងពលតូចថ្មើរជើងលេខ៥១ ដឹកនាំដោយឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ ជាមេបញ្ជាការ បានចុះទៅជួយសម្របសម្រួលនៅបន្ទាត់ព្រំដែន ដោយពិនិត្យសុខភាពរោគមេរោគកូវីដ១៩ តាមរយៈតេស្តរហ័ស និងដឹកជញ្ជូនពួកគេទៅមណ្ឌលចត្តាឡីស័ក។ លោកមេបញ្ជាការ សឹង្ហ ទុំ បានគូសបញ្ជាក់ថា ក្រៅពីជួយសម្រួលពលករចូលមកទឹកដីខ្មែរ ត្រួតពិនិត្យសុខភាព និងបញ្ជូនទៅមណ្ឌលចត្តាឡីស័កហើយនោះ កម្លាំងអន្តរាគមន៍កងពលតូចថ្មើរជើងលេខ៥១ បន្តឈរជើងរឹតបណ្តឹងបំពេញប្រតិបត្តិការ ល្បាត ទប់ស្កាត់ ការលួចឆ្លងដែន ក្នុងភូមិសាស្ត្រដែលអង្គភាពទទួលខុសត្រូវ ជានាកុំឱ្យមានឆ្លងរាលដាលចូលក្នុងសហគមន៍នូវមេរោគកូវីដ១៩ បំប្លែងថ្មីប្រភេទដែលតា (Delta)។ លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ ក៏បានណែនាំទៅកងកម្លាំងជួរមុខទាំងអស់ មានការប្រុងប្រយ័ត្នខ្ពស់ក្នុងពេលឃាត់ពលករ ដោយសារពលករមួយចំនួនដែលវិលត្រឡប់មកពីប្រទេសថៃ អាចមានវិជ្ជមានមេរោគកូវីដ១៩ បំប្លែងថ្មី ប្រភេទដែលតា (Delta)។

សូមបញ្ជាក់ថា បើទោះបីមានការបើកច្រកព្រំដែនឡើងវិញយ៉ាងណាក្តី តែសម្រាប់ខេត្តបន្ទាយមានជ័យ អាជ្ញាធរណែនាំឱ្យពលករចូលមកកម្ពុជាតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន និងម៉ាឡៃ ដើម្បីងាយស្រួលក្នុងការពិនិត្យសុខភាព និងធ្វើចត្តាឡីស័ក។ ជាមួយគ្នានៅតាមបន្ទាត់ព្រំដែន និងច្រករបៀងនានា ត្រូវបានពង្រាយកម្លាំងយាម

កាមយ៉ាងតឹងរឹងប្រជាពលរដ្ឋលួចឆ្លងដែនតាមច្រករបៀង នឹងត្រូវចាប់បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក ដែលអាជ្ញាធរបានរៀបចំ។

លោកឧត្តមសេនីយ៍ត្រី សឹង្គ ទុំ បានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានបំណងវិលចូលប្រទេសវិញតាមខេត្តបន្ទាយមានជ័យ កុំឱ្យលួចឆ្លងដែននៅតាមច្រករបៀង ត្រូវឆ្លងតាមច្រកដែលអាជ្ញាធររៀបចំ ដើម្បីតេស្តសុខភាព និងធ្វើចត្តាឡីស័ក ចៀសវាងការនាំមេរោគទៅគ្រួសារ និងឆ្លងរាលដាលក្នុងសហគមន៍៕

## ក្រោយបើកព្រំដែន ពលករខ្មែរជាច្រើននាក់ សម្រុកចេញពីថៃមកស្រុកកំណើតវិញ, ៥០០នាក់ រកឃើញវិជ្ជមានកូវីដជាង៦០នាក់

http://freshnewsasia.com/ 2021-08-13 01:33pm

**(បន្ទាយមានជ័យ)៖** ពេលអាជ្ញាធរសម្រេចបើកឡើងវិញ ច្រកព្រំដែនជាមួយប្រទេសថៃ ក្រោយបិទអស់រយៈពេល ២សប្តាហ៍កន្លងមកនេះ គេសង្កេតឃើញថា ពេញមួយព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ ពលករខ្មែរ បានសម្រុកចេញពីប្រទេសថៃ ចូលមកស្រុកកំណើតវិញ មានការកើនឡើងជាបន្តបន្ទាប់។

អភិបាលខេត្តបន្ទាយមានជ័យ លោក អ៊ុំ រាត្រី បានប្រាប់បណ្តាញព័ត៌មាន Fresh News នៅរសៀលថ្ងៃនេះថា តាំងពីព្រឹករហូតមកដល់ពេលនេះ មានពលករខ្មែរ ដែលធ្វើដំណើរចេញពីប្រទេសថៃ បូករួមមួយពលករដែលអាជ្ញាធរ បានឃាត់ពួកគាត់នៅតាមព្រំដែនសរុបក្បែរ៥០០នាក់។ អភិបាលខេត្តបានបន្តថា សម្រាប់ពលករខ្មែរដែលធ្វើដំណើរចូលមកប្រទេសកម្ពុជាវិញ គឺនៅតាមច្រកបឹងត្រកួន ច្រកម៉ាឡៃ និងច្រកអូរបើជាន់ ហើយចំនួននេះនឹងមានការកើនឡើងជាបន្តទៀត។ លោកបន្តថា ក្នុងចំណោមពលករដែលវិលចូលស្រុកវិញនេះ បានតេស្តឃើញជំងឺកូវីដ១៩ ផងដែរ ដោយគិតត្រឹមម៉ោងនេះ (ម៉ោង១ជាង) មានអ្នកវិជ្ជមានជាង៦០នាក់ហើយ។ លោកថា កម្លាំងអាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធ សហការជាមួយមន្ត្រីសុខាភិបាល បានរៀបចំការធ្វើតេស្តរហ័ស ទៅលើពលករខ្មែរទាំងនោះ នៅច្រកព្រំដែនដែលពួកគេ ធ្វើដំណើរឆ្លងកាត់ មុនបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក៕

## ពលករជិត ៥០០នាក់ ត្រូវអាជ្ញាធរខេត្តបន្ទាយមានជ័យ សម្រួលចូលមកកម្ពុជាវិញ បន្ទាប់ពីជាប់គាំង១៤ថ្ងៃ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៣ សីហា ២០២១ដោយ Sorn Phanith

អាជ្ញាធរខេត្តបន្ទាយមានជ័យ បានធ្វើការសម្របសម្រួលជាមួយអាជ្ញាធរថៃក្រោយពលករជិត ៥០០នាក់ បន្ទាប់ពីជាប់គាំងនៅតាមព្រំដែនអស់រយៈពេល១៤ថ្ងៃ បានវិលចូលមកកម្ពុជាវិញ ក្នុងនោះសមត្ថកិច្ចឈរជើងនៅទីនោះ បានដឹកពលករទាំងអស់ទៅតាមខេត្តរៀងខ្លួនចត្តាឡីស័ក និងចាក់វ៉ាក់សាំងជូនពួកគាត់ ដើម្បីបញ្ចៀសនៅជំងឺដ៏កាចសាហាវ វីរុសបំប្លែងថ្មីប្រភេទDelta នៅព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១។

លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការទិសទី១ បន្ទាយមានជ័យ នៃយោធភូមិភាគទី៥បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ពលករទាំង៥០០នោះ មុននឹងដឹកតាមរថយន្តរបស់កងទ័ពយកទៅដាក់តាមគោលដៅនោះក្រុមការងារចាំបាច់ ត្រូវយកសំណាកតេស្តរហ័សរកកូវីដ-១៩ មុននឹងបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក ដែលរដ្ឋបាលខេត្ត បានរៀបចំសម្រាប់ទទួលពលករ ហើយក្នុងករណី រកឃើញវិជ្ជមានកូវីដ-១៩ ក្រុមការងារ នឹងយកទៅព្យាបាលនៅមណ្ឌលព្យាបាលភ្លាមៗផងដែរ។ លោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ចំពោះពលករដែលជាប់គាំនៅច្រកបឹងត្រកួន ស្រុកថ្មពួក និងច្រកអូរបើជាន់ ស្រុកអូរជ្រៅ ជាប់ព្រំប្រទល់ខេត្តតាប់ប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ដែលជាច្រកព្រំដែន មានពលករមកស្នាក់នៅបណ្តោះអាសន្នច្រើនជាងច្រកផ្សេ

ងៗនោះមិនឲ្យគេចវេះពីការត្រួតពិនិត្យសុខភាព និងធ្វើចត្តាឡីស័ក ដែលមានហានិភ័យខ្ពស់ពីការឆ្លងរាលដាលកូវីដ-១៩ ចូលក្នុងសហគមន៍ ពិសេសវីរុសបំប្លែងថ្មីប្រភេទDeltaនោះឡើយ។

ជាមួយគ្នានេះ លោក រឿន សុធី អនុប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា នៅក្នុងខេត្តបន្ទាយមានជ័យ បានរកឃើញវីរុសបំប្លែងថ្មីប្រភេទ Deltaចំនួន ៤៣ករណី ក្នុងនោះឆ្លងក្នុងសហគមន៍ ៧ករណី ឆ្លងមន្ត្រីសុខាភិបាលជួមុខចំនួន ៦នាក់ ក្នុងពេញបេសកកម្មព្យាបាលអ្នកជំងឺកូវីដ-១៩ សម្រាប់ទូទាំងប្រទេសកម្ពុជា មេរោគDelta បានរកឃើញជាង ៤០០ករណី ហើយមកដល់ពេលនេះ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ បន្ទាប់ពីមានការបិទខ្ទប់ខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ពិសេសខេត្តបន្ទាយមានជ័យ ដែលមានច្រកសំខាន់ៗក្នុងការទទួលពលករ ដែលជាប់គាំក្នុងដំណាក់កាលបិទខ្ទប់ ១៤ថ្ងៃនោះ មានពលករវិញមកប្រទេសខ្មែរវិញសរុប ៤៦៣នាក់ ក្នុងនោះច្រកបឹងត្រកួន ស្រុកថ្មពួក ដែលមានពលករចំនួន ៣៣៥នាក់ ច្រកស្រុកម៉ាឡៃចំនួន ១០០នាក់ ច្រកស្រុកអូរជ្រៅចំនួន ១៨នាក់ និងច្រកប៉ោយប៉ែតចំនួន ១០នាក់។ ក្រៅពីនេះពលករបានចាប់ផ្តើមចូលមកកម្ពុជាជាបន្តបន្ទាប់ក្រោយពីអាជ្ញាធរបើកច្រកព្រំដែនឡើងវិញ៕

**អត្ថបទ៖ វ៉ាន់ ណាង**

## ពលករខ្មែរ៧៣១នាក់ជាប់គាំងតាមបន្ទាត់ព្រំដែនក្រោយបើកព្រំដែនធ្វើតេស្តឃើញវិជ្ជមានកូវីដ៨៣នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey១៣ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១៥:៣៧

បន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន៧៣១នាក់ ជាប់គាំងតាមបន្ទាត់ព្រំដែនក្រោយពេលរាជរដ្ឋាភិបាលកម្ពុជាបើកច្រកព្រំដែនយកសំណាកធ្វើតេស្តរកឃើញវិជ្ជមានកូវីដ១៩មានចំនួន៨៣នាក់ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២១ នៅភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

លោក វ៉ាន់ ដាវ៉ាន់ ប្រធានគណៈកម្មាធិការច្រកទ្វារព្រំដែនបឹងត្រកួនបានប្រាប់ថា៖ ក្រោយពេលរាជរដ្ឋាភិបាលកម្ពុជា បើកច្រកព្រំដែនកម្ពុជា.ថៃ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ក្រុមការងារច្រកព្រំដែនបឹងត្រកួនស្រុកថ្មពួកបានទទួលពលករខ្មែរ ដែលកំពុងជាប់គាំងនៅតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ រយៈពេល១៤ថ្ងៃ មានចំនួន៣៣៥នាក់ ស្រី១៥៣នាក់ កុមារចំនួន១៧នាក់ ដែលកំពុងពិនិត្យ និងយកសំណាកធ្វើតេស្តរហ័សរកឃើញវិជ្ជមានកូវីដ១៩ចំនួន៣៦នាក់ ។ ដោយឡែកនៅច្រករបឹងបេងស្រុកម៉ាឡៃ ក្រុមការងារបានទទួលពលករខ្មែរចំនួន ២០៩នាក់ យកសំណាកធ្វើតេស្តលទ្ធផលវិជ្ជមានកូវីដ១៩មានចំនួន៤០នាក់ ច្រកអូរបីជាន់ស្រុកអូរជ្រៅ ទទួលពលករខ្មែរចំនួន១៧៧នាក់ យកសំណាកធ្វើតេស្តបាន៧៧នាក់ លទ្ធផលវិជ្ជមានចំនួន៥នាក់ តាមបន្ទាត់ព្រំដែនភូមិសាស្ត្រក្រុងប៉ោយប៉ែត ទទួលពលករ១០នាក់ យកសំណាកធ្វើតេស្តលទ្ធផលវិជ្ជមានកូវីដ.១៩ចំនួន២នាក់ ។

លោកវេជ្ជ បណ្ឌិត រឿន សុធី អនុប្រធានមន្ទីសុខាភិបាលខេត្តបន្ទាយមានជ័យបានបញ្ជាក់ថា ៖ ក្រោយរាជរដ្ឋាភិបាលកម្ពុជាបើកច្រកព្រំដែនកម្ពុជា.ថៃ ដែលកំពុងជាប់គាំងតាមបន្ទាត់ព្រំដែន បានចូលស្រុកកំណើតវិញ ហើយក្រុមគ្រូពេទ្យបានសហការជាមួយក្រុមការងារយកសំណាកធ្វើតេស្តក្នុងចំណោម៧៣១នាក់ រកឃើញវិជ្ជមានកូវីដ.១៩មានចំនួន៨៣នាក់ ។ នៅខេត្តបន្ទាយមានជ័យរហូតដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ បានរកឃើញអ្នកវិជ្ជមានកូវីដ.១៩ប្រភេទដែលតា មានចំនួន៤៣នាក់ នៅក្នុងសហគមន៍៧នាក់ និងក្រុមគ្រូពេទ្យជួរមុខចំនួន៦នាក់ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា.ជប៉ុនមង្គលបូរី។

លោកវរៈសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការនគរបាលវរៈការពារព្រំដែនគោកលេខ៨០៧ ប្រាប់អោយដឹងថា ៖ ក្រោយពេលដែលរាជរដ្ឋាភិបាលកម្ពុជាបើកច្រកព្រំដែនកម្ពុជា.ថៃ កម្លាំងនគរបាលការពារព្រំដែនគោក

សហការជាមួយក្រុមការងារបានទទួលពលករខ្មែរជាប់គាំងតាមបន្ទាត់ព្រំដែនឈមស្រុកថ្មពួក ដើម្បីសម្រួលការយកសំណាកធ្វើតេស្ត ។ អគ្គស្នងការនគរបាលជាតិ បញ្ជាក់ថា ត្រូវពង្រឹងការទប់ស្កាត់ទប់ពលករចំណាក់ស្រុកលួចឆ្លងដែនចូលមកកម្ពុជាដែលគេចវេសពីធ្វើចត្តាឡីស័ក ដើម្បីបង្កាទប់ស្កាត់កូវីដ.១៩មិនអោយរាលដាលក្នុងសហគមន៍ដែលកូវីដ១៩ប្រភេទថ្មីដែលតា ៕

## **អាជ្ញាធរខេត្តកោះកុង ឃាត់ខ្លួនពលករខ្មែរ៩នាក់ ដែលលួចឆ្លងដែនខុសច្បាប់ចូលកម្ពុជា និងត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ**

http://freshnewsasia.com/ 2021-08-13 04:14pm

**(កោះកុង)៖** លោក សុវណ្ណ ប៊ុនធឿន ប្រធានទីស្នាក់ការច្រកទ្វារអន្តរជាតិចាំយាម ស្រុកមណ្ឌលសីមា ខេត្តកោះកុង បានឃាត់ខ្លួនពលករខ្មែរឆ្លងដែនតាមព្រៃភ្នំ ពីក្រោយទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ បានចំនួន៧នាក់ និងឆ្លងដែនតាមមាត់ច្រកទ្វារអន្តរជាតិចំនួន ២នាក់ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ។ លោក សុវណ្ណ ប៊ុនធឿន បានបន្តថា ដោយអនុវត្តន៍តាមអនុសាសន៍របស់រាជរដ្ឋាភិបាល និងការចង្អុលបង្ហាញពីលោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុងក្នុងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងកូវីដ១៩ បំប្លែងថ្មី Detal ពីប្រទេសជិតខាង គឺប្រទេសថៃ ដែលមានពលករសំណាក់ស្រុកខ្មែរ បានចូលទៅរកការងារធ្វើក្នុងប្រទេសថៃ ហើយដោយមានហានិភ័យខ្ពស់ចំពោះជំងឺកូវីដ១៩ ពលករខ្មែរ និងត្រូវវិលត្រឡប់ចូលស្រុកវិញ តែដោយមានការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩ បំប្លែងថ្មីក្នុងប្រទេសថៃ កំពុងមានហានិភ័យខ្ពស់ ហើយដើម្បីសុវត្ថិភាពប្រជាពលរដ្ឋក្នុងស្រុក។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិតព្រំដែនកម្ពុជា-ថៃ ចំនួន១៤ថ្ងៃ និងបន្តបិតបន្ថែមរយៈពេល ៧បន្ថែមទៀត រហូតដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១នេះ ប្រសិនបើជំងឺកូវីដ១៩ មានអាត្រាថយចុះនិងគ្មានកូវីដ១៩។ លោក សុវណ្ណ ប៊ុន ធឿន បានបន្តថា នៅក្នុងខែសីហានេះ សមត្ថកិច្ចប្រចាំការច្រទ្វារអន្តរជាតិចាំយាមបានឃាត់ខ្លួនពលករ ដែលលួចឆ្លងដែនកាត់ព្រៃភ្នំ ក្រោយទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិបានចំនួន៧នាក់ និងតាមច្រកទ្វារអន្តរជាតិចាំយាមបានចំនួន២នាក់។

លោកបានបញ្ជាក់ថា «**ការឃាត់ខ្លួនពលករខ្មែរនៅមាត់ច្រកទ្វារ គឺមិនមែនភាគីថៃបើកឲ្យចូលឆ្លងដែនចូលកម្ពុជាទេ គឺសមត្ថកិច្ចថៃកំពង់ត្រួតពិនិត្យទៅលើរថយន្តដឹកទំនិញតែត្រូវពលករខ្មែរយើងដើររសៀៗ របងហើយដើរចូលមកតែម្តង ពីសមត្ថកិច្ចថៃក៏មានបំរាមគោចរចរឹតបន្តឹងដែរ ចំពោះបញ្ហានេះហើយភាគីថៃ ក៏គោរពគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែរ ហើយចំពោះពលករលួចឆ្លងដែនតាមព្រៃភ្នំ ក្រោយទីស្នាក់ការត្រួតពិនិត្យត្រូវ សមត្ថកិច្ចឃាត់ខ្លួនបានចំនួន៧នាក់ ដោយមានការសហការណ៍ជាមួយសមត្ថកិច្ចយើងទើបឃាត់ខ្លួនបាន**»។ ចំពោះពលករទាំង៩នាក់ ក្រោយពីសមត្ថកិច្ចឃាត់ខ្លួនបានហើយបាននាំគាត់មកធ្វើតេស្តរហ័សនៅមណ្ឌលសុខាភាពប្រចាំមាត់ច្រកហើយធ្វើតេស្តរកមេរោគកូវីដ១៩ ហើយប្រគល់ខ្លួនគាត់ទៅឱ្យអធិការ និងមន្ត្រីសុខាភិបាល ដើម្បីធ្វើចត្តាឡីស័កនៅមណ្ឌលព្យាបាលបន្ត។ លោកបានបញ្ជាក់បន្ថែមថា មន្ត្រីសមត្ថកិច្ចពាក់ព័ន្ធប្រចាំការច្រកទ្វារអន្តរជាតិទាំងអស់ រួមទាំងសមត្ថកិច្ចប្រចាំការណ៍ទាំងសមត្ថកិច្ចជើងទឹកទាំងច្រកធម្មជាតិនានា បានចូលរួមសហការណ៍បានល្អជំប្រសើរ ក្នុងការរឹតបន្តឹងក្នុងការលួចឆ្លងដែន របស់ពលករ និងមានការទំនាក់ទំនងល្អជាមួយភាគីថៃ បានយ៉ាងល្អប្រសើរ។ នេះកាតព្វកិច្ចរបស់សមត្ថកិច្ចការពារខ្សែក្រវ៉ាត់ព្រំដែន ដើម្បីសុវត្ថិភាពប្រជាពលរដ្ឋ ក្នុងហានិភ័យកូវីដ១៩ ដែលជាជំងឺឆ្លងសកល៕

## ឃាត់ខ្លួនជនជាតិថៃ ៦ នាក់ បម្រុងលបឆ្លងដែនមកធ្វើការនៅក្នុងទឹកដីកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៣ សីហា ២០២១ដោយ Mey Soklim

ជនជាតិថៃចំនួន ៦ នាក់ ដែលក្នុងនោះមានប្រុសចំនួន ៥ នាក់ ផងនោះ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១១២ ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង ៥ ទៀបភ្លឺ ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២១ ត្រង់ចំណុចភូមិណងយ៉ាកែវ ឃុំគោកខ្សូង ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបំប្លែងខ្លួន ដែលតា ។

ជនជាតិថៃទាំង ៦ នាក់ គឺមានប្រុស ៥ នាក់ និងស្រី ១ នាក់ ដោយពួកគេមកពីខេត្តឈៀងម៉ៃ ៣ នាក់ ខេត្តរ៉ាក់យ៉ង ២ នាក់ និងទីក្រុងបាងកក ១ នាក់ ដោយគេបានសារភាពថា មកដល់ខេត្តស្រះកែវតាំងពីព្រលប់ថ្ងៃទី ១១ សីហា លុះពេលទៀបភ្លឺពួកគេក៏បានដើរឆ្លងថ្នល់ត្រង់ចំណុចក្បែរវត្តណងយ៉ាកែវ ដើម្បីទៅជួបនឹងមេខ្យល់ដែលជាជនជាតិខ្មែរ ក្នុងការនាំឆ្លងដែនតែត្រូវចាប់ខ្លួនទៅហើយ។ ពួកគេបានអះអាងថា ការលបឆ្លងដែននេះគឺអាចធ្វើអោយពួកគេសល់កម្រៃច្រើន ដោយចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត បើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ៕ អត្ថបទ : សោ និយមរ័ត្ន

## ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១

## ពលករខ្មែរជិត៤០០នាក់ វិលត្រឡប់មកពីថៃចូលស្រុកកំណើតវិញ ក្នុងខេត្តបាត់ដំបង ក្រោយរដ្ឋាភិបាលបញ្ចប់ការបិទខ្ទប់ព្រំដែន

http://freshnewsasia.com/ 2021-08-13 04:54pm

**(បាត់ដំបង)៖** លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងនាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ បានដឹកនាំអភិបាលរងខេត្ត ប្រធានមន្ទីរអង្គភាពជុំវិញខេត្ត ទទួលពលករមកពីប្រទេសថៃជិត ៤០០នាក់ នៅច្រកទ្វារតំបន់ព្រំដែនកម្ពុជា-ថៃ អូរអន្លក់ នៃស្រុកកំរៀង និងច្រករបៀង តាមបណ្តោយព្រំដែន ដែលពួកគាត់ទើបត្រឡប់មកពីថៃចូលស្រុកកំណើតវិញ។ ការសម្រុកចូលស្រុកកំណើតវិញនេះ ក្រោយពេលដែលរាជរដ្ឋាភិបាល បានសម្រេចបិទបញ្ចប់ការបិទព្រំដែន កម្ពុជា-ថៃ ដែលបានអនុវត្តរយៈពេល២សប្តាហ៍មកហើយនោះ។ លោក ងួន រតនៈ បញ្ជាក់ថា សម្រាប់ពលករដែលជាប់គាំងនោះ បានវិលត្រឡប់មកវិញមានចំនួន៣៩៩នាក់ ក្នុងនោះមកពីច្រកទ្វារតំបន់ព្រំដែនសួន ស៊ុ (អូរអន្លក់) នៃស្រុកកំរៀងចំនួន២៨៧នាក់ និងមួយច្រកទៀតមកពីតំបន់ ច្រករបៀងក្នុងស្រុកសំពៅលូនចំនួន១១២នាក់។

លោកថា សម្រាប់ពលករទាំងអស់ ដែលអនុញ្ញាតចូលមកស្រុកកំណើតវិញ ត្រូវបានរៀបចំចុះឈ្មោះ និងយកសំណាកតេស្តរហ័ស ក្នុងករណីមានលទ្ធផលវិជ្ជមាន ក្រុមការងារនឹងរៀបចំដាក់គាត់ព្យាបាលនៅតាមមណ្ឌលព្យាបាល តាមព្រំដែន ដែលអជ្ញាធរបានរៀបចំ។ ចំណែកអ្នកលទ្ធផលអវិជ្ជមាន នឹងដឹកជញ្ជូនពួកគាត់ធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក នៅតាមបណ្តោយព្រំដែនចំនួន១៤ថ្ងៃទៀត មុននឹងធ្វើការដឹកជញ្ជូនពួកគាត់ទៅបណ្តាស្រុកកំណើត រៀងៗខ្លួន។ លោកអភិបាលខេត្តបានថ្លែងទៀតថា ក្នុងដំណើរការបើកព្រំដែនឡើងវិញនេះ កងកម្លាំងយោធពលខេមរភូមិន្ទបានយករថយន្តដែលជាអំណោយរបស់សម្តេចនាយករដ្ឋមន្ត្រី ដឹកពលករដែលកំពុងជាប់គាំងនៅព្រំដែនក្នុងទឹកដីថៃទៅព្យាបាលជំងឺ( ករណីវិជ្ជមាន )និងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័កផងដែរ៕

## ពេញ១ថ្ងៃនេះ មានពលករខ្មែរមកពីប្រទេសថៃ ចូលកម្ពុជាវិញជិត១៤០០នាក់, រកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន១៤៩នាក់

http://freshnewsasia.com/ 2021-08-13 09:35pm

**(ភ្នំពេញ)៖** បើយោងតាមរបាយការណ៍របស់អាជ្ញាធរ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ បានញ្ជាក់ថា ក្នុងរយៈពេលពេញ១ថ្ងៃ ក្រោយរាជរដ្ឋាភិបាល បានបញ្ចប់ការបិទព្រំដែន មានពលករខ្មែរ ចំនួន១,៣៩០នាក់ ត្រឡប់ពីប្រទេសថៃ ចូលស្រុកកំណើតវិញនៅតាមបណ្តាខេត្តជាប់ព្រំដែន ដោយក្នុងចំណោមពលករទាំងនោះ អាជ្ញាធរ និងមន្ត្រីសុខាភិបាល បានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន១៤៩នាក់។ របាយការណ៍ដដែលបានឱ្យដឹងថា សម្រាប់អ្នកជំងឺកូវីដ១៩ ដែលត្រូវបានរកឃើញនាពេលនេះ ត្រូវបានបញ្ជូនទៅតាមមណ្ឌលព្យាបាលអ្នកជំងឺកូវីដ១៩។ ដោយឡែកសម្រាប់ពលករដែលពាក់ព័ន្ធជាមួយពលករដែលរកឃើញវិជ្ជមានជំងឺកូវីដ១៩ ក៏ត្រូវបានបញ្ជូនទៅកាន់មណ្ឌលធ្វើចត្តាឡីស័ក នៅតាមបណ្តាខេត្តជាប់ព្រំដែនរៀងៗខ្លួន។

សម្រាប់ថា នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ចប់ការបិទព្រំដែននៅតាមបណ្តាខេត្តជាមួយប្រទេសថៃ ក្រោយបិទខ្ទប់រយៈពេល១៤ថ្ងៃ ដើម្បីទប់ស្កាត់ការីករាលដាលជំងឺកូវីដ១៩។ សម្រាប់ថ្ងៃនេះ អាជ្ញាធរនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានសហការជាមួយកម្លាំងចម្រុះ និងមន្ត្រីសុខាភិបាល រៀបចំការធ្វើតេស្តរហ័ស ទៅលើពលករខ្មែរទាំងនោះ នៅច្រកព្រំដែនដែលពួកគេ ធ្វើដំណើរឆ្លងកាត់មុនបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក៕

## អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស សហការជាមួយ អាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ ថ្ងៃសុក្រ ទី១៣ ខែសីហា ឆ្នាំ២០២១

ខេត្តសៀមរាប៖ កាលពីព្រឹកថ្ងៃសុក្រ ទី១៣ ខែសីហា ឆ្នាំ២០២១នេះ អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់-CENTRAL) សហការជាមួយ មេឃុំ សំរោងយា និងអាជ្ញាធរមូលដ្ឋាន បានរៀបចំលើកបដាផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅតាមសាលាឃុំ ដែលស្ថិតនៅក្នុងឃុំសំរោងយា នៃស្រុកពួក ខេត្តសៀមរាប។ ដោយស្ថានភាពកូវីដ-១៩បានកំពុងរីករាលដាលទូទាំងពិភពលោករួមទាំងប្រទេសកម្ពុជាផងដែរ ដែលជាហេតុធ្វើអោយប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជាប្រឈមនឹងបញ្ហាផ្សេងៗរួមមានការចាញ់បោកខ្យល់ ការឆ្លងដែនដោយប្រថុយប្រថាននឹងគ្រោះថ្នាក់ និងប្រឈមពីការចាប់ខ្លួនពីសំណាក់អាជ្ញាធរថៃ។ អង្គការសង់ត្រាល់ចូលរួមផ្សព្វផ្សាយលើកបដា ក្នុងគោលបំណងខាងក្រោម៖

១. លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធិការងារគ្រប់រូបភាព។

២.កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈមគ្រោះថ្នាក់នៃអំពើជួញដូរមនុស្សនិងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗ។

៣.លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

អង្គការសង់ត្រាល់នឹងបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានតាមបណ្តាឃុំស្រុកខេត្តដទៃទៀត ដើម្បីផ្សព្វផ្សាយអប់រំពីសិទ្ធិការងារ ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិផ្សេងៗដែលពលរដ្ឋកម្ពុជាគួរយល់ដឹង។

## រកឃើញពលករវិជ្ជមានកូវីដដែលវិលចូលតាមច្រកអូរស្មាច់

https://kohsantepheapdaily.com.kh/  ១៤ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១០:៥៧

ខេត្តឧត្តរមានជ័យ ៖ ស្ថិតនៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ បើតាមលោកសមុទ្រ សុខនី គ្រូពេទ្យផ្នែកចត្តាឡីស័កប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់បានឱ្យដឹង គិតនៅព្រឹកថ្ងៃទី១៣ សីហា ថា នៅមាត់ច្រកទ្វារអន្តរជាតិអូរស្មាច់ ពលករខ្មែរបានវិលចូលស្រុកវិញមានចំនួន៧១នាក់ ។ លោកបន្តថា ពលករខ្មែរទាំង៧១នាក់ ត្រូវបានក្រុមគ្រូពេទ្យពិនិត្យនិងយកសំណាក ក៏រកឃើញវិជ្ជមានCOVID-19ម្នាក់ ត្រូវ បញ្ជូនទៅព្យាបាលភ្លាមៗ និងពលករផ្សេងៗបាននាំយកទៅធ្វើចត្តាឡីស័កទាំងអស់។ សូមបញ្ជាក់ថា រាជរដ្ឋាភិបាលមានវិធានការយ៉ាងតឹងរឹងបំផុតក្នុងការធ្វើដំណើរឆ្លងដែន ជាពិសេសទៅលើពលករខ្មែរដើម្បីទប់ស្កាត់ជំងឺរាតត្បាតCOVID-១៩ក្នុងសហគមន៍២០កុម្ភៈ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ កន្លងទៅរហូ តមកទល់ព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២១នេះ ត្រូវបានបើកឱ្យពលករខ្មែរ វិលចូលស្រុកជាធម្មតាឡើងវិញ ។

## ពលករខ្មែររាប់រយនាក់ចាប់ផ្ដើមវិលចូលស្រុក ខណៈដែលអាជ្ញាធរតាមព្រំដែនកំណត់វិធានការតឹងរឹង

https://www.rfi.fr/km/  ចុះផ្សាយនៅថ្ងៃ៖ 14/08/2021 - 09:05

*តាមគម្រោងនៃការបើកច្រកព្រំដែនអន្តរជាតិកម្ពុជា-ថៃ នៅថ្ងៃទី១៣សីហាម្សិលមិញ ខេត្តនៅតាមបណ្ដាខ្សែបន្ទាត់ព្រំដែនបានចាប់ផ្ដើមទទួលពលករខ្មែរជាបន្តបន្ទាប់មកក្នុងប្រទេសវិញ។ នៅចំពោះមុខនៃការវិលចូលវិញរបស់ពលករ អាជ្ញាធរនៅតាមព្រំដែនបានកណត់នូវវិធានការសុខាភិបាលយ៉ាងតឹងរឹងដើម្បីទប់ស្កាត់ការឆ្លងនៃជំងឺកូវីដ-១៩។ តាមអាជ្ញាធរខេត្ត ពលករទាំងអស់ត្រូវឆ្លងកាត់ការធ្វើតេស្តសំណាករហ័សរួចបញ្ជូនទៅកាន់ទីតាំងធ្វើចត្តាឡីស័ក ហើយជាបន្ទាប់រាល់សំណាកទាំងអស់នឹងបញ្ជូនមករាជធានីភ្នំពេញដើម្បីធ្វើតេស្តបន្ត រកវីរុសកូវីដ-១៩ប្រភេទ«ដែលតា»។*

ពីខេត្តបាត់ដំបង លោកអភិបាលងួន រតនៈ បានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិនៅព្រឹកថ្ងៃសៅរ៍ទី១៤សីហានេះថា ខេត្តបានទទួលពលករចំនួន៣៩៨នាក់ តាមច្រកព្រំដែនអន្តរជាតិអូរអន្លក់ក្នុងស្រុកកំរៀង និងតំបន់ច្រករបៀងក្នុងស្រុកសំពៅលូន ក្រោយការបើកច្រកព្រំដែនជាមួយនឹងប្រទេសថៃឡើងវិញកាលពីថ្ងៃទី១៣សីហាម្សិលមិញ។ ពលករខ្មែរទាំង៣៩៨នាក់នោះត្រូវបានធ្វើតេស្តរហ័សភ្លាមៗ ហើយជាលទ្ធផលមានពលករខ្មែរចំនួន២១នាក់មានវិជ្ជមានកូវីដ-១៩ ក៏ប៉ុន្តែលោកងួន រតនៈ មិនអាចបញ្ជាក់បានទេថាអ្នកវិជ្ជមានកូវីដ-១៩ទាំង២១នាក់នោះ មានប្រភេទ«ដែលតា»ឬយ៉ាងណា ព្រោះត្រូវបញ្ជូនសំណាកមកពិនិត្យបន្តនៅរាជធានីភ្នំពេញ។ ដោយឡែកសម្រាប់ពលករដែលចូលមកថ្ងៃនេះវិញ លោកថាមិនទាន់មានតួលេខបូកសរុបនៅឡើយនោះទេ។

នៅចំពោះមុខនៃការទទួលពលករខ្មែរចូលមកវិញជាគំហុកនេះ អភិបាលខេត្តបាត់ដំបងបានអះអាងពីវិធានការរដ្ឋបាលនិងវិធានការសុខាភិបាលយ៉ាងតឹងរឹងនៅតាមបណ្ដោយខ្សែបន្ទាត់ព្រំដែន ដោយតម្រូវឲ្យមានការធ្វើតេស្តសំណាក និងយាមល្បាតតាមច្រកព្រំដែនជាពិសេសនៅតាមច្រករបៀងនៃខេត្តបាត់ដំបង។ បើតាមលោក ងួន រតនៈ អាជ្ញាធរខេត្តនឹងទទួលពលករទាំងអស់ដែលចូលមកតាមច្រកនៃខេត្តបាត់ដំបង ទៅដាក់នៅទីតាំងចត្តាឡីស័កតាមបណ្ដាស្រុក ដែលបានត្រៀមស្រាប់ក្នុងការទុកដាក់ពលករបានប្រមាណ៨ពាន់នាក់ ហើយជាការអំពាវនាវលោកស្នើឲ្យពលករទាំងអស់សហការជាមួយអាជ្ញាធរ ដើម្បីឲ្យវិធានការទាំងអស់មានប្រសិទ្ធិភាព។

ដោយឡែកពីខេត្តឧត្តរមានជ័យឯណោះវិញ លោកឌី រ៉ាដូ អភិបាលរងខេត្តបានបញ្ជាក់ប្រាប់ដែរថា នៅច្រកព្រំដែនអន្តរជាតិអូរស្មាច់ កាលពីម្សិលមិញមានពលករខ្មែរតែ៧១នាក់ប៉ុណ្ណោះ ដែលបានរង់ចាំនិងចូលមកកម្ពុជាវិញ។ ក្នុងនោះដែរ តាមរយៈការយកសំណាកភ្លាមៗ មានពលករម្នាក់មានវិជ្ជមានកូវីដ-១៩។

ទាំងខេត្តបាត់ដំបង ទាំងខេត្តឧត្តរមានជ័យ សុទ្ធតែបានអះអាងថា ខេត្តនឹងទទួលពលករឲ្យចូលមកកម្ពុជាដោយមិនមានកំណត់ចំនួនថានឹងទទួលត្រឹមចំនួនប៉ុន្មានជាប្រចាំថ្ងៃនោះទេ។ ពោលគឺច្រកព្រំដែននឹងទទួលពលករខ្មែរទាំងអស់ ទាំងស្របច្បាប់និងមិនស្របច្បាប់ រហូតដល់ច្រកព្រំដែនត្រូវបិទនៅម៉ោង៦ល្ងាច។

គួរបញ្ជាក់ថា ខេត្តចំនួន៨រួមមាន បាត់ដំបង ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន ព្រះវិហារ ពោធិ៍សាត់ កោះកុង និងសៀមរាប ត្រូវបានប្រមុខរដ្ឋាភិបាលកម្ពុជាសម្រេចឲ្យរៀបចំបើកទទួលពលករខ្មែរមកក្នុងស្រុកវិញនៅថ្ងៃទី១៣សីហាម្សិលមិញ បន្ទាប់ពីមានការបិទខ្ទប់រយៈពេល១៤ថ្ងៃកន្លងទៅ។ ជាវិធានការចំពោះមុខនេះ ខេត្តទាំងនោះបានរៀបចំទីតាំងចត្តាឡីស័ក ទីតាំងសម្រាកព្យាបាល និងការចាក់វ៉ាក់សាំងដូសទី៣ដល់បណ្ដាក្រុមជួរមុខដើម្បីបង្ការការឆ្លងជំងឺកូវីដ-១៩ ជាពិសេសប្រភេទ«ដែលតា»៕

## រយៈពេល០២ថ្ងៃ នគរបាលប៉ុស្តិ៍បឹងសាគូ ឃាត់ពលករខ្មែរ បានចំនួន ២៨ នាក់ ធ្វើតេស្តវិជ្ជមាន ០៨ នាក់

http://www.fridaydailynews.com/ Sat,14 August 2021 (Time 01:21 PM)ដោយ ៖ លោក រ៉ែម សាវី

បន្ទាយមានជ័យ ÷ ដោយមានការយកចិត្តទុកដាក់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និង យកចិត្តទុកដាក់ ពី លោកវរសេនីយ៍ឯក សួរ ចាន់ណារី មេបញ្ជាការ នគរបាលការពារព្រំដែនគោក៩១១ និងយកចិត្តទុកដាក់អនុវត្តន៍ តាមបទបញ្ជារ គឺលោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍បឹងសាគូ តែងតែដឹកនាំកម្លាំង ធ្វើការសហការជាមួយកម្លាំងចម្រុះ ដើរល្បាត និងធ្វើការឃាត់ខ្លួនពលករខ្មែរ ដែលលួចឆ្លងដែនពីប្រទេសថៃ ចូលកម្ពុជាបានជាបន្តបន្ទាប់។

ដោយយោងតាមប្រភពពីលោក វរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍ បឹងសាគូ នៃវរសេនាតូចការពារព្រំដែនគោក៩១១ បានប្រាប់សារព័ត៌មាន Friday Daily News យើងឲ្យដឹងនៅព្រឹកថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១នេះថា ក្នុងរយៈពេល២ថ្ងៃ កម្លាំងរបស់លោក បានសហការជាមួយកម្លាំងចម្រុះធ្វើការឃាត់ខ្លួនពលករខ្មែរបានចំនួន ២៨នាក់ ស្រី ០៦ នាក់ និង កុមារ ចំនួន ០៣ នាក់ ។ ក្នុងនោះលោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ បានឲ្យដឹងទៀតថា កាលពីថ្ងៃទី ១៣ ខែសីហា គឺឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែន ដោយ ខុសច្បាប់ ពីប្រទេសថៃ ចូល ប្រទេស កម្ពុជា បានចំនួន ១១នាក់ និង យប់ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២១នេះ ឃាត់ខ្លួនពលរដ្ឋខ្មែរ ឆ្លងដែន ដោយខុសច្បាប់ ពីប្រទេសថៃ ចូល ប្រទេសកម្ពុជា បានចំនួន ១៧ នាក់បន្ថែមទៀត ។

លោកបន្ថែមថា ពលកខ្មែរដែលកម្លាំងប៉ុស្តិ៍បឹងសាគូ សហការជាមួយកម្លាំងចម្រុះឃាត់បានរយៈពេល២ថ្ងៃ មានចំនួន ២៨ នាក់នោះ បន្ទាប់ពីសួរនាំរួច កម្លាំងរបស់លោក បានបញ្ជូន ទៅយកសំណាក នៅស្ថានីយរថភ្លើង ក្នុងក្រុងប៉ោយប៉ែត ដោយធ្វើតេស្តជាមួយឧបករណ៍ Rapid លទ្ធផលឃើញថា វិជ្ជមាន ៨នាក់ ( បញ្ជាក់ នៅថ្ងៃទី ១៣ ខែសីហា វិជ្ជមាន០៤នាក់ និង ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២១នេះ វិជ្ជមាន ០៤នាក់) ។ លោកនាយប៉ុស្តិ៍បឹងសាគូ បានបន្តថា ពលករខ្មែរ ទាំង២៨នាក់នោះ បន្ទាប់ពីធ្វើតេស្តរហ័សរួច អ្នកដែលវិជ្ជមាន០៨នាក់នោះ ត្រូវបានបញ្ជូនទៅព្យាបាល នៅទីតាំងមួយកន្លែងក្នុងក្រុងប៉ោយប៉ែតឈ្មោះ "តាំងប៊ុនហេង" និងលទ្ធផល អវិជ្ជមាន ចំនួន ២០នាក់ រួមជាមួយ កុមារ ០៣នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យនិមិត្ត ៕

## ក្រុមកម្មករ អាជីវករ និងពលករខ្មែរនៅថៃជាង ៦០០នាក់ ប្រមូលផ្តុំគ្នាទាមទារត្រឡប់មកស្រុកខ្មែរវិញ

https://cen.com.kh/ Posted ByPen Srey NeatAugust 14, 2021

ភ្នំពេញ ៖ ក្រុមកម្មករ និងពលករខ្មែរនៅប្រទេសថៃជាង ៦០០នាក់ ក្នុងនោះមានក្រុមកម្មករ អាជីវករនៅផ្សាររុងក្លឿ និងពលករ កម្មករមួយចំនួនទៀត មកពីបាងកក និងបណ្តាខេត្តផ្សេងៗ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២១ នេះ បានប្រមូលផ្តុំគ្នាទាមទារត្រឡប់មកស្រុកខ្មែរវិញ។

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោកកុយ គួង បានឲ្យដឹងថា នៅថ្ងៃទី១៤ ខែសីហានេះ ស្ថានអគ្គកុងស៊ុលនៅស្រះកែវ បានចុះទៅសម្រួលដល់ក្រុមកម្មករអាជីវករនៅផ្សាររុងក្លឿដែលបានមកប្រមូលផ្តុំគ្នាទាមទារត្រឡប់មកស្រុកខ្មែរវិញ និងពលករកម្មករមួយចំនួនទៀត មកពីបាងកក និងបណ្តាខេត្តផ្សេងៗ ត្រូវបានក្រុមមេខ្យល់ដឹកមកទម្លាក់ចោល នៅមុខស្ថានអគ្គកុងស៊ុលតាំងពីរំលងអធ្រាត្រយប់មិញនេះ។ លោកបានបន្តថា ចំពោះករណីនេះ លោកអគ្គកុងស៊ុលកម្ពុជា បានជួបនិងធ្វើការសម្របសម្រួល ជាមួយអាជ្ញាធរខេត្តនិងសមត្ថកិច្ច ថៃ បានការឯកភាពនិងបានជួលរថយន្ត ដឹកបងប្អូនកម្មករនិងពលករខាងលើ មានចំនួន ៥៨៨នាក់ ស្រី១៥០នាក់ និងអ្នកមកពីបណ្តាខេត្តនានា ២៦នាក់ ស្រី១៥នាក់ សរុប ៦១៤នាក់ នាំពួកគាត់ចេញតាមច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដើម្បីប្រគល់ជូនសមត្ថកិច្ចខ្មែរ យកពួកគាត់ទៅត្រួតពិនិត្យ និងធ្វើចត្តាឡីស័កបន្ត៕ ចេស្តារ

## ពលករចំណាកស្រុក ២៤ នាក់ក្នុងចំណោម ២៨៦ នាក់ដែលឆ្លងព្រំដែនបានធ្វើតេស្តវិជ្ជមាន នៅស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃសុក្រ

https://www.khmertimeskh.com/ Khmer August 14, 2021

ស្រុកកំរៀង (បាត់ដំបង)៖ ពលករចំណាកស្រុកសរុបចំនួន ២៤ នាក់ក្នុងចំណោម ២៨៦ នាក់ដែលបានបោះជំរំនៅប្រទេសថៃរហូតដល់ ២ សប្តាហ៍នោះ មាន ២៤ នាក់ត្រូវបានគេធ្វើតេស្តរកឃើញមានមេរោគកូវីដ-១៩ នៅពេលពួកគេឆ្លងកាត់បុស្តិ៍ត្រួតពិនិត្យ នៅភូមិ អូរអន្លក់ កាលពីព្រឹកថ្ងៃសុក្រ។

អភិបាលខេត្តបាត់ដំបង លោក ងួន រតនៈ បានប្រាប់ខ្មែរថាមស៍ថា ពួកគេបានត្រៀមខ្លួនដើម្បីទទួលពលករចំណាកស្រុកដែលបានវិលត្រលប់មកវិញរហូតដល់ ៥០០ នាក់ ហើយរំពឹងថាចំនួនបន្ថែមទៀតនឹងមកដល់នៅព្រឹកថ្ងៃសៅរ៍នេះ។ ការធ្វើតេស្តរហ័សនៅនឹងកន្លែង នៅពេលណាដែលពួកគេឆ្លងកាត់ព្រំដែនចូលមកក្នុងទឹកដីកម្ពុជាគឺជាដំណើរការថ្មីមួយដែលបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណអ្នកវិលត្រឡប់មកវិញមានវិជ្ជមានជំងឺកូវីដ -១៩ ជាជាងបញ្ជូនពួកគេទៅមណ្ឌលចត្តាឡីស័ក និងទាក់ទងជាមួយអ្នកដទៃ។ លោកបានមានប្រសាសន៍ថា "វិធីនេះ យើងបានកាត់ផ្តាច់អ្នកមកដល់ថ្មីទាំងនេះដែលជាជនសង្ស័យខ្ពស់ផ្ទុកវីរុសបំប្លែងខ្លួនប្រភេទថ្មី Delta នៃមេរោគ SARS-CoV-2 ពីអ្នកផ្សេងទៀត ដែលទើបតែត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក ក្រោយពីបានធ្វើតេស្តអវិជ្ជមានហើយកំពុងអនុវត្តការដាក់ឱ្យនៅដាច់ដោយឡែករយៈ ១៤ ថ្ងៃ" ។ លោកបានបន្ថែមថា សំណាកដែលយកពីករណីវិជ្ជមាននឹងត្រូវបញ្ជូនទៅភ្នំពេញដើម្បីធ្វើតេស្ត PCR និងធ្វើវិភាគកំណត់អត្តសញ្ញាណករណីវីរុសបំប្លែងខ្លួនថ្មី Delta ដោយសារមានអ្នកឆ្លងវីរុស Delta នេះ ចំនួន ៥ នាក់រួចហើយ នៅសាលាវិទ្យាល័យកំរៀង។

លោកបាននិយាយថា ពីមុនរថយន្តដឹកកងទ័ពបានមកទទួលពលករ នៅពេលពួកគេឆ្លងកាត់ព្រំដែនហើយនាំពួកគេទៅមណ្ឌលចត្តាឡីស័កដែលនៅទីនោះ ពួកគេបានរៀបចំជាកញ្ចប់ជំនួយដែលមានសម្ភារចាំបាច់ និងបញ្ជូនទៅបន្ទប់ដែលនៅទំនេរ។ "ប៉ុន្មានម៉ោងក្រោយមក ពួកគេត្រូវបានធ្វើតេស្តរកមេរោគកូវីដ-១៩។ ទោះយ៉ាងណាក៏ដោយ សាលាវិទ្យាល័យកំរៀងត្រូវបានផ្លាស់ប្តូរទៅជាមណ្ឌលព្យាបាលដែលមានលក្ខណៈពេញលេញ ហើយ

មណ្ឌលចត្តាឡីស័កទាំងអស់ បច្ចុប្បន្ននេះទទួលយកតែពលករចំណាកស្រុកដែលត្រូវបានធ្វើតេស្តអវិជ្ជមានតាមរយៈការធ្វើតេស្តរហ័សប៉ុណ្ណោះ។ "យើងមិនរើសអើងទេ។ ការធ្វើតេស្តនៅតែអនុវត្ត។ ភាពខុសគ្នាគឺ ឥឡូវនេះ ការធ្វើតេស្តត្រូវបានអនុវត្តភ្លាមៗលើជនចំណាកស្រុកដែលឆ្លងកាត់ព្រំដែន មុនពេលពួកគេត្រូវបានអនុញ្ញាតឱ្យធ្វើចត្តាឡីស័ក។ "ជាមួយនឹងការរីករាលដាលនៃវីរុសបំប្លែងខ្លួនថ្មី Delta និងការឆ្លងជំងឺកូវីដ-១៩ មានចំនួនខ្ពស់នៅខេត្តបាត់ដំបងនាពេលចុងក្រោយនេះ យើងមិនអាចប្រថុយនឹងការចម្លងពោគរបស់អ្នកចំណាកស្រុកត្រឡប់មកវិញបានទេ។ ដូច្នេះ ការធ្វើតេស្តទ្រង់ទ្រាយធំនៅព្រំដែន និងអ្នកដែលរកឃើញវិជ្ជមានត្រូវបានបញ្ជូនទៅមណ្ឌលព្យាបាល ហើយអាចត្រូវបានដាក់ឱ្យនៅដាច់ឆ្ងាយពីគេ នៅពេលលទ្ធផលវិភាគតេស្តពីភ្នំពេញ ជាករណីវិជ្ជមានប្រភេទវីរុសបំប្លែងខ្លួនថ្មី Delata"។

## នគរបាលស្រុកភ្នំព្រឹក ឃាត់ខ្លួនមេខ្យល់២នាក់ ព្យាយាមនាំពលករ លួចឆ្លងដែនចូលទៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatAugust 15, 2021

បាត់ដំបង ៖ អនុវត្តតាមការចង្អុលដឹកនាំ របស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ទោ ហេង បារាំង អធិការនៃអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹកដឹកនាំកម្លាំងរួមសហការជាមួយ កម្លាំងកងពលលេខ៥៣ កម្លាំងផ្នែកសឹករងស្រុកភ្នំព្រឹកនិងកម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនអូរវែ្ជល នៃវរៈសេនាតូចការពារព្រំដែនគោកលេខ៨១៩ បានឃាត់ខ្លួនពលរដ្ឋ២នាក់ កំពុងព្យាយាមនាំពលករលួចឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ ។

ប្រតិបត្តិការនេះ សមត្ថកិច្ចធ្វើនៅពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោ ង២០និង៣០នាទី នៅចំណុចក្រោយរបងកាស៊ីណូ ស្ថិតក្នុងភូមិអូរថ្មី ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។ មេខ្យល់ទាំង២នាក់ដែលឃាត់ខ្លួនមានឈ្មោះ កេ វណ្ណៈ ភេទប្រុស អាយុ៣៥ឆ្នាំ មានទីលំនៅភូមិអូរថ្មី ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង និង២.ឈ្មោះ ឃឿង ដន ភេទស្រី អាយុ២៩ឆ្នាំ មានទីលំនៅភូមិជ្រោយពោន ឃុំកំពង់ឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ ។ ក្រោយពេលឃាត់បានសមត្ថកិច្ចសាកសួររួចមក ឈ្មោះ កេ វណ្ណៈ បានសារភាពថាខ្លួនពិតជាបាននាំពលករលួចឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ពិតប្រាកដមែន ។ បច្ចុប្បន្ន សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនពួកគេ ទៅកាន់ការិយាល័យជំនាញអនុវត្តតាមផ្លូវច្បាប់ ៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## ពលករខ្មែរ ៦១៤នាក់ ចូលដល់កម្ពុជាតាមច្រកបន្ទាយមានជ័យ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានអគ្គកុងស៊ុលនៅសាកែវ បានចុះទៅសំរួលដល់ក្រុមកម្មករ អាជីវករនៅផ្សាររ៉ុងគ្លឿ ដែលបានមកប្រមូលផ្តុំគ្នាទាមទារ ត្រឡប់មកស្រុកខ្មែរវិញ និងពលករកម្មករមួយចំនួនទៀត មកពីបាងកក និងបណ្តារខេត្តផ្សេងៗ ត្រូវបានក្រុមមេខ្យល់ដឹកមកទម្លាក់ចោល នៅមុខស្ថានអគ្គកុងស៊ុល តាំងពីរំលងអាធ្រាតយប់ថ្ងៃទី១៣ សីហា។ ចំពោះករណីនេះ អគ្គកុងស៊ុលកម្ពុជា បានជួប និង ធ្វើការសម្របសម្រួលជាមួយអាជ្ញាធរខេត្ត និង សម្ថកិច្ចថៃ បានការឯកភាពជួលរថយន្តដឹកបងប្អូនកម្មករ និង ពលករចំនួន៥៨៨នាក់ ក្នុងនោះស្រី ១៥០នាក់ និងអ្នកមកពីបណ្តារខេត្តនានា២៦នាក់ ស្រី ១៥នាក់ សរុប ៦១៤នាក់ នាំពួកគាត់ចេញតាមច្រកអូបីជាន់ ក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជយ័ ដើម្បីប្រគល់ជូនសម្ថកិច្ចខ្មែរ យកពួកគាត់ទៅត្រួតពិនិត្យ និង ធ្វើចត្តាឡីសក្ក័បន្ត៕

# អភិបាលខេត្តប៉ៃលិនស្តីបន្ទោសក្រុមជួញដូរមនុស្សនាំខុសខាងព្រំដែន

https://www.khmertimeskh.com/ Khmer Times 14/08/2021

**ប៉ៃលិន៖** អភិបាលខេត្តប៉ៃលិន លោកស្រី បាន ស្រីមុំ បានថ្កោលទោសក្រុមជួញដូរមនុស្សដែលបានបោកបញ្ឆោតពលរដ្ឋក្រីក្រ និងទន់ខ្សោយ ដោយរៀបចំគ្រោងការទុច្ចរិត ដើម្បីប្រាក់ដោយសន្យាថា នឹងទទួលបានការងារមានប្រាក់ខែខ្ពស់នៅប្រទេសថៃ។ ថ្លែងទៅកាន់ខ្មែរថាមស៍នៅថ្ងៃសុក្រនេះ លោកស្រីបាននិយាយថា "មានឈ្មួញកណ្តាលពិតប្រាកដ ដែលដើរតួជាភ្នាក់ងារ និងជាអ្នកជ្រើសរើសឱ្យនិយោជកមានសក្តានុពលនៅប្រទេសថៃ ជាពិសេសការងារនៅផ្សារ ចម្ការផ្លែឈើ កសិដ្ឋាន កសិកម្មផ្សេងទៀត រោងចក្រ និងខាងសំណង់។ "ពលករដែលបានទៅប្រទេសថៃដោយស្របច្បាប់ចង់វិលត្រឡប់ទៅកន្លែងធ្វើការវិញ ដោយសារពួកគេត្រូវបានគេសន្យាថានឹងបន្តការងារ នៅពេលដែលពួកគេត្រឡប់ទៅវិញ ក្រោយពីជំងឺឆ្លងរាតត្បាត និងការចាក់វ៉ាក់សាំងរួច។ បម្រាបគោចរនៅទីនោះ និងការលំបាកផ្សេងទៀតធ្វើឱ្យពលករចំណាកស្រុកបន្តរស់នៅប្រទេសថៃយ៉ាងលំបាក។

លោកស្រីបាននិយាយថា "នៅពេលពួកគេត្រឡប់មកវិញរាល់លើក វាស្រដៀងនឹងពួកគេរើផ្ទះអ៊ីចឹង គឺពួកគេនាំយកអ្វីៗទាំងអស់មកជាមួយដែលធ្វើឱ្យយើងស្រមៃឃើញស្ថានភាពលំបាកចាត់ចែង និងគ្រប់គ្រង ដោយសារយើងចាំបាច់ត្រូវមានឡានដឹកទំនិញជាច្រើនគ្រឿង និងកន្លែងទុកដាក់ឥវ៉ាន់ផ្ទាល់ខ្លួនរបស់ពួកគេ ដែលរួមមានសត្វមាន់ទា និងសត្វចិញ្ចឹម។ "លោកស្រីបាននិយាយថា លោកស្រីខឹងមេខ្យល់បោកប្រាស់ដែលទើបតែទុកពលករចោលក្រោយពីបាននាំពួកគេឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងដោយក្តីអាណិតអាសូរពីអាជ្ញាធរថៃដែលអាចជ្រើសរើសបញ្ជូនពួកគេត្រឡប់ទៅព្រំដែនវិញហើយប្រាប់យើងឱ្យដឹង ឬអាចឃុំខ្លួនពួកគេ។ លោកស្រី បាន ស្រីមុំបានចង្អុលបង្ហាញថា បន្ទាប់ពីការបិទព្រំដែនត្រូវបានអនុវត្តនៅគ្រប់ខេត្តទាំង ៧ ដែលមានព្រំដែនជាប់នឹងប្រទេសថៃ លោកស្រីបានទាក់ទងជាមួយសមភាគីថៃរបស់លោកស្រីអភិបាលខេត្ត ចន្ទាបូរី (Chanthaburi) ហើយបានឱ្យដឹងថាពលករចំណាកស្រុកដែលវិលត្រឡប់មកវិញទាំងអស់នឹងត្រូវធ្វើតេស្តភ្លាមៗនៅពេលឆ្លងកាត់ព្រំដែន ហើយនឹងត្រូវបានចាត់ទុកជាអ្នកផ្ទុកវីរុសបំប្លែងខ្លួនថ្មី Delta នៃមេរោគ SARS-CoV-2 និងការសហការរបស់ភាគីថៃក្នុងការព្យាបាលពលករដោយសប្បុរស។

"លោក អភិបាលបានផ្តល់ព័ត៌មានឱ្យខ្ញុំដឹងអំពីការព្យាបាលដែលបានផ្តល់ដល់ប្រជាពលរដ្ឋរបស់យើងនៅក្នុងប្រទេសថៃ ហើយវាជាកាយវិការល្អនិងមានមនុស្សធម៌ ហើយវាមិនដូចអ្វីដែលជាការចោទប្រកាន់របស់មនុស្សគ្មានការទទួលខុសត្រូវមួយចំនួនកេងចំណេញលើការផ្សព្វផ្សាយមិនល្អ ដោយបំប៉ោងបញ្ហាតូចតាចអំពីការថៃទាំ។ លោកស្រីបាននិយាយថា "មនុស្សទាំងនេះក៏ជាមេខ្យល់ដែលជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូនពលករទៅប្រទេសថៃដោយខុសច្បាប់ និងបោះបង់ចោលពលករ នៅពេលដែលពួកគេប្រឈមមុខនឹងការដើរល្បាតតាមព្រំដែន ឬមន្ត្រីសន្តិសុខថៃ។ នេះគឺជាចរិតអាត្មានិយម មិនទទួលខុសត្រូវ និងគ្មានបេះដូង"។ លោកស្រី បាន ស្រីមុំ បានសង្កត់ធ្ងន់ថា ការបិទខ្ទប់នេះក៏អាចឱ្យអាជ្ញាធរខេត្តពិនិត្យ និងរៀបចំយុទ្ធសាស្ត្រនៃវិធានការរបស់ពួកគេឡើងវិញ ដើម្បីធានាការគ្រប់គ្រងពលករចំណាកស្រុកត្រឡប់មកវិញឱ្យបានល្អប្រសើរ រៀបចំកន្លែងបន្ថែមសម្រាប់ពួកគេ ព្រោះពួកគេជាច្រើននាក់បានរង់ចាំនៅចំណុចឆ្លងកាត់ព្រំដែនក្នុងប្រទេសថៃអស់រយៈពេលជាងពីរសប្តាហ៍មកហើយ ដែលចំនួននេះត្រូវបានគេរំពឹងថានឹងខ្ពស់ជាងមុន។

"យើងបានរៀបចំខ្លួននិងចាត់ចែងបានល្អ និងបានទទួលជំនួយយ៉ាងច្រើនពីនាយករដ្ឋមន្ត្រីដែលយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពលករចំណាកស្រុករបស់យើងនៅប្រទេសថៃ។ ការបិទខ្ទប់គឺចាំបាច់ដើម្បីទប់ស្កាត់ការកើនឡើងករណីឆ្លង ជាពិសេសវីរុសបំប្លែងខ្លួនថ្មី Delta ហើយការបិទខ្ទប់រយៈពេលពីរសប្តាហ៍បានជួយបញ្ចៀស

បញ្ហានេះ។ លោកស្រី បាន ស្រីមុំ បាននិយាយថា "ការបិទនេះក៏ផ្តល់ឱ្យយើងនូវពេលវេលាគ្រប់គ្រាន់ដើម្បីសម្អាតមជ្ឈមណ្ឌលចត្តាឡីស័ក និងធ្វើអនាម័យមណ្ឌលទាំងនោះដើម្បីទទួលអ្នកមកដល់ថ្មី ចាប់ពីថ្ងៃទី ១៣ ខែសីហា"៕

## មានច្រកព្រំដែនខុសច្បាប់ចំនួនរហូតដល់ ២៩ កន្លែង រវាងខេត្តប៉ៃលិន និងខេត្តចន្ទបូរី (Chanthaburi) ប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times August 15, 2021

កិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីសាលាក្រុងប៉ៃលិន ជាពិសេសអភិបាលខេត្ត បាន ស្រីមុំ និងអភិបាលខេត្តចន្ទបូរី (Chanthaburi) របស់ប្រទេសថៃបានជំរុញឱ្យមានការបិទច្រកព្រំដែនខុសច្បាប់ទាំងអស់ ចំនួន ២៩ រវាងខេត្តប៉ៃលិន ប្រទេសកម្ពុជា និងខេត្ត Chanthaburi ក្នុងប្រទេសថៃ ទាំងស្រុងចាប់តាំងពីថ្ងៃទី ២៩ ខែកក្កដាឆ្នាំ ២០២១ ។ មានច្រកឆ្លងកាត់ផ្លូវការតែមួយប៉ុណ្ណោះសម្រាប់ប្រជាពលរដ្ឋ គិតត្រឹមថ្ងៃទី ១៣ ខែសីហា នៅពេលដែលច្រកឆ្លងកាត់ព្រំដែនបានបើកឡើងវិញ ហើយក្រុមពលករចំណាកស្រុកចំនួន ១៥៩ នាក់ដំបូងបានឆ្លងកាត់។ ក្នុងចំណោមនោះ ១៤ នាក់ត្រូវបានធ្វើតេស្តវិជ្ជមាន តាមរយៈការធ្វើតេស្តរហ័សដែលបានធ្វើឡើងនៅឯកន្លែងធ្វើតេស្តច្រកព្រំដែនព្រំ។

លោកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិនបានមានប្រសាសន៍ថា កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់កងកម្លាំងសន្តិសុខព្រំដែនកម្ពុជា និងកងកម្លាំងសន្តិសុខព្រំដែនថៃ បាននាំឱ្យមានការបិទច្រកឆ្លងកាត់ព្រំដែនខុសច្បាប់ទាំងស្រុង។ "គ្មាននរណាម្នាក់បានឆ្លងកាត់ក្នុងកំឡុងពេលជាប់គាំងទេ ហើយច្រកឆ្លងកាត់ទាំង ២៩ នេះនៅតែត្រូវបានបិទយ៉ាងតឹងរឹង ដើម្បីធានាថា គ្មានការលួចឆ្លងដែនខុសច្បាប់ ឬមានសកម្មភាពរត់ពន្ធមនុស្ស។ នេះមានសារៈសំខាន់ណាស់ក្នុងការការពារប្រជាពលរដ្ឋ ខេត្ត និងទីក្រុងរបស់យើង ដោយសារស្ថានភាពឆ្លងរាលដាលធ្ងន់ធ្ងរនៃវីរុសបំប្លែងខ្លួនប្រភេទថ្មី Delta នៅក្នុងប្រទេសថៃ" ។ លោកស្រីបានបន្ថែមថា ការស៊ើបអង្កេតបានបង្ហាញថា ឈ្មួញកណ្តាល ឬអ្នកជួញដូរមនុស្សបានទារប្រាក់យ៉ាងច្រើនពីប្រជាពលរដ្ឋកម្ពុជា និងជនជាតិថៃដែលចង់ឆ្លងដែនតាមមធ្យោបាយណាមួយហើយជាធម្មតាបោះបង់ពួកគេចោលនៅពេលប្រឈមមុខឬធ្លាក់ចូលដោយកម្លាំងល្បាតព្រំដែន។ ជាធម្មតា អ្នកដែលចាប់បានគឺជាជនរងគ្រោះដោយសារអ្នករត់ពន្ធតែងតែរត់គេចខ្លួន ហើយពួកគេមាន ប្រភពបណ្តាញព័ត៌មានផ្ទាល់ខ្លួនពីសមភាគីរបស់ពួកគេនៅតាមព្រំដែនទាំងពីរ។

លោកស្រី បានស្រីមុំបាននិយាយ "យើងកំពុងតាមដានសកម្មភាពខុសច្បាប់ទាំងនេះយ៉ាងជិតដល់ ហើយនឹងចាត់វិធានការនៅពេលប្រមូលបានភស្តុតាង និងព័ត៌មានគ្រប់គ្រាន់។ បច្ចុប្បន្ននេះ សកម្មភាពខុសច្បាប់ទាំងនេះគឺជាការគំរាមកំហែងថ្នាក់ជាតិ ព្រោះអ្នករត់ពន្ធមិនត្រឹមតែអាចរត់ពន្ធករណីវិជ្ជមានកូវីដ-១៩ ប្រភេទថ្មី Detla ប៉ុណ្ណោះទេ ថែមទាំងថ្នាំញៀន និងសារជាតុខុសច្បាប់ដទៃទៀត។ "ខេត្តប៉ៃលិនគឺជាក្រុងជួរមុខមួយ ហើយនៅពេលពួកគេឆ្លងកាត់ចូលក្នុងក្រុងរបស់យើង ពួកគេមានភាពងាយស្រួលឆ្លងកាត់ទៅតំបន់ផ្សេងទៀតនៃប្រទេស។ យើងត្រូវតែ ហើយនឹងខិតខំឱ្យអស់ពីសមត្ថភាពដើម្បីទប់ស្កាត់ និងលុបបំបាត់គ្រប់ពេលវេលា"។

ពលករចំណាកស្រុកដែលបានវិលត្រឡប់មកប្រទេសវិញបាននិយាយថា ពួកគេបង់ប្រាក់ចំនួន ១,០០០ បាត រហូតដល់ ៨,០០០ បាត សម្រាប់មនុស្សម្នាក់ៗ ដើម្បីឆ្លងដែនខុសច្បាប់ចូលមកកម្ពុជា ឬទៅប្រទេសថៃដើម្បីស្វែងរកការងារធ្វើ។ ពលករ ចំណាកស្រុកវិលត្រឡប់មកវិញមួយចំនួនបាននិយាយនៅផ្សារ សោភ័ណ្ឌ កាលពីថ្ងៃសៅរ៍ថា "ប្រសិនបើយើងមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនច្រើន ពួកគេគិតថ្លៃបន្ថែមពីយើងសម្រាប់ថ្លៃដឹកជញ្ជូនហើយយើងត្រូវបង់ ព្រោះយើងគ្មានជម្រើស។ យើងបានធ្វើដូចនេះនៅតាមព្រំដែនអស់រយៈពេលជាយូរមកហើយ"៕

## ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

### ប្រទះឃើញប្រុសស្រី និងកុមារ សរុប១៥នាក់ កំពុងពួនក្នុងព្រៃ លុះសួរនាំទើបដឹង

https://kohsantepheapdaily.com.kh/ Banteay Meanchey១៥ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១០:៤៥

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋប្រុសស្រី មានទាំងកុមារផងសរុបចំនួន១៥នាក់ ត្រូវបានកម្លាំងប៉ុស្តិ៍បឹងសាគួ នៃនគរបាលការពារព្រំដែនគោកលេខ៨១១ សហការជាមួយកម្លាំងចម្រុះជួរមុខធ្វើកាឃាត់សួរនាំខណៈឃើញវិលត្រឡប់ពីថៃ និងចាញ់បោកមេខ្យល់អស់ប្រាក់ម្នាក់ៗ៦០០០បាត។

ករណីខាងលើកើតឡើងកាលពីវេលាទៀបភ្លឺថ្ងៃទី១៤ សីហា ២០២១ នៅបន្ទាត់ព្រំដែនក្នុងភូមិព្រៃព្រិច សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ប្រជាពលរដ្ឋទាំង១៥នាក់ខាងលើនេះ (ស្រី៥នាក់និងកុមារ២នាក់) ដោយពួកគាត់៩នាក់ រស់នៅខេត្តបន្ទាយមានជ័យ, ៤នាក់រស់នៅខេត្តកណ្ដាល, ១នាក់រស់នៅខេត្តកំពង់ស្ពឺ និង១នាក់រស់នៅខេត្តបាត់ដំបង។ យោងការសាកសួរ ប្រជាពលរដ្ឋទាំងនេះមាន១១នាក់ ជាអាជីវករលក់ដូរនៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ និង៤នាក់ជាកម្មករធ្វើការនៅជិតព្រំដែន ។

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍បឹងសាគួ នៃនគរបាលការពារព្រំដែនគោកលេខ៨១១ ប្រាប់តាមបណ្តាញសង្គមវ៉ាស់អាប់ថា ប្រជាពលរដ្ឋទាំងនេះចាញ់បោកមេខ្យល់ម្នាក់ៗអស់ប្រាក់៦០០០បាត។ យោងការសាកសួរពួកគាត់ប្រាប់សមត្ថកិច្ចថា ដំបូងគេដឹកទៅស្រុកអារញ្ញតាមរថយន្ត ហើយឲ្យដើរមកព្រំដែនវិញអស់ជាច្រើនម៉ោងទើបដល់។ លោកនាយប៉ុស្តិ៍បន្តថា មេខ្យល់គ្រោងនាំពលរដ្ឋទាំង១៥នាក់នេះចូលមកកម្ពុជា ដើម្បីបញ្ចៀសកាធ្វើចត្តាឡីស័ក និងគេចពីសមត្ថកិច្ចតែដោយកម្លាំងចម្រុះធ្វើកាល្បាត ដើម្បីពង្រឹងសន្តិសុខ និងទប់ស្កាត់រាល់បទល្មើសពិសេសទប់ស្កាត់កូវីដកុំឲ្យឆ្លងចូលសហគមន៍តាមបទបញ្ជារបស់ថ្នាក់លើ ពិសេសប្រមុខរាជរដ្ឋាភិបាលពេលប្រទះឃើញប្រជាពលរដ្ឋទាំងនេះកំពុងពួនក្នុងព្រៃ៤ទៅ៥កន្លែង ទើបសមត្ថកិច្ចហៅសួរនាំទាំងអស់តែម្តង។

ជនសង្ស័យជាមេខ្យល់បានគេចខ្លួនបាត់ស្រមោលសង្ស័យរត់ចូលទៅទឹកដីថៃវិញ ។ ទោះយ៉ាងណាក៏ដោយប្រជាពលរដ្ឋទាំង១៥នាក់ ក្រោយឃាត់សួរនាំសមត្ថកិច្ចបានធ្វើការបញ្ជូនទៅទីតាំងធ្វើតេស្តរហ័សនៅស្ថានីយរថភ្លើងក្នុងក្រុងប៉ោយប៉ែត។ តាមប្រភពថា ក្នុងចំណោមពលរដ្ឋ១៥នាក់ខាងលើ រកឃើញវិជ្ជមានកូវីដ១៩ចំនួន៣នាក់ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមណ្ឌលចត្តាឡីស័កមួយកន្លែងនៅឯក្រុងសិរីសោភ័ណ ចំណែក១២នាក់ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាព្រហ្មនិមិត្តក្នុងក្រុងប៉ោយប៉ែតតាមវិធានការរបស់ក្រសួងសុខាភិបាល ៕

### ពលករ១៥១នាក់ក្នុងចំណោម ៧៥៥នាក់មានវិជ្ជមានកូវីដ១៩ ពីរថ្ងៃនេះ

https://www.khmertimeskh.com/ Khmer Times August 15, 2021

ពលករខ្មែរសរុប ៧៥៥នាក់ បានឆ្លងព្រំដែនតាមច្រកស្រះកែវ ប្រទេសថៃ រវៀងម៉ោង៤រសៀលម្សិលមិញ និងម៉ោង៦ព្រឹកនេះ។ ក្នុងចំណោមពលករទាំងនោះ មាន១៥១នាក់ បានធ្វើតេស្ត៍មានវិជ្ជមានកូវីដ១៩ ហើយត្រូវបានបញ្ជូនទៅកន្លែងព្យាបាលក្នុងទីរួមខេត្តបន្ទាយមានជ័យ។ នេះមានន័យថា ក្នុងចំណោមពលករទាំងអស់ ពួកគេ ២០ភាគរយបានធ្វើតេស្ត៍មានវិជ្ជមានកូវីដ១៩។

លោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់កាសែតខ្មែរថាមស៍ថា ច្រកព្រំដែនបានបើក២៤ម៉ោងក្នុងមួយថ្ងៃ ចាប់តាំងពីព្រំដែនបានបើកឡើងវិញនៅយប់ថ្ងៃទី១២ ខែសីហា ហើយបានទទួលពលករទាំងយប់ ដោយគ្មានឈប់សម្រាកឡើយ។ លោកបានបញ្ជាក់ថា មិនដូចច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតដែលមានការចុះបញ្ជីឯកសារចេញចូលម៉ឺងម៉ាត់ វិធានការបែបនេះមិនបានអនុវត្តឱ្យបានហ្មត់ចត់នៅច្រកអូរបីជាន់ឡើយ៕

## ២ថ្ងៃ ពលករខ្មែរមកពីប្រទេសថៃ តាមច្រកអូរបីជាន់ ជាង៩០០នាក់ រកឃើញអ្នកវិជ្ជមាន កូវីដ១៩ ចំនួន ១៥៩នាក់

https://cen.com.kh/ Posted ByPen Srey NeatAugust 15, 2021

បន្ទាយមានជ័យ ៖ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ ឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥ និងជាប្រធានគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ គោលដៅធ្វើចត្តាឡីស័ក ប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ យោធភូមិភាគទី៥ អញ្ជើញចុះត្រួតពិនិត្យ ស្ថានភាពពលករខ្មែរ ដែលបានត្រឡប់មកពីប្រទេសថៃ តាមច្រកតំបន់អូរបីជាន់ មណ្ឌលសំចតត្រួតពិនិត្យសុខភាពពលករខ្មែរ មុននឹងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាលបាល ក្រោយពីរាជរដ្ឋាភិបាល សម្រេចឲ្យបើកព្រំដែនឡើងវិញ បន្ទាប់ពីបិទខ្ទប់ព្រំដែនរយៈពេល១៤ថ្ងៃ។

គួរកត់សម្គាល់ថា បន្ទាប់ពីបើកឡើងវិញ ប្រជាពលករបន្តត្រឡប់មកជាបន្តបន្ទាប់ ជាក់ស្តែងចាប់ពីរសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ មកដល់ព្រឹកនេះ មានពលករខ្មែរមកពីប្រទេសថៃ តាមច្រកអូរបីជាន់ សរុបជាង ៩០០នាក់ ក្នុងនោះរកឃើញអ្នកវិជ្ជមានកូវីដ១៩ សរុបចំនួន ១៥៩នាក់។

ឧត្តមសេនីយ៍ទោ សេង ធារិន បានគូសបញ្ជាក់ថា បន្ទាប់ពីបើកព្រំដែនឡើងវិញ ពលករខ្មែរមួយចំនួន បានវិលត្រឡប់មកស្រុកកំណើតវិញ តាមច្រកទាំង៣ក្នុងខេត្តបន្ទាយមានជ័យ ដែលបានកំណត់ និងមួយចំនួនចាញ់បោកមេខ្យល់ បន្តលួចឆ្លងចូលតាមតំបន់ដែលហាមឃាត់ ប៉ុន្តែត្រូវបានកងកម្លាំងចម្រុះចាប់ឃាត់បានជាបន្តបន្ទាប់ បញ្ជូនទៅត្រួតពិនិត្យសុខភាព និងអនុវត្តតាមវិធានការសុខាភិបាល។ ក្នុងដំណើរចុះត្រួតពិនិត្យស្ថានភាពនៅច្រកអូរបីជាន់ ឧត្តមសេនីយ៍ទោ សេង ធារិន ក៏បានអញ្ជើញចុះសួរសុខទុក្ខ ដល់កងកម្លាំងជួរមុខរបស់ ទិសទី១ បន្ទាយមានជ័យ និងដាក់បទបញ្ជាដល់កងកម្លាំងទាំងអស់ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងពេលបំពេញប្រតិបត្តិការទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ១៩ និងមេរោគបំប្លែងថ្មីដែលតា (Delta) នៅតាមបន្ទាត់ព្រំដែន ធ្វើយ៉ាងណាអនុវត្តឲ្យបានដាច់ខាត ៣កុំ ៣ការពារ ធានាបានសុខសុវត្ថិភាព ផ្ទាល់ខ្លួន និងមិត្តរួមក្រុម។

ក្នុងឱកាសនោះដែរ ឧត្តមសេនីយ៍ទោ សេង ធារិន បានថ្លែងអំណរគុណដល់កងកម្លាំងទាំងអស់ដែលបានខិតខំ ដោយមិនខ្លាចនឿយហត់ទាំងយប់ទាំងថ្ងៃ បំពេញបេសកកម្ម ក្នុងប្រតិបត្តិការទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ១៩ និងមេរោគបំប្លែងថ្មីដែលតា (Delta) នៅតាមបន្ទាត់ព្រំដែន ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាពលរដ្ឋ៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ថ្ងៃនេះពលករមកពីថៃជាង ៦០០នាក់ ចូលមកកម្ពុជា តាមច្រកអូរស្មាច់, លោកអភិបាលខេត្ត ណែនាំពលករឱ្យគោរពវិធានការបង្ការជំងឺកូវីដ១៩

http://freshnewsasia.com/ 2021-08-15 09:07pm

**(ឧត្តរមានជ័យ)៖** គិតត្រឹមម៉ោង ៥នាទីល្ងាចថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១នេះ ពលករត្រឡប់មកពីប្រទេសថៃចំនួន ៦២១នាក់ បានចូលមកកម្ពុជាវិញតាមច្រកអន្តរជាតិអូរស្មាច់ ក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ក្នុងចំណោមពលករទាំងអស់ត្រូវបានអនុវត្តន៍តាមវិធានការនានារបស់ក្រសួងសុខាភិបាលពិសេសការធ្វើតេស្តរហ័ស ដើម្បីស្វែងរករកមេរោគកូវីដ១៩ និងបញ្ជូនទៅធ្វើចត្តាឡីស័ក។

លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ និងជាប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ខេត្ត បានដឹកនាំក្រុមការងារ ចុះពិនិត្យស្ថានភាពការវិលត្រឡប់របស់ពលករដែលធ្វើចំណាកស្រុកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់។ នៅក្នុងឱកាសនោះ លោកអភិបាលខេត្តឧត្តរមានជ័យ

បានណែនាំពលករទាំងអស់ ត្រូវចូលរួមអនុវត្តន៍ឱ្យបានគ្រប់ៗគ្នា នូវវិធានាការនានារបស់ក្រសួងសុខាភិបាល និងការណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩។

លោកអភិបាលខេត្ត បានលើកឡើងថា ស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យបានវិវត្តន៍ដល់ចំណុចមួយគួរឱ្យព្រួយបារម្ភខ្ពស់ តែស្ថិតក្នុងការគ្រប់គ្រងបាន ដោយវាបាននិងកំពុងឆ្លងរាលដាលចូលដល់សហគមន៍។ ក្នុងនោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បាននិងកំពុងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះ។ លោក ប៉ែន កុសល្យ បានឱ្យដឹងដែរថា ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ក្នុងខេត្ត ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់សម្តេចប្រមុខរាជរដ្ឋាភិបាលនោះ ខេត្តទទួលបាននូវរថយន្តសង្គ្រោះ រោងតង់ គ្រែពេទ្យ និងសម្ភារ វេជ្ជសាស្ត្រ រួមនឹងគ្រឿងឧបភោគបរិភោគ ឃីតជំណេកជាដើម។ ក្នុងនោះក្រោមការដឹកនាំ និងចុះអនុវត្តផ្ទាល់ពីសំណាក់លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត, លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត និងនាយឧត្តមសេនីយ៍ ខេង សុមេធ ក្រុមការងារកំពុងដំណើរការរៀបចំពង្រីកមណ្ឌលចត្តាឡីស័ក និងមណ្ឌលព្យាបាលកំរិតធ្ងន់ក្នុងខេត្ត ដែលនឹងរួចរាល់នាពេលដ៏ឆាប់ខាងមុខដើម្បីបំពេញសេចក្តីត្រូវការបន្ថែមនៃសភាពការណ៍ចំពោះមុខ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ ខេត្តឧត្តរមានជ័យរកឃើញអ្នកជំងឺកូវីដ១៩ សរុប ៥,៥៧៣នាក់ (ករណីនាំចូលពីបរទេស ៤.៦៣១នាក់ និងករណីព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ៩៤១នាក់)។ ក្នុងនោះ បានសម្រាកព្យាបាលនៅក្នុងខេត្តឧត្តរមានជ័យមានចំនួន ៣,៤៤០នាក់ ដោយព្យាបាលជាសះស្បើយ ២,២២៨នាក់, ស្លាប់ ០៩នាក់ និងកំពុងសម្រាកព្យាបាល ១,២០៣នាក់។ **ក្នុងចំនួនអ្នកជំងឺទាំង ៣,៤៤០នាក់ ដែលបានសម្រាកព្យាបាលនៅក្នុងខេត្តមាន៖** * វីរុសបំប្លែងខ្លួនប្រភេទអាល់ហ្វា (Alpha) ចំនួន ៣,៣១៥នាក់ ក្នុងនោះព្យាបាលជាសះស្បើយ ២,២១១នាក់ និងកំពុងព្យាបាល ១,០៩៥នាក់។ * វីរុសបំប្លែងខ្លួនប្រភេទដែលតា (Delta) ចំនួន ១២៥នាក់ (ស្រី ៥៧នាក់) ក្នុងនោះព្យាបាលជាសះស្បើយ ១៧នាក់ (ស្រី ១០នាក់) និងកំពុងព្យាបាល ១០៨នាក់ (ស្រី ៤៧នាក់)៕

## ពលករខ្មែរ ជាង២០០នាក់ ខកខ្លួននៅប្រទេសថៃ បានទៅកកកុញនៅស្ថានកុងស៊ុលខ្មែរ សុំអន្តរាគមន៍មកកម្ពុជា

https://cen.com.kh/ Posted ByPen Srey NeatAugust 16, 2021

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរធ្វើការនៅថៃ ក្នុងនោះអ្នកខ្លះខកខ្លួន មិនមានការងារធ្វើអ្វីទាំងអស់ ចំនួន ២៣៧នាក់ ត្រូវបានអគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តស្រះកែវ ជួយសម្របសម្រួលឱ្យបានចូលមកប្រទេសកម្ពុជាវិញ តាមច្រកអូរបីជាន់ និងច្រកប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ ហើយក៏បាននាំពួកគេទៅកាន់កន្លែង ត្រួតពិនិត្យសុខភាព និងធ្វើចត្តាឡីស័កផងដែរ។

មន្ត្រីក្រសួងការបរទេសកម្ពុជា បានឱ្យដឹងថា ក្នុងចំណោមពលករខ្មែរ ២៣៧នាក់ខាងលើនេះ មានអ្នកខ្លះបានជួលរថយន្តគេទៅឈប់នៅមុខអគ្គកុងស៊ុលខ្មែរក្នុងខេត្តស្រះកែវ តែម្តង ដោយស្វែងរកកិច្ចអន្តរាគមន៍ ដើម្បីបានចូលដីខ្មែរវិញ និងពលករខ្លះទៀត តែលតោលគ្មានការងារធ្វើអ្វីទាំងអស់ ដោយសារចាញ់បោកមេខ្យល់ដឹកយកទៅទម្លាក់ចោលនៅស្ថានអគ្គកុងស៊ុលផងដែរ។ ក្នុងគ្រាដែលឃើញកម្មករតែលតោល និងកកកុញនៅមុខស្ថានអគ្គកុងស៊ុលខ្មែរបែបនេះ, អគ្គកុងស៊ុលខ្មែរ ក៏បានជួយអន្តរាគមន៍នាំមកពួកគេមកឆ្លងដែននៅច្រកអូរបីជាន់ និងច្រកអន្តរជាតិប៉ោយប៉ែត ដោយប្រគល់ជូនទៅសមត្ថកិច្ចខ្មែរ ដើម្បីពិនិត្យសុខភាព និងរៀបចំបញ្ជូនពួកគេទៅធ្វើចត្តាឡីស័ក ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩៕ រក្សាសិទ្ធិដោយ៖ពិសិដ្ឋ CEN

# មន្ត្រីទូតកម្ពុជានិងប៉ូលិសម៉ាឡេស៊ីជួយអន្តរាគមន៍បញ្ជូនពលករខ្មែរម្នាក់ឱ្យវិលមកកម្ពុជាវិញ

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 15 August 2021 | 17:55 ICT

**ភ្នំពេញ៖** មន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ី និងប៉ូលិសអន្តោប្រវេសន៍ នៃប្រទេសនេះកាលថ្ងៃទី ១៥ ខែសីហា បានបញ្ជូនពលករនេសាទខ្មែរម្នាក់ឱ្យមកកាន់កម្ពុជាវិញ បន្ទាប់ពីជួយសង្គ្រោះគាត់ពីការលោតចូលក្នុងសមុទ្រ ដើម្បីគេចពីការប៉ុនប៉ងប្រព្រឹត្តមិនល្អពីក្រុមពលករបរទេស ដែលធ្វើការលើទូកនេសាទជាមួយគ្នា។ នេះបើតាមសេចក្តីជូនដំណឹងរបស់អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

បើតាមសេចក្តីជូនដំណឹងចុះថ្ងៃទី១៥ សីហា ពលករខ្មែររូបនេះ ឈ្មោះ ប៊ុ ពឿន អាយុ៤១ឆ្នាំ មានលំនៅក្នុងភូមិត្រឡាចស ឃុំត្របែក ស្រុកកំចាយមារ ខេត្តព្រៃវែង ។ គាត់បានទៅធ្វើការនៅលើទូកនេសាទដោយខុសច្បាប់ នៅតំបន់ Panchor នៃរដ្ឋ Perak របស់ម៉ាឡេស៊ី តាមរយៈ មេខ្យល់ កាលពីដើមឆ្នាំ២០២០។ នៅក្នុងសេចក្តីជូនដំណឹងនេះ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ថា៖«ដោយមានអារម្មណ៍ថាពលករបរទេសផ្សេងទៀតដែលធ្វើការលើទូកនេសាទជាមួយគ្នាមានបំណងធ្វើបាប គាត់ក៏បានសម្រេចចិត្តលោតពីលើទូកដោយបណ្តែតខ្លួនជាមួយពោងរយៈពេល៤ថ្ងៃ នៅលើផ្ទៃសមុទ្រ ទើបត្រូវប៉ូលិសជើងទឹកប្រចាំតំបន់Lumut រដ្ឋPerak ជួយសង្គ្រោះ នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២១»។ បើតាមលោក កុយ គួង បន្ទាប់ពីទទួលបានព័ត៌មាននោះ ក្រុមការងារស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ក៏បានសហការជាមួយមន្ត្រីប៉ូលិសជើងទឹកប្រចាំតំបន់ ដោយបានណែនាំឱ្យក្រុមភ្នាក់ងារស្ម័គ្រចិត្តនៅរដ្ឋ Perak ទៅទទួលពលកររងគ្រោះពីការិយាល័យប៉ូលិសជើងទឹកនិងផ្តល់ការហូបចុក កន្លែងស្នាក់នៅជាបណ្តោះអាសន្ននៅរដ្ឋ Penang ជាប់ព្រំប្រទល់រដ្ឋ Perak ។ ទោះយ៉ាងណា ពលកររងគ្រោះនោះមិនមានព័ត៌មានអ្វីទាំងអស់ពាក់ព័ន្ធនឹងថៅកែទូក ហើយស្នើសុំស្ថានទូតជួយអន្តរាគមន៍ឱ្យបានត្រឡប់ទៅកម្ពុជាវិញ។

លោក គួង បានបន្ថែមថា តាមរយៈកម្មវិធី Repatriation Recalibration Plan លោក ប៊ុ ពឿនត្រូវបានស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ីចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន និងសម្របសម្រួលជាមួយមន្ត្រីអន្តោប្រវេសន៍ម៉ាឡេស៊ី ជួយចាត់មន្ត្រីជូនដំណើរទៅកាន់អាកាសយានដ្ឋានអន្តរជាតិ KLIA ដើម្បីឱ្យគាត់វិលត្រឡប់មកកម្ពុជាវិញតាមជើងយន្តហោះ អាកាសចរណ៍សិង្ហបុរីលេខ SQ158 ដែលត្រូវមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញនៅម៉ោង ៥:៣០ នាទីល្ងាចថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០២១៕

# នគរបាលការពារព្រំដែនគោក លេខ៩១១ ស្ទាក់ចាប់បានក្រុមពលករខ្មែរ ខណៈមេខ្យល់លួចនាំឆ្លងដែន ខុសច្បាប់

https://www.rasmeinews.com/ 15 August, 2021

**ដោយ៖ ប.ជ័យ / ព្រំដែនកម្ពុជា ថៃ៖** *កម្លាំងនគរបាលការពារព្រំដែនគោក លេខ៩១១ និងយោធា កងពលតូច ថ្មើរជើងលេខ៥១ កាលពី វេលាម៉ោង ៣ កន្លះ យប់ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២១ បានស្ទាក់ចាប់បាន ពលករខ្មែរ ចំនួន ១៧ នាក់ ដែលចាញ់បោកមេខ្យល់ លួចនាំឆ្លងដែនខុសច្បាប់ ហើយបានដើរជិតដល់ ព្រំដែនកម្ពុជា ថៃ ទាំងយប់ងងឹតឈឹងនោះ ។*

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍ការពារព្រំដែន បឹងសាគូ នៃនគរបាលការពារព្រំដែនគោក ៩១១ បានអោយដឹង នៅថ្ងៃទី១៥ ខែសីហានេះថា៖ ពលករទាំងនោះ បានខំរត់ដើរទាំងប្រថុយប្រថាន ក្នុងចម្ងាយផ្លូវថ្មើរជើងប្រមាណ ៤១០ គីឡូម៉ែត្រ ហើយមកដល់ភូមិសាស្ត្រ ឈរជើងនៃនគរបាល ការពារព្រំដែន វរៈ ៩១១ របស់លោក ក៏ត្រូវបានកម្លាំងចម្រុះ នគរបាល និងយោធា ឃាត់ខ្លួន។ លោកបានបន្តថា៖ ក្នុងជំហានមុនគេ គឺត្រូវយក

សំណាក រកមេរោគកូវីដ១៩ ពីក្នុងចំណោមពលករ ចំនួន ១៧ នាក់នោះ លទ្ធផលតេស្តរហ័ស ( Rapid Test) រកឃើញ ៥ នាក់ វិជ្ជមាន ជំងឺកូវីដ ១៩ ។ អ្នកវិជ្ជមាន ត្រូវបានគ្រូពេទ្យយករថយន្តពេទ្យដឹកទៅមណ្ឌលព្យាបាល ។ ឯអ្នកអវិជ្ជមាន ត្រូវបញ្ជូនទៅ មណ្ឌលចត្តាឡីស័ក ។

លោកវរសេនីយ៍ រស់ ពិសិដ្ឋ បានបន្តថាៈ ពលករអវិជ្ជមាន ត្រូវរង់ចាំសួរនាំ និងធ្វើកំណត់ហេតុ នៅប៉ុស្តិ៍នគរបាល ការពារព្រំដែនគោក បឹងសាគូ សិន ។ ឆ្លៀតឱកាសនោះ អនុវត្តតាមបទបញ្ជា មេបញ្ជាការវរៈ លោកសូមបងប្អូនពលរដ្ឋ កុំជឿតាមមេខ្យល់ ដែលថានាំឆ្លងដែន ទៅរកការងារធ្វើ នៅប្រទេសថៃ ឬនាំពីថៃ ឆ្លងដែនមកកម្ពុជាវិញ ព្រោះពួកវានោះ រង់ចាំតែបោកប្រាស់ យកតែលុយ បងប្អូនប៉ុណ្ណោះ ៕/V

## បើកព្រំដែនឡើងវិញៈ ពលករខ្មែរ វិលពីថៃ តាមច្រកព្រំដែន ក្នុងខេត្តបន្ទាយមានជ័យ មានជាង ២.000 នាក់ ក្នុងរយៈពេល ២ ថ្ងៃ

https://www.rasmeinews.com/ 15 August, 2021

**ដោយៈ ប.ជ័យ / ព្រំដែនកម្ពុជា ថៃៈ** *ក្រោយពីរាជរដ្ឋាភិបាលកម្ពុជា បើកព្រំដែនឡើងវិញ សម្រាប់ពលករខ្មែរ វិលពីប្រទេសថៃ គេសង្កេតឃើញថា តាមច្រកព្រំដែនតំបន់ និងច្រករបៀងនានា ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ក្នុងរយៈពេល ២ ថ្ងៃ(ថ្ងៃទី១៣ និង ១៤ ខែសីហា ឆ្នាំ២០២១) កន្លងមកនេះ មានពលករខ្មែរជាង ២.០០០ នាក់ បានវិលមាតុភូមិនិវត្តិន៍* ។

លោកឧត្តមសេនីយ៍ត្រី អ៊ុ សុផល ស្នងការរង ទទួលផែននគរបាលការពារព្រំដែនគោក ខេត្តបន្ទាយមានជ័យ បានអោយដឹងកាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ថាៈ នៅបណ្តោយព្រំដែនកម្ពុជា ថៃ ភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ក្នុងផ្នែកដែលកម្លាំង នគរបាលការពារ ព្រំដែនគោក ៤ វរៈ ៨១៥, ៨៩១, ៩១១ និង ៧០៨) នៃស្នងការដ្ឋាននគរបាល ខេត្តបន្ទាយមានជ័យ ឈរជើង បានកំណត់គោលដៅ ល្បាតព្រំដែន និងទប់ស្កាត់ពលករខ្មែរ និងបរទេសឆ្លងដែនខុសច្បាប់ ចំនួន ៣១៤ គោលដៅ ។ លោកបានបន្តថាៈ ដោយសាររាជរដ្ឋាភិបាលកម្ពុជា ដាក់បញ្ជាអោយបិទខ្ទប់ព្រំដែន ដើម្បីគ្រប់គ្រង ការរីករាលដាល ជំងឺកូវីដ១៩ មេរោគប្រភេទបំប្លែងថ្មី ដែលតា (Delta) ចំនួន១៤ថ្ងៃ ហើយគិតមកត្រឹម ម៉ោង ២៣និង៥៩ នាទី អធ្រាត្រ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ កន្លងមក នៅខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ នៃភូមិសាស្ត្រខេត្តនេះ មានពលករខ្មែរ រាប់រយនាក់ ដែលជាប់គាំងនៅព្រំដែន ខាងទឹកដីថៃ និងខាងទឹកដីកម្ពុជា គឺនៅក្នុងភូមិសាស្ត្រ ស្រុកអារញ្ញប្រាថេត ស្រុកគោកស៊ូង ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ទល់មុខភូមិសាស្ត្រ ស្រុកម៉ាឡៃ ក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកស្វាយចេក និងស្រុកថ្មពួ្ក កខេត្តបន្ទាយមានជ័យ។

ក្នុងនោះ កងកម្លាំង និងអាជ្ញាធរ នៃភាគីទាំង ២ បានរៀបចំជំរំតង់មួយចំនួន អោយពលករ ជ្រកកោនបណ្តោះអាសន្ន នៅលើបន្ទាត់ព្រំដែន។ គោលដៅទាំងនោះ មាន ៦ គោលដៅ នៅខាងទឹកដីថៃ ក្នុងភូមិសាស្ត្រ ស្រុកអារញ្ញប្រាថេត ទល់មុខភូមិសាស្ត្រ ស្រុកម៉ាឡៃ។ មាន២គោលដៅ ខាងទឹកដីថៃ នៅម្តុំផ្សាររោងក្លឿ ភូមិសាស្ត្រអារញ្ញ ទល់មុខភូមិសាស្ត្រ ក្រុងប៉ោយប៉ែត។ ១គោលដៅខាងទឹកដីកម្ពុជា នាច្រកអូរបីជាន់ ស្រុកអូរជ្រៅ ឈមស្រុកគោកស៊ូងនិង១គោលដៅខាងទឹកដីកម្ពុជា នៅច្រកបឹងត្រកួន ស្រុកថ្មពួក ឈមនឹងភូមិសាស្ត្រ ស្រុកតាប្រាយ៉ា ។

លោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់កាសែតរស្មីកម្ពុជា កាលពីថ្ងៃទី១៤ ខែសីហាថាៈ ក្នុងពេលដែលកម្ពុជា បើកព្រំដែនឡើងវិញ សម្រាប់លំហូរពលករ ពីប្រទេសថៃ ក្រៅពីពលករខ្មែរ ដែលវិលវិញ តែបានជាប់គាំង នៅតាមបណ្តោយព្រំដែន រយៈពេល ១៤ ថ្ងៃ ក៏បន្ថែមពលករខ្មែរ ដែលធ្វើការនៅកន្លែងការងារ នៅរាជធានីបាងកក និងខេត្តនានា ក៏បានសម្រុក វិលវិញដែរ។ ជាងនេះទៅទៀត ក៏មានកម្មករខ្មែរ រាប់រយនាក់ នៅផ្សាររោងក្លឿ នាស្រុកអារញ្ញ ក៏បានវិលវិញ ហើយគេ រំពឹងទុកថា នឹងមានពលករខ្មែរ រាប់ពាន់នាក់ ដែលធ្វើ

ការនៅប្រទេសថៃ នឹងបន្តវិលមកកម្ពុជា ទាំងតាមព្រំដែន នៃភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ក៏ដូចជា ភូមិសាស្ត្រ ខេត្តព្រំដែនគោកនឹងប្រទេសថៃ មានខេត្តកោះកុង ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង ឧត្តរមានជ័យ និងខេត្តព្រះវិហារ ផងដែរ ។ លោកបានបន្តថាៈ ក៏ប៉ុន្តែអាជីវករខ្មែរ ប្រមាណ ១០.០០០ នាក់ ដែលប្រកបរបរ នៅផ្សាររោងក្លឿ មិនចង់ចាកចេញ ពីប្រទេសថៃទេ ព្រោះពួកគេ បានប្រកបរបរ រកស៊ីនៅទីនោះ ហើយពួកគេស្វះស្វែង រកអន្តរាគមន៍ ពីអាជ្ញាធរមានសមត្ថកិច្ច ភាគីទាំង ២ ដើម្បីបានចាក់វ៉ាក់សាំង បង្ការជំងឺកូវីដ១៩ ។

ក្នុងនោះ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តស្រះកែវ កាលពីកិច្ចប្រជុំ ឈរលើស្ពានព្រំដែន កាលពីថ្ងៃទី១៣ ខែសីហា បានស្នើសុំរាជរដ្ឋាភិបាល របស់ផងខ្លួន ដើម្បីកំណត់ពេល ដ៏ខ្លីខាងមុខ អនុញ្ញាតអោយគ្រូពេទ្យកម្ពុជា អាចចូលទៅចាក់វ៉ាក់សាំង ជូនអាជីវករទាំងនេះ នៅលើស្ពានមិត្តភាព នាច្រកព្រំដែន អន្តរជាតិ ប៉ោយប៉ែត-ខ្លងលឹក ឬទីតាំង ២ ទៀត ដែលភាគីទាំង ២ បានកំណត់ ក្នុងតម្រាយផ្លូវ៕/V

## ពលករខ្មែរ១៧នាក់ត្រូវយោធាថៃចាប់ខ្លួនខណៈដែលពួកគេបម្រុងឆ្លងដែន ចូលប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៦ សីហា ២០២១ដោយ sopheak khoun

(បាត់ដំបង)៖ ពលករខ្មែរ ចំនួន១៧ នាក់ ត្រូវបានកម្លាំងយោធាថៃចាប់ខ្លួន ខណៈដែលពួកគេបម្រុងឆ្លងអូរព្រំដែន ដើរកាត់ព្រៃ ដើម្បីចូលទៅរកការងារធ្វើ ដោយខុសច្បាប់ ក្នុងប្រទេសថៃ។ ការឃាត់ខ្លួននេះ គឺបានធ្វើឡើង វេលាម៉ោង២យប់ រំលងអធ្រាត្រ ឈានចូលថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ៨ ឃុំទេពនិមិត្រ ស្រុកពោងណាំរ៉ែន ខេត្តច័ន្ទបុរី។ មុនពេលឃាត់ខ្លួន គឺកម្លាំងកងរយ លេខ១៣០៦ បានល្បាតតាមខ្សែបន្ទាត់ព្រំដែន ក៏បានប្រទះឃើញពលករខ្មែរដែលកំពុងដើរកាត់ព្រៃ ចូលទៅក្នុងទឹកដីថៃ ដោយខុសច្បាប់ ក៏បានឃាត់ខ្លួនតែម្តង។ ពលករទាំង១៧នាក់ គឺមានប្រុស៩នាក់ និងស្រី៨នាក់ ដែលមកពីបណ្តាខេត្តមួយចំនួន ក្នុងប្រទេសកម្ពុជា ដោយមានបំណង ឆ្លងចូលទៅរកការងារធ្វើ នៅក្នុងខេត្តច័ន្ទបុរី ដើម្បីបេះផ្លែមៀន ខ្លះទៅកាន់ខេត្តសមុទ្រប្រាកាន និងទីក្រុងបាងកកដើម្បីធ្វើការងារកសាងដោយពួកគេត្រូវចំណាយលើការឆ្លងដែនអស់ម្នាក់៤.០០០ ទៅ៦.០០០ បាត។ ក្រោយការឃាត់ខ្លួន និងពិនិត្យសុខភាព ពួកគេទាំងអស់គ្នារួចមក កម្លាំងយោធាថៃ បានប្រគល់ឲ្យនគរបាលការពារព្រំដែនកម្ពុជាវិញ៕ (ដោយ)៖ សោ និយមរ័ត្ន

## ទី១៩ ខែសីហា ឆ្នាំ២០២១

## លោកនាយករដ្ឋមន្ត្រីនឹងថ្លែងសុន្ទរកថា បើកកម្មវិធីអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស

https://www.postkhmer.com/ មុំ គន្ធា | Publication date 18 August 2021 | 10:51 ICT

**ភ្នំពេញៈ** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងថ្លែងសុន្ទរកថា បើកកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០២១ នៅថ្ងៃទី ២០ ខែសីហាខាងមុខនេះ ខណៈដែលគ្រប់វត្តអារាម និងព្រះវិហារ នៃគ្រប់សាសនាទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវបន្លឺសំឡេងស្គរជួងកងរំពងនៅរសៀលថ្ងៃដដែលនោះដែរ ដើម្បីបួងសួងឱ្យប្រជាជនកម្ពុជាក៏ដូចជាប្រជាជនលើពិភពលោកទទួលបានសេចក្តីសុខ ចៀសផុតពីការបំភាន់បំពាន និងអំពើជួញដូរមនុស្សដែលជាទាសភាពសម័យទំនើប។

លោក ឈិត សុខុន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាបានឱ្យដឹងនៅថ្ងៃទី ១៧ ខែសីហាថា ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០១៧ មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ.) តែងបានសហការជាមួយក្រសួងធម្មការ និងសាសនា មេដឹកនាំសាសនាធំៗក្នុងប្រទេសកម្ពុជា រៀបចំកម្មវិធីអន្តរសាសនាប្រឆាំងការ

ជួញដូរមនុស្សក្នុងគោលបំណងបួងសួងឱ្យប្រជាជនកម្ពុជាក៏ដូចជាប្រជាជនលើពិភពលោកទទួលបានសេចក្តីសុខចៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស។ លោកបានថ្លែងថា៖ «កម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០២១ នេះសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនឹងអានសុន្ទរកថាបើកកម្មវិធីក្រោមប្រធានបទសូមពិភពលោករួចផុតពីជំងឺរាតត្បាតជំងឺកូវីដ ១៩ និងអំពើជួញដូរមនុស្ស និងមានការបន្លឺសំឡេងស្គរជ្រួងកងរំពងនៅវេលាម៉ោង ៦:០០ នាទីល្ងាច ថ្ងៃទី ២០ ខែសីហានោះផងដែរ»។ ទន្ទឹមនឹងនេះដែរ ដើម្បីឱ្យកម្មវិធីនេះបានជ្រួតជ្រាបដល់គ្រប់ស្រទាប់មហាជនទាំងក្នុងប្រទេស និងក្រៅប្រទេស ក្រសួងធម្មការ និងសាសនាក៏បានធ្វើការណែនាំទៅដល់គ្រប់វត្តអារាម និងព្រះវិហារនៃគ្រប់សាសនាត្រូវបន្លឺសំឡេងស្គរជ្រួងកងរំពងនាថ្ងៃនោះផងដែរដោយត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលជាពិសេសប្រកាន់ខ្ជាប់ជានិច្ចនូវវិធានការ៣កុំ ៣ការពារ។

យោងតាមរបាយការណ៍ ដែលបានបង្ហាញនៅលើបណ្តាញសង្គមហ្វេសប៊ុករបស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីចុងខែកក្កដា កន្លងមកបានឱ្យដឹងថា ក្នុងរយៈពេល ៦ ខែ ដើមឆ្នាំ ២០២១ គឺចាប់ពីខែមករា ដល់ខែមិថុនា អាជ្ញាធរបានបង្ក្រាបបទល្មើសជួញដូរមនុស្សកើនឡើងជាង ១០០ ករណី បើប្រៀបធៀបនឹង ៦ ខែក្នុងឆ្នាំ ២០២០ ដែលបង្ក្រាបបានមានតែ ៦៣ ករណី។ លោក ស ខេង បានលើកឡើងថា ក្នុងប្រតិបត្តិការបង្ក្រាបការជួញដូរមនុស្សរយៈពេល ៦ ខែមកនេះ អាជ្ញាធរបានបង្ក្រាប និងទប់ស្កាត់ករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ចំនួន១៩៨ ករណី ដោយឃាត់ខ្លួនជនល្មើសចំនួន២៩១ នាក់ និងបានរំដោះជនរងគ្រោះចំនួន៧២១ នាក់។ លោកថា៖ «តួលេខ ៦ ខែ ឆ្នាំនេះ គឺកើនឡើងជាងពាក់កណ្តាល បើប្រៀបធៀបតួលេខ ៦ ខែឆ្នាំមុន គឺមានត្រឹមតែ ៦៣ ករណី ឃាត់ខ្លួន ២៩១ នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ៧២១ នាក់»។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ការឈានដល់មានសកម្មភាពជួញដូរមនុស្សនេះ គឺកើតឡើងតាមរយៈអាពាហ៍ពិពាហ៍មិនស្របច្បាប់ទៅក្រៅប្រទេស ការធ្វើចំណាកស្រុកខុសច្បាប់ និងការប្រើឧបាយកលទុច្ចរិតអូសទាញ ឃោសនា ក្រោមរូបភាពផ្សេងទៀតរបស់ជនល្មើស។

នៅព្រឹកថ្ងៃទី ១៧ ខែសីហាដដែលនោះដែរ ក្រសួងសុខាភិបាលបានរៀបចំនូវសិក្ខាសាលាតម្រង់ទិសមួយស្តីពីការពង្រឹងការចូលរួមសហគមន៍ក្នុងការទប់ស្កាត់ការចម្លងកូវីដ ១៩ នៅខេត្តចំនួន ៩ ដែលមានរយៈពេល ២ ថ្ងៃគឺថ្ងៃទី ១៧ និង ១៨ ខែសីហានេះ។ ខេត្តចំនួន ៩ នោះរួមមាន ខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ធំ ស្វាយរៀង តាកែវ កំពត និងកែប។

លោកស្រី ឈា ឆដាភា ប្រធានមជ្ឈមណ្ឌលជាតិលើកកម្ពស់ សុខភាពនៃក្រសួងសុខាភិបាល បានថ្លែងនៅក្នុងពិធីនេះថា ការចូលរួមរបស់សហគមន៍គឺជាការបង្កើត និងពង្រឹងទំនាក់ទំនងដែលជំរុញឱ្យសហគមន៍ និងស្ថាប័នពាក់ព័ន្ធធ្វើការជាមួយគ្នាក្នុងការដោះស្រាយបញ្ហាសុខភាព។ លោកស្រីបានថ្លែងថា៖ «នៅក្នុងបរិបទមានការរីករាលដាលនៃជំងឺឆ្លង និងបញ្ហាសុខភាពបន្ទាន់ផ្សេងៗ សហគមន៍គឺជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យ និងការបាត់បង់នានា»។ លោកស្រី ឈា ឆដាភា បានបន្ថែមថា យន្តការសហគមន៍បានដើរតួនាទីសំខាន់ ប៉ុន្តែបណ្តាញសហគមន៍នៅមានការជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា បុគ្គល និងគ្រួសារមិនទាន់មានការយល់ដឹងត្រឹមត្រូវ និងចូលរួមពេញលេញក្នុងការផ្លាស់ប្តូរឥរិយាបថ ដើម្បីរស់នៅក្នុងគន្លងប្រក្រតីភាពថ្មី និងការប្រឈមផ្សេងៗទៀត។

លោកស្រី លី អៃឡែន តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជាក៏បានលើកឡើងនូវការងារអាទិភាព ៣ ចំណុចសម្រាប់ជំរុញការចូលរួមរបស់សហគមន៍ក្នុងនោះមាន ទី ១ ការពង្រឹងភាពជាដៃគូដែលមានស្រាប់ និងបង្កើតភាពជាដៃគូថ្មី ដើម្បីឈានទៅដល់ក៏ដូចជាចូលរួមជាមួយនឹងបណ្តាញសហគមន៍កាន់តែទូលំទូលាយ ដើម្បីបង្កើនទំនុកចិត្តរបស់តំណាងសហគមន៍ សហគមន៍ និងប្រជាពលរដ្ឋងាយរងគ្រោះ។ លោកស្រីបានបន្តថា

ចំណុចទី ២ គឺការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចសហគមន៍ ដែលមានស្រាប់ ដើម្បីប្រើប្រាស់យន្តការប្រកបដោយភាពច្នៃប្រឌិត ដែលមានស្រាប់ និងកសាងសមត្ថភាពភាគីពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការចូលរួមផ្តល់អំណាច និងគាំទ្រសហគមន៍នៅក្នុងការងារឆ្លើយតបនឹងជំងឺកូវីដ ១៩ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លោកស្រីដែលជាតំណាង អង្គការសុខភាពពិភពលោករូបនេះបានថ្លែងថា៖ «ចំណុចទី ៣ គឺការបង្កើនតួនាទីដ៏សំខាន់របស់បុគ្គលិកថែទាំសហគមន៍នៅក្នុងការងារ ជំរុញការចូលរួមរបស់សហគមន៍ ដូចជានៅក្នុងការងារតាមដានជំងឺ និងការប្រមូលទិន្នន័យ ការត្រៀមខ្លួន និងការងារឆ្លើយតបនឹងជំងឺកូវីដ ១៩ ដូចជាការធ្វើចត្តាឡីស័កជាដើម ដោយប្រើប្រាស់វិធីសាស្រ្តផ្អែកលើការចូលរួមរបស់សហគមន៍»៕

## ពលរដ្ឋម្នាក់ត្រូវក្រុមអាជ្ញាធរថៃដោះលែងឱ្យមានសេរីភាពឡើងវិញ

https://kohsantepheapdaily.com.kh/ Oddar Meanchey១៦ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១០:១៤

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានដោះលែងពលរដ្ឋខ្មែរម្នាក់ឱ្យរួចពីទោស និងបញ្ជូនខ្លួននាំយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិជាំ កាលពីវេលាម៉ោង៣រសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២១ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពលរដ្ឋម្នាក់ដែលក្រុមអាជ្ញាធរថៃដោះលែងឱ្យរួចផុតពីទោស ឈ្មោះស៊ី ម៉ុន ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិត្រពាំងបី ឃុំល្បើក ស្រុកឈូ ខេត្តកំពត ជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ៨ខែ ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ដោយជាប់ពន្ធនាគារនៅខេត្តអូប៊ុន ប្រទេសថៃ ។ មន្ត្រីដែលបម្រើការងារនៅច្រកទ្វារអន្តរជាតិជាំ បានឱ្យដឹងថា ពលរដ្ឋម្នាក់ខាងលើនេះ ក្រោយពីក្រុមអាជ្ញាធរថៃដោះលែងរួចពីទោស ហើយបាននាំយកមកប្រគល់ឱ្យកម្ពុជា ខាងសមត្ថកិច្ចបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនដោយខុសច្បាប់ម្តងទៀត និងប្រគល់ទៅឱ្យក្រុមគ្រូពេទ្យផ្នែកចត្តាឡីស័កធ្វើតេស្តសំណាក ជាលទ្ធផល អវិជ្ជមាន រួចបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សាទួលថ្មី ឃុំថ្លាត ៕

## ៣ថ្ងៃមានពលករខ្មែរវិលមកពីថៃ តាមច្រកខេត្តបាត់ដំបងជិត៩០០នាក់ វិជ្ជមានកូវីដជាង៧០នាក់

https://news.btv.com.kh/ 08/16/2021 11:08 AM

បាត់ដំបង ៖ ក្នុងរយៈពេល៣ថ្ងៃបន្ទាប់ពីបើកដំណើរការច្រកព្រំដែនឡើងវិញ មានពលករខ្មែរត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកព្រំដែនខេត្តបាត់ដំបង ចំនួន៨៨១នាក់ ក្នុងនោះ បានរកឃើញវិជ្ជមានជំងឺកូវីដ១៩ចំនួន ៧១នាក់។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរងខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង បានឲ្យដឹងថា កាលពីថ្ងៃទី ១៣ ខែ សីហា ពលករខ្មែរចេញពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមច្រកទ្វារតំបន់ព្រំដែនសួនស៊ុ (អូរអន្លក់) ស្រុកកំរៀង និង អូរព្រំដែនកោះតូច ស្រុកសំពៅលូន មានចំនួន៣៩៨នាក់ បានធ្វើតេសរហ័ស រកឃើញឆ្លងជំងឺកូវីដ១៩ចំនួន២៩នាក់។ ចំណែកនៅថ្ងៃទី១៤ ខែ សីហា មានពលករចូលមកតាមច្រកទ្វារតំបន់ព្រំដែនសួនស៊ុ (អូរអន្លក់) សរុបចំនួន៣៨៥នាក់ ធ្វើតេស្តរហ័ស រកឃើញមានវិជ្ជមានកូវីដ១៩ ចំនួន៣២នាក់។ សម្រាប់ថ្ងៃទី១៥ ខែ សីហា មានពលករចូលមកតាមច្រកទ្វារតំបន់ព្រំដែនសួនស៊ុ(អូរអន្លក់) ចំនួន៩៨នាក់ បានធ្វើតេស្តរហ័សរកឃើញវិជ្ជមានកូវីដ១៩ ចំនួន១០នាក់។ នៅព្រឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១នេះ ឯកឧត្តម ងួន រតនៈ អភិបាលខេត្តបាត់ដំបង បានអញ្ជើញចូលរួមយុទ្ធនាការអប់រំផ្សព្វផ្សាយក្រោមប្រធានបទ"រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"។

យុទ្ធនាការអប់រំផ្សព្វផ្សាយនេះ ធ្វើឡើងនៅក្នុងក្រុងបាត់ដំបងដោយមានការចុះបិទផ្លាកណែនាំនៅតាមដើមឈើ និងចងបដាអប់រំតាមទីកន្លែងសាធារណៈផ្សេងៗ ដើម្បីជំរុញឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ឲ្យបានគ្រប់ៗគ្នា។ សម្រាប់ខេត្តបាត់ដំបង រហូតមកពេលនេះមិនទាន់មានករណីឆ្លងជំងឺកូវីដ១៩ប្រភេទDelta ចូលក្នុងសហគមន៍ឡើយដោយសារតែអាជ្ញាធរខេត្តគ្រប់គ្រងបានយ៉ាងល្អនូវលំហូរពលករខ្មែរមកពីប្រទេសថៃ តាមរយៈការពង្រឹងកងកម្លាំងមានសមត្ថកិច្ចឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែនមិនឲ្យមានពលករ ឬប្រជាពលរដ្ឋលួចចេញចូលឆ្លងដែនបានឡើយ។ រដ្ឋបាលខេត្តបាត់ដំបងនៅថ្ងៃទី១៥ ខែ សីហា ឆ្នាំ ២០២១ បានចេញសេចក្តីប្រកាសព័ត៌មានស្តីពី ករណីរកឃើញវិជ្ជមានកូវីដ១៩ ចំនួន៩៥នាក់ថ្មី ករណីជាសះស្បើយ១៦៦នាក់ និងស្លាប់ម្នាក់ ។ រហូតមកដល់ពេលនេះ ខេត្តបាត់ដំបង បានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន ៤ ៦៨៧ នាក់ ក្នុងនោះបានព្យាបាលជាសះស្បើយ ៣ ២៨៧នាក់ កំពុងសម្រាកព្យាបាល ១ ៣៤០នាក់ និងស្លាប់៦០នាក់៕ អត្ថបទ៖ នឿត សុភ័ក្រ្ត

## ក្រោយពីបើកច្រកព្រំដែន ខេត្តបន្ទាយមានជ័យ មានពលករខ្មែរវិជ្ជមាន២៥៨នាក់ ក្នុងចំណោម១,៦០៤នាក់

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៦ សីហា ២០២១ដោយ Sorn Phanith

លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរងនាយសេនាធិការ យោធភូមិភាគទី៥ និងជាប្រធានគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ គោលដៅធ្វើចត្តាឡីស័ក ប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ យោធភូមិភាគទី៥ ចុះត្រួតពិនិត្យ ស្ថានភាពពលករខ្មែរ ដែលបានត្រឡប់មកពីប្រទេសថៃក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ សរុបមានចំនួនសរុប១,៦០៤នាក់ ស្រី៥៧៨នាក់ ក្នុងនោះក្រុមគ្រូពេទ្យជួរមុខ បានយកសំណាកធ្វើតេស្តរហ័សរកឃើញអ្នកកើតជំងឺកូវីដ១៩ មានចំនួន២៥៨នាក់ ស្រី៨៥នាក់ ។

លោកឧត្តមសេនីយ៍ទោ សេង ធារិនបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ក្នុងនោះមានច្រកបឹងត្រកួន ស្រុកថ្មពួក មានអ្នកមិនឆ្លងជំងឺកូវីដ១៩មានចំនួន ២២០នាក់ស្រី ៩០នាក់ អ្នកឆ្លងជំងឺកូវីដ១៩មានចំនួន ១៨នាក់ស្រី១១នាក់ ច្រកអូរបីជាន់ ស្រុកអូរជ្រៅមានចំនួន៨៤៧នាក់ ស្រី២៥២អ្នកឆ្លងជំងឺកូវីដ១៩ មានចំនួន១៧១នាក់ស្រី៤២នាក់ ច្រកបឹងត្រកួន ស្រុកថ្មពួកមានអ្នកមិនឆ្លងជំងឺកូវីដ១៩ មានចំនួន ៨៤៧នាក់ស្រី ២៥២នាក់ អ្នកឆ្លងជំងឺកូវីដ១៩ មានចំនួន១៧១នាក់ស្រី៤២នាក់ ច្រកម៉ាឡៃ ស្រុកម៉ាឡៃមានអ្នកមិនឆ្លងជំងឺកូវីដ១៩ មានចំនួន ៣៣៩នាក់ស្រីនាក់១៥២ អ្នកឆ្លងជំងឺកូវីដ១៩ មានចំនួន៣៨នាក់ស្រី១៦នាក់ ច្រកអន្តរជាតិប៉ោយប៉ែត ក្រុងប៉ោយប៉ែត មានអ្នកមិនឆ្លងជំងឺកូវីដ១៩ មានចំនួន១៩៨នាក់ស្រី៨៤នាក់ អ្នកឆ្លងជំងឺកូវីដ១៩ មានចំនួន៣១នាក់ស្រី១៦នាក់គិតត្រឹមម៉ោង៤រសៀល ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១នេះ។

លោកលោកឧត្តមសេនីយ៍ទោ សេង ធារិន បានបញ្ជាក់ឲ្យដឹងបន្តទៀតថា អ្នកកើតជម្ងឺកូវីដ១៩ ដែលមានចំនួន២៥៨នាក់ នោះអាជ្ញាធរ កងកម្លាំងកំពុងដឹកតាមរថយន្តរបស់កងទ័ពយកទៅដាក់មណ្ឌលព្យាបាលនៅក្នុងខេត្តបន្ទាយមានជ័យអស់ហើយផងដែរ ចំណែកអវិជ្ជមានបានបញ្ជូនមណ្ឌលសំចតត្រួតពិនិត្យសុខភាពបន្តមុននឹងបញ្ជូនទៅមណ្ឌលចត្តាឡីស័កនិងមណ្ឌលព្យាបាលបន្ត។ ក្នុងនោះ លោកឧត្តមសេនីយ៍ សេង ធារិន បានដាក់បទបញ្ជាដល់កងកម្លាំងទាំងអស់ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងពេលបំពេញប្រតិបត្តិការទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ១៩ និងមេរោគបម្លែងថ្មីដែលតា (Delta) នៅតាមបន្ទាត់ព្រំដែន ធ្វើយ៉ាងណាអនុវត្តឲ្យបានដាច់ខាត ៣កុំ ៣ការពារ ធានាបានសុខសុវត្ថិភាព ផ្ទាល់ខ្លួន និងមិត្តរួមក្រុម។ ក្នុងឱកាសនោះដែរ ឧត្តមសេនីយ៍ទោ សេង ធារិន បានថ្លែងអំណរគុណ ដល់កងកម្លាំងទាំងដែលខិតខំ ដោយមិនខ្លាចនឿយហត់ទាំងយប់ទាំងថ្ងៃ បំពេញបេសកកម្ម

ក្នុងប្រតិបត្តិការទប់ស្កាត់ ការឆ្លងរីករាលដាលជំងឺកូវីដ.១៩ និងមេរោគបម្លែងថ្មីដែលតា (Delta) នៅតាមបន្ទាត់ព្រំដែន ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាជន។ **អត្ថបទ៖ វ៉ាន់ ណាង**

## ពលករខ្មែរច្រើនពាន់នាក់សម្រុកមកស្រុកវិញ ក្រោយបើកព្រំដែនកម្ពុជា-ថៃ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 17 August 2021 | 09:30 ICT

**ភ្នំពេញ:** ពលករខ្មែរប្រមាណជាង ៣ ពាន់នាក់ បានវិលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា តាមច្រកនានាតាមបណ្តោយព្រំដែន កម្ពុជា-ថៃ នៅពេលដែលរាជរដ្ឋាភិបាលបានប្រកាសបើកព្រំដែនឡើងវិញ កាលពីចុងសប្តាហ៍មុន ក្រោយពីបិទបណ្តោះអាសន្នក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩។ ពលករមកពីថៃទាំងនោះចូលមកតាមខេត្តកោះកុង បាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ ដែលមានពលករចូលមកច្រើនជាងខេត្តដទៃ។

ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ លោក សេក សុខុម ប្រាប់ភ្នំពេញប៉ុស្ដិ៍ថា គិតត្រឹមរយៈពេល ២ ថ្ងៃ ចាប់ពីថ្ងៃទី ១៣ និង ១៤ ខែសីហា មានពលករចូលតាមខេត្តបន្ទាយមានជ័យ ជិត ២ ពាន់នាក់ ក្នុងនោះរកឃើញអ្នកមានវិជ្ជមានកូវីដ ១៩ ចំនួន ៧០ នាក់។ លោកថ្លែងថា អភិបាលខេត្តបន្ទាយមានជ័យលោក អ៊ុំ រាត្រី បានត្រៀមទទួលពលករដែលត្រឡប់មកពីថៃ ដោយបានរៀបចំនូវមណ្ឌលចត្តាឡីស័កប្រមាណ ២០ កន្លែងដែលមានអគារធំទូលាយអាចទទួលបាន។ លោកថ្លែងថា៖ «ចំនួនពលករដែលចូលមក ប្រសិនណាមកក្នុង ១ ថ្ងៃត្រឹម ២០០ ទៅ ៤០០ នាក់ សម្រាប់ខេត្តយើងអាចទ្រទ្រង់ស្ថានភាពការណ៍បាន ប៉ុន្តែបើក្នុង ១ ថ្ងៃលើសពី ១ ពាន់នាក់យើងអាចជួបការលំបាកខ្លះ»។ «យើងបារម្ភបំផុត គាត់មកមិនមែនមកធម្មតាទេ គឺមកទាំងមេរោគបំប្លែងថ្មីដែលតា អ៊ីចឹងជាបន្ទុកធ្ងន់ធ្ងរសម្រាប់មន្ត្រីសុខាភិបាល និងកងកម្លាំងជួរមុខ គឺថាយើងអត់មានពេលសម្រាកទេ គឺនៅចាំសម្របសម្រួលពួកគាត់ធ្វើតេស្តរហ័ស យកមកធ្វើចត្តាឡីស័ក និងរៀបចំបាយទឹកជូនពួកគាត់»។

ប្រធានមន្ទីរព័ត៌មានខេត្តពោធិ៍សាត់ លោក លាត ទិត្យដ្ឋាន បានថ្លែងថា សម្រាប់ខេត្តនេះមានពលករចូលមកតាមច្រកថ្មដា ចំនួន ២៤ នាក់ ខណៈពលករទាំងនោះអវិជ្ជមានកូវីដ-១៩ទាំងអស់ តាមរយៈការធ្វើតេស្តរហ័ស ប៉ុន្តែពួកគេក៏ត្រូវ តម្រូវឱ្យធ្វើចត្តាឡីស័កចំនួន ២១ ថ្ងៃ។ លោកថា៖ «ពេលខ្លះជំងឺនេះសម្ងំក្នុងខ្លួនបានយូរ អ៊ីចឹងហើយបានជាយើងធ្វើចត្តាឡីស័ក ២១ ថ្ងៃ ដើម្បីទប់ស្កាត់ ដែលតា ព្រោះអីនៅថៃមានច្រើន»។

លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងនេះ ថ្លែងកាលពីថ្ងៃទី ១៣ ខែសីហានេះថា ពលករ ៤០០ នាក់ នៅច្រកទ្វារតំបន់ព្រំដែនកម្ពុជា-ថៃ សួនស៊ុំ ឬអូរអន្លក់ នៃស្រុកកំរៀង និងច្រករបៀង តាមបណ្តោយព្រំដែនកម្ពុជា-ថៃ នៃស្រុកសំពៅលូន ដែលជាប់គាំងនៅក្នុងប្រទេសថៃក្នុងអំឡុងពេលដែលប្រទេសកម្ពុជាមានវិធានការបិទខ្ទប់ខេត្តជាប់ព្រំដែនរយៈពេល ១៤ ថ្ងៃ ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងការឆ្លងរាលដាលក្នុងសហគមន៍នៃវីរុសកូវីដ ១៩ បំប្លែងថ្មីប្រភេទដែលតា ដែលបានបញ្ចប់នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០២១។ ពលករដែលជាប់គាំងនោះ ដែលបានវិលត្រឡប់មកវិញមានចំនួន ៣៩៩ នាក់ ដោយមកពី ២ ច្រកផ្សេងគ្នា ក្នុងនោះមកពីច្រកទ្វារតំបន់ព្រំដែនសួនស៊ុំ ឬអូរអន្លក់ ចំនួន ២៨៧ នាក់ និង ១ ច្រកទៀតមកពីតំបន់ច្រករបៀង ដែលនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ស្ថិតក្នុងស្រុកសំពៅលូន ចំនួន ១១២ នាក់ ហើយសម្រាប់ពលករទាំងអស់ដែលអនុញ្ញាតចូលមកស្រុកកំណើតវិញ ត្រូវបានរៀបចំចុះឈ្មោះ និងយកសំណាកតេស្តរហ័ស»។ លោក ងួន រតនៈ បន្តថា ក្នុងករណីពលកររកឃើញវិជ្ជមានកូវីដ ១៩ ក្រុមការងារនឹងរៀបចំដាក់គាត់ព្យាបាលនៅតាមមណ្ឌលព្យាបាលព្រំដែន ដែលអាជ្ញាធរបានរៀបចំ។ ចំណែកអ្នកលទ្ធផលអវិជ្ជមាន នឹងដឹកជញ្ជូនពួកគាត់ធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក នៅតាមបណ្តោយព្រំដែន ចំនួន ១៤ ថ្ងៃទៀត មុននឹងធ្វើការដឹកជញ្ជូនពួកគាត់ទៅបណ្តាស្រុក ឬខេត្តកំណើតរៀងៗខ្លួន។

កញ្ញា ជី ថាវី អាយុ ២៨ ឆ្នាំ ដែលកំពុងសម្រាកព្យាបាលនៅខេត្តបន្ទាយមានជ័យ បន្ទាប់ពីគេស្ដរកឃើញវិជ្ជមានកូវីដ ១៩ បានថ្លែងថា មូលហេតុដែលសម្រេចត្រឡប់មកកម្ពុជាវិញដោយសារបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ខណៈនៅប្រទេសថៃ កំពុងមានបាតុកម្ម រួមនឹងការឆ្លងរាលដាលនៃជំងឺកូវីដកាន់តែកើនឡើងពី ១ ថ្ងៃទៅ ១ ថ្ងៃ។ កញ្ញាថា៖ «ខ្ញុំអត់មានគម្រោងត្រឡប់ទៅថៃវិញទេ ព្រោះផលកម្រៃមិនសូវច្រើន ពេលខ្លះថៅកែអត់បើកលុយឱ្យទៀត ណាមួយខ្ញុំព្រួយបារម្ភដែរ នៅថៃឆ្លងកូវីដច្រើន ជាពិសេសនៅក្រុងថេប (បាងកក) និយាយទៅជួបការលំបាកច្រើន»។ «ខ្ញុំធ្វើការនៅថៃបានជាង ១ ឆ្នាំហើយ ផ្នែកដាំដំណាំ ដកដំឡូង ដាំម្នាស់ នៅខេត្តឈុនបូរី ក្នុង ១ ថ្ងៃរកបានប្រហែល ៥០០ ទៅ ៦០០ បាត តែថ្លៃបន្ទប់ ការហូបចុក គេអត់យកលុយទេ»។ កញ្ញា ថាវី ដែលមានស្រុកកំណើតនៅខេត្តសៀមរាបបានត្រឡប់ចូលមកទឹកដីកម្ពុជាវិញកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២១ ហើយបច្ចុប្បន្នកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយកន្លែងនៅឯខេត្តបន្ទាយមានជ័យ។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) បានថ្លែងថា បញ្ហាចម្បងដែលជំរុញឱ្យពលករខ្មែរ សម្រុកមកស្រុកកំណើតវិញយ៉ាងគំហុកនេះ គឺដោយសារនៅប្រទេសថៃ មានការឆ្លងរាលដាលជំងឺឆ្លងកូវីដនៅក្នុងប្រទេសកាន់តែខ្លាំង មូលហេតុនេះហើយនាំឱ្យរដ្ឋាភិបាលថៃបានសម្រេចបិទការដ្ឋានសំណង់ផ្សេងៗក្នុងក្រុង និងជាយក្រុង និងបិទទីតាំងមួយចំនួនធ្វើឱ្យប៉ះពាល់ដល់ពលករខ្មែរដែលកំពុងបម្រើការងារក្នុងវិស័យនេះ។ ធ្វើឱ្យពលករបរទេសជាពិសេសពលករខ្មែរ ដែលភាគច្រើនធ្វើក្នុងវិស័យកសិកម្ម និងសំណង់ រងផលប៉ះពាល់ច្រើន គាត់បាត់បង់ចំណូល ខ្វះអាហារ។ លោកថា៖ «ខ្ញុំគាំទ្រចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបើកច្រកព្រំដែនឡើងវិញ ដើម្បីទទួលពលករខ្មែរដែលកំពុងមានបញ្ហាប្រឈមនៅថៃ។ រដ្ឋាភិបាលយើងបានរៀបចំកន្លែងមណ្ឌលព្យាបាល មណ្ឌលចត្តាឡីស័ក គឺជាមធ្យោបាយល្អ និងបានពង្រីកទីតាំងច្រើនសម្រាប់ដោះស្រាយបញ្ហានេះ»៕

## មេខ្យល់នាំមនុស្សឆ្លងដែនប៉ុនប៉ងចូលទៅប្រទេសថៃ ដោយខុសច្បាប់ចំនួន០៣នាក់ ត្រូវបានឃាត់ខ្លួនអនុវត្តតាមច្បាប់

http://cambodiapolice.com/policekh/ 9:42 am 18 សីហា 2021

បាត់ដំបង ៖ កាលពីព្រឹកព្រលឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ នៅវេលាម៉ោង០៧និង៥៨នាទី នៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង អនុវត្តតាមយោបល់ដឹកនាំរបស់លោក ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនគរបាលស្រុកកំរៀង ដឹកនាំកម្លាំងសហការណ៍ជាមួយកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៩ ដែលមានលោកវរសេនីយ៍ឯក ម៉ង់ ស៊ី ជាមេបញ្ជាការ បង្ក្រាបករណីនាំយកចេញដោយមិនស្របច្បាប់សម្រាប់ នាំឆ្លងដែន ១ករណីក្នុងបទល្មើសជាក់ស្តែង។

យោងតាមរបាយការណ៍របស់ លោកវរសេនីយ៍ទោ វេ គឹមចត់ អធិការនគរបាលស្រុកកំរៀង បានឲ្យដឹងថា ឃាត់ខ្លួនជនសង្ស័យបានចំនួន០៣នាក់ រថយន្តប្រភេទដឹកជញ្ជូនម៉ាកសាំយ៉ុង ចំនួន០២គ្រឿង ដោយមានប្រជាពលរដ្ឋ ដែលសន្និដ្ឋានថា ជាពលករនិងកូនចៅរបស់គាត់ជាជនរងគ្រោះក្នុងអំពើនាំចេញនេះចំនួន៤៤នាក់ ស្រីចំនួន១០នាក់ អនីតិជនចំនួន១២នាក់ ស្រី០១នាក់ ហើយពួកគាត់ទាំងអស់ជាអ្នករស់នៅឯខេត្តកំពង់ចាម។ មេខ្យល់ទាំង០៣នាក់នោះមាន ១.ឈ្មោះ ហេង ច័ន្ទដារា ភេទប្រុស អាយុ៣៦ ឆ្នាំរស់នៅភូមិត្របែក ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម ជាអ្នកដឹកជញ្ជូន។ ២.ឈ្មោះ ធេន វ័ន្ធវ៉ែន ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅភូមិពពិត ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ជាអ្នកដឹកជញ្ជូន និង ៣.ឈ្មោះ សេង ឈុន ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅ

ភូមិចុង ឃុំសំបូរ ស្រុកបាធាយខេត្តកំពង់ចាម ជាអ្នកដើរប្រមូលមនុស្ស។ ករណីនេះ មេខ្យល់ទាំង០៣នាក់ និងរថយន្តផងសមត្ថកិច្ចនគរបាលស្រុកស្រុកកំរៀង កសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញ ដើម្បីអនុវត្តតាមច្បាប់ រីឯប្រជាពលរដ្ឋរងគ្រោះបានអប់រំណែនាំឱ្យវិលទៅលំនៅដ្ឋានវិញ៕

## សមត្ថកិច្ចថៃចាប់ខ្លួនពលរដ្ឋខ្មែរ០២នាក់ឆ្លងដែនចូលទៅកាប់ឈើខុសច្បាប់

http://cambodiapolice.com/policekh/ 6:10 pm 17 សីហា 2021

បន្ទាយមានជ័យ ៖ សមត្ថកិច្ចថៃបានចាប់ពលរដ្ឋខ្មែរចំនួន០២នាក់ នៅវេលាម៉ោង១២ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ខណៈពួកគេលួចឆ្លងដែនចូលទៅកាប់ឈើក្នុងទឹកដីថៃដោយខុសច្បាប់ ។ ប្រភពព័ត៌មានពីនគរបាលស្រុកថ្មពួក បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង០២នាក់ ដែលត្រូវសមត្ថកិច្ចថៃចាប់ខ្លួនមានឈ្មោះ លឿន សែន ភេទប្រុស អាយុ៣៣ ឆ្នាំ រស់នៅភូមិដងរែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងឈ្មោះ ៣ ពាន់ ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិថ្មីកណ្តាល ឃុំភូមិថ្មី ស្រុកថ្មពួកខេត្តបន្ទាយមានជ័យ ។ ប្រភពដដែលបានបញ្ជាក់ថា មុនពេលចាប់ខ្លួនពលរដ្ឋខ្មែរទាំង០២នាក់ បានលួចឆ្លងដែនចូលទឹកដីថៃទៅកាប់ឈើក្នុងភូមិសាស្រ្តសូន្យសាម ឃុំថាប់ថៃ ស្រុកតាប់ប្រាយ៉ា ហើយត្រូវបានមេព្រៃថៃចាប់ខ្លួននៅត្រង់ចំណុចខាងជើងបង្គោលសីមាលេខ ២៨ប្រហែល ៥០០ ម៉ែត្រ។ បច្ចុប្បន្នពលរដ្ឋខ្មែរទាំង០២នាក់នោះ នៅមិនទាន់ដឹងថាសមត្ថកិច្ចថៃបញ្ជូនទៅណានោះទេ ព្រោះខាងថៃមិនទាន់ផ្តល់ព័ត៌មានមក ៕

## សមត្ថកិច្ចខណ្ឌសែនសុខ រំដោះជនជាតិខ្មែរ និងបរទេស ១២នាក់ សង្ស័យត្រូវមេខ្យល់នាំយកមកបង្ខាំងទុកក្នុងផ្ទះល្វែង

https://www.gntimes.com/news/ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

ភ្នំពេញ៖ ជនជាតិខ្មែរ និងបរទេសសរុប ១២នាក់ ត្រូវបានកម្លាំងនគរបាលខណ្ឌសែនសុខ ចុះទៅរំដោះចេញពីផ្ទះល្វែងមួយកន្លែង ដោយសង្ស័យថា ត្រូវបានមេខ្យល់នាំយកមកបង្ខាំងទុក ។ ប្រតិបត្តិការនេះ សមត្ថកិច្ចធ្វើឡើងកាលពីវេលាម៉ោងប្រមាណជាង ៩ ព្រឹក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២១ នៅចំណុច ផ្ទះល្វែងសង់ថ្មី តាមផ្លូវបេតុង ក្នុងភូមិក្រុងថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្ទាប់ពីមានពាក្យបណ្តឹងពីនារីជាជនជាតិថៃម្នាក់ ក្នុងចំណោមអ្នកត្រូវគេបង្ខាំងទុកទាំងអស់ ។ ជនរងគ្រោះ ដែលត្រូវសមត្ថកិច្ចនាំយកទៅសាកសួររួមមានជនជាតិថៃ ៦នាក់, ជនជាតិចិន ៣នាក់ ,និងជនជាតិខ្មែរ ៣នាក់ សរុបទាំងអស់ ១២នាក់ ក្នុងនោះប្រុស ៨នាក់ ស្រី ៤នាក់ ។

តាមសមត្ថកិច្ចបង្ហើមឲ្យដឹងថា ការចុះមកនាំខ្លួនជនបរទេសនេះ បន្ទាប់ពីមានពាក្យបណ្តឹងឲ្យជួយអន្តរាគមន៍ ដោយអះអាងថា ពួកគេត្រូវបានមេខ្យល់នាំខ្លួនមកពីច្រកជ្រៃធំព្រំដែនវៀតណាម ចូលមកប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ និងបានបង្ខាំងទុកក្នុងផ្ទះខាងលើនេះ ។ តាមព័ត៌មានឲ្យដឹងថា នៅវេលារសៀល ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០២១ មានស្ត្រីម្នាក់ជាជនជាតិថៃ ចេះនិយាយភាសាខ្មែរខ្លះៗ បានទាក់ទងមកអ្នកសារព័ត៌មានឲ្យជួយប្តឹងសមត្ថកិច្ចមកអន្តរាគមន៍ ។ បន្ទាប់ពី ទទួលបានពាក្យបណ្តឹង នៅព្រឹកថ្ងៃទី ១៨ ខែ សីហា នេះ សមត្ថកិច្ច ក៏បានចុះទៅធ្វើរដ្ឋបាល ត្រួតពិនិត្យផ្ទះខាងលើ ហើយរកឃើញជនជាតិខ្មែរ និងបរទេស ដែលស្នាក់នៅប្រមូលផ្តុំក្នុងផ្ទះសរុប ១២នាក់ ហើយបាននាំខ្លួនមកសាកសួរតែម្តង ។ គេពុំដឹងថា ជនបរទេសទាំងនោះ ត្រូវបានគេនាំយកមកបង្ខាំងទុក ឬយ៉ាងណានោះទេ ? ។

ស្ត្រីជាជនជាតិថៃម្នាក់ បានប្រាប់អ្នកសារព័ត៌មានឲ្យដឹងថា ខ្លួនត្រូវបានមេខ្យល់នាំមករកការងារធ្វើ នៅក្នុងប្រទេសកម្ពុជាតាមច្រកជ្រៃធំ និងបានបង្ខាំងទុកនៅក្នុងផ្ទះខាងលើ ប្រមាណជាង ១០ថ្ងៃ មកហើយ ។ បច្ចុប្បន្ន ជន

ជាតិខ្មែរ និងបរទេសទាំង ១២នាក់ ត្រូវបានសមត្ថកិច្ចនាំខ្លួនទៅកាន់អធិការដ្ឋានខណ្ឌសែនសុខ ដើម្បីសាកសួរ និងកំណត់ឲ្យបានច្បាស់ថា អ្នកណាជាមេខ្យល់ដែលនាំយកមកបង្ខាំងទុក ហើយអ្នកណា ជាជនរងគ្រោះពិតប្រាកដ ៕ ដោយ ជល់ ជា

## ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

### ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ចំនួន៧២នាក់, ៥៣នាក់ ជាពលករទើបមកពីថៃ តាមច្រកអូរស្មាច់ និងជាសះស្បើយ១០នាក់

http://freshnewsasia.com/ 2021-08-18 09:40pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១នេះ បានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន ៧២ករណីបន្ថែមទៀត ខណៈអ្នកជំងឺ ១០នាក់ បានព្យាបាលជាសះស្បើយ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី១៨ ខែសីហានេះ។ រដ្ឋបាលខេត្តបានឱ្យដឹងថា អ្នកជំងឺរកឃើញថ្ងៃនេះ មានចំនួន៥៣នាក់ ជាពលករទើបវិលត្រឡប់មកពីប្រទេសថៃ តាមច្រកអូរស្មាច់ ចំនួន១៧នាក់ រកឃើញឆ្លងក្នុងសហគមន៍ និងចំនួន២នាក់ទៀត ជាពលករកំពុងធ្វើចត្តាឡីស័ក។ រដ្ឋបាលខេត្ត អំពាវនាវដល់ប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ជាមួយបុគ្គលវិជ្ជមានកូវីដ១៩ទើបរកឃើញនេះ ត្រូវដាក់ខ្លួនដាច់ដោយឡែករយៈពេល១៤ថ្ងៃ។ ក្នុងករណីមានរោគសញ្ញា ក្អក ផ្តាសាយ ហៀរសំបោរ ឈឺបំពង់ក ថប់ដង្ហើម ក្តៅខ្លួនខ្លាំង ឬរោគសញ្ញាសង្ស័យផ្សេងៗទៀត ត្រូវទាក់ទងក្រុមការងារប្រចាំការ និងយកសំណាកនៅ មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែកអន្លង់វែង ឬទំនាក់ទំនងសាកសួរព័ត៌មានផ្សេងៗតាមរយៈលេខទូរស័ព្ទ៖ ០១២ ៤៩៩ ១៩២។ រដ្ឋបាលខេត្ត បានឱ្យដឹងថា មកទល់ពេលនេះ ខេត្តឧត្តរមានជ័យរកឃើញអ្នកជំងឺកូវីដ១៩ សរុប ៥,៩១៨នាក់។ ក្នុងនោះករណីនាំចូលពីបរទេស ៤,៩០៩នាក់ និងករណីព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ១០០៨នាក់។ ជាមួយគ្នានេះអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន ២,៣៧៩នាក់ កំពុងសម្រាកព្យាបាលចំនួន៣,៥២៩នាក់ និងស្លាប់ចំនួន១០នាក់៕

### ស្ថានទូតកម្ពុជានៅថៃ នាំយកគ្រឿងឧបភោគបរិភោគចែកដល់បងប្អូនពលករខ្មែរ ដែលកំពុងជួបការលំបាកចំនួន៦០គ្រួសារ

https://www.kampucheathmey.com/ ថ្ងៃពុធ ១៨ សីហា ២០២១ដោយ Kang Tola

ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសថៃ ដឹកនាំដោយលោក ធុច ដាលីន តំណាងឱ្យលោកអ៊ុក សោភ័ណ ឯកអគ្គរាជទូត នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១នេះ បាននាំយកគ្រឿងឧបភោគបរិភោគ ដែលមានបន្លែ និងសាច់ ចុះចែកដល់បងប្អូនពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំងដោយសារការរាតត្បាតជំងឺកូវីដ១៩ នៅ២កន្លែងផ្សេងគ្នា ចំនួន៦០គ្រួសារ ស្ថិតតំបន់ផ្លូវប្រះឆាស៊ុងគ្រោះ និងរាចាដា ខណ្ឌហ៊ួយខ្វាង ទីក្រុងបាងកក។ បើតាមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបានឲ្យដឹងដែរថា ប្រទេសថៃបានសម្រេចបន្តការរឹតត្បិតតំបន់ត្រួតពិនិត្យខ្ពស់បំផុត និងតឹងរ៉ឹងបំផុតចំនួន២៩ ខេត្ត ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។ ជាមួយគ្នានោះ ស្ថានទូតបានអំពាវនាវឲ្យបងប្អូនខ្មែរ ដែលកំពុងមានវត្តមាននៅប្រទេសថៃ មេត្តាចូលរួមអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាលថៃ និងវិធានការ ៣ ការពារ ៣ កុំ ឲ្យបានខ្ជាប់ខ្ជួន។

សូមបញ្ជាក់ថា ស្ថានភាពជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃ គិតត្រឹមថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ មានអ្នកឆ្លងសរុបចំនួន៩២៨៣១៤ករណី និងមានអ្នកស្លាប់សរុប៧៧៣៤នាក់ ហើយសម្រាប់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ មានអ្នកឆ្លងថ្មីចំនួន២១១៥៧ និងមានអ្នកស្លាប់ចំនួន១៨២នាក់៕ *ដោយ ៖ កោះកែវ*

# ទោះបីជាមានការបិទខ្ទប់ច្រកឆ្លងដែនខុសច្បាប់ទាំងអស់រវាងកម្ពុជា និងថៃ ការរត់ពន្ធមនុស្សនៅតែមានសកម្មភាព

https://www.khmertimeskh.com/ Khmer Times August 19, 2021

យ៉ាងតិចណាស់មានគណៈអភិបាលខេត្តចំនួន៤នាក់ក្នុងចំណោម៧នាក់ទៀតដែលបានប្រឈមនឹងកាឆ្លងព្រំដែនដែលគ្មានរបៀបរបបត្រឹមត្រូវអស់រយៈពេលជាយូរអង្វែងមកហើយនោះជាមួយប្រទេសប្រទេសថៃបានប្រាប់ការសែតខ្មែរថាមស៍ថា ខណៈដែលលំហូរពលករចំណាកស្រុកត្រូវបានទប់ស្កាត់ក្នុងអំឡុងពេលបិទខ្ទប់ សកម្មភាពខុសច្បាប់ និងវិធានការបង្ក្រាបសកម្មភាពទាំងនេះត្រូវបានបន្តធ្វើឥតឈប់ឈរ។ "ក្នុងខេត្តប៉ៃលិនយើងមានករណីឆ្លងដែនខុសច្បាប់ចំនួន២៩ករណីនិងករណីឆ្លងដែនស្របច្បាប់១ករណី។ យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយភាគីថៃ ក្នុងករណីនេះដែរ អភិបាលខេត្តច័ន្ទថាបុរីក្នុងប្រទេសថៃបានបិទច្រកឆ្លងព្រំដែនខុសច្បាប់ទាំងអស់ ខណៈដែលកំពុងរៀបចំទទួលការឆ្លងដែនស្របច្បាប់ចាប់តាំងពីថ្ងៃទី១៣ ខែសីហា។

លោកស្រី បាន ស្រីមុំ អភិបាលខេត្តប៉ៃលិនបាននិយាយកាលពីសប្តាហ៍មុនថា៖ "យ៉ាងណាក៏ដោយ នៅសងខាងព្រំដែននៃប្រទេសទាំងពីរ កងកម្លាំងសន្តិសុខរបស់យើង និងកងកម្លាំងសន្តិសុខថៃបានឃាត់ខ្លួនអ្នកចង់ឆ្លងដែនបានជាច្រើននាក់ តាមរយៈការរៀបចំបានយ៉ាងល្អពីសំណាក់អ្នករត់ពន្ធមនុស្ស ដែលតែងតែបោកប្រាស់ពលករក្រីក្រដែលគ្រាន់តែចង់រកលុយដើម្បីចិញ្ចឹមគ្រួសាររបស់ពួកគេ។ លុយទាំងនេះភាគច្រើនគឺខ្ចីពីសាច់ញាតិ ឬអ្នកចងការប្រាក់ ហើយនៅពេលដែលពលករទាំងនេះត្រូវបានគេចាប់ខ្លួន ឬក៏បំបោះបង់ដោយអ្នករត់ពន្ធ ឬមេខ្យល់នៅតាមព្រំដែន ពលលករទាំងនោះត្រូវបានត្រលប់ទៅកន្លែងដើមដែលពួកគេបានចាប់ផ្តើម។"

នៅច្រកឆ្លងព្រំដែនស្របច្បាប់អន្តរជាតិព្រំ ក្រុមពលករចំណាកស្រុកជាច្រើនត្រូវបានគេដឹកឆ្លងព្រំដែនដើម្បីរៀបចំចុះឈ្មោះ ហើយនៅពេលដែលយើងបាននិយាយទៅកាន់ពួកគេ ពួកគេបានប្រាប់អំពីរឿងរ៉ាវអាក្រក់ៗជាច្រើនដូចជា មានការរំលោភបំពាន ការធ្វើបាបពីសំណាក់មេខ្យល់ ត្រូវបានលក់អោយក្លាយជាទាសករ និងក្នុងពេលនោះដែរពួកគេក៏បានលក់ទៅអោយម្ចាស់កន្លែងធ្វើការដែលមិនបានបើកប្រាក់ឈ្នួល ឬក៏ចិញ្ចឹមពលករទាំងនោះអោយបានល្អ។ នៅច្រកព្រំដែនអន្តរជាតិនេះ មានថ្ងៃជាច្រើនដែលគ្មានកម្មករឆ្លងកាត់ទាល់តែសោះ។ ប៉ុន្តែសម្រាប់អ្នកដែលឆ្លងព្រំដែននេះ គឺមានការចុះឈ្មោះ ធ្វើតេស្តរហ័ស និងបញ្ជូនទៅកន្លែងព្យាបាលឬមណ្ឌលធ្វើចត្តាឡីស័ក។

ពលករជាច្រើនបាននិយាយថា ពួកគេបានបង់លុយពី១៨,០០០បាទ(ប្រហែល៦០០ដុល្លាអាមេរិក) ទៅអោយមេខ្យល់ដើម្បីស្វែងរកការងារធ្វើនៅប្រទេសថៃ ដែលភាគច្រើនមានដូចជា កម្មករសំណង់ កម្មករចម្ការផ្លែឈើ អ្នកលក់នៅតាមផ្សារ ឬអ្នកជញ្ជូនឥវ៉ាន់ ដោយប្រាប់ថាពួកគេនឹងទទួលបានប្រាក់ខែខ្ពស់ជាងនៅស្រុកខ្មែរ និងមានឱកាសជាច្រើនទៀត។

ពកលរម្នាក់ជាស្រ្តីអាយុ៣៥ឆ្នាំ នៅមណ្ឌលព្យាបាលសាលាក្រៅ បាននិយាយថា៖ "ភាពមានគ្រោះថ្នាក់នោះគឺនៅពេលដែលជំងឺកូវីដ-១៩ បានផ្ទុះឡើង និងរាលដាលដូចជាភ្លើងឆេះនៅក្នុងប្រទេសថៃ ម្ចាស់កន្លែងធ្វើការបានប្រាប់អោយយើងចាកចេញ។ មានអ្នកខ្លះបានបិទអាជីវកម្ម ឬការងារផ្សេងៗទៀត ហើយបានបោះបង់យើង ដូច្នេះហើយយើងត្រូវប្រើលុយសន្សំទាំងប៉ុន្មាននោះធ្វើដំណើររាប់រយគីឡូម៉ែតឆ្ពោះទៅព្រំដែនដែលជិតបំផុត ដើម្បីត្រលប់មកទឹកដីកម្ពុជាវិញ។"ស្រ្តីដដែលបាននិយាយបន្ថែមថា៖ "ខ្ញុំមិនចង់អោយឈ្មោះ ឬរូបថតរបស់ខ្ញុំត្រូវបានផ្សព្វផ្សាយនោះទេ ដោយសារខ្ញុំចង់ត្រលប់ទៅធ្វើការនៅស្រុកថៃវិញ នៅពេលដែលស្ថានភាពបានល្អប្រសើរ ពីព្រោះថាក្រុមគ្រួសាររបស់យើងគឺពឹងផ្អែកលើយើងក្នុងការរកលុយផ្ញើរត្រលប់មកវិញ" ដោយបន្ថែមថាគាត់នៅទីនោះជាមួយបងប្អូនបង្កើតប្រុសពីនាក់ទៀត។

ក្នុងខេត្តបាត់ដំបង ឧត្តរមានជ័យ ប៉ោយប៉ែត ប៉ៃលិន នោះវិញ រឿងដដែលៗត្រូវបានយកមកនិយាយ។ ពួកគេត្រូវបង់លុយរហូតដល់៣០០០បាទ ដើម្បីបានឡានជិះទៅដល់ទីតាំងប្រមូលផ្តុំពលករ ដែលរៀបចំឡើងដោយភាគីថៃ។ ពួកគេត្រូវនៅទីនោះរយៈ១៤ថ្ងៃក្នុងអំឡុងពេលបិទខ្ទប់រវាងថ្ងៃទី២៩ ខែ កក្កដា ដល់ថ្ងៃទី១២ ខែសីហា ហើយបន្ទាប់មក ពួកគេត្រូវបង់លុយបន្ថែមទៀតពី៣០០ ទៅ៥០០បាទទៀត ដើម្បីបានឡានដឹកពួកគេឆ្លងព្រំដែន រួមបញ្ចូលទាំងរបស់របស់ពួកគេផងដែរ។ កាលណាពួកគេមានឥវ៉ាន់កាន់តែច្រើន ពួកគេត្រូវបង់លុយកាន់តែច្រើនដែរ។ ពួកគេបានសង្កត់ធ្ងន់ថា៖ "យើងត្រូវបានភាគីថៃយកចិត្តទុកដាក់មើលថែរក្សានៅទីតាំងប្រមូលផ្តុំពលករ ដោយគេបានប្រាប់យើងថា អាជ្ញាធរកម្ពុជាបានទាក់ទងជាមួយពួកគេ និងស្វែងរកជំនួយរហូតដល់ព្រំដែនត្រូវបានបើកឡើងវិញ។

## ស្ថានអគ្គកុងស៊ុលកម្ពុជា ចុះប្រមូលពលករខ្មែរ មកពីបណ្តាខេត្តនានានៅប្រទេសថៃ កកស្ទះនាផ្សាររុងគ្លឿ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៩ សីហា ២០២១ដោយ deth leng

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បានឲ្យដឹងនៅព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ នេះថា កាលពីនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ បានចុះប្រមូលប្រជាពលករ និងកម្មករខ្មែរ ដែលមកពីបណ្តារខេត្តនានា នៃប្រទេសថៃ ហើយមកកកស្ទះនៅផ្សាររ៉ុងគ្លឿ និងនៅមុខស្ថានអគ្គកុងស៊ុល រួមទាំងបងប្អូនអាជីវករ កម្មករនៅផ្សាររុងគ្លឿផងដែរ ដែលពួកគាត់ត្រៀមសម្រុកចេញមកប្រទេសកម្ពុជា។ បើតាមលោក កុយ គួង ប្រជាពលរដ្ឋ និងកម្មករខ្មែរទាំងនោះមានចំនួន១៦៥នាក់ ស្រី៦១ និងក្មេង២០នាក់ ហើយស្ថានអគ្គកុងស៊ុល បានអន្តរាគមន៏ទៅសមត្ថកិច្ចថៃ និងបានជួលរថយន្តដឹកពួកគាត់ប្រគល់អោយសមត្ថកិច្ច និងក្រុមការងារទប់ស្កាត់កូវីដខ្មែរនៅច្រកអូរបើជាន់ ដើម្បីចាត់វិធានការតាមនិតិវិធីសុខាភិបាលបន្ត៕ ដោយ៖ កោះកែវ

## មនុស្ស ៣ នាក់ត្រូវចាប់ខ្លួន រឿងបម្រុងនាំមនុស្សឆ្លងដែននៅថៃ

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 19 August 2021 | 10:41 ICT

**បាត់ដំបង:** សមត្ថកិច្ចនគរបាលស្រុកកំរៀង កំពុងស៊ើបអង្កេតស្វែងរកមេខ្យល់នាំមនុស្សឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ក្រោយពីបក្ខពួក ៣ នាក់ ត្រូវសមត្ថកិច្ចចាប់ខ្លួន កាលពីថ្ងៃទី ១៧ ខែសីហា នៅភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង និងបានបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តបន្តនីតិវិធីនៅព្រឹកថ្ងៃទី ១៨ ខែសីហា។

លោក ង៉ែត វណ្ណា អធិការរងនគរបាលស្រុកកំរៀង ថ្លែងថាជនសង្ស័យ ៣ នាក់ ក្នុងនោះមាន ២ នាក់ ជាអ្នកដឹកជញ្ជូនមនុស្សមកពីខេត្តកំពង់ចាម និងម្នាក់ទៀតជាអ្នកប្រមូលមនុស្ស។ ចំណែកមេខ្យល់នៅពីក្រោយរឿងនេះ សមត្ថកិច្ចកំពុងស្រាវជ្រាវរកចាប់ខ្លួន។ លោកថ្លែងថា៖ «មេខ្យល់យើងចែកដាច់ដោយឡែក ចំណែកពួកគាត់នេះជាអ្នកប្រមូលផ្តុំ រកឡានដឹកយកមកឱ្យមេខ្យល់បន្តទៀត ប៉ុន្តែពួកគាត់ហ្នឹងក៏ប្រហាក់ប្រហែលនឹងមេខ្យល់ដែរ។ ដោយឡែកមេខ្យល់តែម្តងយើងស្រាវជ្រាវអត់ទាន់ឃើញទេ ដោយសារគាត់បិទទូរស័ព្ទ»។ លោក វណ្ណា បញ្ជាក់ថាជនសង្ស័យជាអ្នកដឹកជញ្ជូន និងប្រមូលផ្តុំមនុស្សនេះ បានដឹកមនុស្សទាំងអស់ចំនួន ៤៤ នាក់ ក្នុងនោះមានទាំងអនីតិជនចំនួន ១២ នាក់ មកពីខេត្តកំពង់ចាមទាំងយប់ ប៉ុន្តែបានមកដល់ចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបងក្នុងវេលាព្រឹក ត្រូវសមត្ថកិច្ចល្បាតប្រទះឃើញ ក៏ឃាត់ខ្លួនពួកគេតែម្តង។

លោកថ្លែងថា៖ «យើងបានឃាត់ខ្លួនជនសង្ស័យបានចំនួន ៣ នាក់ ជិះរថយន្តប្រភេទដឹកជញ្ជូនម៉ាកសាំងយ៉ុងចំនួន ២ គ្រឿង ដោយមានប្រជាពលរដ្ឋដែលសន្និដ្ឋានថា ជាពលករ និងកូនចៅរបស់គាត់ជាជនរងគ្រោះក្នុងអំពើនាំចេញនេះចំនួន ៤៤ នាក់ក្នុងនោះ ស្រីចំនួន ១០ នាក់ អនីតិជនចំនួន ១២ នាក់ ស្រីម្នាក់»។ បើតាមលោក វណ្ណា ជនសង្ស័យទាំង ៣ នាក់ ទី ១ មានឈ្មោះ ហេង ច័ន្ទដារា ភេទប្រុស អាយុ ៣៦ ឆ្នាំរស់នៅភូមិត្របែក ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម ជាអ្នកដឹកជញ្ជូន ទី ២ មានឈ្មោះ ឆេន រ័ត្នវ៉ៃ ភេទប្រុស អាយុ ៤១ ឆ្នាំ រស់នៅភូមិពពិត ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ជាអ្នកដឹកជញ្ជូន និងទី ៣ ឈ្មោះ សេង ឈុន ភេទប្រុស អាយុ ៣០ ឆ្នាំ រស់នៅភូមិចុង ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម ជាអ្នកដើរប្រមូលមនុស្ស។ ដោយឡែកពលរដ្ឋដែលត្រូវជនសង្ស័យនាំមកទាំងនោះត្រូវសមត្ថកិច្ចធ្វើការអប់រំណែនាំ និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ៕

## ស្ថានអគ្គកុងស៊ុល នាំយកស្បៀងអាហារជូនពលករខ្មែរ នៅចំការអំពៅ និងរោងចក្រស្ករស នៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៩ សីហា ២០២១ដោយ Kang Tola

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឲ្យដឹង នាល្ងាចថ្ងៃទី១៩ ខែសីហា នេះថា នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១នេះ ក្រុមការងារស្ថានអគ្គកុងស៊ុលបាននាំយកស្បៀងអាហារ ទៅប្រគល់ជូនដល់ដៃសំរាប់ពលករ និងកម្មករខ្មែរ នៅចំការអំពៅ និងរោងចក្រស្ករសរ នៅក្នុងប្រទេសថៃ។ បើតាមលោក កុយ គួង ស្បៀងអាហារទាំងនោះ រួមមាន អង្ករ មីកញ្ចប់ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ម៉ាស់ អាកុលថ្នាំគ្រុនក្តៅ ថ្នាំក្អក និងសេរ៉ូក្តៅខ្លួនកូនក្មេង ព្រមទាំងបាយធា១០០ ប្រអប់ទឹកសិទ្ធ១០០យួរ។

លោក កុយ គួង អះអាងថា ក្នុងពេលចុះជួបពលករទាំងនោះ លោកអគ្គកុងស៊ុលបានជួបជាមួយអភិបាលស្រុកវឌ្ឍនានៈខន ប្រធានមន្ទីរពេទ្យស្រុក ប្រធានមន្ទីរការងារស្រុក និងបានផ្តាំផ្ញើអោយអាជ្ញាធរជួយយកចិត្តទុកដាក់ដល់កម្មករខ្មែរ ដែលកំពុងធ្វើការងារជាកម្មករចំការអំពៅ និងកម្មកររោងចក្រស្ករស ដែលកំពុងស្ថិតក្នុងការបិទខ្ទប់នៅតំបន់នោះចំនួនជាង៨៧នាក់៕ *ដោយ ៖ កោះកែវ*

## កម្លាំងបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះសហការដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗចំនួន៥០ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញ-ចូល

http://cambodiapolice.com/policekh/ 2:05 pm 18 សីហា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងការណែនាំរបស់លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ នៅយប់ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅតូចៗ ចំនួន៥០ គោលដៅ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញ-ចូលផងដែរ ៕

## ប៉ូលិសថៃដេញចាប់រថយន្តដឹកពលករខ្មែរធ្លាក់ទឹក ស្លាប់៤នាក់ និងរបួស៤នាក់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២០ សីហា ២០២១ដោយ Sokhom Khon

យ៉ាងហោចណាស់ក៏មានពលករខ្មែរស្លាប់៤នាក់ និង៤នាក់ទៀតរងរបួសដែរ ខណៈដែលប៉ូលិសដេញតាមពីក្រោយ ហើយរថយន្តប្រឹងបើកក្នុងល្បឿនលឿន ទើបធ្លាក់ចូលក្នុងស្រះទឹក។ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១២និង៣០នាទីថ្ងៃត្រង់ ក្នុងស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ដែលមានរថយន្តស៊េរីទំនើបមួយគ្រឿងដឹកពលករខ្មែរ ឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ប៉ូលិសថៃចំនួន២កន្លែង ត្រូវបានប៉ូលិសដេញតាមពីក្រោយ ដោយក្នុងល្បឿនលឿនពេកក៏រ៉េចង្កូចធ្លាក់ចូលក្នុងស្រះទឹកតែម្តង។

យោងតាមបានរាយការណ៍បន្ថែមពីហេតុការណ៍នេះថា រថយន្តក្រឡាប់ត្រូវបានត្រួតពិនិត្យ នៅកន្លែងកើតហេតុនិងកំពុងសួរចម្លើយអ្នករងរបួសដែលនៅមានជីវិតអង្គុយក្នុងរថយន្ត បានផ្តល់ព័ត៌មានថា ពួកគេមកពីផ្សារពេងភ្លឿ តាមរយៈការទាក់ទងមេខ្យល់មានមនុស្សមកទទួលហើយបង់លុយ៧៥០០បាត ក្នុងមួយនាក់ មកជាមួយគ្នា៧នាក់ ប្រុស២ ស្រី៣ និងក្មេងស្រី២នាក់ អាយុ២ឆ្នាំ១នាក់ និងអាយុ១ខែ១នាក់ រួមជាមួយអ្នកបើកបរជាជនជាតិថៃម្នាក់ សរុបចំនួន០៨ នាក់។

នៅពេលមកដល់ប៉ុស្តិ៍ប៉ូលិសណងសាង ជាប៉ុស្តិ៍ត្រួតពិនិត្យរបស់មន្រ្តីប៉ូលិស និងអនុរក្សការពារព្រំដែនស្រាប់តែអ្នកបើកបរបានបង្កើនល្បឿនឡើងដើម្បីគេចវេះពីប៉ុស្តិ៍ត្រួតពិនិត្យ។ ដូច្នេះបណ្តាលឱ្យមានការតាមស្ទាក់ចាប់ខ្លួនពីមន្រ្តីប៉ូលិស និងធ្វើអោយ ប៉ូលិសប៉ុស្តិ៍គោកខ្យូងស្ទាក់ចាប់រថយន្តនោះនៅពេលមកដល់។ ទំនងជាមានការស្លន់ផង ពេលដល់ចំណុចផ្លូវបែកជាបីគេបានឃើញថា រថយន្តបានបោះពួយទៅត្រង់ក៏ធ្លាក់ក្នុងស្រះទឹកតែម្តងទើបបានសមត្ថកិច្ចជួយសង្គ្រោះដោយរកឃើញថា មនុស្ស៤នាក់បានស្លាប់ ម្នាក់ជាជនជាតិថៃ(អ្នកបើកបរ) ស្លាប់ស្ត្រីម្នាក់ និងក្មេងស្រីតូចៗ២នាក់ សរុប៤នាក់ រីឯមនុស្ស៤នាក់ទៀតបានចេញពីក្នុងរថយន្ត ផុតពីសេចក្តីស្លាប់ ៕
អត្ថបទ ៖ សោ និយមរ័ត្ន

## ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ៖ ជនល្មើសឱកាសកំពុងទាញយកផលចំណេញវិបត្តិកូវីដ១៩ តាមរយៈការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែននានា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២០ សីហា ២០២១ដោយ Kang Tola

ការបញ្ជាក់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បែបនេះ ខណៈអញ្ជើញថ្លែងសុន្ទរកថា បើកពិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងជំងឺរាតត្បាតសកលកូវីដ១៩ ឆ្នាំ២០២១ នៅល្ងាចថ្ងៃសុក្រ ទី២០ ខែសីហា ឆ្នាំ២០២១នេះ តាមប្រព័ន្ធវីដេអូ។

មានប្រសាសន៍នៅក្នុងពិធីនោះ សម្តេចតេជោ ហ៊ុន សែន បានសម្តែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះស្មារតីសាមគ្គីភាព និងសុខដុមនីយកម្មគ្រប់ជាតិសាសន៍ និងជំនឿសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសស្មារតីជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជា នៅគ្រប់កាលៈទេសៈ ក៏ដូចជាពិភពលោក ដើម្បីសេចក្តីសុខក្សេមក្សាន្តនៃមនុស្សជាតិ ។ បើតាមសម្តេចតេជោ ចាប់តាំងពីឆ្នាំ២០១៧ មក កម្ពុជាតែងប្រារព្ធពិធីអន្តរសាសនាយ៉ាងអធិកអធមប្រឆាំងការជួញដូរមនុស្ស ហើយកន្លងមកសម្តេចបានប្រគល់ភារកិច្ចនេះជូនសម្តេចក្រឡាហោម ស ខេង រួមជាមួយសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងមេដឹកនាំគ្រប់និកាយសាសនា ព្រមទាំងថ្នាក់ដឹកនាំមន្ត្រីរាជការ គឺគ្រប់ក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

សង្គមស៊ីវិល វិស័យឯកជនរាប់ពាន់នាក់ ដើម្បីធ្វើពិធីបួងសួង តាមបែបសាសនា និងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សក្នុងគ្រប់រូបភាព។

ទោះជាយ៉ាងណា សម្តេចតេជោ ហ៊ុន សែន អះអាងថា កម្ពុជាបានផ្អាកការជួបជុំទ្រង់ទ្រាយធំកាលពីឆ្នាំ២០២០ ដើម្បីអនុវត្តនូវវិធានការបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហានៃការរាតត្បាតជំងឺកូដ ១៩ ចូលក្នុងសហគមន៍ ហើយនៅឆ្នាំ២០២១ នេះ វិបត្តិកូវី១៩ នៅតែបន្តឆ្លងរាតត្បាត ចំណែកការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែននានា ក៏កំពុងត្រូវបានជនឆ្លៀតឱកាសប្រើគ្រប់មធ្យោបាយ ទាញយកផលចំណេញពីស្ថានភាពដ៏លំបាកនេះ។ សម្តេចតេជោ ហ៊ុន សែន យល់ថា វេទិកាអន្តរសាសនាត្រូវតែរៀបចំតាមគន្លងថ្មី ដើម្បីក្រើនរំលឹកដល់ប្រជាជនគ្រប់ជាតិសាសន៍ និងជំនឿសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រជាជននៅលើពិភពលោក ដើម្បីផ្លាស់ប្តូរហើយសម្របខ្លួនតាមបែបគន្លងថ្មីក្នុងសម័យកូវីដ ជាមួយនឹងការប្រកាន់ខាប់នូវស្មារតីមនុស្សធម៌ សន្តោសប្រណីយកចិត្តទុកដាក់ដល់អាយុជីវិត និងសេចក្តីថ្លៃថ្នូរ នៃមនុស្សជាតិគ្រប់ជាតិសាសន៍ និងជំនឿសាសនា។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានសម្តែងនូវមោទនភាពចំពោះការរក្សាបាននូវភាព សុខដុមរមនា នៃគ្រប់ជំនឿសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈកិច្ចសហការយ៉ាងសកម្ម ជាពិសេស ការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវវប្បធម៌ចែករំលែកពុំចេះរីងស្ងួត ជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងគ្រាដ៏លំបាកនេះ។ សម្តេចបន្តថា រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តយ៉ាងសកម្ម តាមរយៈដៃម្ខាងរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់ និងស្ថិរភាពសង្គម ដើម្បីទ្រទ្រង់ជីវភាពប្រជាជន និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងដៃម្ខាង ទៀតប្រយុទ្ធប្រឆាំងជំងឺរាតត្បាតសកលកូវីដ១៩ តាមគ្រប់រូបភាព ទាំងការបង្ការទប់ស្កាត់ ការព្យាបាល និងការស្តារនីតិសម្បទាជនរងគ្រោះ និងសហគមន៍ ដែលទទួលរងនូវផលប៉ះពាល់។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងនូវអំណរគុណចំពោះស្មារតីសាមគ្គីភាព និងការជួយគ្នាក្នុងគ្រាលំបាក នៃបណ្តាប្រទេសជាមិត្តដែលបានផ្តល់វ៉ាក់សាំងទាន់ពេលវេលា ជាពិសេសសាធារណរដ្ឋប្រជាមានិតចិន ដែលជាប្រទេសឈានមុខក្នុងការផ្តល់វ៉ាក់សាំង ទាំងជំនួយមនុស្សធម៌ ទាំងតាមការបញ្ជាទិញ ក៏ដូចជាប្រទេសជប៉ុន ប្រទេសអង់គ្លេស ប្រទេសអាមេរិកដែលធ្វើឱ្យកម្មវិធីចាក់វ៉ាក់សាំងប្រព្រឹត្តទៅលឿនជាងការគ្រោងទុក៕ *ដោយ ៖ កោះកែវ*

## ទីប្រឹក្សាសម្តេចតេជោ ជួបរដ្ឋមន្ត្រីក្រសួងការងារថៃ ស្នើឱ្យជួយដោះស្រាយការលំបាករបស់ពលករខ្មែរ

http://freshnewsasia.com/ 2021-08-21 07:56am

**(បាងកក, ថៃ)៖** លោកបណ្ឌិត សុខ សុក្រឹត្យា ទីប្រឹក្សាផ្ទាល់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅថ្ងៃទី២០ ខែសីហា ម្សិលមិញនេះ បានចូលជួបលោក Suchat Chomklin រដ្ឋមន្ត្រីក្រសួងការងាររបស់ថៃ នៅទីក្រុងបាងកក ដើម្បីជជែកពីបញ្ហាប្រឈមមួយចំនួនរបស់ពលករខ្មែរក្នុងកំលុងនៃការរាតត្បាតជំងឺកូវីដ១៩។ ក្នុងជំនួបនេះ លោកបណ្ឌិត សុខ សុក្រឹត្យា បានជម្រាបពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកូវីដ១៩ ក្នុងនោះរួមមានការដាក់ចេញវិធានការចាំបាច់មួយចំនួន ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃផងដែរ។ លោកបណ្ឌិត សុខ សុក្រឹត្យា បានគូសបញ្ជាក់ថា ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ជាពិសេសមេរោគបំប្លែងថ្មី «ដែលតា» នោះ រាជរដ្ឋាភិបាល បានរៀបចំឱ្យពលករខ្មែរទាំងអស់ ធ្វើចត្តាឡីស័ក និងទទួលការព្យាបាលនៅតាមខេត្តជាប់ព្រំដែនផ្ទាល់តែម្តង។

លោកបណ្ឌិត សុខ សុក្រឹត្យា ដែលជាប្រធានក្រុមប្រឹក្សាភិបាលមូលនិធិខ្មែរចំណាកស្រុកផងដែរនោះ បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនរបស់ពលករខ្មែរក្នុងកំលុងពេលនៃការរាតត្បាតជំងឺកូវីដ១៩ និងការធ្វើដំណើរដោយប្រថុយប្រថានរបស់ពលករខ្មែរ ដើម្បីត្រឡប់ទៅកម្ពុជាវិញជាដើម។ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ

នាយករដ្ឋមន្ត្រី លោកបណ្ឌិត សុខ សុក្រឹត្យា បានស្នើឱ្យរដ្ឋមន្ត្រីក្រសួងការងារ ក៏ដូចជាអាជ្ញាធរថៃ ជួយដោះស្រាយការលំបាករបស់ពលករខ្មែរក្នុងកំលុងរាតត្បាតជំងឺកូវីដ១៩ និងជួយឱ្យពួកគេបានទទួលការព្យាបាលនៅពេលពួកគេឆ្លងជំងឺកូវីដ១៩ជាដើម។

តបតាមសំណើនេះ រដ្ឋមន្ត្រីក្រសួងការងារថៃ បានសន្យាបន្តយកចិត្តទុកដាក់លើពលករខ្មែរ ដោយជួយសម្រួលលើការរស់នៅ និងរៀបចំវិធានដោះស្រាយផលវិបាកផ្សេងៗជាច្រើនក្នុងកំឡុងវិបត្តិកូវីដ-១៩។ លោករដ្ឋមន្ត្រី ក៏បានអះអាងដែរថា ភាគីថៃ នឹងរៀបចំអនុស្សារណៈយោគយល់គ្នាពិសេស១ រវាងកម្ពុជា-ថៃ ដើម្បីប្រមូលយកពលករខ្មែរទាំងស្របច្បាប់ និងមិនស្របច្បាប់មកធ្វើការ នៅប្រទេសថៃឡើងវិញ ទោះបីជំងឺរាតត្បាតកូវីដ-១៩ មិនទាន់ស្រាកស្រាន្តក៏ដោយ។ លោក Suchart Chomklin ក៏បានសន្យាថា នឹងស្នើសុំទៅសមត្ថកិច្ចពាក់ព័ន្ធរបស់ថៃសម្រួលដល់ពលករខ្មែរខុសច្បាប់ដោយចាប់ពីពេលនេះទៅមិនឱ្យចាប់នោះឡើយ តែត្រូវផ្តល់ព័ត៌មានឲ្យក្រសួងការងារ ដើម្បីក្រុមការងារក្រសួងរៀបចំផ្តល់សិទ្ធិស្របច្បាប់ដល់ពួកគេឡើងវិញ។ រដ្ឋមន្ត្រីក្រសួងការងារថៃ ក៏បានសន្យាដែរថា រដ្ឋាភិបាលថៃ នឹងផ្តល់ការចាក់វ៉ាក់សាំងការពារកូវីដ១៩ ដល់ពលករខ្មែរទាំងអស់ដែលកំពុងធ្វើការ និងរស់នៅប្រទេសថៃដោយមិនមានការរើសអើងនោះ។

ការសន្យារបស់លោករដ្ឋមន្ត្រីក្រសួងការងារថៃ គឺជាក្តីសង្ឃឹមថ្មី ដើម្បីសម្រួលការលំបាករបស់ពលករខ្មែរនៅក្នុងប្រទេសថៃនាពេលបច្ចុប្បន្ននេះ។ តំណាងឱ្យសម្តេចតេជោ ហ៊ុន សែន, លោកបណ្ឌិត សុខ សុក្រឹត្យា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងការងារថៃ អាជ្ញាធរ និងរដ្ឋាភិបាលថៃ ដែលបានបង្ហាញជំហរផ្តល់នូវការគាំពារខ្ពស់ដល់ពលករខ្មែរ។ ក្នុងជំនួបនោះ លោក Suchart Chomklin ក៏បានធ្វើការនឹករលឹក និងការសួរសុខទុក្ខជូនសម្តេចតេជោ ហ៊ុន សែន និងបានភ្ជាប់ជាមួយនូវវត្ថុអនុស្សាវរីយ៍ជូនសម្តេចតេជោនាយករដ្ឋមន្ត្រីផងដែរ៕

## ពលករខ្មែរ៣នាក់ ស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នៅថៃ មិនទាន់រកសាច់ញាតិឃើញ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២១ សីហា ២០២១ដោយ Dy Bunnara

អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ កំពុងតែស្វែងរកសាច់ញាតិរបស់ពលករខ្មែរចំនួន៣នាក់ ដែលបានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ ដោយរថយន្តធ្លាក់ចូលទឹក កាលពីថ្ងៃទី១៩ ខែសីហា ដើម្បីទាមទារសំណងតាមផ្លូវច្បាប់ពីអាជ្ញាធរថៃ។ នេះបើតាមការបញ្ជាក់ពីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានថ្លែងប្រាប់កម្ពុជាថ្មីនៅព្រឹកនេះថា ករណីរថយន្តបើកធ្លាក់ទឹកកាលពីថ្ងៃទី១៩ ខែសីហា បណ្តាលឲ្យស្លាប់ចំនួន៤នាក់នោះ មិនមែនខ្មែរទាំងអស់ទេ គឺតែកុងឡានថៃម្នាក់ ហើយ៣នាក់ទៀត គឺជាម្តាយ និងកូនតូច២នាក់ជនជាតិខ្មែរ។ លោកថា មកដល់ពេលនេះ សពពលរដ្ឋខ្មែរនេះ ត្រូវបានអគ្គកុងស៊ុលកម្ពុជា នាំយកមឈូសទៅដាក់ និងបញ្ជូនមកទឹកដីខ្មែរវិញហើយ។ ចំណែកឯកអគ្គកុងស៊ុលកម្ពុជា កំពុងតែស្វែងរកសាច់ញាតិ ដើម្បីទៅរកដំណោះស្រាយតាមផ្លូវច្បាប់ទាក់ទងទៅនឹងសំណងផ្សេងៗ។

គួររំលឹកថា កាលពីថ្ងៃទី១៩ សីហា ឆ្នាំ២០២១ វេលាម៉ោង១២ និង៣០ នាទីថ្ងៃត្រង់ ក្នុងស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ មានរថយន្តស៊េរីទំនើបមួយគ្រឿងដឹកពលករខ្មែរឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ប៉ូលីសថៃចំនួន២កន្លែង ត្រូវបានប៉ូលិសដេញតាមពីក្រោយ ដោយបើកបរក្នុងល្បឿនលឿនពេក ក៏រេចង្កូតធ្លាក់ចូលក្នុងស្រះទឹកតែម្តង។
យោងតាមបានរាយការណ៍បន្ថែមពីហេតុការណ៍នេះថា រថយន្តក្រឡាប់ ត្រូវបានត្រួតពិនិត្យ នៅកន្លែងកើតហេតុ និងកំពុងសួរចម្លើយអ្នករងរបួស ដែលនៅមានជីវិតអង្គុយក្នុងរថយន្ត បានផ្តល់ព័ត៌មានថា ពួកគេមកពីផ្សាររោងក្លឿ តាមរយៈការទាក់ទងមេខ្យល់មានមនុស្សមកទទួលហើយបង់លុយ ៧៥០០ បាតក្នុងមួយនាក់ មកជាមួយគ្នា៧

នាក់ គឺប្រុសចំនួន២នាក់ ស្រីចំនួន០៣នាក់ និងក្មេងស្រីចំនួន០២នាក់ អាយុ០២ឆ្នាំម្នាក់ និង អាយុ១ខែម្នាក់ រួមជាមួយអ្នកបើកបរជាជនជាតិថៃម្នាក់ សរុបចំនួន០៨ នាក់។

នៅពេលមកដល់ប៉ុស្តិ៍ប៉ូលិសណងសាង ជាប៉ុស្តិ៍ត្រួតពិនិត្យរបស់មន្ត្រីប៉ូលីស និងអនុរក្សការពារព្រំដែន ស្រាប់តែអ្នកបើកបរបានបង្កើនល្បឿនឡើង ដើម្បីគេចវេសពីប៉ុស្តិ៍ត្រួតពិនិត្យ។ ដូច្នេះបណ្តាលឱ្យមានការតាមស្ទាក់ចាប់ខ្លួនពីមន្ត្រីប៉ូលីស និងធ្វើអោយប៉ូលីសប៉ុស្តិ៍គោកខ្យូងស្ទាក់ចាប់រថយន្តនោះនៅពេលមកដល់។ ទំនងជាមានការស្លន់ផងលុះដល់ចំណុចផ្លូវបែកជាបី រថយន្តបានបោះពួយធ្លាក់ក្នុងស្រះទឹកតែម្តង។ សមត្ថកិច្ចបានជួយសង្គ្រោះ ដោយរកឃើញថា មនុស្ស៤ នាក់បានស្លាប់ ម្នាក់ជាជនជាតិថៃ (អ្នកបើកបរ) ស្លាប់ស្ត្រីម្នាក់ និងក្មេងស្រីតូចៗ២នាក់ សរុប ៤ នាក់ រីឯមនុស្ស៤ នាក់ទៀត បានចេញពីក្នុងរថយន្ត ផុតពីសេចក្តីស្លាប់៕ អត្ថបទ៖ កោះកែវ

## ខេត្តបន្ទាយមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ២១៥ករណី ជាពលករមកពីថៃ

https://cen.com.kh/ Posted ByPen Srey NeatAugust 21, 2021

បន្ទាយមានជ័យ៖ រដ្ឋបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ បានប្រកាសពីការរកឃើញចំនួនអ្នកឆ្លង ២១៥ករណី ។ រដ្ឋបាលខេត្ត បានឲ្យដឹងថា អ្នកជំងឺកូវីដ១៩ ទាំង ២១៥ករណី ជាពលករមកពីថៃ ដែលកំពុងធ្វើចត្តាឡីស័ក ហើយក្នុងនោះ រដ្ឋបាលខេត្តក៏បញ្ជាក់ថា មានអ្នកជាសះស្បើយ ២០០នាក់៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះសហការទទួលពលរដ្ឋ ចំនួន៥នាក់ ពីសមត្ថកិច្ចថៃ បញ្ជូនទៅមណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 10:11 am 21 សីហា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍ព្រំដែនចក្រីនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ឯក ស៊ឹម កុសល នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២, វរសេនាតូចលេខ១ ដឹកនាំដោយលោកវរសេនីយ៍ត្រី ណន វន្នី មេបញ្ជាការកងអនុសេនាធំ ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញចំនួន៥នាក់(ស្រី១នាក់) ពីយោធាថៃកងអនុសេនាធំលេខ១១១៣នៃកងវរសេនាធំលេខ១៣ ត្រង់ចំណុចនិយាម កា0213666- 1482174 ភូមិសាស្រ្ត ភូមិខៅធង់ឃែប ឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវទល់មុខប៉ុស្តិ៍ព្រំដែនចក្រីភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

បន្ទាប់ពីសាកសួរ កត់ឈ្មោះរួច កម្លាំងយើងបានប្រគល់បងប្អូនប្រជាពលរដ្ឋជូនក្រុមគ្រូពេទ្យដើម្បីធ្វើតេស្តរហ័សរកកូវីដ-១៩ ជាលទ្ធផល អវិជ្ជមាន ទាំងអស់ រួចក្រុមគ្រូពេទ្យបញ្ជូនបងប្អូនទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## នគរបាលស្រុកភ្នំព្រឹកឃាត់ខ្លួនពលរដ្ឋ៣នាក់ អប់រំណែនាំមិនឲ្យឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

http://cambodiapolice.com/policekh/ 10:56 am 21 សីហា 2021

បាត់ដំបង ៖ អនុវត្តតាមយោបល់ដឹកនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ លោកវរសេនីយ៍ទោ ហេង បារាំង អធិការនគរបាលស្រុកភ្នំព្រឹក បានដឹកនាំកម្លាំងជំនាញ ចុះឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៣នាក់ ធ្វើការអប់រំណែនាំ ខណៈពួកគេបម្រុងឆ្លងដែនដោយខុសច្បាប់ចូលប្រទេសថៃ ។ ពលរដ្ឋទាំង៣នាក់ រួមមាន ១-ឈ្មោះ សាន់ ខុន ភេទស្រី អាយុ ៤៤ឆ្នាំ រស់នៅភូមិភ្នំតូច ឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង, ២-ឈ្មោះ ហៀក ឡាង ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិភ្នំតូច ឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង និង៣-ឈ្មោះ គឿត រឿន ភេទប្រុស អាយុ ៣២ឆ្នាំ រស់នៅភូមិអូរល្ហុង ឃុំអូររំដួល ស្រុកភ្នំព្រឹកខេត្តខេត្តបាត់ដំបង ។ សមត្ថកិច្ចនគរបាលបានធ្វើកិច្ចសន្យាអប់រំណែនាំឱ្យពួកគាត់យល់អំពីច្បាប់ ហើយធ្វើកិច្ចសន្យាឈប់ប្រព្រឹត្តសកម្មភាពនេះបន្តទៀតនិងឱ្យវិលត្រឡប់ទៅលំនៅឋានវិញ ៕

## ថៃចាប់ពលករខ្មែរ ២៣ នាក់ កំពុងចាកចេញពីផ្សាររុងក្លឿ បម្រុងចូលមកកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២០ សីហា ២០២១ដោយ deth leng

ពលករខ្មែរចំនួន ២៣ នាក់ ត្រូវបានកម្លាំងឈុតខ្មៅថៃ ធ្វើការឃាត់ខ្លួនបានជាបន្តបន្ទាប់ ខណៈពួកគេកំពុងធ្វើដំណើរឆ្លងផ្លូវ ឆ្ពោះទៅរកខ្សែបន្ទាត់ព្រំដែនថៃ-កម្ពុជា។ ការឃាត់ខ្លួននេះ គឺរសៀលថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ដោយកម្លាំងកងវរយលេខ ១២០៥ ដែលកំពុងល្បាតតាមខ្សែបន្ទាត់ព្រំដែនត្រង់ចំណុច បានដុងងូ ក្នុងភូមិប៉ារ៉ៃម៉ែ ឃុំប៉ារ៉ៃ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ខណៈដែលពលករខ្មែរទាំង២៣នាក់ កំពុងធ្វើដំណើរឆ្ពោះទៅកាន់ខ្សែបន្ទាត់ព្រំដែន។ នៅពេលកម្លាំងត្រួតពិនិត្យដោយបានសាកសួរដោយពួកគេបានសារភាពថា ពួកគេបានមកធ្វើការនៅក្នុងផ្សាររុងក្លឿយូរហើយ លុះពេលកូវីដផ្ទុះខ្លាំងក៏អស់ការងារធ្វើ ដោយសារតែផ្សារត្រូវបានអាជ្ញាធរថៃបិទជាបណ្តោះអាសន្ន ទើបសម្រេចថានឹងវិលត្រឡប់ទៅប្រទេសខ្លួនវិញ ដោយធ្វើដំណើរតាមច្រករបៀងដើម្បីឆាប់បានដល់ផ្ទះព្រោះមិនចង់អោយអាជ្ញាធរកម្ពុជាឃុំខ្លួន១៤ថ្ងៃ ដើម្បីធ្វើចត្តាឡីស័ក។ បច្ចុប្បន្នពលករខ្មែរទាំង ២៣ នាក់ ត្រូវបានសមត្ថកិច្ចថៃ ពិនិត្យសុខភាពព្រមទាំងបានបញ្ជូនអោយទៅសមត្ថកិច្ចកម្ពុជាតាមច្រកអូរបីជាន់ ក្នុងស្រុកគោកខ្សូង ដើម្បីធ្វើចត្តាឡីស័កនៅលើទឹកដីកម្ពុជា៕ អត្ថបទ : សោ និយមវ័ត្ន

# ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១

## វត្តទាំង២៤៥វត្ត និងវិហារស្លាក់ការថ្វាយបង្គំពាហិរសាសនាទាំង៦០កន្លែង នៅក្នុងខេត្តស្វាយរៀង ចូលរួមបន្លឺសម្លេងស្គរ ជួងកងរំពង

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២០ សីហា ២០២១ដោយ Kang Tola

ស្វាយរៀង ៖ នៅវេលាម៉ោង៦និង០០នាទី ល្ងាចថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ នៅតាមបណ្តាទីវត្តអារាមនៅទូទាំងខេត្តស្វាយរៀង បានបន្លឺសម្លេងស្គរ ជួងកងរំពង របស់ព្រះសង្ឃគ្រប់ទីវត្តអារាម និងវិហារ នៃគ្រប់សាសនា ដើម្បីចូលរួមកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២១ ក្រោមប្រធានបទ «សូមឱ្យពិភពលោកទាំងមូលរួចផុតពីជំងឺរាតត្បាតកូវីដ-១៩ នឹងអំពើជួញដូរមនុស្ស» ។

លោក ទីវ សុភា ប្រធានមន្ទីរធម្មការនិងសាសនាខេត្តស្វាយរៀង បានមានប្រសាសន៍ឲ្យដឹងថា យោងតាមសេចក្តីណែនាំលេខ១៤/២១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងធម្មការ និងសាសនា ហើយដោយ

មានការណែនាំពីសំណាក់ ឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត មន្ទីរធម្មការ និងសាសនាខេត្តស្វាយរៀង បានសម្របសម្រួលវត្តទាំង២៤៥វត្ត និងវិហារស្នាក់ការថ្វាយបង្គំពាហិរសាសនាទាំង៦០កន្លែង ចូលរួមបន្លឺសម្លេងស្គរ ជួងកងរំពង នៅវេលាម៉ោង៦និង០០នាទីល្ងាច ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដើម្បីបួងសួងសូមឲ្យពិភពលោកទាំងមូលរួចផុតពីជំងឺរាតត្បាតកូវីដ-១៩ និងអំពើជួញដូរមនុស្ស។

សូមបញ្ជាក់ផងដែរថា ជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៧មក គណៈកម្មការជាតិប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស (គជបជ) តែងបានសហការជាមួយក្រសួងធម្មការនិងសាសនា មេដឹកនាំសាសនាធំៗក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំកម្មវិធីអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស ក្នុងគោលបំណងបួងសួងឲ្យប្រជាជនកម្ពុជាក៏ដូចជា ប្រជាជនលើពិភពលោក ទទួលបានសេចក្ដីសុខជៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្សដែលជាទាសភាពសម័យទំនើប៕ *ដោយ៖ កក្ដី*

## ព្រះសង្ឃវត្តក្រពើហា ក្រុងតាខ្មៅ ធ្វើការ ទួងស្គរ វាយជួងស្របតាមការណែនាំ របស់រាជរដ្ឋាភិបាល

https://news.btv.com.kh/ 08/20/2021 07:08 PM

កណ្ដាលៈ ព្រះឃោសមុនីវង្ស វ័ន្ត វណ្ណោ ព្រះចៅអធិការវត្តប្រជុំនទី ហៅវត្តក្រពើហា បានដឹកនាំព្រះសង្ឃក្នុងវត្តធ្វើពិធីសូត្រមន្តទួងស្គរ វាយជួង នៅវេលាម៉ោង ៦ល្ងាច ថ្ងៃទី២០ ខែសីហានេះ ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីជាស់តឿនក្រើនរំលឹក ដល់អ្នកដែលនៅរស់កុំធ្វេសប្រហែសភ្លេចខ្លួនឲ្យរងគ្រោះដោយជំងឺកូវីដ-១៩ ក៏ដូចជាអំពើជួញដូរមនុស្សជាដើមនោះ។ ក្រោយធ្វើពិធីសូត្រមន្តតាមបែបព្រះពុទ្ធសាសនា និងទួងស្គរវាយជួងរួច ឃោសមុនីវង្ស វ័ន្ត វណ្ណោ បានមានសង្ឃដីកា ព្រះសង្ឃ លោកតាជី យាយជី ក្នុងវត្តក្រពើហាទាំងអស់ តែងតែធ្វើទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងធម្មការជានិច្ច ហើយការធ្វើនេះ គឺដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាពិភពលោកទាំងមូលឲ្យរួចផុតពីជំងឺរាតត្បាតកូវីដ១៩ ក៏ដូចជាជៀសឲ្យឆ្ងាយពីការជួយដូរមនុស្សជាដើម។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងធម្មការ និងសាសនា បានអំពាវនាវ និងប្រគេនដល់គណៈសង្ឃទាំងពីរគណៈថ្នាក់ដឹកនាំគ្រប់សាសនាទាំងអស់នៅកម្ពុជា ត្រូវបន្លឺសំឡេងស្គរ ជួងកងរំពង នៅវេលាម៉ោង៦ល្ងាចថ្ងៃទី២០ ខែសីហាខាងនេះ គ្រប់វត្ត និងគ្រប់វិហារទាំងអស់ទូទាំងប្រទេស ដើម្បីជាស់តឿនក្រើនរំលឹកដល់អ្នកដែលនៅរស់កុំធ្វេសប្រហែសភ្លេចខ្លួន ឲ្យរងគ្រោះដោយជំងឺកូវីដ-១៩ ក៏ដូចជាអំពើជួញដូរមនុស្សជាដើម។ ក្រសួង បានជូនដំណឹងដល់សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ថ្នាក់ដឹកនាំគ្រប់សាសនា និងលោកប្រធានមន្ទីរធម្មការ និងសាសនា រាជធានី-ខេត្ត ត្រូវសហការគ្នាជាមួយថ្នាក់ដឹកនាំសាសនាធំៗទាំងអស់ក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ក្នុងគោលបំណងបួងសួងឲ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជននៅលើពិភពលោកទទួលបានសេចក្ដីសុខ ជៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើបនោះ។ មួយវិញទៀតការទួងស្គរ និងវាយជួងនេះដែរ ក៏ដើម្បីជាស់តឿនក្រើនរំលឹកអ្នកដែលនៅរស់កុំធ្វេសប្រហែសភ្លេចខ្លួន ក្នុងកិច្ចការពារមេរោគកូវីដ១៩ជាដើមនោះ៕

## ខេត្តបាត់ដំបង ដាក់ពង្រាយកម្លាំង ៥០គោលដៅ ទប់ស្កាត់ពលរដ្ឋចេញ-ចូល ច្រកព្រំដែន

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១

(បាត់ដំបង)៖ កម្លាំងវរសេនាតូចនគរបាលការពារព្រំដែន គោកលេខ៨១៧ ដាក់ពង្រាយកម្លាំងប្រចាំការតាមគោលដៅចំនួន៥០តាមខ្សែបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋចេញ-ចូលខុសច្បាប់។ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ចេញវិធានការបន្ថែម ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។

លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងដាក់ពង្រាយកម្លាំងប្រចាំការ តាមគោលដៅតូចៗ ៥០គោលដៅ ដើម្បីខ្ទប់ស្កាត់ប្រជាពលរដ្ឋចេញ-ចូល។ កាលពីថ្ងៃទី១៣ សីហា កម្ពុជា បានសម្រេចបើកព្រំដែន ដោយអនុញ្ញាត ឱ្យពលករខ្មែរមកពីថៃ ចូលមកកម្ពុជាវិញ ទោះបីជាមានករណីសង្ស័យកូវីដ១៩ និងកូវីដដែលតាក៏ដោយ៕

## នគរបាលបញ្ជូនជនសង្ស័យម្នាក់ទៅសាលាដំបូងខេត្ត ពីបទនាំពលករឆ្លងដែន

http://nokorwatnews.com/ 22/08/2021

ខេត្តបន្ទាយមានជ័យ៖ ជនសង្ស័យម្នាក់ត្រូវបានកម្លាំងនគរបាលការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ បញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ នេះ ។

លោក គឿង ម៉ាន់សិង្ហ នាយការិយាល័យ នគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ បានឲ្យដឹងថា៖ ជនសង្ស័យឈ្មោះ ពីត ពេត ហៅ ពីន ពេត ភេទប្រុសអាយុ ៣៨ឆ្នាំ នៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ។ ជនសង្ស័យរូបនេះត្រូវបានកម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ចាប់ឃាត់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឲ្យចាប់ខ្លួនដែលចេញដោយលោក លឹម សុគន្ធារ៉ា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ ដោយជាប់ចោទពីបទការនាំយកពលករចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន ។ ហើយត្រូវបានកម្លាំងនគរបាលចាប់ឃាត់ខ្លួន បាននៅរសៀលថ្ងៃទី២១ ខែសីហា ឆ្នាំ ២០២១នៅនឹងផ្ទះជនជាប់ចោទ នៅភូមិល្បើកស្វាយ ឃុំ ស្វាយចេក ស្រុកស្វាយចេក។ លោកបញ្ជាក់ថា៖ ជនជាប់ចោទឈ្មោះ ពីត ពេតហៅ ពីន ពេត ត្រូវបានកម្លាំងនគរបាលជំនាញរបស់លោកបញ្ជូនខ្លួនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធីច្បាប់ហើយ៕

## ក្រុមចិនឆ្លងដែនខុសច្បាប់ពីថៃហើយចង់ចូលមកកម្ពុជា តែត្រូវឃាត់ទាន់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៣ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ០៩:៥៧

ខេត្តបន្ទាយមានជ័យ ៖ ជនជាតិចិនប្រុស-ស្រី៦នាក់បានលួចឆ្លងដែនដោយខុសច្បាប់ពីប្រទេសថៃចូលមកកម្ពុជា ដោយត្រូវបានកម្លាំងចម្រុះឃាត់ខ្លួន ស្ថិតតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។

លោកវរសេនីយ៍ត្រី រាជ ម៉ូ នាយប៉ុស្តិ៍រិទ្ធីសែននគរបាលវរៈការពារព្រំដែនគោកលេខ៩១១បានអោយដឹងថាជនជាតិចិនទាំង៦នាក់ដែលត្រូវឃាត់ខ្លួនមាន១-ឈ្មោះ ឈិន ណា ភេទប្រុស អាយុ២៣ឆ្នាំ ២-ឈ្មោះ វិញ ស៉រ ភេទប្រុស អាយុ៣២ឆ្នាំ ៣-ឈ្មោះ ឆេ ល៉រ ភេទប្រុស អាយុ២៤ឆ្នាំ ៤-ឈ្មោះ សុន ឈានរ៉ុង ភេទស្រី អាយុ៣២ឆ្នាំ ៥-ឈ្មោះ ផ៉រ ហ៉ាឡុង ភេទប្រុស អាយុ២៥ឆ្នាំ និង៦-ឈ្មោះ គុង គ័រ ភេទប្រុស អាយុ២៧ឆ្នាំ ។ លោកបានបញ្ជាក់ថានៅពេលឃាត់ខ្លួនជនជាតិចិន គឺកម្លាំងចម្រុះបានចេញល្បាតតាមបន្ទាត់ព្រំដែន ដើម្បីការពារបូរណភាពទឹកដីទប់ស្កាត់បទល្មើសឆ្លងដែន និងពលករចំណាកស្រុកខុសច្បាប់ ដែលគេចវេសធ្វើចត្តាឡីស័ក ក៏បានប្រទះឃើញជន

ជាតិចិនចំនួន៦នាក់ (ស្រី១នាក់) ខាងលើ លួចឆ្លងដែលពីប្រទេសថៃចូលមកកម្ពុជា ត្រង់ចំណុចនិយាមការ (២៥៦០១៩.១៥២៨៧៣៤)។ លោកវរសេនីយ៍ត្រី រាជ្យ ម៉ូ បានបញ្ជាក់ថា ក្រោយពេលឃាត់ខ្លួនជនជាតិចិន៦នាក់ត្រូវបានកម្លាំងនគរបាលវការពារព្រំដែនគោកលេខ៩១១ បានប្រគល់ជូនស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដើម្បីអនុវត្តតាមច្បាប់។

## ពលករចូលតាមច្រកបន្ទាយមានជ័យ ប្រចាំថ្ងៃ៤00ទៅ៥00នាក់ និងមាន១០ភាគរយ រកឃើញវិជ្ជមាន

https://news.btv.com.kh/ 08/23/2021 11:08 AM

ភ្នំពេញ៖ ការវិលត្រឡប់របស់ពលករខ្មែរពីប្រទេសថៃ តាមច្រកនានាជាប់ខេត្តបន្ទាយមានជ័យ ជាប្រចាំថ្ងៃនៅតែបន្តមាន ក្នុងរង្វង់ចាប់ពី៤០០ ទៅ៥០០នាក់ ហើយត្រូវបានមន្ត្រីសុខាភិបាលខេត្ត ធ្វើសំណាកតាមរយៈឧបករណ៍តេស្តរហ័ស ដើម្បីរកវីរុសកូវីដ១៩ ជាលទ្ធផលមានប្រមាណ ១០ភាគរយ នៃពលករទាំងនោះ មានវិជ្ជមានកូវីដ១៩ ។

ឯកឧត្តម អ៊ុ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ មានប្រសាសន៍ថា ចាប់តាំងពីមានការបើកព្រំដែនជាមួយប្រទេសថៃ ក្នុងការឲ្យពលករខ្មែរត្រឡប់មកស្រុកកំណើតវិញ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ មានពលករខ្មែរចូលតាមច្រកខេត្តបន្ទាយមានជ័យ នៅតែមានចំនួនច្រើន និងមាន១០ភាគរយ នៃពលករទាំងអស់នោះ វិជ្ជមានកូវីដ១៩ ហើយត្រូវបញ្ជូនទៅសម្រាកព្យាបាលតាមមណ្ឌលនានាដែលមាននៅក្នុងខេត្តសរុបចំនួនជិត ២០កន្លែង ។ ឯកឧត្តម បានបន្តថា ដោយកំណើនមកជាបន្តបន្ទាប់នេះ អាជ្ញាធរខេត្តបានរៀបចំមណ្ឌលចត្តាឡីស័ក នៅក្នុងក្រុងសិរីសោភ័ណ និងតាមបណ្ដាស្រុកមួយចំនួន រហូតដល់ចំនួន ២២កន្លែង និងបច្ចុប្បន្នមានអ្នកកំពុងធ្វើចត្តាឡីស័កតាមមណ្ឌលនានាចំនួន ៦ ៦២៧នាក់ ។ ឯកឧត្តមអភិបាលខេត្ត បន្ថែមថា ទន្ទឹមនឹងការរកឃើញអ្នកវិជ្ជមានកូវីដ១៩ អាជ្ញាធរ និងមន្ត្រីសុខាភិបាលខេត្ត បាននិងកំពុងពន្លឿនក្នុងការចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋនៅទូទាំងខេត្ត ដោយរហូតមកដល់ពេលនេះ អ្នកមានអាយុចាប់ពី ១៨ឆ្នាំឡើង ចាក់បានជាង ៣០ម៉ឺននាក់ និងនៅថ្ងៃទី២៣ ខែសីហានេះ ចាប់ផ្ដើមយុទ្ធនាការចាក់វ៉ាក់សាំងដល់កុមារ និងយុវវ័យ ចាប់ពីអាយុ១២ឆ្នាំ ទៅដល់ក្រោម១៨ឆ្នាំ ដែលគម្រោងត្រូវចាក់ចំនួន ១០៩ ០០០នាក់ នៅមណ្ឌលសុខភាពក្នុងខេត្តចំនួន ៦៨ទីតាំង ។

ឯកឧត្តម អ៊ុ រាត្រី បញ្ជាក់ថា ពុំមានករណីយុវជននៅមណ្ឌលបន្សាប់គ្រឿងញៀន រត់ចេញពីមណ្ឌលនោះ គឺគ្រាន់តែពួកគេពេលដឹងថា មានករណីវិជ្ជមានកូវីដ១៩ ហើយនោះ ចង់ស្វែងរកទីតាំងព្យាបាល ប៉ុន្តែបច្ចុប្បន្នអាជ្ញាធរបានសម្រួលឲ្យពួកគេ បានទៅមណ្ឌលព្យាបាលខាងក្រៅចំនួន ១៥០នាក់ និងក្រៅពីនោះព្យាបាលនៅក្នុងមណ្ឌលបន្សាប់គ្រឿងញៀន ។ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ អាជ្ញាធរខេត្តបានរកឃើញអ្នកវិជ្ជមានកូវីដ១៩ ចំនួន ២៨២នាក់ និងជាសះស្បើយចំនួន ១៦៨នាក់ ។ រហូតមកដល់ពេលនេះ នៅខេត្តបន្ទាយមានជ័យ ក្រសួងសុខាភិបាលបានរកឃើញអ្នកវិជ្ជមានវីរុសបំប្លែងថ្មីដែលតា (Delta) ចំនួន១៤៦នាក់ និងសរុបនៅទូទាំងប្រទេសកម្ពុជា គឺបានរកឃើញអ្នកវិជ្ជមានវីរុសនេះ ចំនួន៩៩៩នាក់ ប៉ះពាល់លើរាជធានី និងខេត្តសរុបចំនួន២៣ លើកលែងខេត្តកែប និងខេត្តក្រចេះ ៕ អត្ថបទ បាន សុខវិទ្ធ

## មេខ្យល់៣នាក់ត្រូវបានឃុំខ្លួនក្រោយកម្លាំងស្នងការខេត្តបាត់ដំបងបញ្ជូនដល់តុលាការ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៣ សីហា ២០២១ដោយ KC Virak

ខេត្តបាត់ដំបង៖ មេខ្យល់ចំនួន៣នាក់ត្រូវបានតុលាកាសម្រេចឃុំខ្លួន ក្រោយសមត្ថកិច្ចឈរជើងតាមបន្ទាប់ព្រំដែនឃាត់ខ្លួន ខណៈពួកគេទាំង៣នាក់ បាននាំពលករខ្មែរចំនួន៣៨នាក់ ប៉ុនប៉ងឆ្លងដែនចូលក្នុងទឹកដីថៃខុសច្បាប់កាលពីពេលថ្មីៗកន្លងទៅនេះ។

លោកវរសេនីយ៍ឯក ប៊ិន វណ្ណារ៉ា នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការនគរបាលខេត្តបាត់ដំបង បានប្រាប់ឱ្យដឹងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១នេះថា ជនសង្ស័យទាំង៣នាក់ដែលជាមេខ្យល់បាននាំពលករខ្មែរជាច្រើននាក់ប្រុងឆ្លងដែនចូលក្នុងទឹកដីថៃ ហើយត្រូវកម្លាំងការពារតំបន់ព្រំដែនចម្រុះឃាត់ខ្លួនបានកាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១មកនេះ ត្រូវបានតុលាការសម្រេចឃុំខ្លួនហើយនៅក្នុងពន្ធនាគារខេត្តបាត់ដំបង ក្រោយការិយាល័យជំនាញបញ្ជូនដល់ដៃតុលាការ។ លោកបន្តថា ជនល្មើសទាំងបីនាក់ខាងលើរួមមាន ១. ឈ្មោះ ជ្រី សុហេង ភេទប្រុសអាយុ២១ឆ្នាំ ២. ឈ្មោះ ជ្រ សំណាង ភេទប្រុស អាយុ១៦ឆ្នាំទាំង២នាក់រស់នៅភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបងនិងទី៣ ឈ្មោះ ផាន់ នីឌី ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិនិមិត្ត ឃុំស្រកា៥ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ការឃាត់ខ្លួនមេខ្យល់ទាំង៣នាក់ខាងលើនេះអនុវត្តឡើងដោយកម្លាំងផ្នែកជំនាញជាមួយនឹងកម្លាំងប៉ុស្តិ៍នគរបាលតាសែន ចុះឃាត់ខ្លួនបានរួមជាមួយពលករខ្មែរចំនួន៣៨នាក់ផ្សេងទៀតទៀត ខណៈពួកគេកំពុងនាំគ្នាធ្វើដំណើរដោយថ្មើរជើងកាត់ព្រៃឫស្សីឆ្ពោះទៅកាន់ប្រទេសថៃ ត្រង់ចំណុចស្ពានអូតចម្លង ស្ថិតក្នុងភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង៕ អត្ថបទ៖ សៅ សារិទ្ធ

## ពលរដ្ឋខ្មែររកស៊ីនៅប្រទេសវៀតណាម ៤៣នាក់ ត្រូវបានបញ្ជូនខ្លួនមកប្រទេសកម្ពុជា តាមច្រកទ្វារអន្តរជាតិបាវិត និងធ្វើតេស្តបឋម រកឃើញវិជ្ជមាន ៤នាក់

https://gntimes.com/news/ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១

ខេត្តស្វាយរៀង៖ ពលរដ្ឋខ្មែរប្រុស-ស្រី ដែលទៅរកស៊ីនៅប្រទេសវៀតណាម ៤៣នាក់ ត្រូវបានអាជ្ញាធរវៀតណាម បញ្ជូនខ្លួនមកប្រទេសកម្ពុជា កាលពីរសៀលថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២១ តាមច្រកអន្តរជាតិបាវិត ហើយក្រុមគ្រូពេទ្យបានធ្វើតេស្តបឋមទៅលើប្រជាពលរដ្ឋទាំង ៤៣ នាក់ រកឃើញវិជ្ជមាន ៤នាក់ និងបានបញ្ជូនទៅព្យាបាល នៅក្រុងបាវិត ។ ចំណែកប្រជាពលរដ្ឋ និងក្មេងៗ ៣៩នាក់ទៀត ដែលអវិជ្ជមាន ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅសាលាបឋមសិក្សាស្វាយតាយាន ស្ថិតនៅភូមិស្វាយតាយាន ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

បើតាមលោក ភោគ សុផា មេឃុំស្វាយតាយាន បានឲ្យដឹងថា កាលពីវេលាម៉ោងជាង ៦ល្ងាច ថ្ងៃទី ២២ ខែសីហា ក្រុមការងារគណៈកម្មការកូវីដ-១៩ បានបញ្ជូនបងប្អូនប្រជាពលរដ្ឋរកស៊ីចំណាកស្រុកនៅប្រទេសវៀតណាម មកធ្វើចត្តាឡីស័ក មានប្រុសស្រី និងកុមារសរុប ៣៩នាក់ ។ លោកបន្ត នេះជាលើទី ២ហើយ ដែលអាជ្ញាធរឃុំទទួលយកកម្មករ កម្មការនីរោងចក្រ និងបងប្អូនប្រជាពលរដ្ឋរកស៊ីចំណាកស្រុក ត្រូវអាជ្ញាធរប្រទេសវៀតណាមបញ្ជូនមកប្រទេសកម្ពុជា និងត្រូវធ្វើចត្តាឡីស័កនៅឃុំស្វាយតាយាន ។ ចំពោះប្រជាពលរដ្ឋទាំង ៤៣នាក់ ដែលប្រទេសវៀតណាមបញ្ជូនមកប្រទេសកម្ពុជា គឺជាប្រជាពលរដ្ឋដែលរស់នៅភូមិថ្នល់កែង ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ៕ ដោយ ព្រហ្មសារ៉េត

# ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១

## ពលករចំនួន៧នាក់ រួមនឹងមេខ្យល់ម្នាក់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅក្បែរអូរព្រំដែន

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៣ សីហា ២០២១ដោយ Kang Tola

បាត់ដំបង ៖ មេខ្យល់ម្នាក់ត្រូវបានកម្លាំងវរការពារព្រំដែនឃាត់ខ្លួន ខណៈមេខ្យល់រូបនេះកំពុងនាំពលករខ្មែរបម្រុងឆ្លងដែនចូលទៅក្នុងទឹកដីថៃ។ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១១ និង ៣០ នាទីថ្ងៃត្រង់ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោក៨១៧ប្រចាំប៉ុស្តិ៍ព្រំដែនគីឡូ១៣ បានសហការទប់ស្កាត់ពលករខ្មែរបំរុងឆ្លងដែនចូលទឹកដីថៃ តាមបន្ទាត់ព្រំដែន ក្រោមការដឹកនាំពីលោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនលេខ៨១៧ បានដាក់បទបញ្ជាដល់កម្លាំងសហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន និង កម្លាំងយោធាវរសេនាតូច៥៣៣ បានធ្វើសកម្មភាពទប់ស្កាត់ពលករខ្មែរបំរុងលួចឆ្លងដែនចូលទឹកដីថៃ។

សមត្ថកិច្ចបានឲ្យដឹងថា ការឃាត់ខ្លួននេះគឺមានពលករខ្មែរចំនួន០៧នាក់ ក្នុងនោះស្រី០៤នាក់ និងឃាត់មុខសញ្ញានាំមនុស្សឆ្លងដែនដែន(មេខ្យល់)ចំនួន០១នាក់ ឈ្មោះ យឹម-ជឿន ភេទប្រុសអាយុ៣០ឆ្នាំមានទីលំនៅក្រុមទី០១ភូមិពោធិ៍ជ្រៃ ឃុំសេរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ សមត្ថកិច្ចបានបញ្ជាក់បន្ថែមថា បន្ទាប់ពីកម្លាំងបានសាកសួរ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពលករខ្មែរទាំងអស់រួមទាំងមេខ្យល់ឲ្យទៅកម្លាំងនៃអធិការដ្ឋាននគរបាលស្រុកសំពៅលូនដើម្បីចាត់ការតាមនីតិវិធីបន្ត ដើម្បីបញ្ជូនខ្លួនមេខ្យល់ទៅកាន់តុលាការ៕

*អត្ថបទ ៖ សោ និយមវត្ថ៌*

## ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ តាមខេត្តបន្ទាយមានជ័យ ១ថ្ងៃ ៣០០នាក់ រកឃើញឆ្លងកូវីដ ២៧នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៣ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ២៣:៤១

បន្ទាយមានជ័យ៖ ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកភូមិសាស្រ្តខេត្តបន្ទាយមានជ័យ ១ថ្ងៃ មានចំនួនប្រមាណ ៣០០នាក់ ក្នុងនោះ អ្នកវិជ្ជមានកូវីដ.១៩ មានចំនួន ២៧នាក់ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១។

លោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់ថា នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២១ ពលករខ្មែរត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកព្រំដែន ក្នុងភូមិសាស្រ្តខេត្តបន្ទាយមានជ័យ មានចំនួន ៣០០នាក់ ក្នុងមានស្ត្រី ១២៥នាក់ ហើយត្រូវបានរកឃើញអ្នកវិជ្ជមានកូវីដ.១៩ ចំនួន ២៧នាក់ (ស្ត្រី ១៣នាក់)។ លោកបានបញ្ជាក់ថា ខេត្តបន្ទាយមានជ័យ មានច្រកព្រំដែនចំនួន ៣កន្លែង ដែលក្រុមការងារ ទទួលពិនិត្យសុខភាព និងយកសំណាក់ពលករឆ្លងដែនពីប្រទេសថៃ រួមមាន៖ ១.ច្រកអូរបីជាន់ ស្រុកអូរជ្រៅ មានពលករ ចំនួន ១១០នាក់ ( ស្ត្រី ៤១នាក់ ) ក្នុងនោះ រកឃើញវិជ្ជមានកូវីដ.១៩ ចំនួន ១២នាក់ ( ស្ត្រី ៤នាក់ ) ២.ច្រកតំបន់ព្រំដែនបឹងត្រកួន ក្នុងស្រុកថ្មពួក មានពលករ ចំនួន ១៦៧នាក់ (ស្ត្រី ៧៦នាក់) វិជ្ជមានកូវីដ.១៩ មានចំនួន ១៥នាក់ ( ស្ត្រី ៩នាក់ ) និង៣.ច្រកបឹងបេង ក្នុងស្រុកម៉ាឡៃ មានពលករចំនួន ១៤នាក់ ( ស្ត្រី ៨នាក់)។ លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា ត្រូវបានក្រុមការងារ ទទួល ជូនអាហារសម្រន់ ហើយពិនិត្យសុខភាព និងយកសំណាក។ អ្នកវិជ្ជមានកូវីដ ត្រូវបានបញ្ជូនទៅព្យាបាល និងអ្នកអវិជ្ជមានកូវីដ.១៩ ត្រូវបានបញ្ជូនទៅដាក់មណ្ឌលធ្វើចត្តាឡីស័ក ដោយដឹកជញ្ជូនតាមរថយន្តក្រសួងការពារជាតិ៕ ប៊ុន ធឿន

## ស្ត្រីខ្មែរម្នាក់លួចឆ្លងដែនពីថៃចូលខ្មែរ ធ្លាក់បាក់ជើងស្តាំ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៤ សីហា ២០២១ដោយ deth leng

ស្ត្រីខ្មែរម្នាក់លួចឆ្លងដែនពីប្រទេសថៃ ចូលមកកម្ពុជា ធ្លាក់ពីលើរបងបាក់ជើងស្តាំ ត្រូវសមត្ថកិច្ច និងក្រុមគ្រូពេទ្យ ជួយសង្គ្រោះដឹកតាមរថយន្តទៅព្យាបាលនៅមន្ទីរពេទ្យ។ ហេតុការណ៍នេះ បានកើតឡើង កាលពីវេលាម៉ោង ៧ យប់ ថ្ងៃទី ២៣ ខែសីហា ស្ថិតនៅចំណុចផ្សារ បេន ចាវ៉ាន់ នៃក្រុមផ្សាររុងក្លឿ។

លោក វរសេនីយ៍ រស់ ពិសិដ្ឋ បេបញ្ជាការរង នគរបាល ការពារព្រំដែន និងជានាយប៉ុស្តិ៍ បានឱ្យដឹងថា កម្លាំង ប៉ុស្តិ៍ព្រំដែន បឹងសាគូ វរៈ ៩១១ ចំនួន ៤ នាក់ និង កម្លាំង ទាហាន ចំនួន ៥ នាក់ បានដើរឆ្លងអូរ ព្រំដែនទៅ ជួយប្រជាពលរដ្ឋខ្មែរម្នាក់ ធ្លាក់បាក់ ស្មងជើង ខាងស្តាំ នៅចំណុចផ្សារ បេន ចា វ៉ាន់ យកទៅព្យាបាលនៅមន្ទីរពេទ្យបង្អែក ក្រុងប៉ោយប៉ែត។ នាយប៉ុស្តិ៍ នគរបាលបានប្រាប់ឱ្យដឹងបន្តទៀតថាពលរដ្ឋខ្មែរម្នាក់នោះមាន ឈ្មោះ ស្រី សុឃីម ភេទស្រី អាយុ ៤០ ឆ្នាំ មានទីលំនៅ ភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ពោលគឺនៅម្ខាងអូរ និងរបងព្រំដែន ជិតកន្លែងគ្រោះថ្នាក់ម្នាក់ម្ខាង៕

## ពលករខ្មែរជាច្រើននាក់បន្តត្រឡប់ទៅកម្ពុជាវិញដោយសារខ្លាចឆ្លងជំងឺកូវីដ១៩ នៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន2021-08-23

ពលករខ្មែរធ្វើការនៅប្រទេសថៃជាច្រើននាក់ នៅតែបន្តធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ ដោយសារពួកគាត់ព្រួយបារម្ភខ្លាចឆ្លងជំងឺកូវីដ-១៩ គ្មានគ្រូពេទ្យព្យាបាលជំងឺ។ មន្ត្រីសង្គមស៊ីវិលយល់ថា រឿងនេះអាជ្ញាធរខ្មែរ គួរតែរៀបចំឱ្យពលករធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ និងដើម្បីឱ្យពួកគាត់ឆាប់បានត្រឡប់ទៅស្រុកកំណើតវិញ។ ពលករខ្មែរប្រមាណពី ២០០ ទៅ ៣០០ នាក់ ក្នុងមួយថ្ងៃបានប្រថុយប្រថានឆ្លងដែនត្រឡប់មកកម្ពុជាវិញតាមច្រកទ្វារព្រំដែនក្នុងខេត្តបន្ទាយមានជ័យជាបន្តបន្ទាប់។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែនលោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២២ ខែសីហាថា ពលករទាំងនោះភាគច្រើនជិះឡានឈ្នួលដោយខ្លួនឯង ចូលមកតាមច្រករបៀងព្រំដែនបឹងត្រកួនក្នុងស្រុកស្វាយចេក ច្រកទ្វារព្រំដែនអូរបីជាន់ស្រុកអូរជ្រៅ និងច្រករបៀងព្រំដែនក្នុងស្រុកម៉ាឡៃ។ លោកបន្ថែមថា នៅថ្ងៃទី២២ ខែសីហា មានពលករខ្មែរជាង ២០០ នាក់បានត្រឡប់មកពីប្រទេសថៃចូលមកកម្ពុជាវិញតាមច្រកទ្វារព្រំដែនខេត្តបន្ទាយមានជ័យ។ លោកបញ្ជាក់ថា ភ្លាមៗក្រោយពេលពលករមកដល់ព្រំដែនអាជ្ញាធរខ្មែរបានត្រួតពិនិត្យសុខភាពរបស់ពួកគាត់ជាមុនសិន ទើបបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័កនៅទីរួមខេត្តបន្ទាយមានជ័យ និងនៅស្រុកជាប់ព្រំដែនថៃ៖ «មកដល់ភ្លាមយើងយកសំណាកភ្លាម តែយកឡានទាហានបញ្ជូនទៅមណ្ឌលចត្តាឡីស័កភ្លាមអត់ទុកទេ។ ប្រចាំការ២៤ម៉ោង តើមកដល់យើងកកស្ទះតែយប់ទេ យើងអត់បានបញ្ជូនដោយសារតែយប់ពេក បើព្រលឹមឡើង យើងចាប់បញ្ជូនហ្មង។ គាត់មកប៉ះប៉ូលិសថៃ ថៃបញ្ជូនមកថៃមបណ្តោយអាហ្នឹងបើថៃចាប់បានគាត់បញ្ជូនមកផ្លូវត្រង់ តាមច្រកអន្តរជាតិប៉ោយប៉ែត គាត់ដូចមកខ្លួនឯងអីចឹង គាត់មកហើយថៃគេចាប់ហើយបញ្ជូនមកភ្លាមអត់ទុកទេ»។

ទោះជាយ៉ាងណា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc)ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា យល់ថា ស្ថានភាពបែបនេះ អាជ្ញាធរគួរតែរៀបចំកន្លែងធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវជូនដល់ពលករ ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ-១៩ផង និងដើម្បីសម្រួលឱ្យពួកគេឆាប់បានត្រឡប់ទៅស្រុកកំណើតវិញផង។ លោកប្រាប់ថា កន្លងមកមានពលករជាច្រើននាក់ហើយដែលបានជាប់គាំងនៅក្នុងមណ្ឌលចត្តាឡីស័កជាង ២ខែ

មិនទាន់បានចេញទៅផ្ទះវិញ។ លោកបញ្ជាក់ថា ការដែលអាជ្ញាធរធ្វើបែបនេះបានប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់ពលរដ្ឋ ហើយធ្វើឱ្យខាតបង់ថវិកាជាតិ ដែលបានផ្តល់ស្បៀងអាហារជូនដល់អ្នកធ្វើចត្តាឡីស័ក៖ «ព្រោះដោយសារតែកន្លងមកយើងឃើញកន្លែងចត្តាឡីស័កហ្នឹងបន្ទប់ទឹកក៏រួមគ្នា បន្ទប់អនាម័យក៏រួមគ្នា ដូច្នេះហើយមិនអាចជៀសផុតពីការឆ្លងការអីបានទេ។ អីចឹងអាជ្ញាធរគួរតែយកចិត្តទុកដាក់ ទាំងអស់ហ្នឹង។ ទី២បើសិនតែពួកគាត់ដល់ថ្ងៃដល់ពេលវេលាហើយ ត្រូវឱ្យពួកគាត់ចាកចេញ ដែលអាចជួយដល់ធ្វើឱ្យជីវភាពរបស់គាត់ហ្នឹងប្រសើរដែរ ព្រោះគាត់នៅពេលត្រឡប់ទៅផ្ទះវិញ គាត់ធ្វើអ្វីបន្ថែមទៀតបាន ដើម្បីចិញ្ចឹមគ្រួសារ»។

ជាមួយគ្នានេះ ពលករខ្មែរជាច្រើននាក់ផ្សេងទៀត កំពុងកាន់ឥវ៉ាន់សំពីងសំពោងនាំគ្នាអង្គុយរង់ចាំជិះឡានឈ្នួលនៅទីក្រុងបាងកក ដើម្បីធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ។ ពលករខ្មែរម្នាក់ធ្វើការសំណង់នៅកណ្តាលទីក្រុងបាងកកលោកស្រី ហ៊ុម រ៉ាន់ ថ្លែងថា លោកស្រីនិងពលករខ្មែរប្រមាណ ៧០ នាក់ ត្រៀមចេញពីទីក្រុងបាងកកនៅយប់ថ្ងៃទី២២ ខែសីហា ដើម្បីទៅឱ្យដល់ព្រំដែនកម្ពុជានៅពេលព្រឹក។ ស្ត្រីវ័យ ៤៥ ឆ្នាំរូបនេះបន្តថា ពួកលោកស្រីមិនអាចទ្រាំរស់នៅប្រទេសថៃបន្តទៅទៀតបាន ព្រោះគ្មានប្រាក់ទិញស្បៀងអាហារហូបចុក និងគ្មានប្រាក់ព្យាបាលជំងឺ៖ «ជាប់កូវីដទៅងាកឈប់វាអត់មានការងារធ្វើអីចឹងទៅក៏ទៅផ្ទះ។ កន្លែងខ្ញុំធ្វើការសម្រាកជាង១ខែហើយ ដល់ពេលជាប់កូវីដក៏គេឈប់តទៅទៀត អត់មានការងារធ្វើរាប់ខែអីចឹងនៅបានអីហូបហើយចេះតែនាំគ្នាទៅផ្ទះទៅ។ ដូចខ្ញុំអីវាអស់ប្រាក់អស់អីហើយ មិនដឹងមានអីរស់ទេ នៅអត់លុយចាយច្រើនខែពេកហើយសុខចិត្តទៅផ្ទះមួយរយៈសិន»។

ពលករខ្មែរជាច្រើននាក់ បាននាំគ្នាត្រឡប់ទៅកម្ពុជាវិញជាបន្តបន្ទាប់ចាប់តាំងពីថ្ងៃទី១៣ ខែសីហា ដែលអាជ្ញាធរខ្មែរបើកច្រកទ្វារព្រំដែនជាប់ជាមួយប្រទេសថៃ។ ការដែលពលករធ្វើមាតុភូមិនិវត្តន៍នេះ ដោយសារពួកគេមិនអាចទ្រាំរស់នៅទីនោះបន្តទៅទៀតបាន ព្រោះអត់ការងារធ្វើ និងព្រួយបារម្ភខ្លាចឆ្លងជំងឺកូវីដ១៩ ដែលកំពុងរាតត្បាតខ្លាំងនៅប្រទេសថៃ។ ហេតុមកទល់ពេលនេះមានពលករខ្មែររាប់ពាន់នាក់ហើយបានត្រឡប់ទៅប្រទេសវិញ។ ក្នុងនោះមានពលករមួយចំនួនត្រូវបានអាជ្ញាធរខ្មែរបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល ២១ ថ្ងៃ និងពលករដែលគ្រូពេទ្យរកឃើញជំងឺកូវីដ១៩ បញ្ជូនទៅមណ្ឌលព្យាបាលជំងឺកូវីដនៅខេត្តជាប់ព្រំដែនប្រទេសថៃ ហេតុដល់ជាសះស្បើយទើបអាជ្ញាធរអនុញ្ញាតឱ្យពួកគេត្រឡប់ទៅស្រុកកំណើតវិញ៕

**អគ្គកុងស៊ុលកម្ពុជានៅថៃ និង ស្ថានទូតខ្មែរនៅម៉ាឡេ ដោះស្រាយការលំបាកជូនពលរដ្ឋខ្មែរ**

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃនិងឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានចុះជួយសម្រួល ដល់ពលករខ្មែរឱ្យត្រលប់មកវិញ និង ចែកស្បៀងជូនពលករ ជួបការលំបាក។

តាមប្រភពព័ត៌មាន ពីក្រសួងការបរទេសកម្ពុជា ឱ្យដឹងថា នៅថ្ងៃទី ២៤ សីហា ឆ្នាំ២០២១នេះ ឆ្លើយតបតាមសំណើរ របស់ប្រជាពលរដ្ឋ ដែលមានបំណងវិលត្រឡប់មកកម្ពុជាវិញ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានអន្តរាគមន៍ ជាមួយអាជ្ញាធរថៃ និង ជួលរថយន្តដឹកជញ្ជូនពលរដ្ឋខ្មែរ ដែលបានប្រមូលផ្តុំគ្នាមកពីតំបន់ផ្សេងៗ ក្នុងប្រទេស សរុបចំនួន ២៦៤នាក់ ទៅកម្ពុជាវិញ តាមច្រកអូរបីជាន់ ប្រគល់ជូនអាជ្ញាធរកម្ពុជាទទួល និង ចាត់ការតាមនិតិវិធីសុខាភិបាល។

ជាមួយគ្នានេះ នៅព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី រួមជាមួយក្រុមការងារស្ថានទូត បាននាំយកអំណោយ ជាកញ្ចប់ស្បៀងអាហារ ដើម្បីចែកជូនប្រជាពលរដ្ឋ និង ពលករកម្ពុជាចំនួន ១២០ គ្រួសារ ស្ថិតនៅក្នុងតំបន់បិទខ្ទប់ (red zone) ក្នុងស្រុក Sungai Buloh រដ្ឋ Selangor ដែល

កំពុងជួបការខ្វះខាតខ្លាំង ដោយពួកគាត់គ្មានការងារធ្វើច្រើនខែមកហើយ ក្នុងអំឡុងពេលម៉ាឡេស៊ី បិទប្រទេសជាលើកទី៣ ចាប់ពីខែមិថុនា ឆ្នាំ២០២១មក៕

## បញ្ជូនមេខ្យល់ម្នាក់ទៅតុលាការ នាំពលករខ្មែរ៧នាក់ ឆ្លងដែនចូលប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatAugust 24, 2021

បាត់ដំបង ៖ នៅព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១នេះ សមត្ថកិច្ចជំនាញ បានបញ្ជូនខ្លួនបុរស ជាមេខ្យល់ម្នាក់ទៀតទៅសាលាដំបូងខេត្ត ដើម្បីចាត់ការតាមផ្លូវច្បាប់ ក្រោយឃាត់ខ្លួនបានក្នុងករណី លួចនាំពលករខ្មែរ ប្រុសស្រីចំនួន០៧នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់។

លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនលេខ៨១៧ បានឱ្យដឹងថា ការចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះធ្វើឡើង កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ម្សិលមិញ នៅត្រង់ចំណុចភូមិសាស្ត្រក្រុមទី៥ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ លោកបានបញ្ជាក់ថា ការចុះអនុវត្តច្បាប់នេះធ្វើឡើងរវាងកម្លាំងនគរបាលការពារព្រំដែនលេខ៨១៧ កម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច៥៣៣ នៅថ្ងៃកើតហេតុបានចុះឃាត់ខ្លួនមេខ្យល់ម្នាក់ រួមជាមួយពលករខ្មែរចំនួន០៧នាក់ផ្សេងទៀត ខណៈពេលដែលពួកគេបម្រុងលួចឆ្លងដែនចូលក្នុងទឹកដីថៃ ដោយខុសច្បាប់។ លោកបានបន្តថា មុខសញ្ញាមេខ្យល់ដែលបានឃាត់ខ្លួនខាងលើមាន ឈ្មោះ យឹម ធឿន ភេទប្រុស អាយុ៣០ឆ្នាំ មានទីលំនៅក្នុងក្រុមទី០១ ភូមិពោធិ៍ជ្រៃ ឃុំសេរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំណែកក្រុមពលករខ្មែរទាំង០៧នាក់ ក្នុងនោះមានស្រី០៤នាក់ រស់នៅទីតាំងផ្សេងៗពីគ្នា។ លោកបានបន្ថែមថា ចំពោះប្រជាពលរដ្ឋជាពលករអនុវត្តវិធានការអប់រំ ណែនាំ។ រីឯមេខ្យល់ត្រូវកម្លាំងជំនាញរបស់លោក ប្រគល់ឱ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់ការបន្តតាមផ្លូវច្បាប់៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរបានសម្រុកមកកម្ពុជាវិញ ខណៈដែលប្រទេសវៀតណាម កំពុងវិករាលដាលជំងឺកូវីដ ១៩

https://www.postkhmer.com/ ឡាយ សាមាន | Publication date 24 August 2021 | 14:13 ICT

**ស្វាយរៀង:** ពលករខ្មែរដែលធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ៥០ នាក់ បានសម្រុកមកកម្ពុជាវិញ ខណៈដែលប្រទេសវៀតណាម កំពុងជួបបញ្ហារីករាលដាលនៃជំងឺកូវីដ ១៩ នៅទីក្រុងហូជីមិញ និងបានបិទខ្ទប់តំបន់មួយចំនួន។

អភិបាលរងខេត្តស្វាយរៀង លោក រស់ ផារិទ្ធ ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២៤ សីហាថា តាមគម្រោងពលករខ្មែរ ចំនួន ៦៤ នាក់ បានស្នើសុំឯកសារពីអគ្គកុងស៊ុលខ្មែរ នៅវៀតណាម ត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែមានតែពលករ ៥០ នាក់ប៉ុណ្ណោះ ដែលចូលមកដល់កម្ពុជា ក្រៅពីនោះ នៅជាប់បម្រាមបិទខ្ទប់ ក្នុងប្រទេសវៀតណាម។ លោកថា៖ «គាត់មកតាមច្រកបាវិត កាលពីថ្ងៃទី ២២ ខែសីហា តែគាត់មកអត់បានទាំងអស់ទេ គឺមកបានតែ ៥០ នាក់។ ប៉ុន្មាននាក់ទៀត ចេញមកអត់ទាន់ នៅជាប់បម្រាមគោចរ នៅវៀតណាម ព្រោះក្រុងហូជីមីញគេបិទខ្ទប់»។ លោកបានឱ្យដឹងថា ក្នុងចំណោម ៥០ នាក់ ដែលមកដល់កម្ពុជា ក្នុងនោះពលករចំនួន៣នាក់ មានវិជ្ជមានកូវីដ ១៩ ដែលតម្រូវឱ្យបញ្ជូនទៅព្យាបាល ខណៈអ្នកអវិជ្ជមានបញ្ជូនទៅធ្វើចត្តាឡីស័ក។ បើតាមលោក រស់ ផារិទ្ធ ៖« ពលករខ្មែរទាំងនោះ អ្នកខ្លះកត់ឆ្នោត លក់ ឆ្នោត នៅវៀតណាម ហើយដោយសារក្រុងហូជីមីញ បិទខ្ទប់ កំពុងតែផ្ទុះការឆ្លងខ្លាំង អ៊ីចឹងគាត់មិនអាចនៅបានទេ ព្រោះអត់មានអីធ្វើ ចឹងគាត់បានសុំការអនុញ្ញាតពីអគ្គកុងស៊ុលកម្ពុជានៅហូជីមិញ ដើម្បីធ្វើលិខិតផ្លូវការបញ្ជូនគាត់មកវិញ»៕

## ឃាត់ខ្លួនពលករខ្មែរ ១៤នាក់ ដែលគ្រៀមឆ្លងដែនចូលមកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៤ សីហា ២០២១ដោយ Sorn Phanith

ពលករខ្មែរចំនួន ១៤ នាក់ ដែលក្នុងនោះមានទាំងក្មេងតូចៗចំនួន៥នាក់ផងនោះ ត្រូវបានកម្លាំងយោធាឈុតខ្មៅថៃ ធ្វើការឃាត់ខ្លួនជាបណ្តោះអាសន្ន ខណៈដែលពួកគេកំពុងនាំគ្នាដើរកាត់តាមចម្ការអំពៅបម្រុងឆ្លងដែនចូលមកកម្ពុជាវិញ។ ការឃាត់ខ្លួនរបស់កម្លាំងកងវរលេខ ១២០៥ នេះគឺបានធ្វើឡើងកាលពីរសៀលថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុចនៅទិសខាងជើងផ្សាររោងក្លឿ និងមានចម្ងាយពីអូរព្រំដែនប្រមាណ ៣០ ម៉ែត្រប៉ុណ្ណោះ ស្ថិតក្នុងស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ។ ពលករដែលត្រូវទាហានថៃឃាត់ខ្លួនមានចំនួន ១៤ នាក់ ក្នុងនោះមានមនុស្សប្រុស ៥ នាក់ ស្រី ៤ នាក់ ក្មេងប្រុស ៤ នាក់ និងក្មេងស្រី ១ នាក់ ដោយពួកគេកំពុងនាំគ្នាដើរកាត់តាមចម្ការអំពៅក្បែព្រំដែនដើម្បីរកច្រកចេញ ដោយខ្លះពកូនតូច ខ្លះទៀតដឹកដៃក្មេងៗផងដែរ។

ក្រោយពេលឃាត់ខ្លួនពួកគេបានសារភាពថា ពួកគេគឺជាកម្មករបោកគក់ស្បែកជើងជជុះ នៅក្នុងផ្សារឥណ្ឌូចិន ដែលជាផ្នែកមួយរបស់ផ្សាររោងក្លឿ ដោយពេលនេះក្រោយពីផ្សារត្រូវបានបិទខ្ទប់មួយរយៈរួចមក និងដោយសារពួកគេដេកចាយលុយអស់ផងនោះ ទើបសម្រេចចិត្តនាំគ្នាវិលត្រឡប់ទៅមាតុភូមិរបស់ខ្លួនវិញ ។ កម្លាំងយោធាថៃ ក្រោយពីបានពិនិត្យទៅលើកម្តៅម្នាក់ៗរួចមក ក៏បានប្រគល់ទៅឲ្យកម្លាំងតម្រួតការពារព្រំដែនលេខ៣៨ ដើម្បីសាកសួរបន្ត និងត្រៀមប្រគល់ទៅឲ្យភាគីកម្ពុជាវិញតាមច្រកអូរបីជាន់ ក្នុងការឃុំខ្លួនធ្វើចត្តាឡីស័កនៅលើទឹកដីកម្ពុជា៕ អត្ថបទ៖ សោ និយមរ័ត្ន

## ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១

### នគរបាលស្រុកកំរៀងកំពុងតាមចាប់មេខ្យល់ម្នាក់ បន្ទាប់ពីឃាត់ខ្លួនពលករកំពុងលួចឆ្លងដែន ៣៨ នាក់

https://m.postkhmer.com/ អោម ប៊ុនធឿន24 August 2021 | 10:02 ICT

**បាត់ដំបង:** កម្លាំងសមត្ថកិច្ចនគរបាលស្រុកកំរៀង កំពុងស្វែងរកចាប់ខ្លួនជនសង្ស័យជាមេខ្យល់ម្នាក់ បន្ទាប់ពីឃាត់ខ្លួនពលរដ្ឋ ៣៨ នាក់ ខណៈពួកគេប៉ុនប៉ងលួចឆ្លងដែនដោយខុសច្បាប់តាមមេខ្យល់កាលពីយប់ថ្ងៃទី ២១ សីហា នៅចំណុចស្ពានអូរចម្លង ស្ថិតក្នុងភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង។

លោក ង៉ែត វណ្ណា អធិការរងនគរបាលស្រុកកំរៀងថ្លែងនៅថ្ងៃទី ២៣ ខែសីហាថា សមត្ថកិច្ចនគរបាលស្រុកកំរៀងកំពុងស្រាវជ្រាវតាមនីតិវិធី ដើម្បីចាប់ខ្លួនជនសង្ស័យជាមេខ្យល់ម្នាក់ ដែលប្រមូលពលរដ្ឋបម្រុងនាំឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ។ ប៉ុន្តែត្រូវកម្លាំងសមត្ថកិច្ចនគរបាលការពារព្រំដែនគោកលេខ ៨១៩ ឃាត់ពលរដ្ឋបាន ៣៨ នាក់នៅយប់ថ្ងៃទី ២១ សីហា នៅចំណុចស្ពានអូរចម្លង ស្ថិតក្នុងភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង ហើយនៅពេលនោះ មេខ្យល់រត់គេចខ្លួនបាត់។ លោកបន្តថា នៅថ្ងៃទី ២២ សីហា នៅម៉ោងជាង ១១ ព្រឹកសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកកំរៀង បានទទួលពលរដ្ឋចំនួន ៣៨ នាក់ ស្រី ចំនួន ១៥ នាក់ អនីតិជនចំនួន ១៣ នាក់ ស្រីចំនួន ៥ នាក់ពីនគរបាលការពារព្រំដែនគោកលេខ ៨១៩ យកមកសួរចម្លើយ។

បើតាមលោក ង៉ែត វណ្ណា ពលរដ្ឋទាំងអស់នោះបានឆ្លើយថា ពួកគេមកពីខេត្តផ្សេងៗគ្នាមានខេត្តកំពង់ចាម និងត្បូងឃ្មុំជាដើម ដោយមេខ្យល់ប្រើទូរស័ព្ទទាក់ទង ដើម្បីនាំលួចឆ្លងដែនចេញទៅប្រទេសថៃយកថ្លៃឈ្នួលក្នុងម្នាក់ ៥ ៥០០ បាត ដោយជូនដល់កន្លែងធ្វើការទើបយកប្រាក់។ លោកថ្លែងថា៖ «ពេលពួកគាត់មកដល់ស្រុកកំរៀង មានម៉ូតូឌុបមកឌុបទៅដាក់នៅក្នុងចម្ការដំឡូងមី ក្នុងភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង មិនយកថ្លៃ។ ហេតុ

ដល់ម៉ោង ៨ យប់ មេខ្យល់បាននាំពួកគាត់ដើរឆ្លងអូរព្រំដែនកម្ពុជា- ថៃ បានប្រមាណ ៥០០ ម៉ែត្រត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ចំណែកមេខ្យល់ពាក់មួកពាក់ម៉ាស់ឃ្លុំមុខជិតពលរដ្ឋអត់ស្គាល់ទេ»។ លោក វណ្ណា បញ្ជាក់ថា ប្រជាពលរដ្ឋទាំងអស់ដែលសមត្ថកិច្ចបានឃាត់ខ្លួន ស្ថិតក្នុងចំណាត់ថ្នាក់ជាជនរងគ្រោះ ហេតុនេះក្រោយធ្វើការសាកសួរ សមត្ថកិច្ចបានធ្វើការអប់រំ និងធ្វើកិច្ចសន្យាឱ្យត្រឡប់ទៅលំនៅឋានរៀងៗខ្លួនវិញ៕

## កុមារចំណាកស្រុកកម្ពុជាប្រឈមនឹងហានិភ័យបន្ថែមទៀតនៅប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times August 25, 2021

ក្នុងចំណោមពលករចំណាកស្រុកចំនួន៩៧,០៦០នាក់ មកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលបានឆ្លងជំងឺកូវីដ-១៩ នៅចន្លោះខែមីនា ឆ្នាំមុន និងខែសីហាឆ្នាំនេះ មានចំនួន ៤,២០២ នាក់ អាយុក្រោម ១៨ ឆ្នាំ។ សកម្មជនសិទ្ធិកុមារបាននិយាយថា ពួកគេគឺជាផ្នែកមួយ នៃកូនៗរបស់ពលករចំណាកស្រុកជាង៣០០,០០០ នាក់ នៅក្នុងប្រទេសថៃ ដែលកំពុងត្រូវការការអប់រំ និងការថែទាំសុខភាពយ៉ាងខ្លាំងដោយជំរុញឱ្យរដ្ឋាភិបាលចូលរួមចំណែកយ៉ាងសកម្មជាងមុនក្នុងការការពារសិទ្ធិ និងសុខុមាលភាពជាមូលដ្ឋានរបស់ពួកគេ។

នៅក្នុងសិក្ខាសាលាដែលមានចំណងជើងថា"ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើកុមារនិងគ្រួសារជនចំណាកស្រុក" នៅថ្ងៃទី ១៩ ខែសីហា លោក Adisorn Kerdmonkol អ្នកសម្របសម្រួលជាមួយក្រុមការងារចំណាកស្រុក បាននិយាយថា កុមារចំណាកស្រុកជាង ៣០០,០០០ នាក់ប្រឈមនឹងហានិភ័យខ្ពស់ នៃការរំលោភសិទ្ធិ ចាប់តាំងពីជំងឺរាតត្បាតកូវីដ-១៩ បានចាប់ផ្តើមកាលពីឆ្នាំមុន។ លោកបាននិយាយថា អត្រាឆ្លងក្នុងចំណោមពលករចំណាកស្រុកត្រូវគេរំពឹងថា នឹងកើនឡើងបន្ថែមទៀតក្នុងការផ្ទុះនៅរលកទី ៣ នេះ ដោយកត់សម្គាល់ថា ការឆ្លងជាង ៨០,០០០ ករណីត្រូវបានរកឃើញក្នុងចំណោមពលករចំណាកស្រុកចាប់តាំងពីខែមេសាឆ្នាំនេះ។

លោកស្រី Linfah Upatcha មកពីមូលនិធិទស្សនៈពិភពលោកនៃប្រទេសថៃបាននិយាយថា ការសម្រេចចិត្តបិទលំនៅដ្ឋាននៅជុំវិញការដ្ឋានសំណង់ បានជះឥទ្ធិពលអាក្រក់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារចំណាកស្រុកដែលត្រូវនៅស្នាក់នៅខាងក្នុងនោះ។ លោកស្រីបានមានប្រសាសន៍ថា" ក្មេងៗជាច្រើនមានសម្ពាធធ្ងន់ធ្ងរដោយសារពួកគេមិនត្រូវបានអនុញ្ញាតឱ្យលេងជាមួយកុមារដទៃទៀតនៅខាងក្រៅកន្លែងស្នាក់នៅ។ ពួកគេត្រូវបានដាក់ឱ្យនៅក្នុងបន្ទប់ទំហំ ៣ គុណ ៣ ម៉ែត្រដាច់ឆ្ងាយពីអ្នកដទៃក្នុងកំឡុងពេលមានជំងឺរាតត្បាត" ។

Dararai Raksasiripong អ្នកសម្របសម្រួលក្លឹបយុវជនស្នាមញញឹម បាននិយាយថាកុមារចំណាកស្រុកជាច្រើនក៏រងគ្រោះដោយសារការរំលោភបំពានលើកុមារក្នុងកំឡុងពេលមានជំងឺរាតត្បាតផងដែរ។ លោកស្រី Dararai បាននិយាយថា "កុមារចំណាកស្រុកជាច្រើនកំពុងរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ដែលបណ្តាលមកពីភាពតានតឹងរបស់ឪពុកម្តាយក្នុងកំឡុងពេលមានជំងឺរាតត្បាត។ ពេលខ្លះពួកគេត្រូវបានទុកចោលមិនអើពើ វាយដំ ឬទុកនៅជាមួយសាច់ញាតិរំលោភបំពានដែលធ្វើឱ្យក្មេងៗខ្លះរត់ចេញ"។ ការរំលោភបំពានផ្សេងទៀត រួមមាន ការបង្ខំក្មេងស្រីឱ្យរៀបការជាមួយដៃគូចាស់ និងការឃាយីផ្លូវភេទ។ កុមារខ្លះត្រូវបានគេបង្ខំឱ្យធ្វើការនៅរោងចក្រដែលបង្កើនហានិភ័យឆ្លងវីរុសនេះបន្ថែមទៀតដល់កុមារ។ លោកស្រីបាននិយាយថា "រដ្ឋាភិបាលត្រូវតែស្តាប់អ្នកដែលកំពុងធ្វើការជាមួយពលករចំណាកស្រុក។ ពួកគេក៏ត្រូវពិនិត្យ និងកែសម្រួលច្បាប់ការពារកុមារដែលពាក់ព័ន្ធដើម្បីផ្តល់សន្តិសុខល្អប្រសើរជាងនេះដល់កុមារចំណាកស្រុក"។ bangkokpost

## បម្រុងដឹកនាំពលករ ២០ នាក់ចេញទៅថៃ ត្រូវសមត្ថកិច្ចចាប់បាន ៤ នាក់

https://www.kampucheathmey.com/ ថ្ងៃពុធ ២៥ សីហា ២០២១ដោយ Dy Bunnara

ខេត្តបាត់ដំបង៖ មេខ្យល់ចំនួន៤នាក់ ត្រូវបានកម្លាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួន ខណៈកំពុងដឹកនាំពលករចំនួន ២០នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់ចូលទៅក្នុងទឹកដីថៃ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២១ ដោយរកឃើញពលករចំនួន ២០នាក់ មានស្រី១០នាក់ ក្មេង៤នាក់។ កម្លាំងបានរកឃើញមេខ្យល់ជាអ្នករៀបចំការនាំចេញ ចំនួន៤នាក់មានឈ្មោះដូចខាងក្រោម៖

១-ឈ្មោះ សាន់ ហៃ ភេទប្រុស អាយុ៥១ឆ្នាំ មានទីលំនៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ជាអ្នកបើកតាក់ស៊ី ២-ឈ្មោះ នេត ម៉ាប់ ភេទប្រុស អាយុ៣១ឆ្នាំ មានទីលំនៅភូមិ ពពាលខែ ឃុំអូរតាគី ស្រុកថ្មគោល ៣-ឈ្មោះ សាយ តុងហេង ភេទប្រុស អាយុ២៣ឆ្នាំ មានទីលំនៅភូមិត្រពាំងព្រលិត ឃុំ សន្តិភាព ស្រុកសំពៅលូន និង ៤-ឈ្មោះ នៅ វ៉ាន់ ភេទប្រុស អាយុ ៥៤ឆ្នាំ មានទីលំនៅភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

សមត្ថកិច្ចបានដកហូតវត្ថុតាងរួមមាន ១-រថយន្ត ម៉ាក់កាមេរី ឆ្លាមពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ ភ្នំពេញ 2M 4356 ចំនួន០១គ្រឿង ២-រថយន្តម៉ាក នីសាន់ ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ 0462ភព២និង ៣-ទូរស័ព្ទដៃចំនួន៦គ្រឿង។ បច្ចុប្បន្នជនសង្ស័យដែលជាមេខ្យល់ និង វត្ថុតាងខាងលេី សមត្ថកិច្ចនគរបាលស្រុកបានកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ដើម្បីចាត់ការតាមនីតិវិធីច្បាប់៕ អត្ថបទ៖ សោ និយមវត្ថ

## ដឹកជញ្ជូនពលករខ្មែរត្រឡប់ពីថៃ មកដាក់នៅមណ្ឌល ចត្តាឡីស័ក មុនបញ្ជូនទៅខេត្តរបស់ពួកគេ

https://kohsantepheapdaily.com.kh/ ២៥ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ០៩:១២

បន្ទាយមានជ័យ ៖ រថយន្តដឹកពលកររបស់កងពលតូចដឹកជញ្ជូនលេខ៩០ បន្តដឹកជញ្ជូនពលករពីច្រកព្រំដែនមកកាន់មណ្ឌលចត្តាឡីស័ក និងដឹកជញ្ជូនពលករដែលបានធ្វើចត្តាឡីស័កគ្រប់១៤ថ្ងៃទៅកាន់ខេត្តគោលដៅ។ នេះបើយោងតាមកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ បានផ្សាយនាព្រឹកថ្ងៃទី២៥ ខែសីហានេះ ។ ដោយអនុវត្តតាមបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ដោយតម្រូវឱ្យកងទ័ពដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានត្រឡប់មកពីប្រទេសថៃតាមច្រកទ្វារ ដែលបានកំណត់យកមកដាក់នៅមណ្ឌលចត្តាឡីស័ក ដែលបានរៀបចំត្រៀមសម្រាប់ដាក់ពលករទាំងនោះនៅតាមបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-ថៃ មុននឹងដឹកជញ្ជូនបន្តទៅកាន់ខេត្ត ដែលជាគោលដៅ របស់ពួកគេ ។

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ នេះរថយន្តដឹកជញ្ជូនរបស់កងពលតូចដឹកជញ្ជូនលេខ៩០ បានបន្តដឹកជញ្ជូនប្រជាពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃមកដាក់ក្នុងមណ្ឌលចត្តាឡីស័កចំនួន៣៣៦នាក់ និងបានដឹកជញ្ជូនពលករដែលបានធ្វើចត្តាឡីស័ករួច១៤ថ្ងៃតាមការកំណត់ទៅកាន់ខេត្តគោលដៅនានាសរុបចំនួន២៧២នាក់។ ដើម្បីបង្ការជៀសវាងពលករទាំងនោះដើរ បែកខ្ញែកដែលនាំទៅចម្លងជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឱ្យកងទ័ព ចេញដឹកជញ្ជូនប្រជាពលករខ្មែរទាំងនោះយកមកធ្វើចត្តាឡីស័ក នៅតាមមណ្ឌលដែលបានរៀបចំរួចគ្រប់១៤ថ្ងៃ មុននឹងដឹកជញ្ជូនបន្តទៅកាន់ខេត្ត ដែលជាគោលដៅ

របស់ពួកគេ ។ ដោយក្នុងប្រតិបត្តិការដឹកពលករនេះដែរត្រូវបានប្រើប្រាស់ រថយន្តដឹកជញ្ជូនរបស់ កងពលតូចដឹកជញ្ជូនលេខ៩០កងទ័ពជើងគោក និងកងពលតូចដឹកជញ្ជូនលេខ៩៩ អគ្គបញ្ជាការ ។

សូមជម្រាបជូនផងដែរថា កងកម្លាំង និងរថយន្តរបស់កងពលតូចដឹកជញ្ជូនលេខ៩០ បានចុះដឹកជញ្ជូនពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃនេះ គឺនៅក្រោយពេលដែល មានការផ្ទុះ ឆ្លងមេរោគ កូវីដ-១៩ ជាសហគមន៍ នៅប្រទេសថៃ កាលពីចុងឆ្នាំ២០២០ កន្លងទៅ និងបានបន្តហូតមកដល់បច្ចុប្បន្ន ៕

## អ.ស.ប៖ សុខភាពផ្លូវចិត្តពលករចំណាកស្រុករងការគំរាមកំហែងក្នុងពេលវិបត្តិកូវីដ១៩

https://khmer.voanews.com/ 25 សីហា 2021 ហ៊ុល រស្មី

ភ្នំពេញ៖ ខណៈជំងឺកូវីដ១៩ បានបង្កការគំរាមកំហែងសុខភាពផ្លូវកាយរបស់មនុស្ស ជំងឺនេះក៏បង្កផលប៉ះពាល់យ៉ាងធំធេងមកលើសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋជាពិសេសពលករចំណាកស្រុកដែលវិលចូលមកប្រទេសកម្ពុជាវិញ។ នេះជាការកត់សម្គាល់របស់ការិយាល័យអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ការិយាល័យអង្គការសហប្រជាជាតិ បានយោងតាមការប៉ាន់ប្រមាណរបស់ធនាគារពិភពលោកកាលពីខែឧសភាថា ការរាតត្បាតជាសាកលនៃជំងឺកូវីដ១៩ បានធ្វើឲ្យ«ការងារប្រមាណ១,៧លាននៅកម្ពុជា» ត្រូវប្រឈមនឹងហានិភ័យ ដែលបង្កជាបញ្ហាសង្គមសេដ្ឋកិច្ច និងបញ្ហាផ្លូវចិត្តខ្លាំងក្លាមកលើពលរដ្ឋកម្ពុជា។ កម្មករនិយោជិតនៅក្នុងឧស្សាហកម្មជាច្រើនត្រូវបានកាត់ប្រាក់ខែ ឬមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ត្រូវទទួលការគំរាមកំហែង។ សិស្សនិស្សិត និងគ្រួសារត្រូវសម្របខ្លួននៅពេលដែលសាលារៀនបិទទ្វារ ហើយគ្រប់គ្នាត្រូវទប់ទល់ជាមួយនឹងបញ្ហាជាច្រើនដូចជា ការរស់នៅដាច់ដោយឡែកពីគ្នា និងភាពមិនប្រាកដប្រជាដែលចេះតែបន្តកើនឡើង។ នេះបើតាមឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់ អ.ស.ប នៅកម្ពុជាដែលបានចេញផ្សាយក្នុងសប្តាហ៍នេះ។

ឯកសារព័ត៌មានរបស់អង្គការសហប្រជាជាតិដែលចេញផ្សាយជាសាធារណៈនៅថ្ងៃទី២៣ ខែសីហា បានគូសបញ្ជាក់ក្នុងន័យដើមថា៖ «បញ្ហាប្រឈមទាំងនេះធ្វើឲ្យមនុស្សមានអារម្មណ៍អន្ទះអន្ទែង និងធ្លាក់ទឹកចិត្ត។ ពលករទេសន្តរប្រវេសន៍ជាក្រុមដែលទទួលរងផលប៉ះពាល់ពិសេស ត្បិតពួកគេត្រូវខិតខំស្វែងរកប្រភពចំណូល ក្រោយពេលធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ដែលបង្កជាបញ្ហាស្ត្រេស(តប់ប្រម៉ល់) ការធ្លាក់ទឹកចិត្ត និងបញ្ហាសុខភាពផ្លូវចិត្តដទៃទៀតយ៉ាងច្រើន»។ អង្គការសហប្រជាជាតិបន្ថែមថា គិតហូតមកដល់ពេលនេះ មានពលករទេសន្តរប្រវេសន៍ ឬពលករចំណាកស្រុក កម្ពុជាជាង២២៥,០០០នាក់ ក្នុងនោះមានស្ត្រី៥៦%ហើយ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសជិតខាង ចាប់តាំងពីពេលដែលការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ចាប់ផ្តើមកើតឡើង។ ដូច្នេះតម្រូវការសេវាសុខភាពផ្លូវចិត្តក៏មានការកើនឡើងផងដែរ។

លោកស្រីវេជ្ជបណ្ឌិត លី អាយឡាន(Li Ailan) តំណាងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា ត្រូវគេដកស្រង់សម្តីក្នុងឯកសារព័ត៌មានរបស់អ.ស.ប ក្នុងន័យដើមថា៖ «សុខភាពពុំមាននោះឡើយ ប្រសិនបើពុំមានសុខភាពផ្លូវចិត្ត។ ជំងឺកូវីដ១៩ បានបង្កការគំរាមកំហែងដល់សុខភាពផ្លូវចិត្តនៅកម្ពុជា ជាពិសេសពលរដ្ឋងាយរងហានិភ័យ ដូចជាពលករទេសន្តរប្រវេសន៍ជាដើម។ អង្គការសុខភាពពិភពលោក និងអង្គការសហប្រជាជាតិកំពុងខិតខំធានាយ៉ាងណាឲ្យក្រុមងាយរងគ្រោះទាំងនេះ បានទទួលសេវាគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គម»។

អ្នកការពារសិទ្ធិមនុស្សមួយចំនួនស្នើឲ្យរដ្ឋាភិបាលមានវិធានការឆ្លើយតបបន្ទាន់ទៅនឹងបញ្ហានេះ ដើម្បីបញ្ចៀសអំពើហិង្សាផ្សេងៗក្នុងគ្រួសារ និងសង្គម។ អ្នកសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តបន្ទាយមានជ័យដែលជាប់ព្រំដែនថៃ លោក ស៊ុំ ចន្ទគា សង្កេតឃើញស្ថានភាពកាន់តែយ៉ាប់យឺនឡើងរបស់ពលករចំណាកស្រុក ដោយលោកជំរុញឲ្យរដ្ឋាភិបាលត្រូវមានវិធានការឆ្លើយតបជាក់លាក់ និងឲ្យចំក្រុមដែលកំពុង

មានការលំបាកខ្លាំង ពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងសុខភាពផ្លូវចិត្ត។ លោកពន្យល់យ៉ាងដូច្នេះ៖ «នៅក្នុងភូមិករណ៍របស់គាត់ ពីដើមគាត់អាងទៅថៃទៅអីទៅដើម្បីមានថវិកាផ្ញើឲ្យបងប្អូន សម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ ទីពីរទាក់ទងរឿងបំណុល។ បំណុលហ្នឹងនៅពេលដែលពួកគាត់ទៅធ្វើការនៅថៃនៅអី គាត់មានលុយសម្រាប់ដោះស្រាយបំណុលហ្នឹងប្រចាំជារៀងរាល់ខែ។ ប៉ុន្តែឥឡូវហ្នឹង ពួកគាត់ត្រឡប់មកសហគមន៍គាត់វិញ ហើយគាត់ប្រឈមមុខទាក់ទងកត្តាជីវភាព ដោយសារអត់មានការងារធ្វើ។ អត់មានអ្វីដែលជួយគាត់»។

លោកបន្ថែមថា រដ្ឋគួរមានវិធានការបន្ថែម ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់របស់ពលករចំណាកស្រុកទាំងឡាយណាដែលកំពុងស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើនិងអាចបាត់បង់ដីធ្លីផ្ទះសម្បែងទៅម្ចាស់បំណុល។ «ហើយតួនាទីរបស់ភ្នាក់ងាររដ្ឋ យើងឃើញដើរផ្សព្វផ្សាយឲ្យពួកគាត់ហ្នឹងបីកុំ បីការពារអីចឹងទៅ។ ប៉ុន្តែអ្វីដែល បីដោះស្រាយក្រពះ ឬក៏ប្អូនដោះស្រាយក្រពះហ្នឹងវាអត់មាន។ ទីពីរទាក់ទងរឿងបំណុល។ បំណុលហ្នឹងបើសិនជាមិនមានការដោះស្រាយលក្ខណៈណាមួយ ជួយអំពីភ្នាក់ងាររបស់រដ្ឋ។ ជួយបន្ធូរបន្ថយ ឬយ៉ាងណាទេ ខាងធនាគារហ្នឹងគឺគេរាប់ថ្ងៃ រាប់ខែ រាប់លេខយកតែម្តង។ អីចឹងហើយ ពួកគាត់នឹងប្រឈមមុខទៅលើការបាត់បង់ ទៅលើដីធ្លីផ្ទះសម្បែង អចលនទ្រព្យរបស់គាត់បាទ»។

ការិយាល័យអង្គការសហប្រជាជាតិ លើកឡើងក្នុងឯកសារព័ត៌មានរបស់ខ្លួន ដែលមានកម្រាស់៤ទំព័រថា សុខភាពផ្លូវចិត្ត និងការគាំទ្រចិត្តសង្គម ក៏ជាផ្នែកមួយដ៏សំខាន់នៃការឆ្លើយតបចំពោះជំងឺកូវីដ១៩ ហើយការបន្តវិនិយោគលើសេវាគាំទ្រទាំងនេះ នឹងរួមចំណែកធ្វើឲយពលរដ្ឋកម្ពុជាទាំងអស់កាន់តែមានសុវត្ថិភាពនិងសុខភាពមាំមួននាពេលអនាគត។

លោក មឿន តុលា នាយកប្រតិបត្តិនៃអង្គការសង់ត្រាល់ដែលធ្វើការលើពលករចំណាកស្រុក យល់ស្របនឹងការវាយតម្លៃរបស់ការិយាល័យអង្គការសហប្រជាជាតិអំពីស្ថានភាពផ្លូវចិត្តរបស់ពលករចំណាកស្រុក ដែលបានវិលត្រឡប់មកពីប្រទេសក្បែរខាង ជាពិសេសប្រទេសថៃហើយ តែគ្មានការងារ និងមុខរបរចិញ្ចឹមជីវិត។ លោកប្រាប់វីអូអេបន្ថែមនៅថ្ងៃអង្គារនេះថា ការផ្តល់សេវាប្រឹក្សាយោបល់ ដែលអាចធ្វើឡើងនៅមណ្ឌលចត្តាឡីស័កជាកិច្ចការសំខាន់មួយ ដែលអាជ្ញាធរមូលដ្ឋានគួរសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពង្រឹងស្មារតីពលករចំណាកស្រុកដែលបានត្រឡប់មកវិញ ហើយកំពុងប្រឈមនឹងការជាប់បំណុលផងនោះ។ «រឿងប្រឹក្សាយោបល់ផ្លូវចិត្តរបស់គាត់ វាជារឿងចាំបាច់មួយដែលគួរធ្វើ នៅពេលដែលគាត់មកដល់ហ្នឹង ដើម្បីប៉ះប៉ូវផ្លូវចិត្តគាត់ កុំឲ្យភ័យ កុំឲ្យខ្លាច កុំឲ្យបារម្ភអី។ ខ្ញុំគិតថា ក្រៅពីការព្យាបាល ទៅលើជំងឺគាត់បើសិនជាគាត់ មានវិជ្ជមានអី។ល។និង។ល។ហ្នឹង ក៏ត្រូវតែមានព្យាបាលផ្លូវចិត្តមួយដែរ អាហ្នឹងចំណុចទីមួយ»។

បើតាមលោក មឿន តុលា ការផ្តល់ស្បៀងសង្គ្រោះបន្ទាន់ ឬក៏ការផ្អាកជាបណ្តោះអាសន្ននៃការសងបំណុល និងការផ្តួចផ្តើមឲ្យពលករចំណាកស្រុកទាំងអស់នោះមានមុខរបរក្នុងសហគមន៍ ដែលពួកគាត់រស់នៅអាចជាផ្នែកមួយនៃការបន្ធូរភាពតានតឹងខាងផ្លូវចិត្ត និងសេដ្ឋកិច្ចគ្រួសារផងដែរ។ «រឿងមួយទៀត ដែលត្រូវតែធ្វើដែរ គឺរឿងរៀបចំឲ្យគាត់មានមុខរបរនៅក្នុងសហគមន៍របស់គាត់ ដែលគាត់អាចមានចំណូលចាប់ផ្តើមពីល្មមរហូតដល់ចំណូលដែលអាចគាត់រស់នៅបាន។ អាហ្នឹងគឺជាចំណុចមួយដែលអាជ្ញាធរត្រូវពិចារណាដែរ។ ខ្ញុំឃើញរឿងកសិកម្មនេះ គឺជារឿងត្រឹមត្រូវដែលឲ្យគាត់សម្លឹងមើលរឿងកសិកម្ម ប៉ុន្តែយើងគួរតែជួយឲ្យគាត់មានលទ្ធភាព មានដីគ្រប់គ្រាន់មានគ្រាប់ពូជមានអីជាកសិករ កុំឲ្យគាត់ទៅជាកម្មករ ឬក៏ពលករគេនៅក្នុងកសិដ្ឋាននៃក្រុមហ៊ុនឯកជន»។ ក្នុងការឆ្លើយតបទៅនឹងស្ថានភាពលំបាកលំបិនរបស់ពលរដ្ឋដែលរងផលប៉ះពាល់ទាំងខាងសង្គម និងសេដ្ឋកិច្ចចំពេលមានការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩នោះ រដ្ឋាភិបាលបានរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីជួយដល់ពលរដ្ឋក្រីក្រ

និងងាយរងគ្រោះឲ្យមានលទ្ធភាពរស់បានក្នុងស្ថានភាព នៃការឆ្លងជំងឺរាតត្បាតសាកលដែលមិនទាន់ថមថយខ្លាំងនៅឡើយនេះ។

ប៉ុន្តែការឧបត្ថម្ភសាច់ប្រាក់ទាំងនេះ ហាក់ដូចជាមិនទាន់បានទៅដល់ដៃពលករចំណាកស្រុកដែលត្រឡប់មកវិញភ្លាមៗនោះទេ ដោយសារពួកគាត់មិនមានបណ្ណក្រីក្រ ឬបណ្ណសមធម៌។ នេះបើតាមការសង្កេតរបស់លោក ស៊ុំ ចន្ទគា អ្នកសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុកប្រចាំខេត្តបន្ទាយមានជ័យ។ «យើងឃើញពលករហ្នឹង នៅធ្វើចត្តាឡីស័កបានត្រឹមតែបាយទឹកអីចឹងទៅ។ ចំណែកទាក់ទងទៅលើកញ្ចប់សាច់ប្រាក់ណាមួយដែលជួយដល់ផ្តល់ហើយនិងជួយដល់គ្រួសារគាត់អត់មាន។ ហើយនៅក្នុងកន្លែងចត្តាឡីស័ក ឬក៏កន្លែងរាំងខ្ទប់យើងឃើញមានការចែកអំណោយរប៉េះរប៉ោះអីច្រើនដែរជូនដល់ពួកគាត់ ដូចជាអង្ករ ដូចជាមី ដូចជាត្រីអីចឹងទៅគឺរយៈពេលខ្លីៗអីចឹងទៅណា!...ចំណែកកញ្ចប់សាច់ប្រាក់ កញ្ចប់ថវិកាហ្នឹង ឃើញទាក់ទងទៅលើដែលចាស់ជរា ដែលគេហៅថា មានបណ្ណក្រីក្រអីចឹង ឃើញមានការបើកលុយបើកកាក់ជាបន្តបន្ទាប់ដែរ»។

អ្នកស្រី ជាល កេសី វ័យ២៥ឆ្នាំ បានទៅធ្វើការជាអ្នកលើកម្ហូបអាហារនៅខេត្តឈុនបូរី ប្រទេសថៃអស់រយៈពេលមួយឆ្នាំ និងបានត្រឡប់មកវិញ ចំពេលមានការផ្ទុះនៃការឆ្លងរាតត្បាតជំងឺកូវីដ១៩នៅប្រទេសថៃកាលពីឆ្នាំ២០២០។ ត្រឡប់មកស្រុកកំណើតវិញ អ្នកស្រីនិយាយថា ការងារដាក់លាក់ក៏គ្មានធ្វើ និងត្រូវសងបំណុលខ្លះដែលគាត់ជំពាក់គេផងដែរ។ ការណ៍នេះ ធ្វើឲ្យអ្នកស្រីមានការធុញថប់ ដែលតម្រូវឲ្យមានការពិគ្រោះយោបល់។ អ្នកស្រីចង់ឃើញការរៀបចំឲ្យមានសេវាប្រឹក្សាយោបល់ ដើម្បីស្រាយកង្វល់ពាក់ព័ន្ធស្ថានភាពរស់នៅប្រចាំថ្ងៃ និងការសងប្រាក់ទៅម្ចាស់បំណុលវិញ។ «យើងតានតឹងមិនដឹងថា រត់ទៅរកខាងណា ចងការលុយគេ ក៏គេ ចងអង្គការយើងអត់មានដីដាក់ឲ្យគេ ហើយចង់ទៅចងលុយ ខាងឯកជនក៏គេអត់ទុកចិត្តយើងចឹង»។ សព្វថ្ងៃ អ្នកស្រីកំពុងធ្វើជាកម្មករកាត់ស្មៅ និងកាច់ពោត ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។

អ្នកស្រី យឹម សុធារី អ្នកជំនាញចិត្តសាស្ត្រឯករាជ្យមួយរូប យល់ថាការពង្រីកបណ្តាញប្រឹក្សាផ្លូវចិត្ត ទាំងតាមបណ្តាញទំនាក់ទំនងសង្គម ឬខ្សែទូរស័ព្ទ អាចបើកផ្លូវឲ្យពលករចំណាកស្រុកទាំងនោះទទួលបានការប្រឹក្សាអំពីបញ្ហាប្រឈមផ្សេងៗដែលពួកគាត់ជួបប្រទះ ក្នុងនោះមានការបាត់បង់ប្រាក់ចំណូលជាដើម។ អ្នកស្រីបន្ថែមថា មន្ត្រីនិងអាជ្ញាធរពាក់ព័ន្ធដែលទទួលយកពលករចំណាកស្រុក ក៏គួរតែទទួលបានការបណ្តុះបណ្តាលជំនាញទាក់ទិនការប្រឹក្សាយោបល់នេះផងដែរ។ «អាចមួយទៀត ជម្រើសផ្តល់ អ្វីដែលមានស្រាប់ហ្នឹង សម្រាប់ខ្ញុំ ខ្ញុំយល់ថា train [បណ្តុះបណ្តាល] បង្រៀន ឬក៏បង្ហាញអ្នកដែលជួយគាំទ្រគាត់ តាំងពីការទទួលគាត់ធ្វើតេស្ត ការពីអីអស់ហ្នឹងឲ្យមានអត្តចរិត welcome [ស្វាគមន៍] និងទន់ភ្លន់ដាក់គាត់បន្តិច ក៏ជាចំណុចមួយរួមចំណែក ដើម្បីឲ្យគាត់ កុំឲ្យតានតឹងពេកដែរ គ្រាន់តែសាមញ្ញៗតូចៗទេ»។

លោក ឈួរ សុបញ្ញា ប្រធាននាយកដ្ឋានសុខុមាលភាពសង្គមនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសង្គមកិច្ចអតីត យុទ្ធជន និងយុវនីតិសម្បទា ប្រាប់វីអូអេនៅថ្ងៃអង្គារនេះថារដ្ឋាភិបាលបានដាក់ឲ្យដំណើរការរួចទៅហើយ សេវាប្រឹក្សាយោបល់ នៅតាមខ្សែបន្ទាត់ព្រំដែនដែលពលករកម្ពុជា ត្រឡប់មកពីប្រទេសជិតខាង។ «គឺយើងបានធ្វើការផ្សព្វផ្សាយសម្រាប់ បើករណីដែលគាត់មាននូវការវិបត្តិផ្លូវចិត្ត ឬករណីដែលគាត់មានការចង់សួរចម្ងល់ពាក់ព័ន្ធបញ្ហាដោយសារកត្តាជីវភាព កត្តាអី តើគាត់ទៅណា? ហើយទៅទំនាក់ទំនងទៅលេខណា?បាទទីមួយ។ ទីពីរយើងក៏បានធ្វើការអប់រំ ដោយផ្ទាល់ផងដែរនៅតាមជួរបន្ទាត់ព្រំដែនហ្នឹងឯង»។ លោកបន្ថែមថា៖ «បានន័យបង្ហាញអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ថា ពេលគាត់មកដល់មិនមែនរដ្ឋាភិបាលបោះបង់គាត់ទេ គឺរដ្ឋាភិបាលគឺថា ក្រៅពីការផ្តល់កន្លែងព្យាបាល កន្លែងចត្តាឡីស័កហើយគឺថា រដ្ឋាភិបាលផ្តល់នូវការប្រឹក្សាយោបល់ពីគាត់ ដើម្បីរក្សានូវលំនឹងនៃហៅថាសុខភាពផ្លូវចិត្តផ្នែកជីវិតរបស់គាត់ផងដែរ»។ បើតាមលោកឈួរ សុបញ្ញា ពលករចំណាក

ស្រុក ក៏កំពុងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងកម្មវិធីស្ត្រីមានផ្ទៃពោះ សម្រាប់គាំទ្រពលរដ្ឋក្រីក្រ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩ផងដែរ។ នេះមានមានន័យថា ពលករចំណាកស្រុក អាចទៅស្នើសុំបណ្ណសមធម៌នៅឃុំសង្កាត់ ដើម្បីទទួលបានការវាយតម្លៃពីស្ថានភាពជីវភាព រួចទទួលបាននូវសាច់ប្រាក់ដែលផ្តល់ជូនដោយរដ្ឋាភិបាល។ គិតត្រឹមចុងខែសីហានេះ រដ្ឋាភិបាលបានចំណាយប្រាក់ជាង៤០០លានដុល្លារសហរដ្ឋអាមេរិកដើម្បីផ្តល់ ជូនពលរដ្ឋដែលមានស្ថានភាពរស់នៅក្រលំបាក។ការផ្តល់សាច់ប្រាក់នេះ គឺត្រូវបានធ្វើឡើងចំនួន១៤លើករួចមកហើយ ដែលមានប្រជាពលរដ្ឋចំនួនជាង៧០ម៉ឺនគ្រួសារ បានទទួលអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ។ នេះបើតាមការបញ្ជាក់បន្ថែមរបស់លោកឈួរ សុបញ្ញា។

បើតាមទិន្នន័យរបស់ការិយាល័យអង្គការសហប្រជាជាតិប្រចាំកម្ពុជា ចាប់តាំងពីឆ្នាំ២០២០មក កុមារប្រមាណ១១ម៉ឺននាក់ និងឳពុកម្តាយ អ្នកផ្តល់ការថែទាំសរុបប្រមាណ៧៦០០០នាក់ បានទទួលសារអប់រំអំពីសុខភាពផ្លូវចិត្ត និងការគាំទ្រចិត្តសង្គម និងសារអប់រំការពារជំងឺកូវីដ១៩ និងដំបូន្មានអំពីការចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជមាន។ លើសពីនេះ កុមារចំនួន៤,៨០៥នាក់ និងឳពុកម្តាយ អ្នកផ្តល់ការថែទាំចំនួន៥,៣៩២នាក់ បានទទួលការអប់រំ តាមរយៈវគ្គអប់រំឳពុកម្តាយនៅតាមសហគមន៍គោលដៅ មិត្តអប់រំមិត្ត និងការចុះសួរសុខទុក្ខតាមផ្ទះ។ ក្រៅពីការតាមដាននៃស្ថានភាពផ្លូវចិត្តរបស់ពលករចំណាកស្រុក អង្គការសហប្រជាជាតិក៏ធ្លាប់បានលើកទឹកចិត្តឲ្យអាជ្ញាធរកម្ពុជាផ្តល់ការការពារនិងបើកផ្លូវឲ្យអ្នកចំណាកស្រុកដែលត្រឡប់មកវិញមានលទ្ធភាពយកឈ្នះលើផលប៉ះពាល់រយៈពេលវែងនៃជំងឺកូវីដ១៩។ អង្គការសហប្រជាជាតិបានទទូចដល់អាជ្ញាធរធានាថាប័ណ្ណក្រីក្រត្រូវបានផ្តល់ជូនអ្នកចំណាកស្រុកដែលត្រឡប់មកវិញរូបណាដែលមានលក្ខណៈសម្បត្តិអាចទទួលបាន និងជំនួយបន្ថែមទៀតត្រូវបានផ្តល់ដើម្បីមានលទ្ធភាពទទួលបានការងារ ឬក៏ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជំរុញឲ្យពួកគេអាចសម្របខ្លួនបាននៅក្នុងសហគមន៍៕

## ពលករខ្មែរបន្តសម្រុកវិលមកកម្ពុជា ខណៈប្រទេសជិតខាងឆ្លងកូវីដខ្លាំង

https://www.postkhmer.com/ ឡាយ សាមាន | Publication date 25 August 2021 | 09:43 ICT

**ឧត្តរមានជ័យៈ** ពលករខ្មែរដែលធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសជិតខាងកម្ពុជា រួមមាននៅវៀតណាម និងថៃ នៅតែបន្តសម្រុកវិលមកកម្ពុជាវិញ ខណៈប្រទេសជិតខាងទាំង២នេះ កំពុងជួបបញ្ហារីករាលដាលនៃជំងឺកូវីដ ១៩ ខ្លាំងឡើង និងបានបិទខ្ទប់តំបន់មួយចំនួន ដែលធ្វើឱ្យប៉ះពាល់ដល់ពលករដែលកំពុងបម្រើការងារនៅទីនោះ។ កាលពីថ្ងៃទី ២២ ខែសីហា មានពលករខ្មែរចំនួន ៥០ នាក់ បានសម្រុកចេញពីប្រទេសវៀតណាម មកកម្ពុជាវិញ ខណៈប្រទេសវៀតណាម បានដាក់ចេញវិធានការនានា ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ ១៩ និងបិទខ្ទប់នៅទីក្រុងហូជីមិញ។

អភិបាលរងខេត្តស្វាយរៀង លោក រស់ ផារិទ្ធ ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២៤ ខែសីហាថា តាមគម្រោងពលករខ្មែរចំនួន ៦៤ នាក់ បានស្នើសុំឯកសារពីអគ្គកុងស៊ុលខ្មែរនៅវៀតណាមត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែមានតែ ៥០ នាក់ប៉ុណ្ណោះ ដែលបានមកដល់កម្ពុជាហើយក្រៅពីនោះនៅជាប់បម្រាមបិទខ្ទប់នៅវៀតណាម។ លោកថា៖ «គាត់មកតាមច្រកបាវិតកាលពីថ្ងៃទី ២២ ខែសីហា តែគាត់មកអត់បានទាំងអស់ទេ គឺមកបានតែ ៥០ នាក់ ប៉ុន្មាននាក់ទៀតចេញមកអត់ទាន់ នៅជាប់បម្រាមគោចរនៅវៀតណាម ព្រោះក្រុងហូជីមិញគេបិទខ្ទប់»។ លោកឱ្យដឹងថា ក្នុងចំណោមពលករ ៥០ នាក់ ដែលមកដល់កម្ពុជា គឺមាន ៣ នាក់មានវិជ្ជមានកូវីដ ១៩ ហើយត្រូវបានបញ្ជូនទៅព្យាបាល ខណៈអ្នកអវិជ្ជមានតម្រូវឱ្យធ្វើចត្តាឡីស័ក ២១ ថ្ងៃ។ លោក រស់ ផារិទ្ធ បានបញ្ជាក់ថា៖ «ពលករខ្មែរទាំងនោះ អ្នកខ្លះកត់ឆ្នោត លក់ឆ្នោតនៅវៀតណាម ហើយដោយសារក្រុងហូជីមិញ បិទខ្ទប់ កំពុងតែផ្ទុះការ

ឆ្លងខ្លាំង អ៊ីចឹងគាត់មិនអាចនៅបានទេ ព្រោះអត់មានអីធ្វើ អ៊ីចឹងគាត់បានសុំការអនុញ្ញាតពីអគ្គកុងស៊ុលកម្ពុជានៅហូជីមិញ ដើម្បីធ្វើលិខិតផ្លូវការបញ្ជូនគាត់មកវិញ»។

ដោយឡែកនៅព្រំដែនថៃវិញ គិតចាប់ពីថ្ងៃបើកច្រកព្រំដែនឡើងវិញពីថ្ងៃទី ១៣ ខែសីហាដល់ថ្ងៃទី ២៣ ខែសីហា គឺមានពលករខ្មែរត្រឡប់ពីថៃវិញចំនួន ៣ ៧៨៩ នាក់ ក្នុងនោះវិជ្ជមានកូវីដ ១៩ ចំនួន ៤៧៤ នាក់។ នេះបើយោងតាមរបាយការណ៍របស់ខេត្តឧត្តរមានជ័យ។ លោក ផល លឹម ប្រធានមន្ទីរព័ត៌មានខេត្តឧត្តរមានជ័យបានឱ្យដឹងថា បើគិតជាមធ្យមមានពលករខ្មែរដែលបន្តវិលត្រឡប់មកកម្ពុជាវិញក្នុង ១ ថ្ងៃៗចន្លោះពីជាង ១០០ ទៅជាង ២០០ នាក់។ លោកថា គ្រាន់តែ ១ ថ្ងៃ គឺនៅថ្ងៃទី ២៣ ខែសីហា មានពលករវិលចូលស្រុកចំនួន ២៣៨ នាក់ ក្នុងនោះវិជ្ជមានកូវីដចំនួន ២០ នាក់។ លោកបានថ្លែងថា៖ «ការឆ្លងក្នុងសហគមន៍តិចតួចទេ ប៉ុន្តែភាគច្រើនពលករមកពីខាងថៃ ដោយសារមកច្រើនពេក យើងសង់បន្ថែមមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និយាយរួមករណីចូលច្រើនជាងបញ្ជូនចេញមានន័យថា ពលករពីថៃមកច្រើន ហើយអ្នកបញ្ចប់ធ្វើចត្តាឡីស័ក ឬអ្នកព្យាបាលជាសះស្បើយក្នុងសហគមន៍វាតិចតួច ដែលត្រូវបញ្ជូនចេញទៅតាមខេត្ត ឬទីតាំងស្រុកកំណើត»។

ចំណែកអ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យលោក សេក សុខុម បានឱ្យដឹងដែរថា ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃបើកច្រកព្រំដែនវិញ ពលករខ្មែរជាង៥ពាន់នាក់បានត្រឡប់ចូលស្រុកវិញ ក្នុងនោះមានអ្នកឆ្លងកូវីដជាច្រើននាក់។ លោកថា៖ «ចំនួនពលករចូលមកមិនថមថយទេ ចាប់ពីថ្ងៃបើកច្រកព្រំដែនវិញ (ថ្ងៃទី ១៣ សីហា) មានពលករជាង ៥ ពាន់នាក់ក្នុងនោះអ្នកវិជ្ជមានសរុបប្រមាណ ១ ពាន់នាក់ ហើយបើគិតជាមធ្យមពលករចូលមកក្នុង ១ថ្ងៃ ២០០ ទៅ ៣០០នាក់»។ លោកបន្តថា តាមទម្លាប់ពលករខ្មែរនឹងសម្រុកមកកាន់តែច្រើនក្នុងខែកញ្ញាខាងមុខនេះដោយសារបុណ្យភ្ជុំបិណ្ឌខិតជិតមកដល់គួបផ្សំនៅប្រទេសថៃជួបបញ្ហាការរីករាលដាលនៃជំងឺកូវីដ១៩។ ទន្ទឹមនេះដែរ រដ្ឋបាលខេត្តបន្ទាយមានជ័យបានកំណត់ភូមិសាស្ត្រមួយចំនួនក្នុងសង្កាត់ទឹកថ្លា និងសង្កាត់កំពង់ស្វាយនៃក្រុងសិរីសោភ័ណជា "តំបន់ក្រហម" ដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ធ្ងន់ធ្ងរ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩។ ក្នុងសេចក្ដីជូនដំណឹងចុះហត្ថលេខាដោយលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី ២៣ ខែសីហា បានបញ្ជាក់ថា៖ «តំបន់ក្រហមទាំងនោះរួមមាន នៅបរិវេណផ្សារទឹកថ្លា បរិវេណវត្តភ្នំជញ្ជាំង (ផ្លូវចូលវត្តតាមរបងវត្ត) ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ និងបរិវេណផ្សារពង្រស្ថិតនៅភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ»។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) ធ្លាប់បានថ្លែងថា បញ្ហាចម្បងដែលជំរុញឱ្យពលករខ្មែរសម្រុកមកស្រុកកំណើតវិញ គឺដោយសារនៅប្រទេសថៃមានការឆ្លងជំងឺកូវីដ ១៩ កាន់តែខ្លាំងឡើង។ ហេតុនេះហើយទើបរដ្ឋាភិបាលថៃបិទការដ្ឋានសំណង់ផ្សេងៗទាំងក្នុងក្រុង និងជាយក្រុង និងបិទទីតាំងមួយចំនួនធ្វើឱ្យប៉ះពាល់ដល់ការងាររបស់ពលករខ្មែរក្នុងវិស័យនេះ។ លោកថា៖ «យើងដឹងហើយនៅប្រទេសថៃ ចំនួនពលករដែលទទួលបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ បានចំនួនតិចនៅឡើយ ជាពិសេសពលករខ្មែរយើងដែលមានឯកសារត្រឹមត្រូវទទួលបានចាក់វ៉ាក់សាំងតិចណាស់ ដូច្នេះនៅពេលផ្ទុះកូវីដ ១៩ ជាពិសេសមេរោគបំប្លែងថ្មីដែលតាធ្វើឱ្យមានការចលាចលខ្លាំងជាពិសេសវិស័យការងារទើបធ្វើឱ្យពលករខ្មែរវិលចូលស្រុកវិញ»។ យ៉ាងណាក្តី លោក តុលា បានគាំទ្រចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលសម្រេចបើកច្រកព្រំដែនឡើងវិញ ដើម្បីទទួលពលករខ្មែរដែលកំពុងមានបញ្ហានៅប្រទេសជិតខាង៕

## កម្ពុជាស្នើភាគីថៃ ជួយព្យាបាលពលករកម្ពុជា ដែលឆ្លងជំងឺកូវីដ-១៩ ក្នុងរយៈពេលកំពុងស្វែងរកការងារធ្វើនៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatAugust 25, 2021

បន្ទាយមានជ័យ ៖ ក្នុងកិច្ចប្រជុំពិភាក្សាការងាររាជការ និងអភិវឌ្ឍសម្ព័ន្ធមេត្រីភាព កម្ពុជា-ថៃ តាមប្រព័ន្ធបញ្ជូនរូបភាពនិងសំឡេង (VTC) កម្ពុជាស្នើភាគីថៃ ជួយព្យាបាលពលករកម្ពុជា ដែលឆ្លងជំងឺកូវីដ-១៩ ក្នុងរយៈពេលកំពុងស្វែងរកការងារធ្វើនៅប្រទេសថៃ។ នៅទីបញ្ជាការយោធភូមិភាគទី៥ នាព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២១ កម្ពុជាដឹកនាំដោយ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរង នាយសេនាធិការយោធភូមិភាគទី ៥ ប្រធានក្រុមការងារលេខា និងមន្ត្រីរាជការ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ជួបប្រជុំពិភាក្សា ជាមួយភាគីថៃ ដែលដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី ក្រៃភព ឆៃយ៉ាក់ផាន់ នាយសេនាធិការកងទ័ពភូមិភាគទី១ ក្រុមលេខា និងមន្ត្រីរាជការ ខេត្តស្រះកែវ ប្រជុំពិភាក្សាការងាររាជការ និងអភិវឌ្ឍសម្ព័ន្ធមេត្រីភាពកម្ពុជា-ថៃ រវាងយោធភូមិភាគទី៥ ជាមួយកងទ័ពភូមិភាគទី១ តាមប្រព័ន្ធបញ្ជូនរូបភាព និងសំឡេង (VTC) ។ ក្នុងកិច្ចប្រជុំអភិវឌ្ឍសម្ព័ន្ធមេត្រីភាព និងពិភាក្សាការងាររាជការ រវាងកងទ័ពភូមិភាគទី១ ជាមួយយោធភូមិភាគទី៥ នាព្រឹកនេះគឺបានលើកបញ្ហាចំនួន ៤ខ្លឹមសារ យកមកពិភាក្សា៖ ខ្លឹមសារទី១ ការការពារ និងទប់ស្កាត់ពលករឆ្លងដែន និងការរៀបចំការងារសំរាប់ពលករ ខ្លឹមសារទី២ បញ្ហាគ្រឿងញៀន ខ្លឹមសារទី៣ បញ្ហាផ្ទុះជំងឺក្នុងស្ថានការណ៍បច្ចុប្បន្ន ខ្លឹមសារទី៤ បញ្ហាល្បែងភ្នាល់តាមអនឡាញ។

លោកឧត្តមសេនីយ៍ទោ សេង ធារិន បានស្នើអោយភាគីថៃ ជួយព្យាបាលពលករកម្ពុជា ដែលមានជំងឺកូវីដ-១៩ ជាពិសេសពលករ ដែលកំពុងស្វែងរកការងារធ្វើ ក្នុងប្រទេសថៃ និងស្នើភាគីថៃជួយសម្របសម្រួល ករណីពលករខ្មែរឆ្លងដែនខុសច្បាប់ មិនទាន់បានប្រព្រឹត្តទោសធ្ងន់ធ្ងរ សូមបញ្ជូនខ្លួនពលករទាំងនោះ ត្រឡប់មកកម្ពុជាវិញ និងជួយទប់ស្កាត់មិនឲ្យមានមេខ្យល់រង់ចាំ ទទួលពលករខុសច្បាប់ពីកម្ពុជា។

ភាគីទាំងពីរបានស្នើសុំឲ្យកម្លាំងសមត្ថកិច្ច កងកម្លាំងប្រដាប់អាវុធនៅជួរមុខ និងស្ថាប័នជំនាញដែលមានការពាក់ព័ន្ធទាំងពីរ ភាគីរួមគ្នាពិចារណា ដើម្បីកំណត់ជាគោលការណ៍ សម្រាប់ធ្វើការដោះស្រាយបញ្ហាផ្សេងៗ តាមព្រំដែនឲ្យសមស្របជាប្រទេស មានភូមិផងរបងជាមួយគ្នា។ ក្នុងកិច្ចប្រជុំនាព្រឹកនេះ ភាគីទាំងពីរ បានពិភាក្សាគ្នាដោយយកចិត្តទុកដាក់ និងផ្អែកលើទស្សនៈ ផលប្រយោជន៍រួមរបស់ប្រទេសទាំងពីរ ពិសេសប្រជាពលរដ្ឋយើងដែលរស់នៅតាមបរិវេណព្រំដែន៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

# ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១

## សមត្ថកិច្ចឃាត់ប្រជាពលរដ្ឋ៤០នាក់បម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/08/2021

ខេត្តបាត់ដំបង៖ កម្លាំងសមត្ថកិច្ចចម្រុះ កាលពីថ្ងៃទី២១ ខែ សីហា ឆ្នាំ ២០២១ វេលា ម៉ោង២០និង០០នាទី យប់បានសហការទប់ស្កាត់ពលករ បម្រុងលួចឆ្លងដែនចូលទៅក្នុងទឹកដីប្រទេសថៃ ដោយមិនស្របច្បាប់ចំនួន ០១ ករណីនៅចំណុចស្ពានអូតចម្លងស្ថិតក្នុង ភូមិអូរចម្លង ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ដោយបានឃាត់ប្រជាពលរដ្ឋចំនួន៤០នាក់ ស្រីចំនួន ១១ នាក់ក្មេងៗចំនួន០៨នាក់។ ក្រោយឃាត់ខ្លួន សមត្ថកិច្ច បានបញ្ជូនពួកគាត់ ទៅឱ្យកម្លាំងនគរ បាលនៃអធិការដ្ឋានស្រុកកំរៀងធ្វើការ ស្រាវជ្រាវតាមនីតិវិធី ៕

## សមត្ថកិច្ចឃាត់ខ្លួនមេខ្យល់២នាក់ និងអប់រំពលរដ្ឋ៦នាក់បម្រុងឆ្លងដែនទៅប្រទេសថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/08/2021

ខេត្តបាត់ដំបង ៖ លោក ទឹម រិទ្ធិយ អធិការនគរបាលស្រុកសំពៅលូន បានដឹកនាំកម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន សហការជាមួយកម្លាំងប៉ុស្តិ៍ការពារព្រំដែនគីឡូ១៣ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កម្លាំងផ្នែកសឹករងស្រុកសំពៅលូន និងកម្លាំងវរៈសេនាតូចលេខ៥៣៣ ប្រចាំការតាមមាត់អូរព្រំដែន បានធ្វើការបង្ក្រាបករណីលួចនាំពលករឆ្លងដែនខុសច្បាប់ នៅចំណុចដីថៃជាប់មាត់អូរព្រំដែនកម្ពុជា-ថៃ ជាប់ភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០២១ វេលាម៉ោង១១និង៣០នាទី ថ្ងៃត្រង់។

សមត្ថកិច្ចបានឲ្យដឹងថា ករណីខាងលើនេះ បានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន០២នាក់ រួមទាំងប្រជាពលរដ្ឋ ៦នាក់ក្នុងនោះ ស្រីចំនួន០៤នាក់ ដែលចាញ់បោកមេខ្យល់ បម្រុងនាំចេញទៅប្រទេសថៃ។ សមត្ថកិច្ចបញ្ជាក់ថា មេខ្យល់ទាំង២នាក់ខាងលើ គឺទី/១.ឈ្មោះ យឹម ជឿន ភេទប្រុស អាយុ ៣០ឆ្នាំ មានទីលំនៅភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង និងទី២/ឈ្មោះ មិត្ត ពេជ្រ ភេទប្រុស អាយុ ១៨ឆ្នាំ មានទីលំនៅភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០២នាក់ដើម្បីកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញដើម្បីអនុវត្តបន្តតាមផ្លូវច្បាប់ ។ ចំណែកប្រជាពលរដ្ឋរងគ្រោះទាំង០៦នាក់ សមត្ថកិច្ចបានធ្វើការអប់រំណែនាំនិងចុះកិច្ចសន្យារួចឱ្យវិលត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ៕

## កំណើនពលករឆ្លងដែនមកពីថៃ តាមច្រកអូរស្មាច់មានការធ្លាក់ចុះច្រើន

https://news.btv.com.kh/ 08/26/2021 10:08 AM

ឧត្តរមានជ័យ ៖ ក្នុងរយៈពេលមួយសប្តាហ៍ចុងខែសីហា ឆ្នាំ២០២១នេះ កំណើនលំហូរពលករខ្មែរ ឆ្លងដែនមកពីស្រុកថៃ គឺហាក់បីដូចជាមានការថយចុះច្រើន ក្នុងមួយថ្ងៃមានចំនួនជាង២០០នាក់ តែប៉ុណ្ណោះ បើធៀបនឹងពាក់កណ្តាលដើមខែសីហាវិញនោះ គឺមានចំនួនដល់ទៅ ៥០០នាក់ក្នុងមួយថ្ងៃៗ។

លោក ឌី រ៉ាដូ អ្នកនាំពាក្យរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា បច្ចុប្បន្ននេះ ស្ថានភាពកំណើនពលករខ្មែរ ឆ្លងមកពីថៃចូលតាមច្រកអូរស្មាច់ មានការថយចុះច្រើនជាងមុន គឺមួយថ្ងៃមានត្រឹម២០០នាក់ ហើយចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩នោះ ខាងក្រុមគ្រូពេទ្យជួរមុខបានរកឃើញជាបន្តបន្ទាប់ ប៉ុន្តែមានចំនួនតិចតួចមិនមានច្រើនដូចករណីមុនៗនោះឡើយ ទាំងការឆ្លងក្នុងសហគមន៍ផងនោះ។ លោកបន្តថា ទោះបីជាស្ថានភាពកំណើនពលករឆ្លងដែនមកពីថៃ បច្ចុប្បន្នមិនមានករណីឆ្លងច្រើនយ៉ាងណាក្តីក៏យើងនៅបន្តអនុវត្តវិធានការការពារកិច្ចពាក់ម៉ាក ការរក្សាគម្លាតឲ្យបានខ្ជាប់ខ្ជួន ជាប់ជាប្រចាំ ដើម្បីទប់ស្កាត់ការកាត់ផ្តាច់កុំឲ្យមានការចម្លងបន្តក្នុងសហគមន៍ឲ្យមានប្រសិទ្ធភាពខ្ពស់។

តាមការប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្ត គិតត្រឹមម៉ោង៧:៣០នាទីថ្ងៃទី២៥ សីហា ចំនួនពលករចូលមកថ្មីមានចំនួន១៨៤នាក់ ស្រី៨១នាក់ វិជ្ជមាន២៣នាក់ ស្រី១១នាក់ សហគមន៍៣៤នាក់ ជាសះស្បើយ១០២នាក់ សរុបមកអ្នកឆ្លងកូវីដ-១៩ក្នុងខេត្តមាន៦.៣៥៩ករណី ១.៤២៥ករណី កំពុងសម្រាកព្យាបាល១០ករណីស្លាប់ ៕ អត្ថបទ ៖ ឃិនសារិទ្ធ

## ទូតកម្ពុជា ប្រចាំម៉ាឡេស៊ី បន្តយកកញ្ចប់ស្បៀងអាហារ ចែកឲ្យពលករខ្មែរ ២២គ្រួសារ កំពុងជួបការខ្វះខាតខ្លាំង

https://dap-news.com/ BySKK106 Posted on August 26, 2021

ភ្នំពេញ៖ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ស្ថានទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានយកកញ្ចប់ស្បៀងអាហារ ចែកជូនប្រជាពលករខ្មែរចំនួន ២២គ្រួសារ នៅស្រុក KUANTAN រដ្ឋ PAHANG ដែលជួបការខ្វះខាតខ្លាំង ក្នុងអំឡុងពេល នៃការ រាតត្បាតកូវីដ-១៩ ធ្ងន់ធ្ងរ ៕

## អគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃជួយអន្តរាគមន៍បញ្ជូនពលរដ្ឋខ្មែរ២១នាក់មកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៦ សីហា ២០២១ដោយ Sorn Phanith

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងនៅថ្ងៃនេះថា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១នេះ ស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃ បានសហការជាមួយអាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរចំនួន២១ នាក់ ដែលមកពីតំបន់ផ្សេងៗក្នុងប្រទេសថៃ មកអោយអាជ្ញាធរកម្ពុជា តាមច្រកអន្តរជាតិ ខ្លងលឹក-ប៉ោយប៉ែត ដើម្បីអនុវត្តន៍ តាមនិតិវិធីសុខាភិបាល។

សូមបញ្ជាក់ថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ បានដឹកពលករខ្មែរ ចំនួន២៦៤ នាក់ បញ្ជូនមកមកកម្ពុជាវិញ តាមច្រក អូរបីជាន់ ផងដែរ នេះបើតាមការបញ្ជាក់ពីលោក កុយ គួង ហើយជាការឆ្លើយតបតាមសំណើរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានបំណង វិលត្រឡប់មកកម្ពុជាវិញ។ ក្នុងនោះ អគ្គកុងស៊ុល បានជួលរថយន្តដឹកជញ្ជូនពលរដ្ឋខ្មែរ ដែលបានប្រមូលផ្តុំគ្នាមកពីតំបន់ផ្សេងៗក្នុងប្រទេសថៃសរុបចំនួន២៦៤ នាក់ ប្រគល់ជូនអាជ្ញាធរកម្ពុជា និងចាត់ការតាមនីតិវិធីសុខាភិបាល៕ **អត្ថបទ៖ កោះកែវ**

## ស្ថានអគ្គកុងស៊ុល សហការជាមួយអាជ្ញាធរចិន ជួយសង្គ្រោះស្ត្រីខ្មែរ ១២នាក់ រងគ្រោះដោយការជួញដូរ

https://cen.com.kh/ Posted ByPen Srey NeatAugust 26, 2021

ភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោកកុយ គួង បានឲ្យដឹងនៅយប់ថ្ងៃទី២៦ ខែសីហា នេះថា ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងធុងឈីង ប្រទេសចិន នៅថ្ងៃទី២៦ សីហានេះ បានជូនដំណឹងមកថា ស្ថានអគ្គកុងស៊ុល បានសហការជាមួយអាជ្ញាធរចិន ជួយសង្គ្រោះស្ត្រីខ្មែរ ១២រូប ដែលរងគ្រោះដោយការជួញដូរ វិលត្រឡប់ទៅកម្ពុជាវិញ ដែលគ្រោងមកដល់នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៣និង៣០នាទីល្ងាច តាមជើងយន្តហោះ K6669 ៕ រក្សាសិទ្ធិដោយ ៖ ចេស្តារ

## បន្ទាយមានជ័យ រកឃើញអ្នកឆ្លងវីរុសបំប្លែងថ្មី Delta ចំនួន២៣០នាក់ មានទាំងពលករ និងក្នុងសហគមន៍

https://news.btv.com.kh/ 08/26/2021 10:08 AM

ភ្នំពេញ៖ អាជ្ញាធរខេត្តបន្ទាយមានជ័យ និងមន្ត្រីសុខាភិបាលខេត្ត បានរកឃើញអ្នកវិជ្ជមានកូវីដ ១៩ ប្រភេទបំប្លែងថ្មីដែលតា (Detla) ចំនួន២៣០ករណី ដែលតួលេខនេះគឺឈរនៅលេខរៀងទី២ បន្ទាប់ពីរាជធានីភ្នំពេញ ដែលបានរកឃើញរហូតដល់ចំនួន ៣៧៥ករណី នេះបើគិតត្រឹមថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៤ ខែសីហានេះ បានថ្លែងថា ចំពោះការរកឃើញអ្នកឆ្លងវីរុសបំប្លែងថ្មី Delta នៅក្នុងខេត្តបន្ទាយមានជ័យនេះ មានទាំងពលករត្រឡប់មកពីប្រទេសថៃ និងឆ្លង

ក្នុងសហគមន៍ ដោយអ្នកជំងឺកូវីដ១៩ បំប្លែងថ្មីនេះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាល ដាច់ដោយឡែកពីអ្នកជំងឺកូវីដ១៩ ប្រភេទធម្មតា ។ ឯកឧត្តមបន្តថា ដោយសារកំណើនអ្នកជំងឺកូវីដ១៩ បានរកឃើញជាបន្តបន្ទាប់ អាជ្ញាធរខេត្តបានរៀបចំនូវកន្លែងព្យាបាលធំថ្មី គឺមណ្ឌលព្យាបាល ហ៊ុន សែន ខ្លាកូន ស្ថិតក្នុងក្រុងសិរីសោភ័ណ ដោយដាក់អ្នកជំងឺអាការៈស្រាលចូលហើយ គឺបានចំនួនប្រមាណ២០០០នាក់ អ្នកជំងឺជាពលករសុទ្ធ ។

ឯកឧត្តមអភិបាលខេត្ត បានបន្ថែមថា ក្រៅពីនោះអាជ្ញាធរកំពុងរៀបចំជិតរួចហើយ ទីតាំងព្យាបាលមួយទៀតនៅមណ្ឌលផ្សារ អឹងវណ្ណម៉ៅ ស្ថិតក្នុងស្រុកមង្គលបូរីសម្រាប់ដាក់អ្នកជំងឺឆ្លងក្នុងសហគមន៍ ហើយកំពុងរៀបចំមណ្ឌលចត្តាឡីសក្តមួយទៀត នៅសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត អាចដាក់ពលករបានចំនួន ៣០០០នាក់ ។ ឯកឧត្តម អ៊ុំ រាត្រី បានបញ្ជាក់ថា ចំពោះការវិធានការ អាជ្ញាធរបានរៀបចំអ្នកជំងឺប្រភេទបំប្លែងថ្មី Detla នៅមណ្ឌលដាច់ដោយឡែកពីអ្នកជំងឺផ្សេង, បន្តស្វែងរកអ្នកពាក់ព័ន្ធផ្ទាល់ និងប្រយោល ឲ្យធ្វើចត្តាឡីសក្តតាមការណែនាំ, បន្តអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់ និងវិធានការបង្ការលើការរីករាលដាល, បន្តអនុវត្តបំរាមគោចរ និងហាមការជួបជុំ និងរឹតបន្តឹងការអនុវត្តវិធានការរដ្ឋបាល ៕

## កម្ពុជា-ថៃបញ្ជាររួមគ្នាទប់ស្កាត់ និងឈានទៅលុបបំបាត់វីរុសកូវីដបំប្លែងថ្មីប្រភេទ Delta

https://news.btv.com.kh/ 08/26/2021 11:08 AM

បាត់ដំបង ៖ យោធាភូមិភាគទី៥របស់កម្ពុជា និងកងទ័ពភូមិភាគទី១របស់ថៃ បានធ្វើការប្តេជ្ញារួមគ្នាទប់ស្កាត់ និងឈានទៅលុបបំបាត់វីរុសកូវីដ១៩បំប្លែងខ្លួនថ្មីប្រទេសឥណ្ឌា (Delta) ដែលកំពុងរាតត្បាតក្នុងប្រទេសទាំងពីរ និងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ មួយចំនួនទៀត។ ក្នុងកិច្ចប្រជុំអភិវឌ្ឍន៍សម្ព័ន្ធមេត្រីភាព និងពិភាក្សាការងាររាជការរវាងយោធភូមិភាគទី៥ និងរដ្ឋបាលខេត្តបាត់ដំបង ជាមួយកងទ័ពភូមិភាគទី១ នៃព្រះរាជាណាចក្រថៃ នៅព្រឹកថ្ងៃទី២៦ ខែ សីហា ឆ្នាំ ២០២១នេះ ភាគីទាំងពីរកម្ពុជា-ថៃ មានជំនឿយ៉ាងមុតមាំថា យើងនឹងបង្កើននូវកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងយោធភូមិភាគទី៥ និងកងទ័ពភូមិភាគ១ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ច នៃប្រទេសយើងទាំងពីរក្នុងការអភិវឌ្ឍតំបន់ព្រំដែនលើគ្រប់វិស័យ និងក្លាយជាប្រយោជន៍នៃប្រទេសយើងទាំងពីរ ព្រមទាំងប្រជាពលរដ្ឋដែលរស់នៅតាមព្រំដែនប្រកបដោយភាពសុខសាន្ត និងប្រកបមុខរបរនៅតាមខ្សែបន្ទាត់ព្រំដែនកាន់តែប្រសើរឡើងថែមទៀត។

ពាក់ព័ន្ធការទប់ស្កាត់ ការការពារពលករបរទេស និងការរៀបចំការងារសម្រាប់ពលករ ភាគីទាំងពីរបានឯកភាពគ្នាទប់ស្កាត់ និងការពារការលបលួចឆ្លងកាត់ព្រំដែន និងការឆ្លងដែនឲ្យបានម៉ឺងមាត់ ដោយអនុវត្តន៍ទៅតាមច្បាប់នៃប្រទេសទាំងពីរ។ ចំពោះជនជាតិកម្ពុជាដែលត្រូវចូលទៅធ្វើការនៅក្នុងប្រទេសថៃ ត្រូវចូលទៅដោយត្រឹមត្រូវតាមច្បាប់ ហើយក្នុងករណីមានការបិទព្រំដែនដោយប្រការណាមួយ ភាគីទាំងពីរត្រូវសហការ ជូនដំណឹងគ្នាទៅវិញទៅមកឲ្យបានម៉ឺងមាត់ និងទាន់ពេលវេលា។ ជាមួយគ្នានោះ ភាគីទាំងពីរបានឯកភាពគ្នា ក្នុងការចាត់វិធានការឲ្យបានម៉ឺងមាត់ ចំពោះអ្នកលបលួចល្មើសក្នុងការធ្វើដំណើរចេញចូលក្នុងប្រទេសនីមួយៗ ដោយចាត់វិធានការចំពោះមេខ្យល់នៅខាងប្រទេសថៃ ដែលរង់ចាំទទួលពលករកម្ពុជាឆ្លងដែនខុសច្បាប់។ ទាក់ទិនបញ្ហាពលករបរទេស ភាគីទាំងពីរបានឯកភាពគ្នា សហការបង្កើតបណ្តាញព័ត៌មាន ដោយការទំនាក់ទំនងតាមការឆ្លើយតបតាមប្រព័ន្ធឡាញ និងបង្កើតចំពោះការជួលពលករបរទេសឲ្យបានត្រឹមត្រូវស្របតាមច្បាប់ការងារ និងអនុវត្តតាមវិធានការការពាររបស់ក្រសួងសុខាភិបាលក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩។ ចំពោះការបន្តសុពលភាពលិខិតឆ្លងដែនរបស់ពលករកម្ពុជា ក្នុងករណីលិខិតឆ្លងដែន ឬឯកសារប្រើជំនួសលិខិតឆ្លងដែនដែលអស់សុពលភាព ត្រូវជំរុញឲ្យពលករកម្ពុជាដំណើរការឲ្យបានត្រឹមត្រូវតាមការកំណត់ត្រឹមថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០២២។

ចំពោះបញ្ហាគ្រឿងញៀនភាគីទាំងពីរសហការគ្នាជំរុញទិន្នន័យលើវិស័យព័ត៌មាន ចំពោះអ្នកប្រព្រឹត្តល្មើស និងវិធីលបលួច នាំយកគ្រឿងញៀនឆ្លងដែនដោយខុសច្បាប់ ដោយបង្កើតបណ្តាញទិន្នន័យព័ត៌មាន ដើម្បីទំនាក់ទំនងតាមប្រព័ន្ធឡាញ។ ពាក់ព័ន្ធបញ្ហាល្បែងភ្នាល់តាមប្រព័ន្ធអនឡាញភាគីទាំងពីររួមគ្នាសហការជំរុញផ្សព្វផ្សាយ និងការបង្កើតបណ្តាញទិន្នន័យព័ត៌មានរបស់ជនល្មើស ក្នុងការបើកវេបសាយល្បែងភ្នាល់គ្នាតាមប្រព័ន្ធអនឡាញ ដោយខុសច្បាប់ដោយទំនាក់ទំនងឆ្លើយតបគ្នាតាមប្រព័ន្ធឡាញ។

គួរបញ្ជាក់ថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាសម្រេចបើកដំណើរច្រកព្រំដែនឡើងវិញ ជាមួយភាគីថៃ ជាង ១០ថ្ងៃកន្លងមកនេះ មានពលករខ្មែរចំនួន ១.៧៩២នាក់ បានចេញពីប្រទេសថៃចូលមកកម្ពុជាតាមច្រកផ្សេងៗក្នុងខេត្តបាត់ដំបង ក្នុងនោះបានរកឃើញវិជ្ជមានជំងឺកូវីដ១៩ ចំនួន១១២នាក់ ខណៈចំនួនអ្នកជាសះស្បើយនៅក្នុងខេត្តបានកើនឡើងច្រើន។ រហូតមកដល់ពេលនេះ ខេត្តបាត់ដំបង បានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ សរុបចំនួន ៥ ៤១៨នាក់ព្យាបាលជាសះស្បើយចំនួន៤៥២៦នាក់កំពុងសម្រាកព្យាបាលចំនួន៨២០នាក់និងស្លាប់ចំនួន៧២នាក់៕

# ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ ៦ខែឆ្នាំនេះ កម្ពុជាបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច បាន ១៩៨ករណី កើន១៣៥ករណី ធៀបនឹងឆ្នាំមុន

http://freshnewsasia.com/ 2021-08-27 12:36pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ៦ខែ ឆ្នាំ២០២១នេះ កម្ពុជាបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចបាន ១៩៨ករណី។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានបញ្ជាក់នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ថា ចំនួនបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ទាំង១៩៨ករណីនេះ គឺកើនឡើង ១៣៥ករណី បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ដែលមានត្រឹមតែ ៦៣ករណី។ លោកស្រីបន្តថា ក្នុងការបង្ក្រាបទាំងអស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ឃាត់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧២១នាក់។ លោកស្រី ជូ ប៊ុនអេង បានបន្ថែមថា ក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ទាំង១៩៨ករណីនេះដែរ មានករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ១៣៩ករណី ដែលឃាត់ខ្លួនបានជនសង្ស័យ ២៣១នាក់ និងការធ្វើអាជីវកម្មផ្លូវភេទ ៥៩ករណី ដែលឃាត់ខ្លួនជនសង្ស័យបាន ៦០នាក់។

លោកស្រីកត់សម្គាល់ថា ករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ទាំង ១៣៩ករណី ភាគច្រើនគឺជាការនាំចេញដោយខុសច្បាប់សម្រាប់ឆ្លងដែន រហូតដល់ទៅ ១២១ករណី ដែលឃាត់បានជនសង្ស័យ ១៩៨នាក់។ នៅមានប្រភេទនៃការជួញដូរមនុស្ស និងកេងវ័ញ្ច ច្រើនទៀត ប៉ុន្តែចំណុចដែលលើកឡើងនេះ ជាករណីធំៗ និងទូទៅ។ នៅពេលសួរថា ហេតុអ្វីបានជាឆ្នាំ២០២០ មានអំពើល្មើសតិច? លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ដោយសារតែឆ្នាំ ២០២០ ជាពេលដែលជំងឺកូវីដ១៩ វាយលុកបឋម ប្រជាពលរដ្ឋម្នាក់ៗ នៅតែភ័យព្រួយនៅឡើយ ខណៈកម្ពុជាក៏មានវិធានការបិទខ្ទប់ព្រំដែន អញ្ចឹងជនខិលខូចមិនទាន់រកវិធីឃើញទេ។ «ប៉ុន្តែមកដល់ ដើមឆ្នាំ២០២១ ស្រាប់តែមានសកម្មភាពពុះកញ្ជ្រោលឡើងវិញ ទាក់ទងទៅនឹងសកម្មភាពនេះ។ ប៉ុន្តែយើងមិនកន្តើយទេ គឺយើងបង្ក្រាបបាន ១៩៨ករណី ចាប់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះ ៧២១នាក់ឯណោះ»។ នេះជាការបញ្ជាក់ របស់មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ។ ថ្លែងក្នុងនាមតំណាងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង ក៏បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ស

ម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ប្ដេជ្ញាសហការជាមួយ ដៃគូរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ប្រទេស និងកម្រិតតំបន់ លុបបំបាត់រាល់ទម្រង់នៃ អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ដើម្បីលើកស្ទួយការគោរពសិទ្ធិ សេចក្ដីថ្លៃថ្នូរ និងយុត្តិធម៌សង្គមមនុស្សជាតិ៕

## ស្ថានទូតសហរដ្ឋអាមេរិក បើកដំណើរការគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

https://www.postkhmer.com/ វី សុចាន់ | Publication date 27 August 2021 | 09:19 ICT

**ភ្នំពេញៈ** ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បើកដំណើរការគម្រោងថ្មីរបស់ទីភ្នាក់ងារជំនួយអាមេរិក USAID ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (CTIP) រយៈពេល ៥ឆ្នាំ ដើម្បីស្វះស្វែងរកការការពារជនងាយរងគ្រោះពីការជួញដូរ និងការរំលោភបំពាន។ គម្រោងនេះអនុវត្តដោយអង្គការ Winrock International ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៦ និងមានវិសាលភាពគ្របដណ្ដប់ចំនួន ៨ រាជធានី-ខេត្តរួមមានរាជធានីភ្នំពេញ ខេត្តព្រៃវែង កំពង់ចាម កោះកុង ព្រះសីហនុ បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ។ គម្រោងនេះក៏មានទិសដៅស្វែងរកដំណោះស្រាយ ឫសគល់បញ្ហាបង្កឱ្យមានការជួញដូរ និងការពារប្រជាជនដែលមានហានិភ័យពីការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន និងជួយរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងជួយជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

លោក Mark Laylor ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (CTIP) នៃអង្គការ Winrock International ថ្លែងក្នុងពិធីដាក់ឱ្យដំណើរការ គម្រោងនេះកាលពីថ្ងៃទី ២៦ ខែសីហាថា គម្រោងនេះនឹងពង្រឹងការអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ពង្រឹងប្រព័ន្ធកំណត់អត្តសញ្ញាណ និងជួយជនរងគ្រោះពីការជួញដូរ និងពង្រឹងគណនេយ្យភាព ដោយឱ្យជនល្មើសត្រូវទទួលការផ្ដន្ទាទោសតាមច្បាប់។ លោកថ្លែងថា កម្មវិធីនៅក្នុងគម្រោងនេះនឹងផ្ដោតលើសន្តិសុខស្បៀងអាហារ ប្រាក់ចំណូលជាមូលដ្ឋានរបស់ប្រជាជន ដើម្បីចៀសវាងការប្រឈមនឹងការចំណាកស្រុក ដោយប្រថុយប្រថាន។ នៅពេលពួកគាត់ទទួលបានឱកាសការងារ នៅក្នុងស្រុក ពួកគាត់នឹងសម្រេចចិត្ត មិនធ្វើចំណាកស្រុកតទៅទៀតនោះទេ ដែលអាចកាត់បន្ថយហានិភ័យចំណាកស្រុកផងដែរ។ លោក Mark Laylor ថ្លែងថា៖ «ជំនួយរបស់យើង យើងមើលទៅលើតម្រូវការខាងផ្នែកទីផ្សារបានន័យថា ជួយទៅលើមុខរបរ ឬផ្នែកណាដែលមានទីផ្សារដែលអាចឱ្យគាត់លក់ដូរ រកចំណូលបាន»។ គម្រោងនេះ ក៏នឹងធ្វើការអប់រំផ្សព្វផ្សាយផ្លាស់ប្ដូរឥរិយាបថ ឬផ្នត់គំនិត ដែលមានកន្លងមក ចំពោះការជួញដូរមនុស្សក៏ដូចជាការចំណាកស្រុកដោយប្រថុយប្រថាន។ លើសពីនេះនឹងធ្វើការផ្សព្វផ្សាយ និងជំរុញទៅដល់ឱកាសការងារផ្សេងៗដើម្បីឱ្យពលរដ្ឋទាំងនោះអាចមានឱកាសធ្វើការងារនៅក្នុងស្រុក។ លោកបន្តថា៖ «យើងចង់លើកទឹកចិត្តឱ្យគ្រប់គ្នានៅផ្ទះ ពីព្រោះនៅផ្ទះគឺមានសុវត្ថិភាព ដោយបង្កើតជីវភាពសេដ្ឋកិច្ចក្នុងសហគមន៍នៅភូមិស្រុករបស់គាត់នៅកម្ពុជាហ្នឹងតែម្ដង»។ លោក Mark Laylor បន្តថា គម្រោង CTIP នឹងពង្រឹងប្រព័ន្ធរបស់រដ្ឋាភិបាល ដើម្បីកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះនៃការជួញដូរដើម្បីទទួលបានសេវាចាំបាច់ និងពង្រីកសេវាក្នុងការជួយដល់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ តាមរយៈកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងអង្គភាពផ្ដល់សេវារបស់រដ្ឋាភិបាល។

លោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ថ្លែងក្នុងពិធីនេះថា គោលដៅគម្រោងនឹងស្វះស្វែងរកឫសគល់នៃអំពើជួញដូរមនុស្សដើម្បីជួយប្រជាជន ដែលរងគ្រោះ ដោយសារការរំលោភបំពានដើម្បីទប់ស្កាត់ការចំណាកស្រុកដោយប្រថុយប្រថាន និងការធ្លាក់ទៅក្នុងអំពើជួញដូរ។ អង្គការ Winrock International ត្រូវបានគេទទួលស្គាល់ច្រើន សម្រាប់ការខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដោយមានទាំងបទពិសោធ មិនត្រឹមតែនៅកម្ពុជាទេតែថែមទាំងនៅក្នុងតំបន់ទៀតផង។ លោក Patrick Murphy ថ្លែងថា ការជួញ

ជួរមនុស្សកើតឡើងគ្រប់កន្លែងក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ ១៩ ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកាន់តែមានការលំបាក។ ជោគជ័យរបស់កម្ពុជាលើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺជាជោគជ័យរបស់សហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀតក្នុងសកលលោកដែលកិច្ចការនេះតម្រូវឱ្យធ្វើការរួមគ្នា។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គជបជ) ថ្លែងក្នុងពិធីនោះថា តាមរយៈការគាំទ្រពីគម្រោងថ្មី CTIP នេះនិងដៃគូដទៃទៀត គជបជ នឹងអាចរុករកបន្ថែមទៀត ដើម្បីកែលម្អនូវករណីបញ្ជូនជនល្មើសទៅតុលាការ ប្រព័ន្ធក្នុងការរាយការណ៍ ការការពារ និងការផ្តល់សេវាជួយដល់ជនរងគ្រោះ។ លោកស្រីថ្លែងថា តាមរយៈការគាំទ្រនេះ គជបជ ចូលរួមក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងថ្នាក់ជាតិ ថ្នាក់អន្តរជាតិទ្វេភាគីនិងថ្នាក់តំបន់ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងសេវាគាំទ្រដល់ជនរងគ្រោះ ដោយសារការជួញដូរជាពិសេសការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ លោកស្រី ជូ ប៊ុនអេង បន្តថា គជបជ ស្វាគមន៍រាល់កិច្ចសហប្រតិបត្តិការរបស់គម្រោង CTIP របស់ USAID នេះដើម្បីកែលម្អឱ្យកាន់តែប្រសើរ ក្នុងគោលដៅប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការជួយដល់ជនរងគ្រោះការការពារ និងស្តារឡើងវិញអ្នករងគ្រោះ និងអ្នកដែលងាយរងគ្រោះ។ ការរាតត្បាតជំងឺកូវីដ ១៩ អាចនឹងមានផលប៉ះពាល់ច្រើនបន្ថែមទៀត ប៉ុន្តែវាមិនអាចបញ្ឈប់សកម្មភាពរបស់អាជ្ញាធរកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរនោះបានទេ៕

## អ្នកនាំពាក្យការបរទេស៖ ៦ខែឆ្នាំនេះ ស្ត្រីរងគ្រោះ ២៣០នាក់ ត្រូវបានសង្គ្រោះពីចិន

http://freshnewsasia.com/ 2021-08-27 02:47pm

**(ភ្នំពេញ)៖** លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ បានថ្លែងថា ៦ខែ ឆ្នាំ២០២១នេះ ស្ត្រីរងគ្រោះរបស់កម្ពុជាដែលចាញ់បោកតាមរយៈអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច មានចំនួន ២៣០នាក់ ត្រូវបានជួយសង្គ្រោះពីប្រទេសចិន។ មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេស បានថ្លែងប្រាប់អ្នកសារព័ត៌មានយ៉ាងដូច្នេះថា៖ «**រយៈពេល៦ខែដើមឆ្នាំនេះ (ចាប់មករា-មិថុនា) ស្ត្រីដែលបានជួយសង្គ្រោះពីប្រទេសចិន សរុបចំនួន ២៣០នាក់**»។

បើតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ៦ខែ ឆ្នាំ២០២១នេះ កម្ពុជាបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចបាន ១៩៨ករណី។ ចំនួនបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ទាំង ១៩៨ករណីនេះ គឺកើនឡើង១៣៥ករណី បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ដែលមានត្រឹមតែ ៦៣ករណី។ លោកស្រីបន្តថា ក្នុងការបង្ក្រាបទាំងអស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក៏ឃាត់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧២១នាក់។ លោកស្រី ជូ ប៊ុនអេង បានបន្ថែមថា ក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ទាំង១៩៨ករណីនេះដែរ មានករណីជួញដូរមនុស្សបែបកម្លាំងពលកម្ម ១៣៩ករណី ដែលឃាត់ខ្លួនបានជនសង្ស័យ ២៣១នាក់ និងការធ្វើអាជីវកម្មផ្លូវភេទ ៥៩ករណី ដែលឃាត់ខ្លួនជនសង្ស័យបាន ៦០នាក់។

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ក៏បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ប្តេជ្ញាសហការជាមួយ ដៃគូពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ប្រទេស និងកម្រិតតំបន់ លុបបំបាត់រាល់ទម្រង់នៃ អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ដើម្បីលើកស្ទួយការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សង្គមមនុស្សជាតិ៕

## សមត្ថកិច្ចបញ្ជូនមេខ្យល់ ៦ នាក់ទៅតុលាការ ខណៈពលករចំនួន ២១ នាក់ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក

https://www.postkhmer.com/ គីម សារុំ | Publication date 27 August 2021 | 13:29 ICT

**បាត់ដំបង:** នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបាត់ដំបងបានបញ្ជូនបុរសជាមេខ្យល់ចំនួន ៦ នាក់ ទៅតុលាការខេត្តនៅថ្ងៃទី ២៦ សីហា បន្ទាប់ពីឃាត់ខ្លួនបាន ៣ ថ្ងៃ នៅស្រុកសំពៅលូន និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ខណៈពលករចំនួន ២១ នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក។

លោក ប៊ិន វណ្ណារ៉ា នាយការិយាល័យប្រឆាំងការជួញដូរមនុស្សខេត្តបាត់ដំបង បានឱ្យភ្នំពេញប៉ុស្ដិ៍ដឹងនៅថ្ងៃទី ២៦ សីហាថា សមត្ថកិច្ចជំនាញបានបញ្ជូនជនសង្ស័យជាមេខ្យល់ចំនួន ៦ នាក់ទៅសាលាដំបូងខេត្តបាត់ដំបងនៅថ្ងៃទី ២៦ សីហា។ ក្រុមជនសង្ស័យទាំងនេះបានលួចនាំពលករឆ្លងដែន ដោយថ្មើរជើងចូលទៅប្រទេសថៃចំនួន ២១ នាក់ (ក្មេង ២ នាក់) ហើយសមត្ថកិច្ចឃាត់ខ្លួនពួកគេបានកាលពីថ្ងៃទី ២៣ សីហា។ លោកបានថ្លែងថា៖ «ពាក់ព័ន្ធសំណុំរឿងពួកគេទៅតុលាការវិញ គឺខ្ញុំមិនអាចប្រាប់ឈ្មោះជនសង្ស័យបានទេ ព្រោះសំណុំរឿងនេះ គឺកំពុងស្ថិតក្នុងចំណាត់ការរបស់តុលាការ»។ បើតាមលោក វណ្ណារ៉ា ថា សមត្ថកិច្ចបានឃាត់ខ្លួនមេខ្យល់ទាំង ៦ នាក់នេះ ៣ករណីក្នុងស្រុកសំពៅលូន និងស្រុកភ្នំព្រឹកនៅថ្ងៃទី ២៣ សីហាដូចគ្នា។ នៅស្រុកសំពៅលូន សមត្ថកិច្ចឃាត់ និងទប់ស្កាត់បានពលករចំនួន ៦ នាក់ ក្នុងនោះមានស្រី ៤ នាក់ និងប្រុស ២ នាក់ និងមេខ្យល់ ២ នាក់ សរុបទាំងអស់ចំនួន ៨ នាក់។

ចំណែកនៅក្នុងស្រុកភ្នំព្រឹកវិញ គឺសមត្ថកិច្ចឃាត់ និងធ្វើការទប់ស្កាត់ពលករក្នុង ២ គោលដៅ។ គោលដៅទី ១ ទប់ស្កាត់បានពលករចំនួន ៥ នាក់ក្នុងនោះស្រី ២ នាក់ និងបុរសជាមេខ្យល់ម្នាក់សរុបចំនួន ៦ នាក់។ រីឯគោលដៅទី ២ សមត្ថកិច្ចទប់ស្កាត់បានពលករ ១០ នាក់ ក្នុងនោះមានស្រី ៨ នាក់ រាប់ទាំងក្មេងស្រី ២ នាក់ផងនិងឃាត់ខ្លួនមេខ្យល់បាន ៣ នាក់។ លោកបញ្ជាក់ប្រាប់ថា ករណីនេះបុរសជាមេខ្យល់ទាំង ៦ នាក់បានយកលុយពីពលករមុនជាថ្នូរនឹងការនាំឆ្លងដែនចូលទៅប្រទេសថៃ។ ប៉ុន្តែលោកមិនចាំថា ក្នុងពលករម្នាក់ត្រូវបានមេខ្យល់យកលុយអស់ចំនួនប៉ុន្មាននោះទេ។ ចំពោះពលករប្រុស-ស្រីទាំង ២១ នាក់ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅមណ្ឌលចត្តាឡីស័កអស់ហើយ ក្រោយពីសមត្ថកិច្ចបានធ្វើការទប់ស្កាត់ពួកគេមក។

លោក ហេង បារាំង អធិការនគរបាលស្រុកភ្នំព្រឹកខេត្តបាត់ដំបងបានប្រាប់នៅថ្ងៃទី ២៦ សីហាថា នៅថ្ងៃទី ២៣ សីហា សមត្ថកិច្ចរបស់លោកបានឃាត់ខ្លួនមេខ្យល់បានចំនួន ៤ នាក់ និងទប់ស្កាត់បានពលករ ១៥ នាក់។ លោកថា៖ «មេខ្យល់តែងតែគិតថា កន្លែងព្រៃ ឬទីស្ងាត់ប្រហែលជាសមត្ថកិច្ចទៅមិនដល់អ៊ីចឹងទៅ។ តែតាមពិតយើងដាក់កម្លាំងឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ មិនដូចពួកគេគិតនោះទេ»។

ចំណែកលោកអធិការនគរបាលស្រុកសំពៅលូនលោក ទឹម រិទ្ធិយ បានឱ្យដឹងនៅថ្ងៃទី ២៦ សីហាថា កងកម្លាំងរបស់លោកបានធ្វើការទប់ស្កាត់ពលករបានចំនួន ៦ នាក់ និងឃាត់មេខ្យល់បាន ២ នាក់។ សមត្ថកិច្ចនិយាយថា បើទោះបីជានៅប្រទេសថៃមានការផ្ទុះឆ្លងជំងឺកូវីដយ៉ាងខ្លាំងក៏ដោយក៏នៅតែមានមេខ្យល់លួចនាំពលករឆ្លងដែនទៅថៃដែរ៕

## សាលាឧទ្ធរណ៍ជំនុំជម្រះបណ្តឹងឧទ្ធរណ៍របស់ស្ត្រីជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹងការជួញដូរស្ត្រីខ្មែរ១៥នាក់ ទៅរៀបការប្តីនៅចិន !!

https://cen.com.kh/ Posted ByPen Srey NeatAugust 27, 2021

ភ្នំពេញ ៖ សាលាឧទ្ធរណ៍ភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២១ បានបើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ របស់ស្ត្រីជាប់ចោទ ម្នាក់ ដែលត្រូវបានតុលាការរាជធានីភ្នំពេញ កាត់ទោសដាក់ពន្ធនាគារ ០៧

ឆ្នាំ ជាប់ពាក់ព័ន្ធបទល្មើស« ការនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ» ប្រព្រឹត្តនៅក្នុងរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១៧ ដល់ ២០១៨ ។

លោកជំទាវ គឹម ដានី ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍ភ្នំពេញ បានថ្លែងដឹងនៅក្នុងសវនាការថា ជនជាប់ចោទមានឈ្មោះ ស៊ុ សុគន្ធា ភេទ ស្រី អាយុ ៣៧ ឆ្នាំ ។ ជនជាប់ចោទ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ០៧ ឆ្នាំ អំឡុង ២០១៩ និង បង្គាប់ឲ្យសងជម្ងឺចិត្តដល់ជនរងគ្រោះម្នាក់ៗ ចំនួន ២០លានរៀលពីបទ« ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ » តាមបញ្ញាតិមាត្រា ១០ នៃ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ តែជនជាប់ចោទ បានប្តឹងជំទាស់មកសាលាឧទ្ធរណ៍ដើម្បីសុំបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ ស៊ុ សុគន្ធា ត្រូវបាន សមត្ថកិច្ចចាប់ឃាត់ខ្លួន និងបញ្ជូនទៅតុលាការសម្រាប់ចោទប្រកាន់ និងត្រូវបានសម្រេចឃុំខ្លួន នៅអំឡុងឆ្នាំ ២០១៩ ជាប់ពាក់ព័ន្ធនឹងការជ្រើសរើសស្ត្រីជនជាតិខ្មែរ ចំនួន១៥ នាក់ ឲ្យទៅប្រទេសចិន ដើម្បីរៀបការប្តីចិន ព្រោះមានលុយច្រើន តែពេលទៅជនរងគ្រោះ បានទៅដល់ប្រទេសចិន ពួកគេត្រូវបានគេលក់ដូរ ពីបុរសចិនមួយទៅបុរសចិនមួយ ដូចសត្វធាតុ ដើម្បីគ្រាន់តែបំពេញការសប្បាយផ្លូវភេទ និងកាមគុណរបស់ពួកប្រុសៗចិន អស់រយៈពេលជាច្រើនឆ្នាំ នៅក្នុងប្រទេសចិន។ ជនជាប់ចោទឈ្មោះ ស៊ុ សុគន្ធា ក្រោយមកត្រូវបានចាប់ឃាត់ខ្លួន នៅក្នុងអំឡុងឆ្នាំ ២០១៩ តាមបណ្តឹងនារីរងគ្រោះ បន្ទាប់ពីពួកគេត្រូវមន្ត្រីស្ថានទូតខ្មែរ ប្រចាំនៅចិនសហការជាមួយសមត្ថកិច្ចនគរបាលចិន ជួយសង្គ្រោះ និងបានបញ្ជូនពួកគេវិលត្រឡប់ មកកាន់ប្រទេសកម្ពុជាវិញ នៅក្នុងឆ្នាំ ២០១៩។ នាពេលសវនាការជនជាប់ចោទ ឈ្មោះស៊ុ សុគន្ធា បានឆ្លើយបដិសេធចំពោះ ការចោទប្រកាបន់ខាងលើ និង និយាយថា ខ្លួនមិនបានប្រព្រឹត្តិ អំពើដូចការចោទប្រកាន់ទេ។

ទោះជាយ៉ាងណាក្តី ជនជាប់ចោទ ឈ្មោះស៊ុ សុគន្ធា បានទទួលស្គាល់ថា ខ្លួនពិតបានជួយសម្រួល និងជួយបកប្រែ ជាភាសាចិនឲ្យពួកកគេ ឲ្យបុរសចិនម្នាក់ (គេចខ្លួន) ដែលជាអ្នកជ្រើសរើសជនរងគ្រោះ ទៅរៀបការប្តីនៅចិនតែប៉ុណ្ណោះ។ ឈ្មោះ ស៊ុ សុគន្ធា បានសំណូមពរ ដល់តុលាការឧទ្ធរណ៍ មេត្តាជួយរកយុត្តិធម៌ និងបន្ធូរបន្ថយទោសដល់នាងខ្លះៗ ផង ដើម្បីឆាប់បនាវិលត្រឡប់ទៅជួយជុំគ្រួសាររបស់នាងវិញ។

សំណុំរឿងនេះ សាលាឧទ្ធរណ៍ ភ្នំពេញ នឹងប្រកាសសាលដីកា នៅព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៨និង០០ ព្រឹក៕ រក្សាសិទ្ធិ ដោយ ចន្ទា ភា

## ឃាត់ខ្លួនជនជាតិថៃ ៣០ នាក់ ដែលបម្រុងលបឆ្លងដែនមកធ្វើការនៅក្នុងទឹកដីកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៨ សីហា ២០២១ដោយ Blue Sky

ជនជាតិថៃចំនួន ៣០ នាក់ ដែលក្នុងនោះមានមេខ្យល់ ចំនួន ៣ នាក់ ផងនោះ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១២ សហការជាមួយកម្លាំងអធិការ ស្រុកគោកខ្សូង ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេកំពុងប្រមូលផ្តុំគ្នា បម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជាដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាម៉ោង ១០ យប់ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២១ ត្រង់ចំណុច ផ្ទះលេខ ៩៧ ភូមិ១ ឃុំគោកខ្សូង ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបម្លែងខ្លួន ដែលតា ។

ជនជាតិថៃទាំង ៣០ នាក់ គឺពួកគេមកពីបណ្តាខេត្តមួយចំនួន ដោយគេបានសារភាពថា ការប្រមូលផ្តុំគ្នានេះ ដោយសាររង់ចាំឱកាស សម្រាប់ឲ្យមេខ្យល់ចំនួន ៣ នាក់ ក្នុងការនាំឆ្លងដែនចូលទៅកាន់ប្រទេសកម្ពុជា តែត្រូវចាប់ខ្លួនទៅហើយ។ ពួកគេ បានអះអាងថា ការលបឆ្លងដែននេះគឺអាចធ្វើឲ្យពួកគេសល់កម្រៃច្រើន ដោយចូលទៅ

ធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត បើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ ហើយទទួលបានប្រាក់ខែចាប់ពី២២.០០០ បាតដល់ ២៥.០០០ បាត ៕ **អត្ថបទ ៖សោ និយមវត្ថ**

## ទទួលពលរដ្ឋកម្ពុជាវិលត្រឡប់មកពីថៃ និងពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូល

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៨ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ០៩:២៦

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង បានទទួលប្រជាពលរដ្ឋវិលត្រឡប់មកពីប្រទេសថៃ មកកម្ពុជាវិញ ចំនួន០៣នាក់ ពីយោធាថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ នេះបើយោងតាមផេក អគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ហោះមុននេះបន្តិច ។

លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនចក្រីនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី២ បានទៅទទួលប្រជាពលរដ្ឋវិលត្រឡប់មកពីប្រទេសថៃ មកកម្ពុជាវិញ ចំនួន០៣នាក់,ស្រី០១នាក់ ក្នុងនោះក្មេងប្រុស០១នាក់ ពីយោធាថៃ កងអនុសេនាធំលេខ១១១៣ នៃកងវរសេនាធំលេខ១៣ ត្រង់ចំណុចនិយាមកា0213666-1482174 ភូមិសាស្រ្ត ភូមិខៅធង់យែប ឃុំខ្លូងហាត ស្រុកខ្លុងហាត ខេត្តស្រះកែវ ទល់មុខប៉ុស្តិ៍ព្រំដែនចក្រីភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ក្រោយពីសាកសួរ កត់ឈ្មោះរួច កម្លាំងយើងបានប្រគល់ជូនក្រុមគ្រូពេទ្យ បន្ទាប់មកក្រុមគ្រូពេទ្យបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ដើម្បីពិនិត្យសុខភាពនិងធ្វើតេស្តរហ័សនៅទីនោះ ៕

# ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១

## អាមេរិក ធ្វើសកម្មភាព ៥ឆ្នាំ លើគំរោងលុបបំបាត់ឫសគល់ ជួញដូរមនុស្ស

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១

(ភ្នំពេញ)៖ រដ្ឋាភិបាលអាមេរិក ផ្តើមសកម្មភាពថ្មី នៅកម្ពុជារយៈពេល ៥ឆ្នាំ លើគំរោងលុបបំបាត់ឫសគល់នៃការជួញដូរមនុស្ស។ សកម្មភាពនេះផ្តើមដោយលោកឯកអគ្គរដ្ឋទូត W.Patrick Murphy និងលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បំពេញបន្ថែមលើបទពិសោធន៍រាប់ឆ្នាំ ពីកម្មវិធីកន្លងមក ក្នុងការប្រឆាំងការជួញដូរមនុស្ស ដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារ USAID។

ស្ថានទូតបញ្ជាក់ថា«រដ្ឋាភិបាលសហរដ្ឋអាមេរិក មានមោទនភាពសូមប្រកាសការចាប់ផ្តើមសកម្មភាពថ្មីមួយ មានរយៈពេល ៥ ឆ្នាំ របស់ទីភ្នាក់ងារជំនួយអាមេរិក USAID ស្តីពីការប្រឆាំងការជួញដូរមនុស្ស សកម្មភាពនេះមានបំណងលុបបំបាត់មូលហេតុជាឫសគល់នៃការជួញដូរមនុស្ស ការពារក្រុមមនុស្សងាយរងគ្រោះពីការជួញដូរ ហើយជួយរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងជួយដល់ជនរងគ្រោះឱ្យបានល្អ»៕

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ចំនួន៦៤នាក់ ក្នុងនោះ៥៤នាក់ ជាពលករ ទើបមកពីថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងជាសះស្បើយ១៥៩នាក់

http://freshnewsasia.com/ 2021-08-28 10:18am

(ឧត្តរមានជ័យ)៖ រដ្ឋបាលខេត្តឧត្តរមានជ័យ នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ បានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន ៦៤នាក់បន្ថែមទៀត ក្នុងនោះចំនួន៥៤នាក់ ជាពលករទើបមកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់, ៩នាក់ ឆ្លងក្នុងព្រឹត្តិការណ៍សហគមន៍ និង ១នាក់ទៀត ជាពលករកំពុងធ្វើចត្តាឡីស័ក ខណៈមានអ្នកជាសះស្បើយជំងឺកូវីដ១៩ ចំនួន១៥៩នាក់ផងដែរ។ នេះបើតាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១នេះ។

រដ្ឋបាលខេត្តឧត្តរមានជ័យ បានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ជាមួយបុគ្គលវិជ្ជមានកូវីដ១៩ ទើបរកឃើញនេះ ត្រូវដាក់ខ្លួនដាច់ដោយឡែករយៈពេល ១៤ថ្ងៃ។ ក្នុងករណីមានរោគសញ្ញាក្អក ផ្តាសាយ ហៀរសំបោរ ឈឺបំពង់ក ថប់ដង្ហើម ក្តៅខ្លួនខ្លាំង ឬរោគសញ្ញាសង្ស័យផ្សេងៗទៀត ត្រូវទាក់ទងក្រុមការងារប្រចាំការ និងយកសំណាកនៅមន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែកអន្លង់វែង ឬទំនាក់ទំនងសាកសួរព័ត៌មានផ្សេងៗតាមរយៈលេខទូរស័ព្ទ៖ ០១២ ៤៩៩ ១៩២។

គួរបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យរកឃើញអ្នកជំងឺកូវីដ១៩ សរុបចំនួន ៦,៤៧៩នាក់ ក្នុងនោះករណីនាំចូលពីបរទេស ៥,៣២៨នាក់ និងករណីព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ មានចំនួន ១,១៥២នាក់។ ជាមួយគ្នានេះ មានអ្នកព្យាបាលជាសះស្បើយក្នុងខេត្តចំនួន ២,៩៦០នាក់ និងកំពុងសម្រាកព្យាបាលក្នុងខេត្តចំនួន ១,៣៨៤នាក់ ស្លាប់ចំនួន ១២នាក់៕

## ១ថ្ងៃមានពលករខ្មែរ២៥៨នាក់ ត្រឡប់ពីថៃចូលតាមច្រកចំនួន៣ក្នុងខេត្តបន្ទាយមានជ័យ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៨ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១១:០១

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរត្រឡប់ពីថៃចូលមកកម្ពុជាតាមច្រកចំនួន៣ត្រឹមពេល១ថ្ងៃ គឺមានចំនួន ២៥៨នាក់ ហើយបានរកឃើញវិជ្ជមានកូវីដ.១៩ចំនួន៤៤នាក់ គិតត្រឹមថ្ងៃទី២៧ សីហា នៅខេត្តបន្ទាយមានជ័យ។

យោងតាមលោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យបានប្រាប់ថា ខេត្តបន្ទាយមានជ័យមានច្រកចំនួន៣កន្លែង ដែលមានពលករខ្មែរត្រឡប់ពីប្រទេសថៃចូលមកកម្ពុជា ដែលត្រូវបានក្រុមការងារទទួលដើម្បីពិនិត្យសុខភាព នៅថ្ងៃទី២៧ សីហា ឆ្នាំ២០២១ ទី១-ច្រកអូរបីជាន់ ស្រុកអូរជ្រៅរកឃើញអ្នកវិជ្ជមានកូវីដ.១៩ ចំនួន ២៦នាក់ (ស្រី១២នាក់)។ ទី២-ច្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួករកឃើញវិជ្ជមានកូវីដ.១៩ចំនួន១៥នាក់ (ស្រី៨នាក់) និងទី៣-ច្រកបឹងបេង ស្រុកម៉ាឡៃ រកឃើញវិជ្ជមានកូវីដ.១៩ចំនួន៣នាក់ (ស្រី១នាក់) ។ លោកបានបញ្ជាក់ថា ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលតាមច្រកចំនួន៣កន្លែង ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យមានក្រុមការងារទទួលដើម្បីពិនិត្យសុខភាពនិងយកសំណាក់ ដើម្បីធ្វើតេស្តអ្នកដែលរកឃើញវិជ្ជមានកូវីដ.១៩ ត្រូវបានដឹកជញ្ជូនតាមរថយន្តសង្គ្រោះទៅមណ្ឌលព្យាបាលកម្រិតស្រាលខ្លាកូប្បី ក្រុងសិរីសោភ័ណ និងអ្នកអវិជ្ជមានកូវីដ.១៩ ត្រូវដឹកជញ្ជូនតាមរថយន្តក្រសួងការពារជាតិដាក់តាមមណ្ឌលក្នុងខេត្តបន្ទាយមានជ័យ ដើម្បីធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ ៕

## សង្គមស៊ីវិលបារម្ភថា នារីរងគ្រោះពីការជួញដូរកម្លាំង និងផ្លូវភេទនឹងមិនទទួលបានសេវាជំនួយរយៈពេលវែង

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី2021-08-28

សង្គមស៊ីវិលព្រួយបារម្ភថា ស្ត្រីដែលរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម និងកេងប្រវ័ញ្ចផ្លូវភេទមិនទទួលបានសេវាជំនួយបានរយៈពេលវែង។ ការព្រួយបារម្ភនេះ ធ្វើឡើងបន្ទាប់ពី រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលថ្ងៃទី២៧ ខែសីហា ឲ្យដឹងថា ៦ខែ ពីមករា-មិថុនា ឆ្នាំនេះ ស្ត្រីរងគ្រោះរបស់កម្ពុជាដែលចាញ់បោកតាមរយៈអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច មានចំនួន ២៣០នាក់ ត្រូវបានជួយសង្គ្រោះពីប្រទេសចិន។

អនុប្រធានផ្នែកស្ត្រី និងកុមារ នៃសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) អ្នកស្រី មាស សាអ៊ីម ថ្លែងថា ស្ត្រីរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម និងកេងប្រវ័ញ្ចផ្លូវភេទ ពិតជាមានចំនួនច្រើនដូច្នេះមែន។ អ្នកស្រីថា ការជួយសង្គ្រោះឲ្យពួកគាត់បានត្រឡប់មកស្រុកកំណើតវិញនេះ គឺពិតជាបានជួយច្រើនមែនពីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ប៉ុន្តែអ្វីដែលជាក្ដីបារម្ភនោះ គឺជំនួយរយៈពេលវែង។ អ្នកស្រីថា ជំនួយរយៈពេលវែង ដើម្បីស្ដារនីតិសម្បទា និងជំនាញដល់ពួកគាត់នៅពេលរស់នៅក្នុងសហគមន៍នោះ គឺជារឿងសំខាន់ ពុំនោះទេពួកគាត់នឹងត្រូវប្រឈមមុខ ធ្វើចំណាកស្រុកដោយប្រថុយប្រថាន រួមទាំងបន្តចាញ់បោកមេខ្យល់ម្ដងទៀត៖ «ស្ថានភាពនៃការជួយរយៈពេលមធ្យម និងរយៈពេលវែង។ រយៈពេលបឋមឃើញគាត់សង្គ្រោះគាត់អី ហើយគាត់បញ្ជូនធ្វើសមាហរណកម្មហ្នឹងបានពេញលេញ ប៉ុន្តែយើងបារម្ភសម្រាប់ផែនការរយៈពេលមធ្យម និងរយៈពេលវែង ពីខាងរាជរដ្ឋាភិបាលក៏ដូចជាខាងអាជ្ញាធរមូលដ្ឋាន ព្រោះយើងឃើញសេវាភាគច្រើនគឺសេវាពីខាងអង្គការសង្គមស៊ីវិលទេ ដែលយើងអាចបារម្ភពីនិរន្តរភាពក៏មិនអាចគ្រប់ជ្រុងជ្រោយនៅក្នុងការផ្ដល់សេវាទូទាំងប្រទេសបានព្រោះតំបន់មួយចំនួនខេត្តខ្លះ និងអង្គការខ្លះគាត់គ្របដណ្ដប់ទៅតាមតំបន់ដែរ»។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ប្រាប់សារព័ត៌មានក្នុងស្រុកថា ៦ខែ ឆ្នាំ២០២១ នេះ កម្ពុជាបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចបាន ១៩៨ ករណី។ ចំនួនបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច ទាំង១៩៨ករណីនេះ គឺកើនឡើង ១៣៥ករណី បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ ២០២០ ដែលមានត្រឹមតែ ៦៣ករណី។ គណៈកម្មាធិការនេះ ក៏ឃាត់ខ្លួនជនសង្ស័យបាន ២៩១នាក់ និងសង្គ្រោះជនរងគ្រោះបាន ៧២១នាក់។ ក្នុងចំនួននេះ ១៩៨ ករណីនេះដែរ មានករណីជួញដូរមនុស្សដោយកម្លាំងពលកម្ម ១៣៩ករណី ឃាត់ខ្លួនបានជនសង្ស័យ ២៣១នាក់ និងធ្វើអាជីវកម្មផ្លូវភេទ ៥៩ករណី ដែលឃាត់ខ្លួនជនសង្ស័យបាន ៦០នាក់៕

## កំណើនពលករឆ្លងដែនមកពីថៃ តាមច្រកអូរស្មាច់មានការធ្លាក់ចុះច្រើន

https://news.btv.com.kh/ 08/26/2021 10:08 AM

ឧត្តរមានជ័យ ៖ ក្នុងរយៈពេលមួយសប្តាហ៍ចុងខែសីហា ឆ្នាំ២០២១នេះ កំណើនលំហូរពលករខ្មែរ ឆ្លងដែនមកពីស្រុកថៃ គឺហាក់បីដូចជាមានការថយចុះច្រើន ក្នុងមួយថ្ងៃមានចំនួនជាង២០០នាក់ តែប៉ុណ្ណោះ បើធៀបនឹងពាក់កណ្ដាលដើមខែសីហាវិញនោះ គឺមានចំនួនដល់ទៅ ៥០០នាក់ក្នុងមួយថ្ងៃ។

លោក ឌី រ៉ាដូ អ្នកនាំពាក្យរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា បច្ចុប្បន្ននេះ ស្ថានភាពកំណើនពលករខ្មែរ ឆ្លងមកពីថៃចូលតាមច្រកអូរស្មាច់ មានការថយចុះច្រើនជាងមុន គឺមួយថ្ងៃមានត្រឹម២០០នាក់ ហើយចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩នោះ ខាងក្រុមគ្រូពេទ្យជួរមុខបានរកឃើញជាបន្តបន្ទាប់ ប៉ុន្តែមានចំនួនតិចតួចមិនមានច្រើនដូចករណីមុនៗនោះឡើយ ទាំងការឆ្លងក្នុងសហគមន៍ផងនោះ។ លោកបន្តថា ទោះបីជាស្ថានភាព

កំណើនពលករឆ្លងដែនមកពីថៃ បច្ចុប្បន្នមិនមានករណីឆ្លងច្រើនយ៉ាងណាក្តីក៏យើងនៅបន្តអនុវត្តវិធានការការពារកិច្ចពាក់ម៉ាក ការរក្សាគម្លាតឲ្យបានខ្ជាប់ខ្ជួន ជាប់ជាប្រចាំ ដើម្បីទប់ស្កាត់ការកាត់ផ្តាច់កុំឲ្យមានការចម្លងបន្តក្នុងសហគមន៍ឲ្យមានប្រសិទ្ធភាពខ្ពស់។

តាមការប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្ត គិតត្រឹមម៉ោង៧:៣០នាទីថ្ងៃទី២៥ សីហា ចំនួនពលករចូលមកថ្មីមានចំនួន១៨៤នាក់ ស្រី៨១នាក់ វិជ្ជមាន២៣នាក់ ស្រី១១នាក់ សហគមន៍៣៤នាក់ ជាសះស្បើយ១០២នាក់ សរុបមកអ្នកឆ្លងកូវីដ-១៩ក្នុងខេត្តមាន៦.៣៥៩ករណី ១.៤២៥ករណី កំពុងសម្រាកព្យាបាល១០ករណីស្លាប់ ៕ អត្ថបទ ៖ ឃិនសារិទ្ធ

## កងពលតូចដឹកជញ្ជូនលេខ៩០ កងទ័ពជើងគោក បានដឹកជញ្ជូនពលករចំណាកស្រុក នៅតាមព្រំដែនកម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា បានចំនួន៥៩៥ នាក់

https://cen.com.kh/ Posted ByPen Srey NeatAugust 28, 2021

ភ្នំពេញ ៖ រថយន្តកងទ័ព របស់កងពលតូចដឹកជញ្ជូនលេខ៩០ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១នេះ បានដឹកជញ្ជូនពលករចំណាកស្រុកនៅតាមព្រំដែនកម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា បានចំនួន៥៩៥ នាក់ ដែលស្មើនិង៩៦ ជើង។ កងពលតូចដឹកជញ្ជូនលេខ៩០ កងទ័ពជើងគោក ជាអង្គភាពជំនាញដឹកជញ្ជូនសម្ភារៈ កម្លាំងទ័ព ជានាបម្រើប្រយុទ្ធ បច្ចុប្បន្នកំពុងទទួលបទបញ្ជា ដឹកពលករចំណាកស្រុក នៅតាមព្រំដែនកម្ពុជា-ថៃ មកដាក់នៅតាមបណ្តាខេត្តនានា ដែលជាយន្តការមួយ របស់រដ្ឋាភិបាល ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាល ជំងឺកូវីដ-១៩ ចូលសហគមន៍ តាមរយៈពលករចំណាកស្រុកទាំងនោះ។

តាមបទបញ្ជាដ៏ខ្ពង់ខ្ពស់ ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ក្នុងនោះកងពលតូចដឹកជញ្ជូនលេខ៩០ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ទោ ឈរ សុខ នាយសេនាធិការរងកងទ័ពជើងគោក មេបញ្ជាការកងពលតូចដឹកជញ្ជូនលេខ៩០ និងកងកម្លាំងជំនាញដឹកជញ្ជូន ដែលបានចាត់តាំង ក្នុងបេសកកម្មនេះ នៅបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការដឹកពលករខ្មែរ ទៅដាក់នៅតាមបណ្តាគោលដៅ ដែលបានកំណត់ ទាន់ពេលវេលា និងប្រកបដោយសុវត្ថិភាព៕ រក្សាសិទ្ធិដោយ ៖ បញ្ញាស័ក្តិ

## ពលករខ្មែរ ចំនួន៩នាក់ នៅម៉ាឡេស៊ី នឹងមកដល់កម្ពុជាវិញ នាល្ងាចនេះ និងព្រឹកស្អែក

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ២៩ សីហា ២០២១ដោយ sopheak khoun

ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ និងជួយសម្របសម្រួលបញ្ជូនពលករ-ពលការិនីចំនួន៩នាក់ មកកម្ពុជាវិញ នាល្ងាចថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១នេះ។ នេះបើតាមការឲ្យដឹងពីអ្នកនាំពាក្យ ក្រសួងការបរទេសកម្ពុជា។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹង នារសៀលថ្ងៃអាទិត្យ ទី២៩ ខែសីហា នេះថា ក្នុងចំណោមពលករ-ពលការនីខ្មែរទាំងនោះ មាន៨នាក់ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះ អាកាសចរណ៍សិង្ហបុរី លេខ SQ158 នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០២១ វេលាម៉ោង០៥ និង៣០នាទីល្ងាចនេះ។ ចំណែកពលការិនីម្នាក់ទៀត នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះអាកាស ចរណ៍សិង្ហបូរីលេខ SQ158 នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង៥ និង៣០ នាទីល្ងាចស្អែក។

បើតាមលោក កុយ គួង ករណីនេះស្ថានទូត បានជួយចេញលិខិត ធ្វើដំណើរបណ្ដោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន និងបានផ្ដល់ជំនួយ ជាកញ្ចប់ស្បៀងអាហារ ដល់ពលករ-ពលការិនី ដែលខ្វះខាត និងប្រាក់ឧបត្ថមមួយចំនួន ក្នុងអំឡុងពេល រង់ចាំត្រឡប់ទៅកម្ពុជាវិញ ព្រមទាំងចាត់មន្ត្រីជូនដំណើរពលករ-ពលការិនី និងកុមារខាងលើ ទៅអាកាសយានដ្ឋាន KLIA ផងដែរ៕ អត្ថបទ៖ កោះកែវ

## ពលករខ្មែរ ១៤ នាក់ លួចឆ្លង ដែនត្រូវទាហានថៃ ស្ទាក់ចាប់

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៣០ សីហា ២០២១ដោយ deth leng

ពលករខ្មែរចំនួន ១៤ នាក់ ត្រូវបានក្រុមទាហានឈុតពិសេសរបស់ថៃចាប់ខ្លួន ខណៈដែលពួកគេលួចឆ្លងដែនដោយចំណាយក្នុងម្នាក់ ៦ ពាន់បាត ចូលទៅទឹកដីថៃរកការងារធ្វើដោយខុសច្បាប់។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីព្រឹកថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុចភ្នំកូនដំរី ក្នុងឃុំតាប្រាក់យ៉ា ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ប្រទេសថៃ។ នៅមុនពេលឃាត់ខ្លួនគឺមានពលករខ្មែរចំនួន១៤នាក់ បានលបឆ្លងព្រំដែនចូលទៅក្នុងទឹកដីថៃ ដោយបាននាំគ្នាដើរកាត់តាមចំការ ស្របពេលដែលកម្លាំងទាហានឈុតពិសេសថៃ សហការជាមួយកម្លាំងតម្រួតព្រំដែនលេខ១២ កំពុងល្បាតក៏បានស្ទាក់ចាប់ ក្នុងនោះប្រុស៨ និងស្រី៦ នាក់។

ក្រោយការចាប់ខ្លួនពលករខ្មែរបានសារភាពថា ពួកគេមកពីខេត្តបន្ទាយមានជ័យ ដោយបានប្រមូលផ្តុំគ្នានៅក្នុងឃុំល្មៀត ស្រុកថ្មពួក ដោយមានមេខ្យល់នាំផ្លូវនិងត្រូវចំណាយម្នាក់ ៦.០០០ បាត និងត្រូវដើរកាត់ចំការដើម្បីឡើងទៅលើផ្លូវជាតិត្រង់ចំណុច បានណាងង៉ាម ហើយនៅពេលដល់គោលដៅទើបត្រូវចាយលុយ ដែលក្នុងមនិស្សទាំង១៤នាក់ គោលដៅដែលត្រូវទៅធ្វើការគឺ ខេត្តស្រះកែវ ១ នាក់ ខេត្តរ៉ាក់យ៉ង ២ នាក់ ខេត្តឆៈឈើងសៅ ២ នាក់ និងទីក្រុងបាងកក ចំនួន ៩ នាក់។ ក្រោយពេលឃាត់ខ្លួន ក្រុមយោធាថៃបានត្រួតពិនិត្យសុខភាពពួកគេទាំងអស់ និងបានបញ្ជូនទៅឱ្យតម្រួតព្រំដែនលេខ ៣៨ ដើម្បីប្រគល់ទៅអោយភាគីកម្ពុជាវិញតាមច្រកអូរបីជាន់ ៕ អត្ថបទ : សោ និយមរ័ត្ន

## ឃាត់ខ្លួនជនជាតិថៃ ៦ នាក់ បម្រុងឆ្លងដែនមកធ្វើការនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៣០ សីហា ២០២១ដោយ deth leng

ជនជាតិថៃចំនួន ៦ នាក់ ដែលក្នុងនោះមានប្រុសចំនួន ២ នាក់ និងស្រី ៤ នាក់ ត្រូវបានតម្រួតការពារព្រំដែនថៃ លេខ១២ ធ្វើការឃាត់ខ្លួននៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេបម្រុងលួចឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជាដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីវេលាល្ងាចថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១ ត្រង់ចំណុច បានណឺនសុំប៊ូន ក្នុងឃុំតាប្រាក់យ៉ា ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីពួកគេកំពុងធ្វើដំណើរតាមរថយន្ត អ៊ីស៊ុយស៊ុយមួយគ្រឿង ក្នុងពេលដែលប្រទេសមានការរឹតបន្តឹង ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបម្លែងខ្លួន ដែលតា។ ជនជាតិថៃទាំង ៦ នាក់ បានសារភាពថា ពួកគេត្រូវចំណាយឱ្យអ្នកបើកបរម្នាក់ ៥០០ បាត ក្នុងការនាំឆ្លងដែនចូលទៅក្នុងទឹកដីកម្ពុជា តាមច្រករបៀងតែត្រូវចាប់ខ្លួនទៅហើយ។ ពួកគេបានអះអាងថា ការលបឆ្លងដែននេះគឺអាចធ្វើអោយពួកគេសល់កម្រៃច្រើន ដោយចូលទៅធ្វើការនៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត ព្រោះឮអ្នកស្គាល់គ្នាប្រាប់ថា បើទៅដល់ទីនោះក្រុមហ៊ុននឹងជួយគ្រប់យ៉ាងទាំងការហូបចុក និងការស្នាក់នៅ ហើយបានប្រាក់ខែ ២០.០០០ បាត៕ សោ និយមរ័ត្ន

## ពលករខ្មែរ ឆ្លងដែនមកពីថៃ តាមច្រកខេត្តបន្ទាយមានជ័យ មានការថយចុះច្រើន

https://news.btv.com.kh/ 08/30/2021 10:08 AM

ភ្នំពេញ៖ នារយៈពេលចុងក្រោយនេះ ស្ថានភាពនៃការឆ្លងដែនរបស់ពលករខ្មែរ មកពីប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ មានការថយចុះជាបន្តបន្ទាប់ ខណៈអត្រានៃការរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ ក្នុងខេត្តមួយនេះ ក៏មានតួលេខទាបជាងមុន នៅចុងខែសីហានេះ ។

ឯកឧត្តម អ៊ុ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានថ្លែងថា បន្ទាប់ពីរាជរដ្ឋាភិបាល បានសម្រេចបើកព្រំដែនឲ្យពលករត្រឡប់មកពីប្រទេសថៃ ចូលស្រុកកំណើតវិញ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ គឺនៅច្រកខេត្តបន្ទាយមានជ័យ គឺពលករឆ្លងដែនមកពីថៃ ចន្លោះពី៤០០ ទៅ៥០០នាក់ បានរកឃើញពលករក្នុងចំណោមនេះប្រមាណ១០ភាគរយមានវិជ្ជមានកូវីដ១៩។ ឯកឧត្តមបន្តថា ប៉ុន្តែរយៈពេលចុងក្រោយនេះ ចំនួនពលករឆ្លងដែនមកពីប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ បានមានការថយចុះ ហើយសម្រាប់ពលករដែលទើបត្រឡប់មកពីថៃទាំងអស់នោះ ក៏បានចូលរួមសហកាល្អជាមួយអាជ្ញាធរ ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ពិសេសប្រភេទបំប្លែងថ្មីដែលតា (Delta) ដោយពួកគេបានឲ្យមន្ត្រីសុខាភិបាលពិនិត្យធ្វើសំណាក និងធ្វើចត្តាឡីស័កបានត្រឹមត្រូវគ្រប់គ្នា និងអ្នកមានវិជ្ជមានក៏នាំទៅសម្រាកព្យាបាល ។ ឯកឧត្តមអភិបាល បញ្ជាក់ថា សម្រាប់រយៈពេលដូចគ្នានេះ សកម្មភាពការលួចនាំពលករឆ្លងដែនទៅមកប្រទេសថៃ ដោយខុសច្បាប់ពីសំណាកពួកមេខ្យល់ក៏គ្មាននោះដែរ នៅតាមច្រកនានា ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យខណៈកម្លាំងព្រំដែនបាននិងកំពុងពង្រឹងការពារយ៉ាងតឹងរឹងក្នុងការទប់ស្កាត់សកម្មភាពលួចឆ្លងដែននេះ ។

សេចក្តីប្រកាសព័ត៌មានរដ្ឋបាលខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា នៅចុងខែសីហា ឆ្នាំ២០២១ ចំនួនអ្នកវិជ្ជមានកូវីដ១៩ នៅក្នុងខេត្តមានការថយចុះច្រើន គឺមួយថ្ងៃអាជ្ញាធររកឃើញនៅក្រោម១០០នាក់ ឬលើស១០០នាក់តិចតួច ខុសប្លែកពីដើមខែ និងពាក់កណ្តាលខែ ដែលរកឃើញប្រមាណពីជាង ២០០នាក់ ទៅ៦០០នាក់ ។ កាលពីថ្ងៃទី២៩ ខែសីហា អាជ្ញាធរបានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ ចំនួន១១៣នាក់ មានទាំងអ្នកពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ និងពលករត្រឡប់មកពីប្រទេសថៃ និងមានអ្នកជាសះស្បើយចំនួន ៦៣នាក់ ។ ប៉ុន្តែយ៉ាងណា បច្ចុប្បន្ន អាជ្ញាធរខេត្តមិនទាន់បានបន្ធូរបន្ថយ ឬបញ្ចប់នៃការបិទខ្ទប់ផ្សារមួយចំនួន និងដាក់តំបន់ដែលបានរកឃើញការឆ្លងរាលដាលខ្លាំង នៃជំងឺកូវីដ១៩ ទៅជាតំបន់ក្រហម រួមទាំងអនុវត្តនូវបំរាមគោចរនៅពេលយប់នោះទេ ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងសុខាភិបាល កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១ បានឲ្យដឹងថា ខេត្តបន្ទាយមានជ័យ រហូតមកដល់ពេលនេះ បានរកឃើញអ្នកវិជ្ជមានកូវីដ១៩ ប្រភេទបំប្លែងថ្មីដែលតា ចំនួន៣២៥នាក់ ខណៈនៅទូទាំងប្រទេសកម្ពុជា បានរកឃើញសរុបចំនួន ១ ៧៥២នាក់ ប៉ះពាល់រាជធានីខេត្ត ចំនួន២៣ លើកលែងតែខេត្តកែប និងក្រចេះ ៕

## ពលរដ្ឋកម្ពុជាចំនួន ២១ នាក់ ត្រូវបានជួយសង្គ្រោះពីប្រទេសម៉ាឡេស៊ី និងពីប្រទេសចិន

https://www.postkhmer.com/ វ៉ែន ដារ៉ា and រី សុចាន់ | Publication date 30 August 2021 | 09:47 ICT

**ភ្នំពេញ៖** ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បន្តជួយអន្តរាគមន៍បញ្ជូនពលករចំនួន ៩ នាក់ទៀតមកកម្ពុជាវិញនៅថ្ងៃទី ២៩-៣០ សីហានេះ ខណៈស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងធុងឈីង ប្រទេសចិនសហការជាមួយអាជ្ញាធរចិន បានជួយសង្គ្រោះស្ត្រីកម្ពុជាចំនួន ១២ នាក់។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ២៩ សីហាថា ពលករ ពលការិនី ធ្វើការងារនៅប្រទេសម៉ាឡេស៊ីទាំង ៩ នាក់នេះ ដោយសារតែជួបការលំបាកក្នុងអំឡុងនៃការរីករាលដាលជំងឺ

កូវីដ ១៩ ដូច្នេះទើបពួកគេចង់ត្រឡប់មកមាតុប្រទេសវិញ ហើយស្នើស្ថានទូតឱ្យជួយ។ លោកបានថ្លែងថា ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីបានអន្តរាគមន៍បានជួយសម្របសម្រួលបញ្ជូនពលករ-ពលការិនី និងកុមារសរុបចំនួន ៩ រូបមកកម្ពុជាវិញ ក្នុងនោះ ៨ នាក់ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមជើងយន្តហោះអាកាសចរណ៍សិង្ហបុរីលេខ SQ158 នៅថ្ងៃទី ២៩ ខែសីហា វេលាម៉ោង ៥:៣០ នាទីល្ងាច។ ចំណែកពលការិនីម្នាក់ទៀត នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមជើងយន្តហោះអាកាសចរណ៍សិង្ហបុរីលេខ SQ158 នៅថ្ងៃទី ៣០ ខែសីហាវេលាម៉ោង ៥:៣០ នាទីល្ងាច។ លោក កុយ គួង បញ្ជាក់ថា៖ «ស្ថានទូតបានជួយចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន»។ ស្ថានទូតក៏បានផ្តល់ជំនួយជាកញ្ចប់ស្បៀងអាហារដល់ពលករ ពលការិនីដែលខ្វះខាត និងប្រាក់ឧបត្ថម្ភមួយចំនួនផងដែរ ក្នុងអំឡុងពេលរង់ចាំនៅប្រទេសម៉ាឡេស៊ីដើម្បីវិលត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតក៏បានចាត់ឱ្យមន្ត្រីជូនដំណើរពលករ-ពលការិនី និងកុមារខាងលើ ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ។

លោកថ្លែងថា៖ «ខ្ញុំសូមបញ្ជាក់រយៈ ៦ ខែដើមឆ្នាំនេះ (មករា-មិថុនា) ពលករ ពលការិនីដែលស្ថានទូតជួយអន្តរាគមន៍ពីប្រទេសម៉ាឡេស៊ីមកកម្ពុជាវិញ សរុបចំនួន ៣៣២ នាក់ក្នុងនោះមានស្ត្រីចំនួន ១៧៥ នាក់»។ ជាមួយគ្នានេះលោក កុយ គួង ក៏បានឱ្យដឹងដែរថា នៅថ្ងៃទី ២៦ សីហា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងធុងឈីងប្រទេសចិន បានជូនដំណឹងមកថា ស្ថានអគ្គកុងស៊ុល បានសហការជាមួយអាជ្ញាធរចិន ជួយសង្គ្រោះស្ត្រីខ្មែរ ១២ រូប ដែលរងគ្រោះដោយការជួញដូរឱ្យវិលត្រឡប់ទៅកម្ពុជាវិញ។ បើតាមលោក កុយ គួង ស្ត្រីកម្ពុជាទាំង ១២ នាក់នេះ គ្រោងមកដល់កម្ពុជានៅថ្ងៃទី ២ ខែកញ្ញា តាមជើងយន្តហោះ K6669។ លោក កុយ គួង បានបញ្ជាក់បន្ថែមថា រយៈពេល ៦ ខែពីខែមករា ដល់ខែមិថុនា ឆ្នាំនេះ ស្ត្រីកម្ពុជាដែលបានជួយសង្គ្រោះពីប្រទេសចិនសរុបមានចំនួន ២៣០ នាក់។

ក្រៅពីនេះ កាលពីថ្ងៃទី ២៦ សីហា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃ ក្នុងកិច្ចអន្តរាគមន៍ជាមួយអាជ្ញាធរថៃបានបញ្ជូនពលរដ្ឋកម្ពុជាចំនួន ២១ នាក់ដែលមកពីតំបន់ផ្សេងៗក្នុងប្រទេសថៃឱ្យអាជ្ញាធរកម្ពុជាតាមច្រកអន្តរជាតិខ្លងលឹកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីអនុវត្តនីតិវិធីសុខាភិបាល៕

## ពលករខ្មែរថាចំណាយក្នុងម្នាក់ៗ៦ពាន់បាត ធ្វើដំណើរចូលថៃ ចុងក្រោយត្រូវឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ៣០ ខែ សីហា ឆ្នាំ ២០២១ ម៉ោង ១៦:៤២

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរប្រុស-ស្រីចំនួន១៤នាក់ ដែលបានលួចឆ្លងដែនចូលប្រទេសថៃ ត្រូវបានទាហានថៃ ចាប់ឃាត់ខ្លួននៅគោលដៅ២ដាច់ដោយឡែកពីគ្នាក្នុងថ្ងៃតែមួយ ខណៈពលករខ្មែរបានអះអាងថា ពួកគាត់បានចំណាយអស់លុយ ចំនួន៦.០០០បាត ក្នុងម្នាក់ៗដើម្បីឆ្លងដែនចូលទឹកដីគេ តែចុងក្រោយត្រូវខាងថៃចាប់ខ្លួន ។ ទន្ទឹមនឹងការចាប់ឃាត់ខ្លួនជនជាតិខ្មែរប្រុស-ស្រីឆ្លងចូលទឹកដីថៃនោះ ទាហានថៃក៏បានចាប់ឃាត់ជនជាតិថៃប្រុស-ស្រីចំនួន៦នាក់ទៀត បម្រុងលួចឆ្លងដែនចូលទឹកដីកម្ពុជា ដើម្បីទៅធ្វើការនៅកាស៊ីណូក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ការឃាត់ខ្លួនទាំងពលករខ្មែរឆ្លងចូលដីថៃ និងការឃាត់ខ្លួនជនជាតិថៃប្រុងលួចឆ្លងដែនចូលដីកម្ពុជាខាងលើនេះត្រូវបានធ្វើឡើងកាលពីវេលាម៉ោង៩និង១០នាទីព្រឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១នេះ នៅបរិវេណភូមិលូកឆាង ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ។

ក្រោយពីចាប់ឃាត់បាន សមត្ថកិច្ចថៃបានធ្វើការសាកសួរ ពលករខ្មែរទាំងអស់ ដែលបានឆ្លើយប្រាប់ថៃថា ពួកគាត់ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ និងប្រមូលផ្តុំគ្នានៅភូមិមួយក្នុងឃុំគោករមៀត ស្រុកថ្មពួក ដោយមានមេខ្យល់ជាជនជាតិខ្មែរជាអ្នកនាំដើរកាត់តាមច្រករបៀង និងដើរកាត់ទៅតាមផ្លូវដីកសិកម្ម ដើម្បីមកឡើងរថយន្តនៅ

បរិវេណថ្នល់ភូមិណាងង៉ាម ឃុំតាប្រាយ៉ា ។ តែចុងក្រោយ ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន ដោយអ្នកទាំងអស់មានបំណង ទៅធ្វើការនៅក្នុងប្រទេសថៃ ក្នុងនោះបានចំណាយលុយក្នុងការធ្វើដំណើរក្នុងម្នាក់៦.០០០បាត។ ក្រោយមក សមត្ថកិច្ចបាននាំពលករទាំងអស់ទៅធ្វើការសាកសួរ នឹងធ្វើកំណត់ហេតុចាប់ខ្លួន អនុវត្តតាមវិធានរបស់ផ្នែកសុខាភិបាល បន្ទាប់មកបានបញ្ជូនឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ តាមច្រកអូរបីជាន់ ខេត្តបន្ទាយមានជ័យបន្ត។

នៅថ្ងៃដដែលនោះដែរ នៅវេលាម៉ោង២និង១៥នាទីរសៀល កម្លាំងទាហានប្រចាំការស្រុកតាប្រាយ៉ា សហការជាមួយកងកម្លាំងបូរផា បានប្រទះឃើញរថយន្តសង្ស័យ១គ្រឿង បើកចូលមកក្នុងភូមិសាស្ត្រខ្លួនទទួលខុសត្រូវ ទើបសមត្ថកិច្ចឃាត់ឲ្យឈប់ និងត្រួតពិនិត្យរថយន្តម៉ាកអ៊ីស៊ុយហ្ស៊ុយ ពាក់ស្លាកលេខក-1195 ស្រះកែវ។ នៅពេលសមត្ថកិច្ចពិនិត្យក្នុងរថយន្ត ឃើញមានជនជាតិថៃចំនួន៦នាក់ ក្នុងនោះប្រុស២ នឹងស្រី៤នាក់ ដោយពួកគេបានសារភាពថា ពួកគេមានបំណងលួចឆ្លងដែនទៅប្រទេសកម្ពុជាដើម្បីទៅធ្វើការនៅកាស៊ីណូក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា ។ហើយការធ្វើដំណើរលើកនេះ ខាងក្រុមហ៊ុនកាស៊ីណូអនឡាញ ជាអ្នកចំណាយទាំងអស់ ដោយឡែកអ្នកនាំបានទទួលថ្លៃឈ្នួលក្នុងម្នាក់៥០០បាតសរុប២,៥០០បាត ក្នុងការនាំជនជាតិថៃខាងលើទៅឯព្រំដែនក្នុងបរិវេណថ្នល់ស្រីពេញ តែក្រោយមកត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ទើបសមត្ថកិច្ចថៃបញ្ជូនទៅឲ្យជំនាញ ដើម្បីចាត់ការបន្ត ៕